ឧបការណ៍ចបស្សនាកម្មដ្ឋាន

(កម្មដ្ឋានប្រចាំខ្លួន)

ឧទ្ទិស

ចំពោះព្រះពុទ្ធសាសនា

ភ្ជំពេញ

ការផ្សាយរបស់អង្គការមូលនិធិវត្តបញ្ញាធំ

ឡោះពុម្ពចែកជាធម្មទាន

ព.ស. ២៥៦១ **គ.ស. ២០១៧**

ឧបការណ៍ចបស្សនាកម្មដ្ឋាន

១បករណ៍១បស្សនាកម្មដ្ឋាន

(កម្មដ្ឋានប្រចាំខ្លួន)

ឧទ្ទិស

ចំពោះព្រះពុទ្ធសាសនា

ផ្ទៃនៅវត្តបទុមវតីរាជវរារាម

ភ្នំពេញ

ព.ស. ២៥០៧ **គ.ស. ១៩៦៤**

ពាក្យប្រារព្ធ

រយៈកាលនេះ យើងខ្ញុំពិនិត្យទៅឃើញថា នៅមានការខ្វះខាតខាងក្បួនច្បាប់សម្រាប់រៀន សម្រាប់ធ្វើវិបស្សនាធុរៈច្រើន ជាពិសេសគឺខ្វះកល្យាណមិត្តទៀតផង ។ ដូច្នេះទើបពួកពុទ្ធសាសនិកទូទៅកម្រមាននរណាមួយចេញមុខបំពេញធុរៈនេះ ។ តាមពិត ធុរៈនេះជំនាន់ពុទ្ធសម័យគេនិយមណាស់ ព្រោះជាធុរៈផ្តល់មគ្គ ផល និងព្រះនិញ្ជាន ឲ្យដល់អ្នកទ្រទ្រង់ (អ្នកបដិបត្តិ) ។ ធុរៈនេះជាភាគធំមួយក្នុងផ្នែពុទ្ធសាសនា ។

យើងខ្ញុំចង់ចេះ ចង់ដឹង នូវគុណភាពរបស់ធុរៈនេះ ទើបសុំលោកគ្រូ **ធម្មវ៉ោត្តម តុង ឈួន ចន្ទ្រជិ៉ោ** ឲ្យលោករៀបចំក្បួនច្បាប់នេះឡើង ដើម្បីសិក្សាផ្ទាល់ខ្លួនយើងខ្ញុំផង ដើម្បីប្រគេន-ជូន ពុទ្ធបរិស័ទគ្រប់ប្រភេទ អ្នកត្រូវការទ្រទ្រង់ធុរៈនេះផង និងដើម្បីទុកជាគោលច្បាប់សម្រាប់ពុទ្ធសាសនាផង លោកក៏មានព្រះទ័យសោមនស្ស ជួយរៀបចំជរាបបានសម្រេចជាសៀវភៅនេះឡើង សមតាមសេចក្តីត្រូវការរបស់យើងខ្ញុំ យើងខ្ញុំក៏ទទួលការៈគ្រប់យ៉ាងហើយយកទៅចាត់ការបោះពុម្ពសម្រេច ។

សូមរួបរួមកុសលរាសីធម្មទានេះ ឧទ្ទិសថ្វាយជូនចំពោះវិញ្ញាណក្ខន្ធលោកអ្នកមានគុណទាំងឡាយ មានមាតាបិតាជាដើម ជាពិសេសគឺ

ព្រះបាទសម្តេច ព្រះហរិរក្សរាមាឥស្សរាធិបតី (ព្រះអង្គឌួងព្រះបរមកោដ្ឋ), **ព្រះបាទសម្តេច ព្រះនរោត្តម** (ព្រះសុវណ្ណកោដ្ឋ), **ព្រះបាទសម្តេច ព្រះស៊ីសុវត្ថិ** (ព្រះរាជានុកោដ្ឋ), **ព្រះបាទសម្តេច ព្រះស៊ីសុវត្ថិ មុនីវង្ស** (ព្រះទត្តិយ-កោដ្ឋ), **ព្រះបាទសម្តេច ព្រះនរោត្តម សុរាម្រីត** (ព្រះមហាកាញ្ចនកោដ្ឋ) **លោកយុនព្រះម៉ែនាង គន្ធបុប្ជាសី, អ្នកម្ចាងឃ្លិប, ព្រះអង្គម្ចាស់ នរោត្តមសុផ្ឋាវង្ស, ព្រះអង្គក្រុមហ្លួងស៊ីសុវត្ថិសុភាណវង្ស, ព្រះអង្គម្ចាស់ក្សត្រី នរោត្តម សុផ្ឋារេតរស្មី ព្រមទាំងព្រះរាជវង្សានុវង្សទាំងឡាយ មានសម្តេចព្រះរាជអយ្យកោ សម្តេចព្រះរាជអយ្យិកាជាដើម** *សូមព្រះអង្គ សូមលោក បានប្រកបដោយព្រះបរមសុខ សមតាមព្រះរាជហបុទ័យប្រាថ្នា តាមសេចក្តីប្រាថ្នា ជាស្ថាពរតរៀងទៅ ។*

ថ្ងៃអាទិត្យ ៥ រោច ខែជេស្ឋ ឆ្នាំ រោង ឆស័ក ព.ស. ២៥០៧

ត្រូវនឹងថ្ងៃទី ៣០ ខែឧសភា ឆ្នាំ ១៩៦៤

ព្រះអង្គម្ចាស់ នរោត្តម សុង គេជ

និងមានពុទ្ធសាសនិកខ្លះទៀតជួយឧបត្ថម្ភ

បញ្ជីមាតិកា

ទំព័រ

ភាគ ១

សម្មតិបញ្ញត្តិ.....១

វ័យ ១០ ..... ១០

បរមត្ថធម៌ ១៤

ភូមិ ៣១ ..... ២០

ចិត្ត ៨៩ ឬ ១២១ .....២៧

ចេតសិក ៥២ ..... ៥៥

រូប ២៨ ..... ៦០

ព្រះនិញ្ជាន ១ ..... ៦៤

រូបនាមក្នុងវិបស្សនាភូមិ ៦ ..... ៦៥

ខន្ធ ៥ ..... ៦៥

អាយតនៈ ១២ .....៦៨

ធាតុ ១៨ .....៧១

ឥន្ទ្រិយ ២២ .....៧៥

អរិយសច្ច ៤ ..... ៨០

បដិច្ចសមុប្បាទ ១២ .....៨៤

បច្ចុប្បន្នធម៌ ៩០

សតិ និងមោហ: ៩៣

ត្រៃលក្ខណ: ប្រហារអនុស័យ ៩៥

សមថយានិក: ១០១

កសិណ ១០ .....១០៤

ពួកអសុភ ១០ .....១១៦

អនុស្សតិ ១០.....១២៣

អប្បមញ្ញា ៤.....១២៨

អាហារេបដិកូលសញ្ញា ១..... ១៣០

ចតុធាតុវវត្ថាន: ១ ..... ១៣១

ពួកអរូប ៤..... ១៣២

វិបស្សនាយានិក: ១៣៦

សិក្ខា ៣ .....១៣៧

វិសុទ្ធិ ៧.....១៤១

ពោធិបក្ខិយធម៌ ៣៧.....១៥០

អស់អាសវ:ដល់សន្តិលក្ខណ: ១៦១

ភាគ ២.....១៦៥

ការលះបលិពោធ ១៦៦

កល្យាណមិត្ត ១៦៣

សប្បាយ ៧ ..... ១៧០

វិធីថ្ងៃចូលបដិបត្តិវិបស្សនា ១៧៣

បដិបត្តិក្នុងសីលវិសុទ្ធិ ១៧៦

ថ្វាយខ្ជូនចំពោះព្រះមានព្រះភាគ ១៧៧

ថ្វាយខ្ជូនចំពោះអាចារ្យ ១៧៨

សូមកម្មដ្ឋាន ១៧៨

ផ្សាយមេត្តា ១៨០

ខហាមក្នុងវេលាបដិបត្តិវិបស្សនា ១៨២

វិធីតាំងសតិដឹងទាន់បច្ចុប្បន្នរបស់រូបនាម ១៨៤

បែបបដិបត្តិទី ១ ..... ១៨៤

បែបបដិបត្តិទី ២-៣-៤ ..... ១៨៥

បែបបដិបត្តិទី ៥-៦-៧ ..... ១៨៦

បែបបដិបត្តិទី ៨ ..... ១៨៧

បែបបដិបត្តិទី ៩ ..... ១៨៨

បែបបដិបត្តិទី ១០ ..... ២១១

បែបបដិបត្តិទី ១១ ..... ២១២

បែបបដិបត្តិទី ១២-១៣ ..... ២១៤

បែបបដិបត្តិទី ១៤ ..... ២១៦

បៃបបដិបត្តិទី ១៥ ..... ២១៧

បៃបបដិបត្តិទី ១៦ ..... ២១៩

បៃបបដិបត្តិទី ១៧ ..... ២២២

ភាគ ៣ ..... ២២៧

ភ័យធំដែលរាំងរាមិនឲ្យបានលុះបដិវេធធម៌ ២២៩

បច្ច័យរបស់បដិវេធធម៌ ២៣៦

នាមរូបបរិច្ឆេទញាណ ២៣៨

នាមរូបបច្ចយវិគ្គហញ្ញាណ ២៤០

សម្មសនញ្ញាណ ២៤៤

ឧទយព្វយញ្ញាណ ២៥០

ភង្គញ្ញាណ ២៥២

ភយតូបដ្ឋានញ្ញាណ ២៥៦

អាទីនវញ្ញាណ ២៥៩

និព្វិទាញ្ញាណ ២៥៩

មុញ្ចិតុកម្យតាញ្ញាណ ២៦១

បដិសង្ខាញ្ញាណ ២៦២

សង្ខារុបេក្ខាញ្ញាណ ២៦៣

អនុលោមញ្ញាណ ២៦៦

គោត្រភូញាណ ២៦៣
បច្ចវេក្ខណញ្ញាណ ២៧២
ញ្ញាណលោកុត្តរៈ ២៧៤
សោតាបត្តិមគ្គ-ផលញ្ញាណ ២៧៥-២៧៦
សកទាគាមិមគ្គ-ផលញ្ញាណ ២៧៩-២៨០
អនាគាមិមគ្គ-ផលញ្ញាណ ២៨១-២៨២
អរហត្តមគ្គ-ផលញ្ញាណ ២៨៥-២៨៦
លោកុត្តរអារម្មណ៍ ២៩៣
សមាបត្តិ ២៩៨
ឈានសមាបត្តិ ២៩៨
ផលសមាបត្តិ ៣០០
និរោធសមាបត្តិ ៣០៤
អានិសង្សវិបស្សនា ៣១២

ទិបស្សនាកម្មដ្ឋាន

ភាគ១

សម្មតិបញ្ញត្តិ

ក្នុងព្រះវិបស្សនាកម្មដ្ឋាននេះ ដែលព្រះមានព្រះភាគ ទ្រង់មានព្រះមហាករុណាទិគុណ ប្រទានទុកដល់ពុទ្ធបរិស័ទទាំង ៤ គឺ ភិក្ខុ ភិក្ខុនី ឧបាសក ឧបាសិកា អស់ ៤៥ វស្សា មុនពុទ្ធបរិនិព្វាន មានសេចក្តីជ្រាលជ្រៅគម្ភីរភាព ញ្ចាំងវេនេយ្យសត្ត ឲ្យរួចផុតចាកកងទុក្ខទាំងពួង ដល់អមតមហានិព្វាន ដែលជាដែនបរមសុខប្រសើរបំផុត ។

វិបស្សនាកម្មដ្ឋានបែកជា៣ភាគគឺ

១- **ភាគ១** បានដល់បរិយត្តិសាសនា គឺប្រដៅបរិយត្តិឲ្យដឹងក្នុងក្របខ័ណ្ឌរបស់វិបស្សនាភូមិ ៦ ប្រការ ដែលជាឧបការណ៍ពិសោធន៍សេចក្តីចូលចិត្ត ឲ្យដឹងសេចក្តីបំណងរបស់ការបដិបត្តិវិបស្សនា និងបណ្តុះសទ្ធាបសាទៈឲ្យមានឥន្ទ្រីយ៍ចាស់ក្លាឡើង ។

២- **ភាគ២** បានដល់បដិបត្តិសាសនា គឺប្រដៅការបដិបត្តិហ្វឹកហាត់អប់រំតាមដែលបានសិក្សាមកក្នុងភាគ ១ គឺភាគបរិយត្តិ ពោលដោយការលះបលិពោធ ការចាត់ឋានទីសប្បាយ ពិធីថ្ងៃចូលបដិបត្តិវិបស្សនាពិធីតាំងសតិកំណត់ដឹងទាន់រូបនាម តាមបែបបដិបត្តិគ្រប់ៗបែបបដិបត្តិ ។

៣- **ភាគ៣** បានដល់បដិវេធសាសនា ពោលដោយមគ្ត ផល និព្វាន គឺប្រដៅឲ្យដឹងក្នុងញាណទាំងលោកិយ ទាំងលោកុត្តរៈ ហ្វឹកហាត់ចូលផល

សមាបត្តិ និង និរោធសមាបត្តិជាដើម ។

ក្នុងភាគ ១ នេះ សម្តែងដល់បរិយត្តិសាសនា ឲ្យដឹងក្នុងសច្ចធម៌ ដែលព្រះបរមសាស្តាទ្រង់ទេសនាទុក មានប្រមាណ ៨៤ ០០០ ព្រះធម្មក្ខន្ធគឺព្រះត្រៃបិដកទាំង ៣ នោះឯង បានដល់

ក្នុងព្រះវិន័យបិដក មាន ២១ ០០០ ព្រះធម្មក្ខន្ធ

ក្នុងព្រះសុត្តន្តបិដក មាន ២១ ០០០ ព្រះធម្មក្ខន្ធ

ក្នុងព្រះអភិធម្មបិដក មាន ៤២ ០០០ ព្រះធម្មក្ខន្ធ

រួម ៨៤ ០០០ ព្រះធម្មក្ខន្ធ ដែលព្រះពុទ្ធអង្គទ្រង់បញ្ចេញព្រះសូរសៀងចាកព្រះឱស្ឋ ប្រកាសសច្ចធម៌មានប្រមាណប៉ុណ្ណេះ បើសរុបបង្រួញចុះមាន ២ ប្រការគឺ

១- ***សម្មតិសច្ច:*** អាស្រ័យបញ្ញត្តិតាំងឡើង គឺសេចក្តីពិតដោយសម្មតិ ។

២- ***បរមត្តសច្ច:*** គឺសភាវ:មានប្រាកដនៅពិត ។

វិបស្សនានោះ គឺការមានបញ្ញាញ្ញាណដឹងច្បាស់ ឃើញពិតក្នុងព្រះបរមត្តសច្ច: និងសម្មតិសច្ច:បានដោយដាច់ខាត ។

ពោលអំពីសម្មតិសច្ច:ដោយន័យសង្ខេបដូចតទៅនេះ ៖

សម្មតិសច្ច: ជាវោហារពាក្យពោល ដែលលោកិយជនបាននិយមប្រើនិយាយគ្នាជាប់តមកអំពីបុរាណកាល គឺសម្មតិយកសត្ត បុគ្គល អត្ត:

ជីវ: សណ្ឋាន សន្តតិ និមិត្ត និងអនុព្យញ្ជន:ជាដើម ។

ពាក្យថា **សត្ត** ជាឈ្មោះដែលសម្មតិប្រើ ហៅបានទាំងមនុស្ស ទេវតា ព្រហ្ម សត្វនរក ប្រេត អសុរកាយ និងសត្វតិរច្ឆាន ។

ពាក្យថា **បុគ្គល** ជាឈ្មោះដែលប្រើហៅឈ្មោះសត្វក្នុង ៣១ ភូមិ ដែលធ្លាប់ជាសត្វនរកមកហើយ បច្ចុប្បន្ននិយមប្រើហៅមនុស្សដែល ប្រសើរជាងសត្វតិរច្ឆាន ។

ពាក្យថា **អត្ត:** ជាឈ្មោះសម្មតិប្រើច្រើន គឺសម្មតិដៅកំណត់យក ខ្លឹមសារនៃខន្ធ ៥ ថាខ្លួន ថាប្រាណ ដោយប្រើសព្វនាមថាយើងនោះឯង ។

ពាក្យថា **ជីវ:** ឬ **ជីវី** នេះជាចំណែកសំខាន់របស់ **អត្ត:** ប្រហែល នឹងសិរសា ឬកំពូលរបស់អត្ត: អត្ត:នឹងតាំងនៅយូរបាន ក៏ដោយអំណាច ជីវ: ឬជីវី ពិភ័ក្សរក្សាទុក ។

ពាក្យថា **សណ្ឋាន** ជាឈ្មោះដែលគប្បីកំណត់រាប់បាន តាំងអំពី បរមាណូ អណូ របស់បឋវីធាតុ គឺធាតុដី រហូតដល់ស្តេចភ្នំ ដែលអាច កំណត់ទទឹង បណ្តោយ ខ្ពី វែង ខ្ពស់ ទាប គ្រប់ចំណែករបស់រូបរាង លក្ខណ: ។

ពាក្យថា **និមិត្ត** គឺលក្ខណ:ទម្រង់ទ្រង់ទ្រាយរបស់សត្ត និងបុគ្គល ជាដើម ចែកចេញជា ២ ប្រភេទគឺ **សុភនិមិត្ត** និង **អសុភនិមិត្ត** បាន ដល់និមិត្តដែលល្អ និងមិនល្អ ។

ពាក្យថា **អនុព្យញ្ជនៈ** គឺការកម្រើកញាប់ញ័ររបស់សត្ត និងបុគ្គល ដូចការឈរ ដើរ អង្គុយ ដេក ជាដើម ដែលមានលក្ខណៈទាំងសុភៈល្អ និងអសុភៈមិនល្អ ។

ពាក្យថា **សម្មតិ** នេះសម្គាល់សេចក្ដី ដឹងព្រម ដូចការឃើញមនុស្សប្រុស កាលឃើញក៏ដឹងព្រមឡើងថា ជាមនុស្សប្រុស ការដឹងព្រមឡើងថាមនុស្សប្រុសនោះ មានបញ្ញត្ដិធម៌ការតាំងឡើងមុនជាបច្ច័យឲ្យសម្មតិគឺសេចក្ដីដឹងព្រមកើតឡើងក្នុងខាងក្រោយ ។

ពាក្យថា **បញ្ញត្ដិ** ជាភាសាបាលីថា **បញ្ញត្ដិ** ប្រែថា ដឹងបានដោយប្រការ: គឺតាំងឡើងចែកចេញជា ២ ប្រភេទគឺ

១- **សទ្ទបញ្ញត្ដិ** គឺតាំងឡើងតាមសំឡេង ។

២- **អត្ថបញ្ញត្ដិ** គឺតាំងឡើងតាមសេចក្ដី ឬតាមសេចក្ដីសម្គាល់នោះៗ ។

សទ្ទបញ្ញត្ដិចែកជា ៦ ប្រការគឺ

១- **វិជ្ជមានបញ្ញត្ដិ** បានដល់ឈ្មោះរបស់បរមត្ថទាំងអស់ ដូចរូប វេទនា សញ្ញាជាដើម ឈ្មោះអម្បាលនេះជាបញ្ញត្ដិ ដែលមានសភាវៈ រ៉ាប់រង (ទទួលរង) ។

២- **អវិជ្ជមានបញ្ញត្ដិ** បានដល់ឈ្មោះរបស់ពោហារ ដែលលោកតាំងទុក ដោយមិនបានអាស្រ័យបរមត្ថ ដូចដី ទឹក ភ្នំ ព្រៃឈើ ជាដើម

ឈ្មោះអម្បាលនេះជាបញ្ញត្តិ ដែលមិនមានសភាវៈរ៉ាប់រង (....) ។

៣- **វិជ្ជមានេនអវិជ្ជមានបញ្ញត្តិ** គឺឈ្មោះរបស់បរមត្ត និងមិនមែនឈ្មោះរបស់បរមត្ត ផ្សំគ្នាហៅដូច **ឆឡាភិញ្ញា** (អ្នកមានអភិញ្ញាទាំង ៦) **ញាណលាភី** (អ្នកបានញាណ) ជាដើម ជាបញ្ញត្តិដែលមានសភាវៈរ៉ាប់រង និងបញ្ញត្តិដែលមិនមានសភាវៈរ៉ាប់រង (....) ។

៤- **អវិជ្ជមានេនវិជ្ជមានបញ្ញត្តិ** ជាឈ្មោះដែលមិនមានបរមត្ត និងឈ្មោះដែលមានបរមត្តផ្សំគ្នា **ឥត្ថីសទ្ទោ** (សំឡេងរបស់ស្ត្រី) **បុរិស-វាយាមោ** (សេចក្តីព្យាយាមរបស់បុរស) ស្ត្រី និង បុរស ជាឈ្មោះមិនមានបរមត្ត សំឡេង និងសេចក្តីព្យាយាម ជាឈ្មោះដែលមានបរមត្ត សម្គាល់សេចក្តីថា ជាបញ្ញត្តិដែលមិនមានសភាវៈរ៉ាប់រង និងបញ្ញត្តិដែលមានសភាវៈរ៉ាប់រង (.....) ។

៥- **វិជ្ជមានេនវិជ្ជមានបញ្ញត្តិ** ជារឿងរបស់បរមត្តទាំង ២ ផ្សំគ្នាដូច **បក្ខុវិញ្ញាណំ** (វិញ្ញាណផ្ទូវភ្នែក) **លោភសេវៈ** (សេពសេចក្តីលោភ) ជាបញ្ញត្តិដែលមានសភាវៈរ៉ាប់រង និងបញ្ញត្តិដែលមានសភាវៈរ៉ាប់រង ។

៦- **អវិជ្ជមានេនអវិជ្ជមានបញ្ញត្តិ** ឈ្មោះទាំង ២ នេះ សុទ្ធជាឈ្មោះដែលប្រាសចាកបរមត្ត ដូច **រាជបុត្តោ** (រាជបុត្រ) **រាជរថោ** (រាជរថ) ជាដើម ពាក្យ ២ នេះ **រាជៈ** ក៏មិនមែនបរមត្ត **បុត្ត** និង **រថ** ក៏មិនមែនបរមត្តដូចគ្នា សម្គាល់សេចក្តីថា បញ្ញត្តិដែលមិនមានសភាវៈរ៉ាប់រង

និងបញ្ញត្តិដែលមិនមានសភាវៈរ៉ាប់រង ។

ចំណែក **អត្ថបញ្ញត្តិ** នោះ ជាបញ្ញត្តិប្រភេទមួយដែលអាស្រ័យអាការ របស់ផ្សេងៗ ដែលមានវិបរិត ឬអាស្រ័យរូបរាងសណ្ឋានរបស់វត្ថុផ្សេងៗ របស់ផ្សេងៗ រួមទាំងដែលមានជីវិត និងមិនមានជីវិត ចំណែកចេញទៅ បាន ៦ ប្រភេទគឺ

១- **សណ្ឋានបញ្ញត្តិ** អាស្រ័យរូបរាងសណ្ឋានហៅ ដូច **ភូមិ** (ដី) **បព្វត:** (ភ្នំ) ជាដើម ។

២- **សម្ហារបញ្ញត្តិ** អាស្រ័យសេចក្តីប្រជុំរបស់វត្ថុ និងរបស់ផ្សេងៗ ទើបបញ្ញត្តិហៅឡើង ដូច **គេហ:** (ផ្ទះ) **រថ** (រថ) **សកដ:** (រទេះ) ជាដើម ។

៣- **សត្តបញ្ញត្តិ** អាស្រ័យខន្ធទាំង ៥ បញ្ញត្តិហៅឡើង ដូច **បុរិស:** (បុរស) **ឥត្ថី** (ស្ត្រី) ជាដើម ។

៤- **ទិសាកាលាទិបញ្ញត្តិ** អាស្រ័យព្រះអាទិត្យ ព្រះចន្ទ ដួងផ្កាយ សេចក្តីវិលវល់ប្រែប្រួលចូលចេញ ទើបបញ្ញត្តិហៅដូចជា ទិសខាងកើត ទិសខាងលិច ថ្ងៃ ខែ ឆ្នាំ ជាដើម ។

៥- **ឋូបគុហាបញ្ញត្តិ** អាស្រ័យអាការ និងអាស្រ័យមហាភូតរូប ទាំង ៤ មិនតជាប់គ្នា ទើបបញ្ញត្តិហៅ ដូច **ឋូប:** (រណ្ដៅ) **គុហា** (ល្អាង) ជាដើម ។

៦- **និមិត្តបញ្ញត្តិ** អាស្រ័យនិមិត្តរបស់កម្មដ្ឋាន និងអាស្រ័យអាការ ដែលកើតរបស់ភាវនា ទើបបញ្ញត្តិតាំងឡើងហៅដូច **បរិកម្មនិមិត្ត ឧគ្គហនិមិត្ត** ជាដើម ។

បណ្តាសម្មតិបញ្ញត្តិទាំងអស់ ដែលសម្តែងមកហើយដោយសង្ខេបប៉ុណ្ណោះ បើនឹងពណ៌នាសម្មតិបញ្ញត្តិដែលមានមកក្នុងលោកទាំងអស់ហើយ ក៏មិនអាចពណ៌នាឲ្យអស់បាន ព្រោះការសម្មតិបញ្ញត្តិនោះ មិនដូចគ្នា ជាតិមួយភាសាមួយ ក៏សម្មតិទៅមួយយ៉ាងៗ ដូចពាក្យថា ក្តៅជាភាសា **ទេមរ:** ភាសាបាលីហៅថា **ឧណ្ហា** ភាសាអង់គ្លេសហៅថា **ហត** ភាសាចិនហៅថា **យ្ហក** មានផ្សេងគ្នាដូច្នេះគ្រប់ភាសា អាស្រ័យសភាវ:ដែលជាតួបរមត្ថគឺសេចក្តីក្តៅស្ថិតនៅទុកឲ្យបញ្ញត្តិ តែកាលពោលដោយបង្រួញទីបំផុតហើយមាន ២ ប្រការគឺ បញ្ញត្តិដែលមានសភាវ:រ៉ាប់រង និងបញ្ញត្តិដែលមិនមានសភាវ:រ៉ាប់រងប៉ុណ្ណោះ ។ តែបញ្ញត្តិ ឬសម្មតិ ដែលមិនមានសភាវ:រ៉ាប់រង ព្រះពុទ្ធអង្គបានត្រាស់ហៅថា **មោឃធម៌** ទាំងអស់ ។

ពាក្យថា **មោឃធម៌** នោះគឺ ទ្រទ្រង់ភាពមិនមានទុក បើនឹងមានបញ្ហាសួរថា មិនមានយ៉ាងណា ? ខនេះវិសជ្ជនាថា គឺជារបស់ទទេ ខសម្គាល់គឺសំដៅយកដោយខ្ជូនឯង សូមឲ្យសម្ជឹងទៅជុំវិញខ្ជូនយើង យើងនឹងឃើញវត្ថុរបស់ផ្សេងៗ ច្រើនយ៉ាង ច្រើនប្រភេទជា

ដើមថា ភូមិ ផ្ទះ គ្រឿងប្រើប្រាស់ផ្សេង ៗ មានសំពត់អាវអាភរណ: គ្រឿងប្រដាប់តាក់តែងរាងកាយ មានការ ចិញ្ចៀន ពេជ្រ នីល ចិន្តា អម្បាលនេះ សុទ្ធតែជាបញ្ញត្តិសម្មតិ ដែលមិនមានសភាវ:រ៉ាប់រងទាំងអស់ កាលវេលាកន្ធងទៅ ទ្រព្យសម្បត្តិនិងភូមិផ្ទះទាំងអស់ រមែងទ្រុឌទ្រោម បាក់បែកពុកផុយរលួយទៅ ដោយអំណាច ក្តៅ ត្រជាក់ ជាដី ទឹក ខ្យល់ ភ្លើង ទាំងអស់ សល់តែភាពទទេ ។ នឹងស្រាវទាញយកមកថា ជារបស់យើងក៏មិនបាន ព្រោះជាមោឃធម៌ មិនមានអ្វី សូម្បីតែវត្ថុ របស់ដែលធ្វាយចេញទៅទូទាំងសកលចក្រវាឡ ក៏មានតែជាមោឃ:ទាំង អស់ ដូចស្មៅទាំងអស់ រល្ងិទាំងអស់ ដើមឈើទាំងអស់ ភ្នំទាំងអស់ ដែក ឬវត្ថុធាតុទាំងអស់ ក៏រមែងបែកធ្វាយ ផុយរលួយជាដី ទឹក ភ្លើង ខ្យល់ទាំងអស់ សូម្បីថា ពួកមនុស្ស សត្ត លើផ្ទៃប្រឹថពីនេះ កាល កើតមកហើយ រមែងជួបប្រទះសេចក្តីជរាចាស់គ្រាំគ្រា ជួបសេចក្តី ឈឺចាប់លំបាកកាយលំបាកចិត្ត ទីបំផុតក៏ដល់សេចក្តីមរណ: មានកាយ ដែលប្រជុំដោយធាតុទាំង ៤ ក៏បែកញ្រែកចេញចាកគ្នា ផុយរលួយជាដី ទឹក ភ្លើង ខ្យល់ តែម្យ៉ាងៗ មិនមានអ្វី ជាមោឃធម៌ពិតៗ សូម្បីថា សត្ត អម្បាលនេះ មានទឹក ដី ភ្លើង ខ្យល់ប្រជុំឲ្យយើងអាស្រ័យនៅ ដែល ហៅថា ឱកាសលោក ឬលោកដទៃទាំងអស់ ព្រោះព្រះបរមសាស្តាទ្រង់ សម្តែងទុកថា "កាលអស់កប្បហើយ លោកនឹងទម្ងាយ" ជាមោឃធម៌

ទៀតដូចគ្នា ។

គ្រានេះពិចារណារលឹកដល់អត្តភាពខ្លួនប្រាណរបស់យើង ក៏ជាមោយ:មកជាលំដាប់ ខណ:ដែលបដិសន្ធិក្នុងគភ៌មាតា តាមព្រះអភិធម្ម រូបបវត្តិ សម្តែងទុកថា មានទឹកកលល:ដែលជារូបក្នុងបដិសន្ធិ រមែងមានត្រឹមចំណែកតូច ប្រមាណបានប្រហែលទឹកដែលរុយតូចៗ បានព្យាយាមផឹកក្នុងកាលម្តងៗ និងជាទឹកកលល: គឺទឹកថ្ងូ នៅបានដល់មួយសប្តាហ៍ ហៅថា **កលលសន្ធាហ:**, តអំពីនោះក្លាយជាពងទឹក នៅបានទៀតមួយសប្តាហ៍ ហៅថា **អម្ពុទសន្ធាហ:**, ហើយក្លាយជារំអិលទៀតមួយសប្តាហ៍, ហៅថា **បេសិសន្ធាហ:**, តអំពីនោះក៏ក្លាយជាដុំសាច់ នៅមួយសប្តាហ៍, ហៅថា **ឃនសន្ធាហ:**, តអំពីនោះក៏កើតជាពកទាំង ៥ គឺក្បាល ១ ដៃ ២ ជើង ២ នៅប្រមាណមួយសប្តាហ៍ ហៅថា **បរិបាកសន្ធាហ:**, តអំពីនោះក៏នឹងកើត អាយតន:ខាងក្នុង មានភ្នែកត្រចៀក ច្រមុះ អណ្តាតកាយ នៅប្រមាណមួយសប្តាហ៍ ហៅថា **បញ្ចាទិសន្ធាហ:**, តអំពីនោះ ក៏នឹងចម្រើនធំចាស់ក្លាឡើងដោយលំដាប់ជាវេលាប្រមាណ ៣០ សប្តាហ៍ ហៅថា **បរិបាកសន្ធាហ:**, តអំពីនោះ កើតសក់ រោម ក្រចកជាដើមជាវេលាប្រមាណមួយសប្តាហ៍ ហៅថា **កេសាទិសន្ធាហ:** រួមវេលាប្រមាណ ៤២ សប្តាហ៍ គិតជាវេលា ៩ ខែ ២៤ ថ្ងៃ ហើយទើបប្រសូតមកចាកគភ៌មាតា នឹងឃើញបានថា ជា

មោយធម៌ជានិច្ច ជាទឹកថ្លាអស់ទៅ ក្លាយជាពងទឹក ពងទឹកអស់ទៅ ក្លាយជារំអិល រំអិលអស់ទៅក្លាយជាដុំសាច់ ដុំសាច់អស់ទៅ ក្លាយជាមានក្បាល ស្មា ភ្លៅ រូបនោះអស់ទៅ ក្លាយជាមាន ភ្នែក ត្រចៀក ច្រមុះ អណ្តាតជាដើមទាល់តែផ្ទាស់សភាពមាន សក់ រោម ក្រចក ជាដើម ។

កាលប្រសូតមកហើយ ក៏ត្រូវអាស្រ័យកវឡិង្ការាហារ មានអាហារ គឺទឹកដោះ និងបាយបញ្ចុក ចម្រើនធំឡើងជាលំដាប់ កន្ទងវ័យទន់ខ្ចី ដែលដេកលើសំពត់ទ្រនាប់[១] ឬអង្រឹងជាដើម តាមថ្ងៃនិងវេលាចែកបានជា ១០ វ័យដូច្នេះ

១- **មន្ទទសក:** វ័យទន់ខ្ចីរាប់តាំងអំពីប្រសូតិមកក្នុងឆ្នាំទី ១ ដល់ ១០ ឆ្នាំ ក្នុងថ្ងៃនេះ នឹងឃើញសេចក្តីជាមោយ:ច្រើនរយ: ដូចរូបទន់ខ្ចីដែលដេកនៅលើសំពត់ទ្រនាប់ចាត់ទៅ ក្លាយជាក្មេងអង្គុយបាន ដើរបាន និយាយបាន រូបលក្ខណ:ដូច្នោះចាត់ទៅ ក្លាយជាក្មេងលេងផង់ធូលីលេងដី អម្បាលនេះជាដើម ។

២- **ខិឌ្ឌទសក:** វ័យសប្បាយ រាប់អំពីអាយុ ១០ ឆ្នាំ ដល់ ២០ ឆ្នាំ ចូលចិត្តសប្បាយ ចូលចិត្តកីឡាផ្សេងៗ ស៊ីច្រើន ដេកច្រើន រីករាយជានិច្ច សប្បាយទីណា ទៅទីនោះ ច្រៀងរាំទីណា ទៅទីនោះ កាលវ័យនេះ

១- កែបសម្រាប់ផ្តេកកូនខ្ចី ។

ប្រាកដឡើង វ័យទន់ខ្ចី(ក្មេង) ដែលនៅលេងផង់ធូលីលេងដី ក៏បាត់ទៅជាមោយ: នឹងស្រែកហៅឲ្យត្រឡប់មកវិញដូចដើម មិនបានទៀតឡើយ សូម្បីអាហារដែលទទួលទានរាល់ៗ ថ្ងៃ ក៏មានតែអស់ទៅៗ មិនមានសល់ ។

៣- **វណ្ណទសក:** វ័យល្អ គឺវ័យកំលោះ វ័យក្រមុំ អាយុតាំងអំពី ២០ ឆ្នាំ ដល់ ៣០ ឆ្នាំ ក្នុងវ័យនេះ ជាវ័យដែលមានតណ្ហារាគ: គឺសេចក្តីតម្រេក ស្រឡាញ់ ចង់បាន ចម្រើនក្លា មានសោមនស្សត្រេកអរនៅនឹងអារម្មណ៍ ជាទីតាំងនៃសេចក្តីស្រឡាញ់តម្រេក សម្លឹងមើលលោកនេះ ពេញទៅដោយវិចិត្រ ត្រកាល ក្នែក ឃើញដើមឈើ ដើមស្មៅ ផ្ការឈើ ក៏ចូលចិត្តរីករាយដូចភមរជាតិ (មានកន្ទង់ជាដើម) ត្រាច់ហើរទៅទំដើមឈើនោះហើយ ក៏ទៅដើមឈើនោះ វង្វេងភ្លេចសេចក្តីទុក្ខលំបាកទាំងមូល សំឡេងខ្យល់ខ្ទប់ស្លឹកឈើ ក៏ស្រមៃទៅថាជាសំឡេងពិណចូលចិត្តក្ងិនក្រអូប ចូលចិត្តរសល្អ រសឆ្ងាញ់ ចូលចិត្តគ្រឿងសម្ជស្សដែលល្អ ដែលប្រណីត ចិត្តនឹកគិតតែក្នុងអារម្មណ៍ ដែលជាឥដ្ឋារម្មណ៍ដែលគួរប្រាថ្នា វង្វេងភ្លើតភ្លើនទៅក្នុងអារម្មណ៍ទាំង ៦ ចិត្តដែលជាប់នៅនឹងតណ្ហា សេចក្តីចំណង់ ប្រាថ្នាឲ្យរូបកាយកម្រើកទៅតាមសេចក្តីត្រូវការផ្ទាស់ប្តូររាល់ថ្ងៃ រាល់យប់រហូត ១០ ឆ្នាំអស់ទៅៗ នឹងស្រែកហៅឲ្យត្រឡប់មកវិញដូចដើមមិនបានទៀតឡើយ ជាមោយធម៌សុទ្ធៗ ។

៤- **ពលទសក:** *វ័យមានកម្លាំង អាយុតាំងអំពី ៣០ ឆ្នាំ ដល់ ៤០ ឆ្នាំ មានកម្លាំងបរិបូរធ្វើការងារមាំមួនជាលក្ខណៈ សម្បូរដោយ ស្វាមី ភរិយា បុត្រ ធីតា ទ្រព្យ យស និងបរិវារ មិនយូរ ១០ ឆ្នាំអស់ទៅៗ នឹងស្រែកហៅឲ្យត្រឡប់មកវិញ នៅជាសភាពនោះទៀតមិនបាន បានឈ្មោះថាមិនមាន ជាមោឃ: ។*

៥- **បញ្ញាទសក:** *វ័យដែលមានបញ្ញាបរិបូរ អាយុតាំងអំពី ៤០ ឆ្នាំ ដល់ ៥០ ឆ្នាំ មានសតិបញ្ញាយ៉ាងមោះមុត ដឹងហេតុ ដឹងផល ដឹងកាល:ទេស: ស្គាល់បុគ្គល ជាអ្នកខ្ពស់ដោយអាយុ និងគុណធម៌ ស្គាល់ភាវ:របស់ខ្លួន ស្គាល់គុណ ទោស ប្រយោជន៍ មិនមែនប្រយោជន៍ ជាទីគោរពរាប់អានរបស់កុលបុត្រ កុលធីតា លុះវេលាកន្ធងទៅអស់ទៅ ១០ ឆ្នាំ បញ្ញាដែលសម្បូរនោះ និងសរីរាង្គកាយ ក៏សូន្យទៅ អស់ទៅ ជាមោឃធម៌ ។*

៦- **ឋានិទសក:** *វ័យមានកម្លាំងថយ អាយុតាំងអំពី ៥០ ឆ្នាំ ដល់ ៦០ ឆ្នាំ កម្លាំងដែលធ្លាប់មាំមួន ក៏អន់ថយចុះ នឹងធ្វើកិច្ចការងារណាដែលធ្ងន់ ក៏ធ្វើមិនបានដូចអំពីមុន នឹងដើរទៅណាមកណា ក៏ត្រូវឈប់សម្រាកដកដង្ហើម ដង្ហក់ មិនស្រួល ត្រូវអាស្រ័យអ្នកដទៃ លុះវេលាកន្ធងទៅអស់ទៅៗ ១០ ឆ្នាំ ភាពនោះក៏ចុតត់ទៅអស់ទៅផង ជាមោឃធម៌ ។*

៧- **បញ្ជារទសក:** *វ័យជរា មានអាយុតាំងអំពី ៦០ ឆ្នាំ ដល់ ៧០*

ឆ្នាំ មានសក់ក្លាយចាកពណ៌ខ្មៅ ជាពណ៌ស ធ្មេញដែលធ្លាប់រឹងមាំ ក៏រង្គោះរង្គើរបូតទៅ ជ្រុះទៅ សាច់ស្បែក ក៏យុវយោរ ភ្នែកដែលធ្លាប់ភ្លឺថ្លា ក៏ស្រវាំង ត្រចៀកដែលធ្លាប់ឮច្បាស់ ធ្លាប់ស្តាប់ច្បាស់ សព្ទសំឡេងបានធ្លាយៗ ក៏ហ៊ីង ក៏ជ្ងង ចង់ទឹងស្តាប់ ក៏ត្រូវផ្ទៀងត្រចៀកចូលទៅជិតៗ ស្តាប់សំឡេងមិនច្បាស់ ចាំខុស ចាំភ្លាត់ រៀលកន្ទុងទៅអស់ទៅ ១០ ឆ្នាំ សភាពនោះមិនមានប្រាកដឲ្យឃើញនៅទៀត ជាមោយ: ។

៨- **រ៉ាំ**ទ**ស**ក: *រ* យ*ន*ង*ក*ង *អ*យុ*ត*ង*អ*ំ*ព*ី ៧០ ឆ្នាំ*ដ*ល់ ៨០ ឆ្នាំ ដើ*រ*ទៅ*ណ*ាម*ក*ណ*ា ក*ត្រ*ូ*ว*ប្រ*ើ*ឈ*ើ*ច្រ*ត*ជ*ួ*យ*ค*ាំ*ទ*ៅ ម*ន*ន*ង*ដ*ល* *ค*ម*ចុ*ះ*ม*ก ធ*ន*ទ*្រ*ាំ*ន*ៅ*ន*ឹ*ង*ค*ារ*ค*ើ*ច*អ*ូ*ส*អ*ត*ត*ภ*ាព ដ*ោ*យ*ส*េ*ច*ค*្ត*ី*ล*ំ*ป*ុ*ค* *ด*ូ*ច*្ន*ោ*ះ ១*០* ឆ្ន*ាំ*អ*ส*់*ទ*ៅ*ៗ ជ*ា*ម*ោ*យ*ธ*ម*ិ*ม*ิ*ន*ม*ាន*អ*ូ*ว ។

៩- មោ**ម**ូ**ហ**ា**ទ**ស**ก**: *រ* យ*ม*ាន*ส*េ*จ*ค*ី*ว*ង*ง*ង ***អ***ាយុ*ต*ាំ*ง*អ*ំ*ព*ី ***៨***០ ***ឆ***ាំ *ด*ល់ ***៩***០ ***ឆ***ាំ ***ม***ាន*ส*េ*จ*ค*ី*ទ*ង*ง*ង*ต*ាំ*ว*ង*ง*ង*ๆ ***ค***ូ*จ*ๆ ***ค***ូ*ง*ง*ๆ ***ธ***ิ*ย*ាយ ***ข***ុ*ส*ๆ ***ค***្ម*ว*ๆ ***ป***រ*ิ*ภ*ោ*ค*ม*ห*ារ*ห*ើ*យ*ป*ាม*ิ*ธ*ป*ាน*ป*រ*ิ*ภ*ោ*ค ***ค***ូ*จ*ម*ุ*ข*ค*ូ*จ*ค*្រ*ោ*យ ***ป***ាទ*ี*ข*ួ*ญ*ม*ห*ួ*ม*ร*ป*ส*់*ค*ូ*ณ*ป*ៅ ***ห***ុ*ค*ม*ิ*ธ*ม*ាน*ส*េ*จ*ค*ី*ค*ต*ญ*ญ*ค*ต*ว*ท*ี ***ธ***ន*ท*្ម*ร*ាំ *ว*ទ*ន*ា*ន*ៅ*ด*ូ*ច*្ន*ោ*ះ ***១***០ ***ឆ***ាំ ***អ***ស*ន*ៅ ***ป***ាម*ោ*យ*ธ*ม*ิ*ต*ิ*ต*ๆ ***ๆ***

១០- សយ**ន**ទ**ស**ก**:** *រ*យ*ด*ក *អ*យុ*ต*ាំ*ง*អ*ំ*ព*ី ***៩***០ ***ឆ***ាំ*ด*ល់ ***១***០០ ***ឆ***ាំ *ค*្រ*ค*ក*ค*ៅ*ณ*ាម*ิ*ธ*ป*ាន*ห*ើ*យ ***ค***្ម*ว*ដ*ค*ក*ล*ិ*จ*ន*ค*ៅ*ล*ើ*ด*ំ*ณ*ក ***ส***ុ*ป*ី*ค*ៅ*ง*ឹ*ง*ค*ន*ូ*ง ***ป***ន្ទ*ว*រ*ข*ច្ច*ว*រ:*ป*ส*ก*ว*:*ค*ៅ*ง*ឹ*ง*ค*ន*ូ*ง ***ด***ក*จ*ា*ม*ៅ*ส*ូ*ป*់ ***ข***ប*ม*ា

ដូចគោដែលនាយគោបាលនាំទៅកាន់ទីសម្ងាប់ដូច្នោះ រៀលកន្ទ ងទៅ ១០ ឆ្នាំ អស់ទៅដោយទទេចាកប្រយោជន៍ មិនមានអ្វី ជាមោឃធម៌ ។

កាលអស់អាយុ១ម្ភៃហើយ ជីវិត (ចំហាយ) ក្តៅឧណ្ហ និងវិញ្ញាណ រមែងរលត់ទៅ សល់នៅតែសាកសពស្អុយរលួយជាទីរង្គ្រៀស របស់មនុស្ស ទាំងឡាយ គេយកទៅកប់ឬដុតនៅទីប៉ាន ដូចកំណាត់ឧស ឬកំណាត់ឈើ ពុកផុយ ដោយត្រជាក់និងក្តៅ ក្លាយជាដី ទឹក ភ្លើង ខ្យល់ ទៅអស់ ជា មោឃធម៌ មិនមានអ្វីពិតៗ គ្រាន់តែជាសម្មតិ បញ្ញត្តឡើងជាសត្ត បុគ្គលប៉ុណ្ណោះ ។

បរមត្ថធម៌

កាលសម្មតិបញ្ញត្តិ ដែលជាមោឃធម៌បានរលាយហើយ ក៏ធម្មជាតិ មួយ ដែលជាសន្ត្តិ ជាប់តគ្នារហូតទៅមិនដាច់ក្រសៃ ធម្មជាតិដែលពិត នោះ ហៅថា **បរមត្ថធម៌** ជាសភាពដែលកើតរលត់ជានិច្ច កាលជិត ទ ងអស់ជីវិត មាន **កម្ម កម្មនិមិត្ត គតិនិមិត្ត** ជាស្ថានឲ្យចិត្តដែលចុតិនិង បដិសន្ធិចាកភពចាស់ កាន់ភពថ្មី មិនចេះអស់ មិនចេះហើយ ហៅថា **វដ្តសង្សារ** គឺការត្រាច់រង្គាត់ទៅក្នុងភព ៣ កំណើត ៤ គតិ ៥ វិញ្ញាណឋិតិ ៧ សត្តាវាស ៩ ភូមិ ៣១ ដែលចាត់ជាភូមិទាងទាប (ក្រោម) ហៅថា **ហេដ្ឋិមភូមិ,** ភូមិកណ្តាល ហៅថា **មជ្ឈិមភូមិ និង**

ភូមិខាងខ្ពស់ (លើ) ឬភូមិជាន់ខ្ពស់ ហៅថា **ឱបរិមភូមិ** ដែលរួមហៅថា **សង្សារ** ការត្រាច់រង្គាត់របស់សត្វទាំងឡាយ មានអធិប្បាយដូចតទៅនេះគឺ ៖

១- ***ហេដ្ឋិមសង្សារ*** ការត្រាច់រង្គាត់របស់សត្វទាំងឡាយ ក្នុងភូមិខាងទាប (ក្រោម) គឺអបាយភូមិ ៤ ប្រេត អសុរកាយសត្វនរក និងសត្វតិរច្ឆាន អាស្រ័យកម្ម កម្មនិមិត្ត និងគតិនិមិត្តដូច្នេះ ។ បុគ្គលដូចមនុស្សកាលជិតនឹងស្លាប់ បញ្ចូទ្វារមែងរលត់មុន គឺភ្នែកមិនឃើញត្រចៀកមិនឮ ច្រមុះមិនដឹងក្លិន អណ្ដាតមិនដឹងរស កាយមិនដឹងសម្ផស្ស កាយខាងលើស្លាប់ចុះមកដល់ក គឺអស់សេចក្ដីដឹងរហូត មកដល់ដើមដៃទាំងពីរខាង កាយខាងក្រោមស្លាប់តាំងអំពីជើងមកដល់ពោះ អស់សេចក្ដីដឹងមានសេចក្ដីដឹងត្រឹមនឹកគិតមនោទ្វារ គឺផ្លូវចិត្តតែម្យ៉ាង របស់ទាំងឡាយមិនមានអ្វីជាសរណៈទីពឹងទីអាស្រ័យបានឡើយ មានតែកម្មដែលធ្លាប់បានធ្វើមកប៉ុណ្ណោះ ជាអារម្មណ៍ ឲ្យអ្នកដែលនឹងទៅកើតក្នុងភូមិនៃប្រេត និងអសុរកាយ កម្មអាក្រក់ដែលជាអកុសលកម្ម ដែលបានធ្លាប់ធ្វើមកហើយអំពីអតីត ដូចការបូន់ ការលួច ឬការប្រព្រឹត្តខុសក្នុងកាមមានលោភៈ តណ្ហា រាគៈ ជាហេតុឲ្យកម្មដែលធ្លាប់ធ្វើអាក្រក់ដូច្នេះ នឹងមកប្រាកដផ្លូវចិត្តឲ្យឃើញថាខ្លួនបានធ្វើក្នុងខណៈនោះហៅថា កម្មនិមិត្ត កាលកម្មនិមិត្តកើតឡើងហើយបាត់ទៅ ជាបច្ច័យឲ្យកើតគតិនិមិត្ត គឺភូមិ

របស់ប្រេតអសុរកាយ មានទិមិត្តជាកក់ជាល្ហាប់ របស់អាក្រក់ស្មោកគ្រោក ឬច្រាំងស្ទឹង ជាយព្រៃជាដើម ជាស្ពានឲ្យបជិសន្ធិចិត្តកើតឡើង កាលចុតិចិត្តរលត់ចុះហើយ ក៏ទ៍ងទៅបជិសន្ធិក្នុងភូមិនៃប្រេត ឬអសុរកាយ បើបច្ចុប្បន្នជាតិ បានធ្លាប់ធ្វើកម្មអាក្រក់ មានសម្ងាប់សត្ត សម្ងាប់មនុស្ស មានវាចាជេរអ្នកដទៃ មានចិត្តគិតព្យាបាទប្រទូសរ៉ាយដែលកើតមកពីទោស: គឺសេចក្ដីក្រោធជាហេតុឲ្យកើតកម្មនិមិត្ត ដូចជា ខ្លួនបានកំពុងធ្វើ នៅក្នុងវេលានោះ ជាបច្ច័យឲ្យកើតគតិនិមិត្ត មានភ្លើង ឬសស្ត្រាវុធ ធ្លាប់ដុតបំផ្លាញ ឬឲ្យបានទទួលទុក្ខវេទនា កាលចុតិរលត់ចុះហើយ ទ៍ងជាហេតុឲ្យកើតបជិសន្ធិចិត្តក្នុងភូមិនៃនរក បានទទួលទុក្ខវេទនាសែនសហ័ស អស់កាលយូរ ទម្រាំទ៍ងអស់អាយុរបស់វិបាកកម្ម ថាបើក្នុងបច្ចុប្បន្នជាតិនេះ បានធ្វើកម្មអាក្រក់ទុក ដោយអំណាចនៃមោហ: គឺសេចក្ដីវង្វ៍ង សេចក្ដីធ្ងេសប្រហែស សេចក្ដីមិនដ៏ង គឺមិនស្គាល់បាប បុណ្យ គុណ ទោស ប្រយោជន៍ ឬមិនមែនប្រយោជន៍ មានកិរិយាស្ទឹ្ធ ធ្វើការងារខុសភ្ងាត់ជានិច្ច និយាយទ្ឆ្ងេះទ្ឆ្ងោះមិនបានជារឿ៍ងអ្ហ៍ទ្ឡើយ មិនមានហេតុផលចិត្តអណ្ដែតអណ្ដ៍ង ប្រាសចាកសេចក្ដីប្រ៍ងគិត ទ៍ងទ៍ងធ្ងើ ក៏ធ្ងើ ទ៍ងទ៍ងនិយាយ ក៏និយាយ កម្មអម្ប្ាលនេះមកប្រាកដហើយ ក្នុងវេលាជិតទ៍ងស្ងាប់ ហៅថាកម្មនិមិត្ត ជាបច្ច័យឲ្យកើតគតិនិមិត្ត ឃើញព្រៃ ឃើញសត្ត តិរច្ឆាន ឬពោះរបស់សត្ត តិរច្ឆាន កាលចុតិរលត់ចុះហើយ បជិសន្ធិចិត្ត

ក៏កើតក្នុងភូមិនៃសត្វតិរច្ឆាន ធន់ទុក្ខវេទនាលុះត្រាតែអស់វិបាកកម្ម សត្វទាំងឡាយអ្នកធ្វើអាក្រក់ និយាយអាក្រក់ គិតអាក្រក់ ដោយអំណាចនៃលោភៈ ទោសៈ មោហៈ រមែងត្រាច់ទៅក្នុងអបាយភូមិ គឺទីនៅរបស់អ្នកប្រាសចាកសេចក្តីសប្បាយ ហៅថា **ហេដ្ឋិមសង្ឃ** ដោយប្រការដូច្នេះ ។

២- **មជ្ឈិមសង្ឃ** គឺត្រាច់រង្គាត់នៅក្នុងភូមិកណ្តាល ឬហៅថាសុគតិភូមិ ៧ គឺ មនុស្សភូមិ ១ និងទេវភូមិ ៦ សត្វអ្នកជិតនឹងស្លាប់ បើប្រាកដកម្មដែលធ្លាប់បានធ្វើមកជាកុសលកម្ម ដែលហៅថា **មនុស្សធម៌** គឺបញ្ចសីល បញ្ចធម៌ ឬកុសលកម្មបថ ១០ ហើយនឹងកើតកម្មនិមិត្ត ដូចជាខ្លួនបានកំពុងធ្វើនៅក្នុងវេលានោះ ព្រោះអាស្រ័យសេចក្តីមិនលោភ មិនក្រោធ មិនវង្វេង ជាហេតុឲ្យកើតគតិនិមិត្ត មានអាគារផ្ទះ ដុំសាច់ ឬគភ៌មាតាជាដើម កាលចុតិរលត់ហើយ ក៏នឹងជាបច្ច័យឲ្យកើតបដិសន្ធិចិត្តក្នុងភូមិនៃមនុស្ស ជាបើក្នុងបច្ចុប្បន្នជាតិនេះ ជាអ្នកមានចិត្តដែលប្រកបដោយ **ហិរិ** សេចក្តីខ្មាសចំពោះបាប **ឱត្តប្ប:** សេចក្តីក្រែងខ្លាចបាបទុច្ចរិត តាំងនៅក្នុងធម៌ស មានចិត្តស្ងប់រម្ងាប់ ប្រាសចាកលោភៈ ទោសៈ មោហៈ ដែលជាហេតុហើយ ជាអ្នកធ្វើទានការកុសល មានការថ្វាយអាហារបិណ្ឌបាតដល់ព្រះភិក្ខុសង្ឆនិងឲ្យទានដល់មនុស្សកម្សត់ទុគ្គតអនាថា ឬថ្វាយត្រៃចីវរដល់ព្រះភិក្ខុសង្ឆ ឲ្យទានសំពត់

អាវដល់មនុស្សកម្សត់ទុគ្គិត សាងកុដិ វិហារ សេនាសនៈ សាលា ឬ សាងរោងរៀន សាងរោងពេទ្យ សាងផ្លូវថ្នល់ សាងរបស់សាធារណៈ ទូទៅ ដែលជាប្រយោជន៍ដល់ភ្ជៀនរួមការកើត ចាស់ ឈឺ ស្លាប់ ជាមួយគ្នា ឬឲ្យទានថ្នាំរក្សារោគជាដើម ឬថាឲ្យចំណែកបុណ្យ អនុមោទនាចំណែកបុណ្យ អម្បាលនេះជាហេតុឲ្យប្រាកដជាកម្មនិមិត្ត ដូចថាខ្លួនកំពុងធ្វើក្នុងវេលានោះ កាលជិតនឹងមរណភាព នឹងជាបច្ច័យឲ្យកើតគតិនិមិត្ត ឃើញជាទេវតា ឬគ្រឿងទ្រង់ទេវតា ឬមានវិមានជាទិព្ធ កាលចុតិរលត់ហើយ បដិសន្ធិចិត្តក៏កើតឡើងក្នុងទេវភូមិ ជាន់ណាមួយ គឺជាន់ចាតុម្មហារាជិកា ជាន់តាវត្តិង្សា ជាន់យាមា ជាន់តុសិតា ជាន់និម្មានរតី ឬជាន់បរនិម្មិត-វសវត្តី តាមវិបាករបស់កុសលកម្មនោះៗ មានអាយុយ៉ាងតិច ៥០០ ឆ្នាំទិព្ធ យ៉ាងច្រើន ៨.០០០ ឆ្នាំទិព្ធ ត្រាច់រង្គាត់ទៅក្នុងសុគតិភូមិ ៧ នេះ ទម្រាំនឹងអស់វិបាក ដោយប្រការដូច្នេះ ។

៣- **ឧបរិមសង្ខ្យា** សេចក្ដីត្រាច់រង្គាត់ក្នុងភូមិជាន់ខ្ពស់ (ខាងលើ) គឺរូបភូមិ ១៦ អរូបភូមិ ៤ ដែលរួមហៅថា **ព្រហ្មភូមិ ២០,** អ្នកជិតនឹងមរណភាពនឹងប្រាកដកម្មដែលជាកុសលកម្មធំ ហៅថា **មហាគ្គតកុសល** បានដល់រូបាវចរកុសល និងអរូបាវចរកុសល មានកម្មដ្ឋាន ៤០ ជាអារម្មណ៍ គឺអនុស្សតិ ១០ កសិណ ១០ អសុភ ១០ ព្រហ្មវិហារ ៤ អាហារេបដិកូលសញ្ញា ១ អរូបកម្មដ្ឋាន ៤ ឯណាមួយ

ជាអារម្មណ៍ មានអង្គ្គឈានចូលប្រកបក្នុងខណៈនោះ បើបានអរូបកម្មដ្ឋាន ៤ ជាអារម្មណ៍ មានឧបេក្ខា ឯកគ្គតា ដែលជាអង្គ្គរបស់បញ្ចមជ្ឈាន ក៏នឹងជាបច្ច័យឲ្យកើតគតិនិមិត្ត គឺភូមិរបស់អរូបព្រហ្ម បើបានរូបកម្មដ្ឋានជាអារម្មណ៍ គឺកម្មដ្ឋាន ១៦ (រឿងអរូបកម្មដ្ឋាន ៤) មានឧបេក្ខា ឯកគ្គតា ដែលជាអង្គ្គឈានចូលប្រកប ក៏នឹងកើតគតិនិមិត្ត គឺភូមិរបស់បញ្ចមជ្ឈាន-ភូមិ បើមានសុខ ឯកគ្គតា ដែលជាអង្គ្គឈានចូលប្រកប ក៏នឹងកើតគតិ-និមិត្ត គឺចតុត្ថជ្ឈានភូមិ បើមានបីតិ សុខ ឯកគ្គតា ដែលជាអង្គ្គឈានចូលប្រកបក៏នឹងកើតគតិនិមិត្ត គឺតតិយជ្ឈានភូមិ បើមានវិចារៈ បីតិ សុខ ឯកគ្គតា ដែលជាអង្គ្គឈានចូលប្រកប ក៏នឹងកើតគតិនិមិត្ត គឺទុតិយជ្ឈានភូមិ បើមានវិតក្ក: វិចារៈ បីតិ សុខ ឯកគ្គតា ដែលជាអង្គ្គឈានចូលប្រកប ក៏នឹងកើតគតិនិមិត្ត គឺបឋមជ្ឈានភូមិ កាលចុតិរលត់ហើយ ក៏នឹងកើតបដិសន្ធិចិត្តក្នុងព្រហ្មភូមិតាមលំដាប់ដូច្នេះ ។

បឋមជ្ឈានភូមិមាន ៣ គឺ ព្រហ្មបារិសជ្ជា ព្រហ្មបុរោហិតា និង មហាព្រហ្ម ។

ទុតិយជ្ឈានភូមិមាន ៣ គឺ បរិត្តាភា អប្បមាណាភា និង អាភស្សរា ។

តតិយជ្ឈានភូមិមាន ៣ គឺ បរិត្តសុភា អប្បមាណសុភា និង *សុភកិណ្ហា* ។

ចតុត្ថជ្ឌានភូមិមាន ២ គឺ **រ៉ៃហប្ផលា** *និង* **អសញ្ញីសត្ត** *(ចំពោះ*
*ឬ*ប*ុ*ជ្ជ*ន)* ។

*ចតុត្ថជ្ឌានភូមិ*ប*ស*់*ព*ះ*ម*ារ*ិ*យ*: *មាន ៥ គឺ* **អ*ារ*ិ*ហ អ*ត*ប្ប
សុ*ទ*ស*ា **សុ*ទ*ស*ី** **អ*ក*ន*ិ*ដ*ា*:** ។

*ប*ញ*ា*ម*ជ*ា*ន*ភ*ូ*ម*ិ*ម*ាន ៤ ហ*ៅ*ថ*ា* *អ*ារ*ូ*ប*ភ*ូ*ម*ិ* *គ*ឺ* **អ*ា*ក*ា*ស*ា*ន*ញ*ា*យ*ត*ន:
ว*ិ*ញ*ញ*ាណ*ញ*ា*យ*ត*ន: **អ*ា*ក*ិ*ញ*ញ*ាយ*ត*ន:** *និ*ង* **ន*ៃ*ว*ិ*ស*ញ*ញ*ានាស*ញ*ា*យ*ត*ន:**
ត្រា*ប*់*ម*ា*ន*ា*ត*់*ន*ៅ*ក*ន*ុ*ង*ព*្រ*ហ*ម*ភ*ូ*ម*ិ* ២០ *ន*េ*ះ* *ម*ា*ន*អ*ា*យ*ុ*យ*ឺ*ន*យ*ូ*រ*ប*្រ*ម*ា*ណ*យ*ា*ង
តិ*ច ១ *ក*ន*ុ*ង ៣ *ម*ហ*ា*ក*ប*្ប *យ*ា*ង*ច*្រ*ើ*ន ៨*៤*.*០*០*០ *ម*ហ*ា*ក*ប*្ប *ក*ា*ល*អ*ស*់
วិ*ប*ា*ក*ដ*ែ*ល*ជ*ា*ម*ហ*ា*គ*ត*ว*ិ*ប*ា*ក*ហ*ើ*យ *ก*็*ន*ឹ*ង*ច*ុ*ត*ិ*ប*ដ*ិ*ส*ន*្ធ*ិ*ក*ន*ុ*ង*ទ*េ*ว*ภ*ូ*ม*ิ *ឬ*
*ม*ន*ុ*ส*្ស*ภ*ូ*ม*ิ*ទ*ៀ*ต *ต*ែ*ន*ៅ*ม*ิ*ន*ធ*្ម*ា*ก*់*ก*ន*ុ*ង*អ*ប*ា*យ*ภ*ូ*ม*ิ *ป*ើ*ធ*្ម*ើ*ป*ា*ป*ป*្រ*ោ*ต*ค*្រ*ោ*ต
ดោ*យ*ก* า*យ*ท*ุ*จ*ว*ิ*ต *ว*ป*ี*ท*ุ*จ*ว*ิ*ต *น*ิ*ง*ม*น*ោ*ท*ุ*จ*ว*ิ*ต *ก*็*น*ឹ*ง*ต*ៅ*ธ*ា*ก*់*ก*ន*ុ*ง*អ*ป*ា*យ-
ภู*ม*ิ*ท*ៀ*ต *อ*ส*ก*ม*ม*ก*ន*ុ*ง*อ*ป*า*ย*ภ*ู*ม*ิ *ก*็*น*ឹ*ง*ม*ก*ก*ើ*ต*ជ*ា*ม*ន*ุ*ส*ส*ท*ៀ*ต *ห*ៅ*ถ* า
ส*ง*ฆ* า*ร*ป*ร*ก **ส*ง*ฆ*า*ร*ว*ิ*ส*ุ*ท*ธ*ิ** *ต*្ร*ា*ป*ា*ต*់*ว*ิ*ล*ว*ล*់*ม*ិ*ន*ม*ា*ន*ท*ី*ป*ំ*ด*ុ*ต *ป*្រ*ោ*ะ
អំ*ณ*ា*ป*ន*ៃ*ก*ิ*ล*ส*ค*ឺ *ล*ោ*ก*: *ท*ោ*ส*: *ม*ោ*ห*: *ช*ា*ด*ើ*ม* ។

*ก*ន*ុ*ង*ภ*ូ*ม*ิ*ផ*្ស*ង*ๆ *ม*ា*น*ส*ะ*ค*ว*ก*ម*្ម*ร*ส*់*ន*ៅ*យ*ា*ง*ณ*า *น*ឹ*ง*ส*ម*ែ*ง*ด*ោ*យ
*ส*ង*្ខ*ป *ด*ู*ป*ต*ท*ៅ*น*េ*ះ ៖

ជំ*ព*ូ*ก*១ **ป*ร*ต** *ค*ឺ*ส*ត*ว*ដ*ែ*ล*ก*ើ*ต*ห*ា*ต*ឲ* យ*ป*า*ก*ส*ะ*ค*ว*ก*ម*្ម*ส*ุ*ข* ។

ជំ*ព*ូ*ก*២ **อ*ส*ุ*ร*ก*ย** *ค*ឺ*ส*ត*ว*ដ*ែ*ล*ม*ิ*ន*ม*ា*น*ส*ะ*ค*ว*ก*ម*្ម*ส*ป*ป*ា*យ* ។

ជំពូក៣ **សត្វនរក** គឺសត្វដែលមិនមានសេចក្ដីសុខ ។

ជំពូក៤ **សត្វតិរច្ឆាន** គឺសត្វដែលដើរទទឹង ដោយបែរមុខទៅកាន់ខាងក្រោយ បានដល់សត្វតិរច្ឆានផ្សេងៗដែលយើញ នៅសព្វថ្ងៃនេះ ។

ជំពូក៥ **មនុស្ស** គឺសត្វដែលមានចិត្តក្លាហាន ទាំងក្នុងផ្លូវល្អនិងផ្លូវអាក្រក់ បានដល់មនុស្សយើងនេះឯង ។

ជំពូក៦ **ចាតុម្មហារាជិកា** បានដល់ទីនៅរបស់ស្ដេចមហារាជ ៤ ព្រះអង្គ ជាជាន់ទី២ ចាកមនុស្ស តាំងនៅក្នុងកណ្ដាលភ្នំសិនេរុ ជាស្ថានទីរបស់ទេវតាជំពូកមួយ ដែលស្ដេចមហារាជទាំង ៤ ជាអ្នកគ្រប់គ្រង តែសត្វដែលអាស្រ័យភ្នំមហាសិនេរុ ក៏មានច្រើនជំពូក ដូចនាគ គ្រុឌ កុម្ភណ្ឌ យក្សជាដើម ខ្លះក៏រាប់ចូលក្នុងទេវតា ខ្លះក៏រាប់ចូលក្នុងតិរច្ឆានតាមតែកំណើតរបស់ខ្លួនៗ ។

ជំពូក៧ **តាវត្តិង្សា** ឬហៅថា តាវត្តិង្ស ជាទីនៅរបស់ពួកទេវរាជ ៣៣ អង្គ មានព្រះឥន្ទជាប្រមុខ ពួកទេវតាដែលកើតទីនោះ ហៅថា **តាវត្តិង្សទេវបុត្រ** តាវត្តិង្សទេវលោកនេះ តាំងនៅលើភ្នំសិនេរុ ឆ្ងាយពីមនុស្ស ៨៤.០០០ យោជន៍ជាប្រមាណ ។

ជំពូក៨ **យាមា** ជានាមរបស់ ស្ដេចមហារាជមួយអង្គ ដែលជាអ្នកគ្រប់គ្រងភូមិនោះ រាប់ពីមនុស្សជាទី ៤ តាំងនៅលើអាកាស ពួក

ទេវតាអម្ចាលនេះ ហៅថា **យាមាទេវតា** មានព្រះសុយាមទេវរាជជាអ្នកគ្រប់គ្រងការ ហៅឈ្មោះភូមិនេះ អាស្រ័យនាមរបស់អ្នកគ្រប់គ្រងជាគោល ហៅថា យាមាភូមិ ។

ជំពូក៩ **តុសិតា** សម្គាល់សេចក្ដីថា ជំពូកទេវតាដែលដល់ការៈមានសេចក្ដីរីករាយ សប្បាយ ពេញចិត្ត ជាភូមិទី ៥ រាប់ពីមនុស្សភូមិ និងតាំងនៅលើអាកាស ដូចជាយាមាភូមិដែរ ។

ជំពូក១០ **និម្មានរតី** សម្គាល់សេចក្ដីថា ទេវតាជំពូកមួយដែលមានសេចក្ដីភ្ញើតភ្ញើនក្នុងកាមគុណផ្សេងៗ ដែលខ្លួននិម្មិតបាន ជាទេវតាដែលមិនមានកិរិយាប្រចាំ កាលមានសេចក្ដីត្រូវការកាលណា ក៏និម្មិតយកតាមគាប់ចិត្ត ហើយសេពកាមតាមធម្មជាតិបានតាមដែលខ្លួនប្រាថ្នា ។

ជំពូក១១ **បរនិម្មិតវសវត្ដី** គឺទេវតាជំពូកមួយ ដែលមានសេចក្ដីភ្ញើតភ្ញើនក្នុងកាមារម្មណ៍ផ្សេងៗ ដែលទេវតាដទៃៗ និម្មិតទុកឲ្យ ខ្លួនមិនបាននិម្មិត កាលត្រូវការអារម្មណ៍ណាៗក្ដី មានទេវតាចាំនិម្មិតឲ្យ មានអ្នករក្សានាទីនៅអែបជិតជរាប ចាំធ្វើនាទីនិម្មិតឲ្យសោយតាមសេចក្ដីត្រូវការ កាលពេញចិត្តក្នុងអារម្មណ៍នោះហើយ ការនិម្មិតក៏ត្រូវលើកចេញសូន្យអន្ដរធានទៅ ។

ជំពូក១២ **ព្រហ្មបារិសជ្ជា** គឺព្រហ្មដែលជាបរិវារបស់ស្ដេចមហា-ព្រហ្ម អ្នកជាប្រមុខ អាស្រ័យនៅក្នុងព្រហ្មបារិសជ្ជាភូមិ ។

ជំពូក១៣ **ព្រហ្មបុរោហិត** គឺព្រហ្មជំពូកមួយដែលទទួលនាទីជាអាមាត្យរបស់ស្តេចមហាព្រហ្ម ដែលជាអ្នកគ្រប់គ្រងក្នុងបឋមជ្ឈានភូមិ ។

ជំពូក១៤ **មហាព្រហ្ម** ជានាមពិសេសរបស់ព្រហ្មមួយអង្គ ដែលជាប្រមុខនៃបឋមជ្ឈានភូមិ ៣ ភូមិ ឧបមាដូចនគរ ៣ នគររបស់ព្រហ្មជំពូកនេះដែលតាំងនៅជាន់ជាមួយគ្នាឥតខ្ពស់ទាបជាងគ្នាឡើយ គឺពួកអ្នកតូចនៅកន្លែងមួយ អ្នកធំនៅកន្លែងមួយ ឯលោកជាប្រមុខក៏នៅកន្លែងមួយទៀតយ៉ាងនេះ ។

ជំពូក១៥ **បរិត្តាភា** គឺព្រហ្មជំពូកមួយដែលមានពន្លឺគឺរស្មី តិចបានដល់ព្រហ្មជំពូកទុតិយជ្ឈានភូមិ ភូមិដំបូង ។

ជំពូក១៦ **អប្បមាណាភា** គឺព្រហ្មដែលមានពន្លឺកู้ មានរស្មីដោយមិនមានប្រមាណ គឺរស្មីច្រើនជាទីបំផុត អាស្រ័យនៅក្នុងទុតិ-យជ្ឈានភូមិ ដែលហៅថា អប្បមាណាភូមិ ។

ជំពូក១៧ **អាភស្សរា** គឺព្រហ្មដែលមានរស្មីចេញនៅរហូតកាលជាឈ្មោះរបស់ព្រះរាជានៃភូមិទាំង ៣ របស់ទុតិយជ្ឈានភូមិនោះឯង ។

ជំពូក១៨ **បរិត្តសុភា** គឺព្រហ្មដែលមានរស្មីល្អស្រស់តែតិច ជាឈ្មោះរបស់ព្រហ្មជំពូកមួយ ក្នុងភូមិដំបូងរបស់តតិយជ្ឈានភូមិ ហៅថា បរិត្តសុភាភូមិ ។

ជំពូក១៩ **អប្បមាណសុភា** គឺព្រហ្មដែលមានរស្មីល្អស្រស់ ដោយ

មិនមានប្រមាណ បានដល់ឈ្មោះរបស់ព្រហ្មជំពូកមួយ ក្នុងតតិយជ្ឈានភូមិ ទាំង ៣ ហៅថា អប្បមាណសុភាភូមិ ។

ជំពូក២០ **សុភកិណ្ហា** គឺព្រហ្មដែលមានរស្មីល្អស្រស់ ចេញ លាយឡំគ្នានៅច្រើនជានិច្ច បានដល់ព្រហ្មអ្នកជាមហារាជក្នុងតតិយជ្ឈាន-ភូមិ ហៅថា សុភកិណ្ហាភូមិ ។

ជំពូក២១ **វេហប្ផលា** គឺព្រហ្មដែលមិនបានផលខ្ពស់ផុតក្នុងរូបជ្ឈាន មានផលវិបុល តាំងនៅក្នុងចតុត្ថជ្ឈានភូមិ ។

ជំពូក២២ **អសញ្ញីសត្តា** បានដល់ព្រហ្មជំពូកមួយដែលមិនមាន នាម គឺសញ្ញាជាដើម ព្រហ្មជំពូកនេះសូម្បីមិនមាននាម តែជាសត្វប្រភេទ មួយ ក្នុងព្រហ្មភូមិ ។

ជំពូក២៣ **អវិហា** គឺព្រហ្មជំពូកមួយ ដែលមិនព្រមចោលភូមិ របស់ខ្លួន ក្នុងវេលាណាមួយសូម្បីតែបន្តិច ។

ជំពូក២៤ **អតប្ឆា** គឺព្រហ្មដែលមិនមានសេចក្តីក្តៅក្រហាយចិត្ត មានចិត្តជាសុខលើសលុប ។

ជំពូក២៥ **សុទស្សា** គឺព្រហ្មដែលមានសេចក្តីអាចឃើញសភាវធម៌ បានដោយបញ្ញាចក្ខុយ៉ាងច្បាស់លាស់ ។

ជំពូក២៦ **សុទស្សី** គឺព្រហ្មដែលមានសេចក្តីអាចឃើញសភាវធម៌ ច្រើនជាង ។

ជំពូក២៧ **អកនិដ្ឋា** គឺព្រហ្មដែលមានសេចក្ដីសុខ និងសេចក្ដីដ៏ងមិនទាបជាងអ្នកណា ព្រោះជាព្រហ្មដែលនឹងជាព្រះអរហន្ដប្រាកដមិនជាយ៉ាងដទៃទៀត ។

ជំពូក២៨ **អាកាសានញ្ចាយតនៈ** គឺព្រហ្មដែលសម្ញឹងអាកាសជាអារម្មណ៍ថា អាកាសមិនមានទីបំផុត តាំងនៅក្នុងអាកាសានញ្ចាយតន-ភូមិ ។

ជំពូក២៩ **វិញ្ញាណញ្ចាយតនៈ** គឺព្រហ្មដែលសម្ញឹងវិញ្ញាណជាអារម្មណ៍ថា វិញ្ញាណមិនមានទីបំផុត តាំងនៅក្នុងវិញ្ញាណញ្ចាយតនភូមិ ។

ជំពូក៣០ **អាកិញ្ចញ្ញាយតនៈ** គឺព្រហ្មដែលសម្ញឹងសេចក្ដីមិនមានអ្វីជាអារម្មណ៍ តាំងនៅលើសេចក្ដីមិនញាប់ញ័រ សូម្បីតែបន្ដិច នៅក្នុងអាកិញ្ចញ្ញាយតនភូមិ ។

ជំពូក៣១ **នេវសញ្ញានាសញ្ញាយតនៈ** គឺព្រហ្មដែលសម្ញឹងសញ្ញាគ្រាតគ្រាត និងសញ្ញាស្ងួតជាអារម្មណ៍ ជួនកាលដ៏ង ជួនកាលមិនដ៏ង ជួនកាលចាំបាន ជួនកាលចាំមិនបាន នៅក្នុងអរូបភូមិជាន់នេវសញ្ញានាសញ្ញាយតនភូមិ ។

សភាវធម៌ដែលធ្វើឲ្យសត្វទាំងឡាយ ត្រាច់រង្គាត់នៅក្នុងវដ្ដសង្សារដែលពេញទៅដោយសេចក្ដីទុក្ខមិនមានទីបំផុត និងសភាវធម៌ដែលធ្វើឲ្យសត្វទាំងឡាយផុតចាកវដ្ដសង្សារ គឺសេចក្ដីអស់ទុក្ខមិនមានចំណែក

សេសសល់ រូមធម៌ទាំងដែលជាសង្ខតធម៌ និងអសង្ខតធម៌ សភាវធម៌ នោះបានដល់ព្រះបរមត្ថធម៌ ៤ ប្រការ គឺធម៌ដែលមានសភាពជាប្រយោជន៍ យ៉ាងលើសគឺ៖

១- ចិត្ត ៨៩ យ៉ាងពិស្តារមាន ១២១

២- ចេតសិក ៥២

៣- រូប ២៨

៤- និញាន ១។

ពាក្យថា ចិត្ត សម្គាល់ដល់សភាវៈដែលដឹងអារម្មណ៍ជាលក្ខណៈ មានភាសាបាលីរ៉ាប់រងថា **អារម្មណវិជានន លក្ខណំ** មានការនាំរូបនាមមកជាកិច្ច មានភាសាបាលីថា **បុព្វង្គមរសំ** មានការរីករាយជាផល មានភាសាបាលីថា **សន្ធហនបច្ចុបដ្ឋានំ** មាននាមរូបជាហេតុជិត មានភាសាបាលីថា **នាមរូបបទដ្ឋានំ** ពាក្យដែលជាពាក្យមួយ ឬ មានសេចក្តីសម្គាល់ជាមួយគ្នានឹងចិត្តគឺ **មនោ មានសៈ ហទយៈ បណ្ឌរៈ មនាយតនៈ មនិន្ទ្រិយៈ វិញ្ញាណៈ វិញ្ញាណក្ខន្ធៈ មនោវិញ្ញាណធាតុ** ។

ពាក្យថា ចេតសិក សម្គាល់ដល់សភាពដែលប្រកបនឹងចិត្តជាលក្ខណៈ ភាសាបាលីថា **ចេតោយុត្តលក្ខណំ** មានលក្ខណៈ ប្រកបនឹងចិត្ត ៤ ប្រការគឺ៖

១- ឯកុប្បាទ: *កើតព្រមនឹងចិត្ត*

២- ឯកនិរោធ: *រលត់ព្រមនឹងចិត្ត*

៣- ឯកាលម្ពណ: *មានអារម្មណ៍ជាមួយគ្នានឹងចិត្ត*

៤- ឯកវត្ថុក: *អាស្រ័យវត្ថុជាមួយគ្នានឹងចិត្ត ។*

ពាក្យថា **រូប** *គឺធម្មជាតដែលបែករលត់ជាលក្ខណៈ ភាសាបាលីថា* **រុប្បនលក្ខណំ** *។*

ពាក្យថា **និព្វាន** *គឺធម្មជាតដែលផុតចាកកងទុក្ខទាំងអស់ រលត់ទាំងកិលេស និង បញ្ចក្ខន្ធ មានសន្តិសុខជាលក្ខណៈ ភាសាបាលីថា* **សន្តិលក្ខណំ** *។*

ចិត្តបរមត្ថធម៌ ៨៩ ចែកជា ៤ ប្រភេទគឺ:

១- **កាមាវចរចិត្ត** *ចិត្តដែលប្រព្រឹត្តទៅក្នុងកាមភូមិមាន ៥៤*

២- **រូបាវចរចិត្ត** *ចិត្តដែលប្រព្រឹត្តទៅក្នុងរូបភូមិមាន ១៥*

៣- **អរូបាវចរចិត្ត** *ចិត្តដែលប្រព្រឹត្តទៅក្នុងអរូបភូមិមាន ១២*

៤- **លោកុត្តរចិត្ត** *ចិត្តដែលផុតចាកលោក គឺរូបលោក នាម-លោក ដែលជាប់តជាសន្ធតិក្នុងកាមលោក រូបលោក និងអរូបលោក គឺ ចិត្តដែលបាននិព្វានជាអារម្មណ៍មាន ៨ ឬ ៤០ ។*

កាមាវចរចិត្ត ៥៤ គឺ:

អកុសលចិត្ត ១២

អហេតុកចិត្ត ១៨

កាមាវចរសោភណាចិត្ត ២៤។

អកុសលចិត្ត *គឺចិត្តដែលមិនមែនកុសល ជាចិត្តបាប ចែកជា ៣ ប្រភេទគឺ៖*

១- លោភមូលចិត្តមាន ៨

២- ទោសមូលចិត្តមាន ២

៣- មោហមូលចិត្តមាន ២។

លោភមូលចិត្ត *គឺចិត្តដែលមានសេចក្តីចង់បានជាមូលដ្ឋាន ៨ មានឈ្មោះដូចតទៅនេះ*

ទី១- ឈ្មោះថា **សោមនស្សសហគតំ ឌិដ្ឋិគត-សម្បយុត្តំ អសង្ខារិកមេកំ** *ចិត្តលោកដែលប្រកបព្រមដោយសេចក្តីពេញចិត្ត ប្រកបដោយសេចក្តីឃើញខុស ដោយមិនមានការដឹកនាំ ១ ។*

ទី២- ឈ្មោះថា **សោមនស្សសហគតំ ឌិដ្ឋិគត-សម្បយុត្តំ សសង្ខារិកមេកំ** *ចិត្តលោកដែលកើតព្រមដោយសេចក្តីពេញចិត្ត ប្រកបដោយសេចក្តីឃើញខុស ដោយមានការដឹកនាំ ១ ។*

ទី៣- ឈ្មោះថា **សោមនស្សសហគតំ ញិដ្ឋិគត-វិប្បយុត្តំ អសង្ខារិកមេកំ** *ចិត្តលោកដែលកើតព្រមដោយសេចក្តីពេញចិត្ត មិនប្រកបដោយសេចក្តីឃើញខុស ដោយមិនមានការដឹកនាំ ១ ។*

ទី៤- ឈ្មោះថា **សោមនស្សសហគតំ ញិដ្ឋិគត-វិប្បយុត្តំ សសង្ខារិកមេកំ** *ចិត្តលោកដែលកើតព្រមដោយសេចក្តីពេញចិត្ត មិនប្រកបដោយសេចក្តីឃើញខុស ដោយមានការដឹកនាំ ១ ។*

ទី៥- ឈ្មោះថា **ឧបេក្ខាសហគតំ ញិដ្ឋិគតសម្ប-យុត្តំ អសង្ខារិកមេកំ** *ចិត្តលោកដែលកើតព្រមដោយសេចក្តីព្រងើយៗ ប្រកបដោយសេចក្តីឃើញខុស ដោយមិនមានការដឹកនាំ ១ ។*

ទី៦- ឈ្មោះថា **ឧបេក្ខាសហគតំ ញិដ្ឋិគតសម្ប-យុត្តំ សសង្ខារិកមេកំ** *ចិត្តលោកដែលកើតព្រមដោយសេចក្តីព្រងើយៗ ប្រកបដោយសេចក្តីឃើញខុស ដោយមានការដឹកនាំ ១ ។*

ទី៧- ឈ្មោះថា **ឧបេក្ខាសហគតំ ញិដ្ឋិគតវិប្បយុត្តំ អសង្ខារិកមេកំ** *ចិត្តលោកដែលកើតព្រមដោយសេចក្តីព្រងើយៗ មិនប្រកបដោយសេចក្តីឃើញខុស ដោយមិនមានការដឹកនាំ ១ ។*

ទី៨- ឈ្មោះថា **ឧបេក្ខាសហគតំ ញិដ្ឋិគតវិប្បយុត្តំ សសង្ខារិកមេកំ** *ចិត្តលោកដែលកើតព្រមដោយសេចក្តីព្រងើយៗ មិនប្រកបដោយសេចក្តីឃើញខុស ដោយមានការដឹកនាំ ១ ។*

ទោសមូលបិត្ត គឺចិត្តដែលមានសេចក្តីក្រោធជាមូលដ្ឋាន ២ មានឈ្មោះដូចតទៅនេះ

ទី១- ឈ្មោះថា **ឧោមនស្សសហកតំ បដិឃសម្ស-ឃុត្តំ អសង្ខ្ហារិកមេកំ** ចិត្តក្រោធដែលកើតព្រមដោយសេចក្តីតូចចិត្ត ប្រកបដោយសេចក្តីក្រោធ (ថ្នាំងថ្នាក់) ដោយមិនមានការដឹកនាំ ១ ។

ទី២- ឈ្មោះថា **ឧោមនស្សសហកតំ បដិឃសម្ស-ឃុត្តំ សសង្ខ្ហារិកមេកំ** ចិត្តក្រោធដែលកើតព្រមដោយសេចក្តីតូចចិត្ត ប្រកបដោយសេចក្តីក្រោធ (ថ្នាំងថ្នាក់) ដោយមានការដឹកនាំ ១ ។

មោហមូលបិត្ត គឺចិត្តដែលមានសេចក្តីវង្វេង សេចក្តីភាន់ច្រឡំជាមូលដ្ឋាន ២ មានឈ្មោះដូចតទៅនេះ

ទី១- ឈ្មោះថា **ឧបេក្ខាសហកតំ វិចិកិច្ឆាសម្ស-ឃុត្តមេកំ** ចិត្តវង្វេងដែលកើតព្រមដោយសេចក្តីព្រងើយៗ ប្រកបដោយសេចក្តីសង្សយ ១ ។

ទី២- ឈ្មោះថា **ឧបេក្ខាសហកតំ ឧទ្ធចូសម្ស-ឃុត្តមេកំ** ចិត្តវង្វេងដែលកើតព្រមដោយសេចក្តីព្រងើយៗ ប្រកបដោយសេចក្តីអណ្តែតអណ្តូងរាយមាយ ១ ។

អហេតុកចិត្ត ១៨

គឺចិត្តដែលមិនមានសម្បយុត្តហេតុ បានដល់លោភហេតុ ទោស-ហេតុ មោហហេតុ អលោភហេតុ អទោសហេតុ អមោហហេតុ ដែលហៅថាហេតុ ៦ ជាហេតុប្រកប ហេតុ ៦ នេះមិនប្រកបនឹងអហេតុកចិត្តឡើយ តែហេតុដែលឲ្យអហេតុកចិត្តកើតនោះមាននៅ ហៅថា ឧប្បត្តិហេតុ អហេតុកចិត្ត ១៨ ចែកជា ៣ ប្រភេទគឺៈ

១- អកុសលវិបាកចិត្ត ចិត្តដែលជាផលរបស់អកុសលមាន ៧

២- កុសលវិបាកចិត្ត ចិត្តដែលជាផលរបស់កុសលមាន ៨

៣- អហេតុកកិរិយាចិត្ត ចិត្តដែលជាកិរិយា មិនប្រកបដោយហេតុ៦ មាន ៣ ។

អកុសលវិបាកចិត្ត ៧ មានឈ្មោះដូចតទៅនេះ

ទី១- ឈ្មោះថា **ឧបេក្ខាសហគតំ ចក្ខុវិញ្ញាណំ** ចិត្តដែលកើតព្រមដោយសេចក្តីព្រងើយៗ ខណៈភ្នែកឃើញរូបដែលមិនល្អ ជាអកុសលវិបាក ។

ទី២- ឈ្មោះថា **ឧបេក្ខាសហគតំ សោតវិញ្ញាណំ** ចិត្តដែលកើតព្រមដោយសេចក្តីព្រងើយៗ ខណៈត្រចៀកបានឮសំឡេងដែលមិនល្អ ជាអកុសលវិបាក ។

ទី៣- ឈ្មោះថា **ឧបេក្ខាសហគតំ ឃានវិញ្ញាណំ**

ចិត្តដែលកើតព្រមដោយសេចក្តីព្រងើយៗ ខណៈច្រមុះដឹងក្ងិនដែលមិនល្អ ជាអកុសលវិបាក ។

ទី៤- ឈ្មោះថា **ឧបេក្ខាសហគតំ ជិវ្ហវិញ្ញាណំ** ចិត្តដែលកើតព្រមដោយសេចក្តីព្រងើយៗ ខណៈអណ្តាតដឹងរសដែលមិនល្អ ជាអកុសលវិបាក ។

ទី៥- ឈ្មោះថា **ឧក្ខាសហគតំ កាយវិញ្ញាណំ** ចិត្តដែលកើតព្រមដោយទុក្ខវេទនា ខណៈកាយពាល់ត្រូវរបស់ដែលមិនល្អ ជាអកុសលវិបាក ។

ទី៦- ឈ្មោះថា **ឧបេក្ខាសហគតំ សម្បដិច្ឆន្នចិត្តំ** ចិត្តដែលកើតព្រមដោយសេចក្តីព្រងើយៗ ខណៈទទួលអារម្មណ៍ដែលមិនល្អ ជាអកុសលវិបាក ។

ទី៧- ឈ្មោះថា **ឧបេក្ខាសហគតំ សន្តីរណចិត្តំ** ចិត្តដែលកើតព្រមដោយសេចក្តីព្រងើយៗ ខណៈដែលពិចារណាអារម្មណ៍ដែលមិនល្អ ជាអកុសលវិបាក ។

កុសលវិបាកចិត្ត ៨ មានឈ្មោះដូចតទៅនេះ

ទី១- ឈ្មោះថា **ឧបេក្ខាសហគតំ ចក្ខុវិញ្ញាណំ** ចិត្តដែលកើតព្រមដោយសេចក្តីព្រងើយៗ ខណៈដែលភ្នែកឃើញរូបដែលល្អ ជាកុសលវិបាក ។

ទី២- ឈ្មោះថា **ឧបេក្ខាសហគតំ សោតវិញ្ញាណំ** *ចិត្តដែលកើតព្រមដោយសេចក្តីព្រងើយៗ ខណៈដែលត្រចៀកបានឮសំឡេងដែលល្អ ជាកុសលវិបាក ។*

ទី៣- ឈ្មោះថា **ឧបេក្ខាសហគតំ ឃានវិញ្ញាណំ** *ចិត្តដែលកើតព្រមដោយសេចក្តីព្រងើយៗ ខណៈច្រមុះដឹងក្លិនដែលល្អ ជាកុសលវិបាក ។*

ទី៤- ឈ្មោះថា **ឧបេក្ខាសហគតំ ជិវ្ហាវិញ្ញាណំ** *ចិត្តដែលកើតព្រមដោយសេចក្តីព្រងើយៗ ខណៈអណ្តាតដឹងរសដែលល្អ ជាកុសលវិបាក ។*

ទី៥- ឈ្មោះថា **សុខសហគតំ កាយវិញ្ញាណំ** *ចិត្តដែលកើតព្រមដោយសុខវេទនា ខណៈកាយពាល់ត្រូវរបស់ដែលល្អ ជាកុសលវិបាក ។*

ទី៦- ឈ្មោះថា **ឧបេក្ខាសហគតំ សម្បដិច្ឆន្នចិត្តំ** *ចិត្តដែលកើតព្រមដោយសេចក្តីព្រងើយៗ ខណៈទទួលអារម្មណ៍ដែលល្អ ជាកុសលវិបាក ។*

ទី៧- ឈ្មោះថា **សោមនស្សសហគតំ សន្តីរណចិត្តំ** *ចិត្តដែលកើតព្រមដោយសេចក្តីពេញចិត្ត ខណៈពិចារណាអារម្មណ៍ដែលល្អ ជាកុសលវិបាក ។*

ទី៨- ឈ្មោះថា **ឧបេក្ខាសហគតំ សន្តីរណចិត្តំ** *ចិត្តដែលកើតព្រមដោយសេចក្តីព្រងើយៗ ខណៈពិចារណាអារម្មណ៍ដែលល្អ ជាកុសលវិបាក ។*

អហេតុកកិរិយាចិត្ត ៣ មានឈ្មោះដូចតទៅនេះ

ទី១- ឈ្មោះថា **ឧបេក្ខាសហគតំ បញ្ចទ្វារាវជ្ជនចិត្តំ** *ចិត្តដែលកើតព្រមដោយសេចក្តីព្រងើយៗ ខណៈដែលពិចារណាអារម្មណ៍ក្នុងទ្វារទាំង ៥ ។*

ទី២- ឈ្មោះថា **ឧបេក្ខាសហគតំ មនោទ្វារាវជ្ជនចិត្តំ** *ចិត្តដែលកើតព្រមដោយសេចក្តីព្រងើយៗ ខណៈដែលពិចារណាធម្មារម្មណ៍ក្នុងមនោទ្វារ ។*

ទី៣- ឈ្មោះថា **សោមនស្សសហគតំ ហសិតុប្បាទចិត្តំ** *ចិត្តដែលកើតព្រមដោយសេចក្តីពេញចិត្ត ខណៈញញឹមរបស់ព្រះអរហន្ត ។*

កាមាវចរសោភណចិត្ត ២៤

កាមាវចរសោភណចិត្ត *គឺចិត្តដែលល្អប្រព្រឹត្តទៅក្នុងកាមភូមិ ចែកជា ៣ ប្រភេទគឺ៖*

១- **កាមាវចរសោភណកុសលចិត្ត** *ឬហៅថា មហាកុសលចិត្តមាន ៨ ។*

២- **កាមាវចរសោភណវិបាកចិត្ត** *ឬហៅថា មហាវិបាកចិត្ត មាន ៨ ។*

៣- **កាមាវចរសោភណកិរិយាចិត្ត** ឬហៅថា មហាកិរិយាចិត្តមាន ៨ ។

មហាកុសលចិត្ត គឺចិត្តដែលជាសេចក្តីល្អមានចំនួនច្រើន ដែលធំជាងកុសលទាំងឡាយ ធ្វើច្រើនឡើងរឹតតែកពូនច្រើនឡើង មានធម្មជាតិប្រហារអកុសល មានប្រយោជន៍ច្រើនជាងកុសលដទៃៗ ព្រោះព្រះអរិយៈជំពូកណាបានមានហើយក្នុងអតីតកាល នឹងមានក្នុងអនាគតកាល និងប្រាកដនៅក្នុងបច្ចុប្បន្ននេះ រមែងអាស្រ័យមហាកុសលចិត្ត ៨ នេះជាមូលជាជណ្តើរហើយចូលទៅកាន់ព្រះនិព្វាន ដូចនឹងសម្តែងឈ្មោះតទៅនេះ

ទី១- ឈ្មោះថា **សោមនស្សសហគតំ ញាណសម្ស-យុត្តំ អសង្ខ្ខារិកមេកំ** ចិត្តមហាកុសលដែលកើតព្រមដោយសេចក្តីពេញចិត្ត ប្រកបដោយបញ្ញា ដោយមិនមានការដឹកនាំ ១ ។

ទី២- ឈ្មោះថា **សោមនស្សសហគតំ ញាណសម្ស-យុត្តំ សសង្ខ្ខារិកមេកំ** ចិត្តមហាកុសលដែលកើតព្រមដោយសេចក្តីពេញចិត្ត ប្រកបដោយបញ្ញា ដោយមានការដឹកនាំ ១ ។

ទី៣- ឈ្មោះថា **សោមនស្សសហគតំ ញាណវិប្ស-យុត្តំ អសង្ខ្ខារិកមេកំ** ចិត្តមហាកុសលដែលកើតព្រមដោយសេចក្តីពេញចិត្ត មិនប្រកបដោយបញ្ញា ដោយមិនមានការដឹកនាំ ១ ។

ទី៤- ឈ្មោះថា **សោមនស្សសហគតំ ញាណវិប្ស-យុត្តំ សសង្ខ្ខារិកមេកំ** ចិត្តមហាកុសលដែលកើតព្រមដោយ

សេចក្ដីពេញចិត្ត មិនប្រកបដោយបញ្ញា ដោយមានការដឹកនាំ ១ ។

ទី៥- ឈ្មោះថា **ឧបេក្ខាសហគតំ ញាណសម្ប-យុត្តំ អសង្ខារិកមេកំ** *ចិត្តមហាកុសលដែលកើតព្រមដោយសេចក្ដីព្រងើយៗ ប្រកបដោយបញ្ញា ដោយមិនមានការដឹកនាំ ១ ។*

ទី៦- ឈ្មោះថា **ឧបេក្ខាសហគតំ ញាណសម្ប-យុត្តំ សសង្ខារិកមេកំ** *ចិត្តមហាកុសលដែលកើតព្រមដោយសេចក្ដីព្រងើយៗ ប្រកបដោយបញ្ញា ដោយមានការដឹកនាំ ១ ។*

ទី៧- ឈ្មោះថា **ឧបេក្ខាសហគតំ ញាណវិប្ផយុត្តំ អសង្ខារិកមេកំ** *ចិត្តមហាកុសលដែលកើតព្រមដោយសេចក្ដីព្រងើយៗ មិនប្រកបដោយបញ្ញា ដោយមិនមានការដឹកនាំ ១ ។*

ទី៨- ឈ្មោះថា **ឧបេក្ខាសហគតំ ញាណវិប្ផយុត្តំ សសង្ខារិកមេកំ** *ចិត្តមហាកុសលដែលកើតព្រមដោយសេចក្ដីព្រងើយៗ មិនប្រកបដោយបញ្ញា ដោយមានការដឹកនាំ ១ ។*

មហាវិបាកចិត្ត *គឺចិត្តដែលជាផលរបស់មហាកុសល មានផលច្រើនជាង ឬលើសជាងផលរបស់កុសលដទៃៗ មហាកុសលចិត្តយ៉ាងណាមហាវិបាកចិត្តក៏យ៉ាងនោះ ព្រោះដូច្នោះ មហាវិបាកចិត្តទើបមានចំនួនប្រហែលគ្នាដូចគ្នានឹងមហាកុសលចិត្ត ដូចមានឈ្មោះប្រាកដតទៅនេះ*

ទី១- ឈ្មោះថា **សោមនស្ឍសហគតំ ញាណសម្ប-**

យុត្តំ អសង្ខ្ហារិកមេកំ ចិត្តមហាវិបាកដែលកើតព្រមដោយ សេចក្តីពេញចិត្ត ប្រកបដោយបញ្ញា ដោយមិនមានការដឹកនាំ ១ ។

ទី២- ឈ្មោះថា **សោមនស្សសហតតំ ញាណសម្ស-យុត្តំ សសង្ខ្ហារិកមេកំ** ចិត្តមហាវិបាកដែលកើតព្រមដោយ សេចក្តីពេញចិត្ត ប្រកបដោយបញ្ញា ដោយមានការដឹកនាំ ១ ។

ទី៣- ឈ្មោះថា **សោមនស្សសហតតំ ញាណវិប្ស-យុត្តំ អសង្ខ្ហារិកមេកំ** ចិត្តមហាវិបាកដែលកើតព្រមដោយ សេចក្តីពេញចិត្ត មិនប្រកបដោយបញ្ញា ដោយមិនមានការដឹកនាំ ១ ។

ទី៤- ឈ្មោះថា **សោមនស្សសហតតំ ញាណវិប្ស-យុត្តំ សសង្ខ្ហារិកមេកំ** ចិត្តមហាវិបាកដែលកើតព្រមដោយ សេចក្តីពេញចិត្ត មិនប្រកបដោយបញ្ញា ដោយមានការដឹកនាំ ១ ។

ទី៥- ឈ្មោះថា **ឧបេក្ខាសហតតំ ញាណសម្ស-យុត្តំ អសង្ខ្ហារិកមេកំ** ចិត្តមហាវិបាកដែលកើតព្រមដោយ សេចក្តីព្រងើយៗ ប្រកបដោយបញ្ញា ដោយមិនមានការដឹកនាំ ១ ។

ទី៦- ឈ្មោះថា **ឧបេក្ខាសហតតំ ញាណសម្ស-យុត្តំ សសង្ខ្ហារិកមេកំ** ចិត្តមហាវិបាកដែលកើតព្រមដោយ សេចក្តីព្រងើយៗ ប្រកបដោយបញ្ញា ដោយមានការដឹកនាំ ១ ។

ទី៧- ឈ្មោះថា **ឧបេក្ខាសហតតំ ញាណវិប្សយុត្តំ**

អសង្ខ្ហារិកមេកំ ចិត្តមហាវិបាកដែលកើតព្រមដោយសេចក្តី ព្រងើយៗ មិនប្រកបដោយបញ្ញា ដោយមិនមានការដឹកនាំ ១ ។

ទី៨- ឈ្មោះថា **ឧបេក្ខាសហតតំ ញាណវិប្បយុត្តំ សសង្ខ្ហារិកមេកំ** ចិត្តមហាវិបាកដែលកើតព្រមដោយសេចក្តី ព្រងើយៗ មិនប្រកបដោយបញ្ញា ដោយមានការដឹកនាំ ១ ។

មហាកិរិយាចិត្ត គឺចិត្តដែលជាកិរិយាអាការរបស់មហាកុសល ដោយមិនមានមហាវិបាក បានដល់ការធ្វើមហាកុសល របស់ព្រះអរហន្ត ដោយចំពោះ កុសលប្រភេទនេះដែលព្រះអរហន្តធ្វើ តែសេចក្តីវិល រល់ទៅកាន់រដ្ត:ព្រមទាំងបុសគល់បានអស់ទៅហើយ វិបាករមែងមិនមាន ទើបគ្រាន់តែជាកិរិយា ព្រោះដូច្នោះមហាកុសលចិត្ត, មហាវិបាកចិត្ត មហាកិរិយាចិត្ត ទើបមានចំនួន ៨ ប្រហែលគ្នា និងដូចគ្នា ចំពោះមហា-កិរិយា ៨ មានឈ្មោះដូចតទៅនេះ ៖

ទី១- ឈ្មោះថា **សោមនស្សសហតតំ ញាណសម្ប-យុត្តំ អសង្ខ្ហារិកមេកំ** ចិត្តមហាកិរិយាដែលកើតព្រមដោយ សេចក្តីពេញចិត្ត ប្រកបដោយបញ្ញា ដោយមិនមានការដឹកនាំ ១ ។

ទី២- ឈ្មោះថា **សោមនស្សសហតតំ ញាណសម្ប-យុត្តំ សសង្ខ្ហារិកមេកំ** ចិត្តមហាកិរិយាដែលកើតព្រមដោយ សេចក្តីពេញចិត្ត ប្រកបដោយបញ្ញា ដោយមានការដឹកនាំ ១ ។

ទី៣- ឈ្មោះថា **សោមនស្សសហគតំ ញាណវិប្ប-យុត្តំ អសង្ខ្ខារិកមេកំ** ចិត្តមហាកិរិយាដែលកើតព្រមដោយ សេចក្តីពេញចិត្ត មិនប្រកបដោយបញ្ញា ដោយមិនមានការដឹកនាំ ១ ។

ទី៤- ឈ្មោះថា **សោមនស្សសហគតំ ញាណវិប្ប-យុត្តំ សសង្ខ្ខារិកមេកំ** ចិត្តមហាកិរិយាដែលកើតព្រមដោយ សេចក្តីពេញចិត្ត មិនប្រកបដោយបញ្ញា ដោយមានការដឹកនាំ ១ ។

ទី៥- ឈ្មោះថា **ឧបេក្ខាសហគតំ ញាណសម្ប-យុត្តំ អសង្ខ្ខារិកមេកំ** ចិត្តមហាកិរិយាដែលកើតព្រមដោយ សេចក្តីព្រងើយៗ ប្រកបដោយបញ្ញា ដោយមិនមានការដឹកនាំ ១ ។

ទី៦- ឈ្មោះថា **ឧបេក្ខាសហគតំ ញាណសម្ប-យុត្តំ សសង្ខ្ខារិកមេកំ** ចិត្តមហាកិរិយាដែលកើតព្រមដោយ សេចក្តីព្រងើយៗ ប្រកបដោយបញ្ញា ដោយមានការដឹកនាំ ១ ។

ទី៧- ឈ្មោះថា **ឧបេក្ខាសហគតំ ញាណវិប្ប-យុត្តំ អសង្ខ្ខារិកមេកំ** ចិត្តមហាកិរិយាដែលកើតព្រមដោយ សេចក្តីព្រងើយៗ មិនប្រកបដោយបញ្ញា ដោយមិនមានការដឹកនាំ ១ ។

ទី៨- ឈ្មោះថា **ឧបេក្ខាសហគតំ ញាណវិប្ប-យុត្តំ សសង្ខ្ខារិកមេកំ** ចិត្តមហាកិរិយាដែលកើតព្រមដោយ សេចក្តីព្រងើយៗ មិនប្រកបដោយបញ្ញា ដោយមានការដឹកនាំ ១ ។

រូបាវចរចិត្ត ១៥

ចិត្តដែលប្រព្រឹត្តទៅក្នុងរូបភូមិ ហៅថា រូបាវចរចិត្ត ចែកជា ៣ ប្រភេទគឺ ៖

១- រូបាវចរកុសលចិត្ត ៥

២- រូបាវចរវិបាកចិត្ត ៥

៣- រូបាវចរកិរិយាចិត្ត ៥។

រូបាវចរកុសលចិត្ត *គឺកុសលចិត្តដែលប្រព្រឹត្តទៅក្នុងរូបភូមិ សម្គាល់សេចក្តីថា ចិត្តរបស់បុគ្គលដែលបានដល់រូបជ្ឈាននោះឯង មានចំនួន ៥ មានឈ្មោះដូចតទៅនេះ ៖*

ទី១- ឈ្មោះថា **វិតក្ការវិចារបីតិសុខេកក្គតាសហិតំ បឋមជ្ឈានកុសលចិត្តំ** *បឋមជ្ឈានកុសលចិត្ត ដែលកើតព្រមដោយវិតក្ក: វិចារ: បីតិ សុខ ឯកគ្គតា ។*

ទី២- ឈ្មោះថា **វិចារបីតិសុខេកក្គតាសហិតំ ទុតិយជ្ឈានកុសលចិត្តំ** *ទុតិយជ្ឈានកុសលចិត្ត ដែលកើតព្រមដោយវិចារ: បីតិ សុខ ឯកគ្គតា ។*

ទី៣- ឈ្មោះថា **បីតិសុខេកក្គតាសហិតំ តតិយ-ជ្ឈានកុសលចិត្តំ** *តតិយជ្ឈានកុសលចិត្ត ដែលកើតព្រមដោយបីតិ សុខ ឯកគ្គតា ។*

ទី៤- ឈ្មោះថា **សុខេកគ្គតាសហិតំ ចតុត្ថជ្ឌាន-កុសលចិត្តំ** ចតុត្ថជ្ឌានកុសលចិត្ត ដែលកើតព្រមដោយសុខ ឯកគ្គតា ។

ទី៥- ឈ្មោះថា **ឧបេក្ខេកគ្គតាសហិតំ បញ្ចម-ជ្ឌានកុសលចិត្តំ** បញ្ចមជ្ឌានកុសលចិត្ត ដែលកើតព្រមដោយ ឧបេក្ខា ឯកគ្គតា ។

រូបាវចរវិបាកចិត្ត គឺចិត្តដែលជាផលរបស់រូបាវចរកុសល សម្គាល់សេចក្ដីថា ចិត្តដែលជាផលរបស់រូបាវចរកុសល ដែលប្រព្រឹត្តទៅក្នុងរូបភូមិ មានចំនួន ៥ ដូចមានឈ្មោះតទៅនេះ ៖

ទី១- ឈ្មោះថា **វិតក្ការិចារបីតិសុខេកគ្គតាសហិតំ បឋមជ្ឌានវិចាកចិត្តំ** បឋមជ្ឌានវិបាកចិត្ត ដែលកើតព្រមដោយ វិតក្ក: វិចារ: បីតិ សុខ ឯកគ្គតា ។

ទី២- ឈ្មោះថា **វិចារបីតិសុខេកគ្គតាសហិតំ ទុតិយជ្ឌានវិចាកចិត្តំ** ទុតិយជ្ឌានវិបាកចិត្ត ដែលកើតព្រមដោយវិចារ: បីតិ សុខ ឯកគ្គតា ។

ទី៣- ឈ្មោះថា **បីតិសុខេកគ្គតាសហិតំ តតិយ-ជ្ឌានវិចាកចិត្តំ** តតិយជ្ឌានវិបាកចិត្ត ដែលកើតព្រមដោយបីតិ សុខ ឯកគ្គតា ។

ទី៤- ឈ្មោះថា **សុខេកក្គតាសហិតំ ចតុត្ថជ្ឈាន-វិចាកចិត្តំ** ចតុត្ថជ្ឈានវិបាកចិត្ត ដែលកើតព្រមដោយសុខ ឯកគ្គតា ។

ទី៥- ឈ្មោះថា **ឧបេក្ខេកក្គតាសហិតំ បញ្ចម-ជ្ឈានវិចាកចិត្តំ** បញ្ចមជ្ឈានវិបាកចិត្ត ដែលកើតព្រមដោយ ឧបេក្ខា ឯកគ្គតា ។

រូបាវចរកិរិយាចិត្ត គឺចិត្តដែលជាកិរិយា ដែលប្រព្រឹត្តទៅក្នុងរូបភូមិ សម្គាល់សេចក្តីថា ជាកិរិយាអាការរបស់ចិត្តព្រះអរហន្ត ដែលធ្វើរូបាវចរ-កុសលដោយចំពោះដូច្នោះ ចំនួនចិត្តទើបមាន ៥ ប្រហែលគ្នា ដូចគ្នានឹងរូបាវចរកុសល ផ្ទាស់តែពាក្យថាកុសលជាកិរិយាប៉ុណ្ណោះ មានឈ្មោះដូចតទៅនេះ ៖

ទី១- ឈ្មោះថា **វិតក្ការវិចារបីតិសុខេកក្គតាសហិតំ បឋមជ្ឈានកិរិយាចិត្តំ** បឋមជ្ឈានកិរិយាចិត្ត ដែលកើតព្រមដោយ វិតក្ក: វិចារ: បីតិ សុខ ឯកគ្គតា ។

ទី២- ឈ្មោះថា **វិចារបីតិសុខេកក្គតាសហិតំ ទុតិយជ្ឈានកិរិយាចិត្តំ** ទុតិយជ្ឈានកិរិយាចិត្ត ដែលកើតព្រមដោយវិចារ: បីតិ សុខ ឯកគ្គតា ។

ទី៣- ឈ្មោះថា **បីតិសុខេកក្គតាសហិតំ តតិយ-ជ្ឈានកិរិយាចិត្តំ** តតិយជ្ឈានកិរិយាចិត្ត ដែលកើតព្រមដោយបីតិ

សុខ ឯកគ្គតា ។

ទី៤- ឈ្មោះថា **សុខេកគ្គតាសហិតំ ចតុត្ថជ្ឌានកិរិយាចិត្តំ** *ចតុត្ថជ្ឌានកិរិយាចិត្ត ដែលកើតព្រមដោយសុខ ឯកគ្គតា ។*

ទី៥- ឈ្មោះថា **ឧបេក្ខេកគ្គតាសហិតំ បញ្ចមជ្ឌាន-កិរិយាចិត្តំ** *បញ្ចមជ្ឌានកិរិយាចិត្ត ដែលកើតព្រមដោយឧបេក្ខា ឯកគ្គតា ។*

អរូបាវចរចិត្ត ១២

ចិត្តដែលប្រព្រឹត្តទៅក្នុងអរូបភូមិ ហៅថា ***អរូបាវចរចិត្ត*** *ចែកជា ៣ ប្រភេទគឺ ៖*

១- **អរូបាវចរកុសលចិត្ត ៤**

២- **អរូបាវចរវិបាកចិត្ត ៤**

៣- **អរូបាវចរកិរិយាចិត្ត ៤។**

អរូបាវចរកុសលចិត្ត *សម្គាល់សេចក្ដីថា កុសលចិត្តដែលប្រព្រឹត្ត ទៅក្នុងអរូបភូមិ គឺចិត្តរបស់បុគ្គលដែលបានអរូបជ្ឌានទោះឯង មានចំនួន ៤ មានឈ្មោះដូចតទៅនេះ ៖*

ទី១- ឈ្មោះថា **អាកាសានញ្ចាយតនកុសលចិត្តំ** *អាកាសានញ្ចាយតនកុសលចិត្ត ។*

ទី២- ឈ្មោះថា **វិញ្ញាណញ្ចាយតនកុសលចិត្តំ**

វិញ្ញាណញ្ចាយតនកុសលចិត្ត ។

ទី៣- ឈ្មោះថា **អាកិញ្ចញ្ញាយតនកុសលចិត្តំ** *អាកិញ្ចញ្ញាយតនកុសលចិត្ត ។*

ទី៤- ឈ្មោះថា **នេវសញ្ញានាសញ្ញាយតនកុសលចិត្តំ** *នេវសញ្ញានាសញ្ញាយតនកុសលចិត្ត ។*

អរូបាវចរវិបាកចិត្ត *គឺចិត្តដែលជាផលរបស់អរូបាវចរកុសល ដែលប្រព្រឹត្តទៅក្នុងអរូបភូមិ មានចំនួន ៤ មានឈ្មោះដូចតទៅនេះ ៖*

ទី១- ឈ្មោះថា **អាកាសានញ្ចាយតនវិចាកចិត្តំ** *អាកាសានញ្ចាយតនវិបាកចិត្ត ។*

ទី២- ឈ្មោះថា **វិញ្ញាណាញ្ចាយតនវិចាកចិត្តំ** *វិញ្ញាណញ្ចាយតនវិបាកចិត្ត ។*

ទី៣- ឈ្មោះថា **អាកិញ្ចញ្ញាយតនវិចាកចិត្តំ** *អាកិញ្ចញ្ញាយតនវិបាកចិត្ត ។*

ទី៤- ឈ្មោះថា **នេវសញ្ញានាសញ្ញាយតនវិចាកចិត្តំ** *នេវសញ្ញានាសញ្ញាយតនវិបាកចិត្ត ។*

អរូបាវចរកិរិយាចិត្ត *គឺកិរិយាចិត្ត ដែលប្រព្រឹត្តទៅក្នុងអរូបភូមិ សម្គាល់សេចក្ដីថា ជាកិរិយាអាការរបស់ចិត្តព្រះអរហន្ត ដែលធ្វើអរូបាវ-ចរកុសលដោយចំពោះ ព្រោះដូច្នោះ ចំនួនទើបប្រហែលគ្នា ដូចគ្នានឹង*

អរូបាវចរកុសល ផ្ទាស់តែពាក្យថាកុសលជាកិរិយាប៉ុណ្ណោះ មានចំនួន ៤ មានឈ្មោះដូចតទៅនេះ ៖

ទី១- ឈ្មោះថា **អាកាសានញ្ចាយតនកិរិយាចិត្ត** *អាកាសានញ្ចាយតនកិរិយាចិត្ត ។*

ទី២- ឈ្មោះថា **វិញ្ញាណញ្ចាយតនកិរិយាចិត្ត** *វិញ្ញាណញ្ចាយតនកិរិយាចិត្ត ។*

ទី៣- ឈ្មោះថា **អាកិញ្ចញ្ញាយតនកិរិយាចិត្ត** *អាកិញ្ចញ្ញាយតនកិរិយាចិត្ត ។*

ទី៤- ឈ្មោះថា **នេវសញ្ញានាសញ្ញាយតនកិរិយាចិត្ត** *នេវសញ្ញានាសញ្ញាយតនកិរិយាចិត្ត ។*

រូបាវចរចិត្ត ១៥ និង អរូបាវចរចិត្ត ១២ រួមជា ២៧ ហៅថា **មហគ្គតចិត្ត** *គឺចិត្តដែលដល់សភាពនៃការធ្វើដ៏ប្រសើរ ឬដ៏លើស សម្គាល់សេចក្ដីថា ជាចិត្តដែលបានដល់ឈានហើយមហគ្គតចិត្ត ២៧ នេះ រួមនឹងកាមាវចរចិត្ត ៥៤ ហៅថា* **លោកិយចិត្ត ៨១** *គឺចិត្តដែលប្រព្រឹត្តទៅក្នុងលោកទាំង ៣ បានដល់កាមលោក រូបលោក អរូបលោក ។*

លោកុត្តរចិត្ត ៨ ឬ ៤០

លោកុត្តរចិត្ត *ប្រែថា ចិត្តដែលផុតចាកលោកទាំង ៣ ចែកជា ២ ប្រភេទគឺ ៖*

១- លោកុត្តរកុសលចិត្តមាន ៤

២- លោកុត្តរវិបាកចិត្តមាន ៤ ។

លោកុត្តរកុសលចិត្ត *ប្រែថា កុសលចិត្តដែលមានផលឲ្យបានផុតចាកលោកទាំង ៣ ឬហៅថា* **"មគ្គចិត្ត"** *សម្គាល់សេចក្តីថា កុសលចិត្តដែលជាផ្លូវឲ្យផុតចាកលោកទាំង ៣ គឺចិត្តដែលកាត់រដ្ត:នោះឯង មាន ៤ សម្តែងឈ្មោះដូចតទៅនេះ ៖*

ទី១- ឈ្មោះថា **សោតាបត្តិមក្គចិត្តំ** *សោតាបត្តិមគ្គចិត្ត ។*

ទី២- ឈ្មោះថា **សកទាគាមិមក្គចិត្តំ** *សកទាគាមិមគ្គចិត្ត ។*

ទី៣- ឈ្មោះថា **អនាគាមិមក្គចិត្តំ** *អនាគាមិមគ្គចិត្ត ។*

ទី៤- ឈ្មោះថា **អរហត្តមក្គចិត្តំ** *អរហត្តមគ្គចិត្ត ។*

លោកុត្តរវិបាកចិត្ត *ប្រែថា វិបាកចិត្តដែលជាផលរបស់លោកុត្តរ-កុសលចិត្ត ហៅថា "ផលចិត្ត" ក៏បាន ផលចិត្តនេះមិនដូចនឹងផល-ចិត្តដទៃៗ ព្រោះជាអកាលិកធម៌ ដែលបានទទួលផលរហ័សបំផុត មិនរង់ចាំកាលវេលាណាៗ កាលមគ្គចិត្តកើតឡើងហើយរលត់ចុះ ផលចិត្តក៏កើតភ្លាម ផលចិត្តមានចំនួនប្រហែលនឹងមគ្គចិត្ត គឺមាន ៤ មានឈ្មោះដូចតទៅនេះ ៖*

ទី១- ឈ្មោះថា **សោតាបត្តិផលចិត្តំ** *សោតាបត្តិផលចិត្ត ។*

ទី២- ឈ្មោះថា **សកទាគាមិផលចិត្តំ** *សកទាគាមិផលចិត្ត ។*

ទី៣- ឈ្មោះថា **អនាគាមិផលចិត្តំ** អនាគាមិផលចិត្ត ។

ទី៤- ឈ្មោះថា **អរហត្តផលចិត្តំ** អរហត្តផលចិត្ត ។

សោតាបត្តិមគ្គចិត្ត និង **សោតាបត្តិផលចិត្ត** ជាចិត្តដែលបានដល់ហើយ នូវក្រសៃដែលជាផ្លូវទៅកាន់ព្រះនិញ្ជានធាតុ បានដល់ចិត្តរបស់ព្រះអរិយបុគ្គលទីដំបូង នឹងបដិសន្ធិទៀតយ៉ាងច្រើនក៏ត្រឹម ៧ ជាតិប៉ុណ្ណោះ ។

សកទាគាមិមគ្គចិត្ត និង **សកទាគាមិផលចិត្ត** ជាចិត្តដែលធ្វើឲ្យបុគ្គលត្រឡប់មកទៀតម្តង បានដល់ចិត្តរបស់ព្រះអរិយបុគ្គលទី ២ ដែលមានបដិសន្ធិ យ៉ាងច្រើនត្រឹមម្តងប៉ុណ្ណោះ ។

អនាគាមិមគ្គចិត្ត និង **អនាគាមិផលចិត្ត** ជាចិត្តដែលធ្វើឲ្យបុគ្គល មិនត្រឡប់មកកាន់កាមលោកទៀត បានដល់ចិត្តរបស់ព្រះអរិយបុគ្គលទី ៣ ដែលមិនត្រូវត្រឡប់មកបដិសន្ធិក្នុងកាមលោកទៀតសូម្បីតែម្តង ។

អរហត្តមគ្គចិត្ត និង **អរហត្តផលចិត្ត** គឺចិត្តដែលធ្វើឲ្យបុគ្គលបានទទួលការបូជាវិសេស បានដល់ចិត្តរបស់ព្រះអរិយបុគ្គលទី ៤ ដែលបានទទួលការបូជារបស់ទេវតា និងមនុស្សទាំងឡាយ ។

លោកុត្តរចិត្ត រាប់ដោយសង្ខ្យមាន ៨ ដូចសម្តែងមកហើយ បើរាប់ដោយពិស្តារមាន ៤០ គឺចែករាប់ដូច្នេះ **សោតាបត្តិមគ្គចិត្ត** មាន

ឈាន ៥ យ៉ាងណា **សកទាគាមិមគ្គចិត្ត អនាគាមិមគ្គចិត្ត អរហត្ត-មគ្គចិត្ត** តែម្យ៉ាងៗ ក៏មានឈាន ៥ យ៉ាងនោះដូចគ្នា ទើបរាប់ មគ្គចិត្តជា ២០ មគ្គចិត្តមានយ៉ាងណា ផលចិត្តក៏មានយ៉ាងនោះដូចគ្នា ទើបចែកជា ២ ប្រភេទគឺ៖

១- **លោកុត្តរកុសលចិត្ត** ឬហៅថា **មគ្គចិត្ត** ដែលប្រកបដោយ ឈាន ៥ មាន ២០ ។

២- **លោកុត្តរវិបាកចិត្ត** ឬហៅថា **ផលចិត្ត** ដែលប្រកបដោយ ឈាន ៥ មាន ២០ ។

មគ្គចិត្ត ២០ មានឈ្មោះដូចតទៅនេះ

ទី១- ឈ្មោះថា **វិតក្ការិចារបីតិសុខេកគ្គតាសហិតំ បឋមជ្ឌានសោតាបត្តិមគ្គចិត្តំ** បឋមជ្ឌានសោតាបត្តិមគ្គចិត្ត ដែលកើតព្រមដោយវិតក្ក: វិចារ: បីតិ សុខ ឯកគ្គតា ។

ទី២- ឈ្មោះថា **វិចារបីតិសុខេកគ្គតាសហិតំ ទុតិយជ្ឌានសោតាបត្តិមគ្គចិត្តំ** ទុតិយជ្ឌានសោតាបត្តិមគ្គចិត្ត ដែលកើតព្រមដោយវិចារ: បីតិ សុខ ឯកគ្គតា ។

ទី៣- ឈ្មោះថា **បីតិសុខេកគ្គតាសហិតំ តតិយ-ជ្ឌានសោតាបត្តិមគ្គចិត្តំ** តតិយជ្ឌានសោតាបត្តិមគ្គចិត្ត ដែលកើតព្រមដោយ បីតិ សុខ ឯកគ្គតា ។

ទី៤- ឈ្មោះថា **សុខេកគ្គតាសហិតំ ចតុត្ថជ្ឌាន-សោតាបត្តិមគ្គចិត្តំ** *ចតុត្ថជ្ឌានសោតាបត្តិមគ្គចិត្ត ដែលកើតព្រមដោយសុខ ឯកគ្គតា ។*

ទី៥- ឈ្មោះថា **ឧបេក្ខេកគ្គតាសហិតំ បញ្ចម-ជ្ឌានសោតាបត្តិមគ្គចិត្តំ** *បញ្ចមជ្ឌានសោតាបត្តិមគ្គចិត្ត ដែលកើតព្រមដោយឧបេក្ខា ឯកគ្គតា ។*

ទី៦- ឈ្មោះថា **វិតក្ការិចារបីតិសុខេកគ្គតាសហិតំ បឋមជ្ឌានសកទាគាមិមគ្គចិត្តំ** *បឋមជ្ឌានសកទាគាមិមគ្គចិត្ត ដែលកើតព្រមដោយវិតក្ក: វិចារ: បីតិ សុខ ឯកគ្គតា ។*

ទី៧- ឈ្មោះថា **វិចារបីតិសុខេកគ្គតាសហិតំ ទុតិយជ្ឌានសកទាគាមិមគ្គចិត្តំ** *ទុតិយជ្ឌានសកទាគាមិមគ្គចិត្ត ដែលកើតព្រមដោយ វិចារ: បីតិ សុខ ឯកគ្គតា ។*

ទី៨- ឈ្មោះថា **បីតិសុខេកគ្គតាសហិតំ តតិយ-ជ្ឌានសកទាគាមិមគ្គចិត្តំ** *តតិយជ្ឌានសកទាគាមិមគ្គចិត្ត ដែលកើតព្រមដោយ បីតិ សុខ ឯកគ្គតា ។*

ទី៩- ឈ្មោះថា **សុខេកគ្គតាសហិតំ ចតុត្ថជ្ឌាន-សកទាគាមិមគ្គចិត្តំ** *ចតុត្ថជ្ឌានសកទាគាមិមគ្គចិត្ត ដែលកើតព្រមដោយសុខ ឯកគ្គតា ។*

ទី១០- ឈ្មោះថា **ឧបេក្ខេកគ្គតាសហិតំ បញ្ចម-ជ្ឌានសកជាតាមិមគ្គចិត្តំ** *បញ្ចមជ្ឌានសកទាគាមិមគ្គចិត្ត ដែលកើតព្រមដោយឧបេក្ខា ឯកគ្គតា ។*

ទី១១- ឈ្មោះថា **វិតក្ការិចារបីតិសុខេកគ្គតាសហិតំ បឋមជ្ឌានអជាតាមិមគ្គចិត្តំ** *បឋមជ្ឌានអនាគាមិមគ្គចិត្ត ដែលកើតព្រមដោយវិតក្ក: វិចារ: បីតិ សុខ ឯកគ្គតា ។*

ទី១២- ឈ្មោះថា **វិចារបីតិសុខេកគ្គតាសហិតំ ទុតិយជ្ឌានអជាតាមិមគ្គចិត្តំ** *ទុតិយជ្ឌានអនាគាមិមគ្គចិត្ត ដែលកើតព្រមដោយវិចារ: បីតិ សុខ ឯកគ្គតា ។*

ទី១៣- ឈ្មោះថា **បីតិសុខេកគ្គតាសហិតំ តតិយ-ជ្ឌានអជាតាមិមគ្គចិត្តំ** *តតិយជ្ឌានអនាគាមិមគ្គចិត្ត ដែលកើតព្រមដោយបីតិ សុខ ឯកគ្គតា ។*

ទី១៤- ឈ្មោះថា **សុខេកគ្គតាសហិតំ ចតុត្ថជ្ឌាន-អជាតាមិមគ្គចិត្តំ** *ចតុត្ថជ្ឌានអនាគាមិមគ្គចិត្ត ដែលកើតព្រមដោយសុខ ឯកគ្គតា ។*

ទី១៥- ឈ្មោះថា **ឧបេក្ខេកគ្គតាសហិតំ បញ្ចម-ជ្ឌានអជាតាមិមគ្គចិត្តំ** *បញ្ចមជ្ឌានអនាគាមិមគ្គចិត្ត ដែលកើតព្រមដោយឧបេក្ខា ឯកគ្គតា ។*

ទី១៦- *ឈ្មោះថា* **វិតក្កវិចារបីតិសុខេកគ្គតាសហិតំ បឋមជ្ឈានអរហត្តមគ្គចិត្តំ** *បឋមជ្ឈានអរហត្តមគ្គចិត្ត ដែលកើតព្រមដោយវិតក្កៈ វិចារៈ បីតិ សុខ ឯកគ្គតា ។*

ទី១៧- *ឈ្មោះថា* **វិចារបីតិសុខេកគ្គតាសហិតំ ទុតិយជ្ឈានអរហត្តមគ្គចិត្តំ** *ទុតិយជ្ឈានអរហត្តមគ្គចិត្ត ដែលកើតព្រមដោយវិចារៈ បីតិ សុខ ឯកគ្គតា ។*

ទី១៨- *ឈ្មោះថា* **បីតិសុខេកគ្គតាសហិតំ តតិយជ្ឈានអរហត្តមគ្គចិត្តំ** *តតិយជ្ឈានអរហត្តមគ្គចិត្ត ដែលកើតព្រមដោយបីតិ សុខ ឯកគ្គតា ។*

ទី១៩- *ឈ្មោះថា* **សុខេកគ្គតាសហិតំ ចតុត្ថជ្ឈានអរហត្តមគ្គចិត្តំ** *ចតុត្ថជ្ឈានអរហត្តមគ្គចិត្ត ដែលកើតព្រមដោយសុខ ឯកគ្គតា ។*

ទី២០- *ឈ្មោះថា* **ឧបេក្ខេកគ្គតាសហិតំ បញ្ចមជ្ឈានអរហត្តមគ្គចិត្តំ** *បញ្ចមជ្ឈានអរហត្តមគ្គចិត្ត ដែលកើតព្រមដោយឧបេក្ខា ឯកគ្គតា ។*

ផលចិត្ត ២០ មានឈ្មោះដូចតទៅនេះ

ទី១- *ឈ្មោះថា* **វិតក្កវិចារបីតិសុខេកគ្គតាសហិតំ បឋមជ្ឈានសោតាបត្តិផលចិត្តំ** *បឋមជ្ឈានសោតាបត្តិផលចិត្ត*

ដែលកើតព្រមដោយវិតក្ក: វិចារ: បីតិ សុខ ឯកគ្គតា ។

ទី២- ឈ្មោះថា **វិចារបីតិសុខេកគ្គតាសហិតំ ឧតិយជ្ឈានសោតាបត្តិផលចិត្តំ** *ទុតិយជ្ឈានសោតាបត្តិផលចិត្ត ដែលកើតព្រមដោយវិចារ: បីតិ សុខ ឯកគ្គតា ។*

ទី៣- ឈ្មោះថា **បីតិសុខេកគ្គតាសហិតំ តតិយ-ជ្ឈានសោតាបត្តិផលចិត្តំ** *តតិយជ្ឈានសោតាបត្តិផលចិត្ត ដែលកើតព្រមដោយបីតិ សុខ ឯកគ្គតា ។*

ទី៤- ឈ្មោះថា **សុខេកគ្គតាសហិតំ ចតុត្ថជ្ឈាន-សោតាបត្តិផលចិត្តំ** *ចតុត្ថជ្ឈានសោតាបត្តិផលចិត្ត ដែលកើតព្រមដោយសុខ ឯកគ្គតា ។*

ទី៥- ឈ្មោះថា **ឧបេក្ខេកគ្គតាសហិតំ បញ្ចម-ជ្ឈានសោតាបត្តិផលចិត្តំ** *បញ្ចមជ្ឈានសោតាបត្តិផលចិត្ត ដែលកើតព្រមដោយឧបេក្ខា ឯកគ្គតា ។*

ទី៦- ឈ្មោះថា **វិតក្ការិចារបីតិសុខេកគ្គតាសហិតំ បឋមជ្ឈានសកទាគាមិផលចិត្តំ** *បឋមជ្ឈានសកទាគាមិផលចិត្ត ដែលកើតព្រមដោយវិតក្ក: វិចារ: បីតិ សុខ ឯកគ្គតា ។*

ទី៧- ឈ្មោះថា **វិចារបីតិសុខេកគ្គតាសហិតំ ឧតិយជ្ឈានសកទាគាមិផលចិត្តំ** *ទុតិយជ្ឈានសកទាគាមិផលចិត្ត*

ដែលកើតព្រមដោយវិចារ: បីតិ សុខ ឯកគ្គតា ។

ទី៨- ឈ្មោះថា **បីតិសុខេកកគ្គតាសហិតំ តតិយ-ជ្ឈានសកទាគាមិផលចិត្តំ** តតិយជ្ឈានសកទាគាមិផលចិត្ត ដែលកើតព្រមដោយបីតិ សុខ ឯកគ្គតា ។

ទី៩- ឈ្មោះថា **សុខេកកគ្គតាសហិតំ ចតុត្ថជ្ឈាន-សកទាគាមិផលចិត្តំ** ចតុត្ថជ្ឈានសកទាគាមិផលចិត្ត ដែលកើតព្រមដោយសុខ ឯកគ្គតា ។

ទី១០- ឈ្មោះថា **ឧបេក្ខេកកគ្គតាសហិតំ បញ្ចម-ជ្ឈានសកទាគាមិផលចិត្តំ** បញ្ចមជ្ឈានសកទាគាមិផលចិត្ត ដែលកើតព្រមដោយឧបេក្ខា ឯកគ្គតា ។

ទី១១- ឈ្មោះថា **វិតក្កវិចារបីតិសុខេកកគ្គតាសហិតំ បឋមជ្ឈានអនាគាមិផលចិត្តំ** បឋមជ្ឈានអនាគាមិផលចិត្ត ដែលកើតព្រមដោយវិតក្ក: វិចារ: បីតិ សុខ ឯកគ្គតា ។

ទី១២- ឈ្មោះថា **វិចារបីតិសុខេកកគ្គតាសហិតំ ទុតិយជ្ឈានអនាគាមិផលចិត្តំ** ទុតិយជ្ឈានអនាគាមិផលចិត្ត ដែលកើតព្រមដោយវិចារ: បីតិ សុខ ឯកគ្គតា ។

ទី១៣- ឈ្មោះថា **បីតិសុខេកកគ្គតាសហិតំ តតិយ-ជ្ឈានអនាគាមិផលចិត្តំ** តតិយជ្ឈានអនាគាមិផលចិត្ត ដែលកើត

ព្រមដោយបីតិ សុខ ឯកគ្គតា ។

ទី១៤- ឈ្មោះថា **សុខេកគ្គតាសហិតំ ចតុត្ថជ្ឌាន-អនាគាមិផលចិត្តំ** *ចតុត្ថជ្ឌានអនាគាមិផលចិត្ត ដែលកើតព្រមដោយសុខ ឯកគ្គតា ។*

ទី១៥- ឈ្មោះថា **ឧបេក្ខេកគ្គតាសហិតំ បញ្ចម-ជ្ឌានអនាគាមិផលចិត្តំ** *បញ្ចមជ្ឌានអនាគាមិផលចិត្ត ដែលកើតព្រមដោយឧបេក្ខា ឯកគ្គតា ។*

ទី១៦- ឈ្មោះថា **វិតក្ការិចារបីតិសុខេកគ្គតាសហិតំ បឋមជ្ឌានអរហត្តផលចិត្តំ** *បឋមជ្ឌានអរហត្តផលចិត្ត ដែលកើតព្រមដោយវិតក្ក: វិចារ: បីតិ សុខ ឯកគ្គតា ។*

ទី១៧- ឈ្មោះថា **វិចារបីតិសុខេកគ្គតាសហិតំ ទុតិយជ្ឌានអរហត្តផលចិត្តំ** *ទុតិយជ្ឌានអរហត្តផលចិត្ត ដែលកើតព្រមដោយវិចារ: បីតិ សុខ ឯកគ្គតា ។*

ទី១៨- ឈ្មោះថា **បីតិសុខេកគ្គតាសហិតំ តតិយ-ជ្ឌានអរហត្តផលចិត្តំ** *តតិយជ្ឌានអរហត្តផលចិត្ត ដែលកើតព្រមដោយបីតិ សុខ ឯកគ្គតា ។*

ទី១៩- ឈ្មោះថា **សុខេកគ្គតាសហិតំ ចតុត្ថជ្ឌាន-អរហត្តផលចិត្តំ** *ចតុត្ថជ្ឌានអរហត្តផលចិត្ត ដែលកើតព្រមដោយ*

សុខ ឯកគ្គតា ។

ទី២០- ឈ្មោះថា **ឧបេក្ខេកគ្គតាសហិតំ បញ្ចម-ជ្ឈានអរហត្តផលចិត្តំ** បញ្ចមជ្ឈានអរហត្តផលចិត្ត ដែលកើតព្រមដោយ ឧបេក្ខា ឯកគ្គតា ។

ព្រោះដូច្នោះ លោកុត្តរចិត្ត ៦០ រួមនឹងលោកិយចិត្ត ៨១ ទើបជា ១២១ ដោយពិស្តារ ដូចសម្តែងឈ្មោះមកហើយ ។

ចេតសិក ៥២

ចេតសិកប្រកបចិត្តទាំងអស់បែកជា ៣ គឺ៖

១- អញ្ញសមានាចេតសិក ១៣

២- អកុសលចេតសិក ១៤

៣- សោភណចេតសិក ២៥។

អញ្ញសមានាចេតសិក គឺចេតសិកប្រកបនឹងចិត្តដទៃៗ បានទាំងដែលជាសោភណចិត្ត និងអសោភណចិត្ត ចែកជាពីរប្រភេទគឺ៖

១- **សព្វចិត្តសាធារណចេតសិក** មាន ៧ ជាចេតសិកដែលសាធារណៈដល់ចិត្តទាំងអស់ សម្គាល់សេចក្តីថា ចិត្តទាំងអស់គឺ ៨៩ ឬ ១២១ នេះ កាលចិត្តណាមួយកើតឡើង ចេតសិកទាំង ៧ រមែងកើតប្រកបព្រមជាមួយគ្នាទាំង ៧ នេះជានិច្ច ដូចសម្តែងឈ្មោះតទៅនេះ ៖

ទី១- ឈ្មោះថា ផស្សៈ គឺចេតសិកដែលខ្ជប់ប្ជប៉ះអារម្មណ៍ ។

ទី២- ឈ្មោះថា វេទនា គឺចេតសិកដែលសោយអារម្មណ៍ ។

ទី៣- ឈ្មោះថា សញ្ញា គឺចេតសិកដែលចាំអារម្មណ៍ ។

ទី៤- ឈ្មោះថា ចេតនា គឺចេតសិកដែលតាំងចិត្ត ។

ទី៥- ឈ្មោះថា ឯកគ្គតា គឺចេតសិកដែលតាំងមាំក្នុងអារម្មណ៍ ។

ទី៦- ឈ្មោះថា ជីវិតិន្ទ្រិយ គឺចេតសិកដែលរក្សាឲ្យមានជីវិតនៅបាន ។

ទី៧- ឈ្មោះថា មនសិការៈ គឺចេតសិកដែលយកចិត្តទុកដាក់ក្នុងអារម្មណ៍ ។

២- បកិណ្ណកចេតសិក មាន ៦ គឺចេតសិកដែលប្រកបនឹងចិត្ត ចំណែកខ្លះ ជួនកាលក៏ព្រមទាំង ៦ ជួនកាលក៏មិនព្រមទាំង ៦ សម្តែងឈ្មោះតទៅនេះ ៖

ទី១- ឈ្មោះថា វិតក្កៈ គឺចេតសិកដែលត្រិះរិះនឹកក្នុងអារម្មណ៍ជានិច្ច ។

ទី២- ឈ្មោះថា វិចារៈ គឺចេតសិកដែលពិចារណាអារម្មណ៍ជានិច្ច ។

ទី៣- ឈ្មោះថា អធិមោក្ខ គឺចេតសិកដែលវិនិច្ឆ័យអារម្មណ៍ជាច់ខាត ។

ទី៤- ឈ្មោះថា វីរិយៈ គឺចេតសិកដែលព្យាយាម ។

ទី៥- ឈ្មោះថា បីតិ គឺចេតសិកដែលឆ្អែតចិត្តក្នុងអារម្មណ៍ ។

ទី៦- ឈ្មោះថា ឆន្ទៈ គឺចេតសិកដែលពេញចិត្តក្នុងអារម្មណ៍ ។

អកុសលចេតសិក មាន ១៤ ជាចេតសិកដែលប្រកបតែត្រឹមអកុសល-ចិត្ត ១២ ប៉ុណ្ណោះ មិនប្រកបនឹងចិត្តដទៃ មានឈ្មោះដូចតទៅនេះ៖

ទី១- ឈ្មោះថា **មោហៈ** គឺចេតសិកដែលភ្លេចភ្លាំងអារម្មណ៍ ។

ទី២- ឈ្មោះថា **អហិរិកៈ** គឺចេតសិកដែលមិនចេះខ្មាសចំពោះបាប ។

ទី៣- ឈ្មោះថា **អនោត្តប្បៈ** គឺចេតសិកដែលមិនខ្លាចចំពោះបាប ។

ទី៤- ឈ្មោះថា **ឧទ្ធច្ចៈ** គឺចេតសិកដែលគិតរាយមាយ ។

ទី៥- ឈ្មោះថា **លោភៈ** គឺចេតសិកដែលចង់បាន ។

ទី៦- ឈ្មោះថា **ទិដ្ឋិ** គឺចេតសិកដែលឃើញខុស ។

ទី៧- ឈ្មោះថា **មានៈ** គឺចេតសិកដែលប្រកាន់ខ្លួន ។

ទី៨- ឈ្មោះថា **ទោសៈ** គឺចេតសិកដែលក្រោធប្រទូសร้าយ ។

ទី៩- ឈ្មោះថា **ឥស្សា** គឺចេតសិកដែលឥច្ឆាឫស្យា (មិនចង់ឲ្យអ្នកដទៃល្អជាងខ្លួន) ។

ទី១០- ឈ្មោះថា **មច្ឆរិយៈ** គឺចេតសិកដែលកំណាញ់ ។

ទី១១- ឈ្មោះថា **កុក្កុច្ចៈ** គឺចេតសិកដែលរំខានចិត្ត (ខូចចិត្ត) ។

ទី១២- ឈ្មោះថា **ថីនៈ** គឺចេតសិកដែលងោកងក់ ។

ទី១៣- ឈ្មោះថា **មិទ្ធៈ** គឺចេតសិកដែលងងុយដេក (ចាប់អារម្មណ៍មិនបាន) ។

ទី១៤- ឈ្មោះថា **វិចិកិច្ឆា** គឺចេតសិកដែលសង្ស័យក្នុងអារម្មណ៍ ។

សោភណចេតសិក ២៥ គឺចេតសិកដែលប្រកបតែនឹងសោភណចិត្ត ទាំងអស់ ដែលជាធម៌ដ៏ល្អ ចែកជា៤ប្រភេទគឺ៖

(១)- **សោភណសាធារណចេតសិក** ១៩ ជាចេតសិកដែលប្រកបនឹងសោភណចិត្តប៉ុណ្ណោះ មានឈ្មោះដូចតទៅនេះ៖

ទី១- ឈ្មោះថា **សទ្ធា** គឺចេតសិកដែលជឿជ្រះថ្លា ។

ទី២- ឈ្មោះថា **សតិ** គឺចេតសិកដែលរឭកបាន (ដឹងទាន់) ។

ទី៣- ឈ្មោះថា **ហិរិ** គឺចេតសិកដែលខ្មាសចំពោះបាប ។

ទី៤- ឈ្មោះថា **ឱត្តប្ប:** គឺចេតសិកដែលក្រែងខ្លាចចំពោះបាប ។

ទី៥- ឈ្មោះថា **អលោភ:** គឺចេតសិកដែលមិនមានលោភ ។

ទី៦- ឈ្មោះថា **អទោស:** គឺចេតសិកដែលមិនមានក្រោធ ។

ទី៧- ឈ្មោះថា **តត្រមជ្ឈត្តា** គឺចេតសិកដែលជាកណ្ដាលៗ ។

ទី៨- ឈ្មោះថា **កាយបស្សទ្ធិ** គឺចេតសិកដែលធ្វើឲ្យចេតសិកស្ងប់ ។

ទី៩- ឈ្មោះថា **បិត្តបស្សទ្ធិ** គឺចេតសិកដែលធ្វើឲ្យចិត្តស្ងប់ ។

ទី១០- ឈ្មោះថា **កាយលហុតា** គឺចេតសិកដែលធ្វើឲ្យចេតសិកស្រាល ។

ទី១១- ឈ្មោះថា **បិត្តលហុតា** គឺចេតសិកដែលធ្វើឲ្យចិត្តស្រាល ។

ទី១២- ឈ្មោះថា **កាយមុទុតា** គឺចេតសិកដែលធ្វើឲ្យចេតសិកទន់ ។

ទី១៣- ឈ្មោះថា **បិត្តមុទុតា** គឺចេតសិកដែលធ្វើឲ្យចិត្តទន់ ។

ទី១៤- ឈ្មោះថា **កាយកម្មញ្ញតា** គឺចេតសិកដែលធ្វើឲ្យចេតសិកគួរដល់ការងារ ។

ទី១៥- ឈ្មោះថា **បិត្តកម្មញ្ញតា** គឺចេតសិកដែលធ្វើឲ្យចិត្តគួរដល់ការងារ ។

ទី១៦- ឈ្មោះថា **កាយបាគុញ្ញតា** គឺចេតសិកដែលធ្វើឲ្យចេតសិកស្អាត់ជំនាញ ។

ទី១៧- ឈ្មោះថា **បិត្តបាគុញ្ញតា** គឺចេតសិកដែលធ្វើឲ្យចិត្តស្អាត់ជំនាញ ។

ទី១៨- ឈ្មោះថា **កាយុជុកតា** គឺចេតសិកដែលធ្វើឲ្យចេតសិកត្រង់ ។

ទី១៩- ឈ្មោះថា **បិត្តុជុកតា** គឺចេតសិកដែលធ្វើឲ្យចិត្តត្រង់ ។

(២)- **វិរតិចេតសិក** ៣ ជាចេតសិកដែលវៀរចាកកាយទុច្ចរិត និងវចីទុច្ចរិត មានឈ្មោះដូចតទៅនេះ

ទី១- ឈ្មោះថា **សម្មាវាចា** គឺចេតសិកដែលវៀរចាកវចីទុច្ចរិត ៤ មានវាចាប្រពៃ (មានសតិគ្រប់ពាក្យនិយាយ) ។

ទី២- ឈ្មោះថា **សម្មាកម្មន្ត:** គឺចេតសិកដែលវៀរចាកកាយ-ទុច្ចរិត ៣ ធ្វើការងារប្រពៃ (មានសតិគ្រប់កាលនិងគ្រប់ឥរិយាបថ) ។

ទី៣- ឈ្មោះថា **សម្មាអាជីវ:** គឺចេតសិកដែលវៀរចាកមិច្ឆាជីវ: ដោយកាយទុច្ចរិត និងវចីទុច្ចរិត រស់នៅប្រពៃ (មានសតិគ្រប់ខណ:ដែលបរិភោគ) ។

(៣)- **អប្បមញ្ញាចេតសិក** ២ ជាចេតសិកដែលមានសេចក្ដីដឹង

ផ្សាយទៅមិនមានប្រមាណ ហៅថា "ព្រហ្មវិហារ" ក៏បាន មានឈ្មោះដូចតទៅនេះ ៖

ទី១- ឈ្មោះថា **ករុណា** គឺចេតសិកដែលមានសេចក្តីអាណិតអាសូរចំពោះសត្វទាំងពួងដែលមានទុក្ខ ។

ទី២- ឈ្មោះថា **មុទុតា** គឺចេតសិកដែលមានសេចក្តីត្រេកអរកាលសត្វទាំងពួងបានទទួលសេចក្តីសុខ ។

(៤)- **បញ្ញិន្ទ្រិយចេតសិក** ១ មានឈ្មោះថា បញ្ញិន្ទ្រិយ: គឺចេតសិកដែលដឹងច្បាស់ កម្ចាត់ងងឹត មិនវង្វេង ជាធំ ជាកំពូលគ្រប់គ្រងសហជាតិធម៌ទាំងពួង មានសមាធិជាហេតុជិត ។

រូប ២៨

រូបបរមត្ថធម៌ គឺសភាវៈរបស់រូបដែលបែករលត់ដោយត្រជាក់ និងក្តៅ ចែកជា ២ ជំពូក បានដល់មហាភូតរូប ៤ គឺរូបដែលធំមានប្រាកដច្បាស់ជាងរូបដទៃៗ រួមជា ៤ រូប, ឧបាទាយរូប ២៤ គឺរូបដែលអាស្រ័យមហាភូតរូបកើតឡើង កាលរួមទាំង ២ ជំពូកហើយ ចែកជា ១១ ប្រការគឺ ៖

១- **មហាភូតរូប** ៤ មានឈ្មោះដូចតទៅនេះ ៖

រូបទី១- ឈ្មោះថា **បថវីធាតុ** *គឺរូបដី មានលក្ខណៈរឹងនិងទន់ ។*

រូបទី២- ឈ្មោះថា **អាបោធាតុ** *គឺរូបទឹក មានលក្ខណៈហូរទៅ និងនឹងនៅ ។*

រូបទី៣- ឈ្មោះថា **តេជោធាតុ** *គឺរូបភ្លើង មានលក្ខណៈក្តៅ និងត្រជាក់ ។*

រូបទី៤- ឈ្មោះថា **វាយោធាតុ** *គឺរូបខ្យល់ មានលក្ខណៈកម្រើក និងរីកតឹង ។*

២- **បសាទរូប** *៥ គឺរូបដែលមានសេចក្តីថ្នា គួរដល់អារម្មណ៍ដែលប៉ះទង្គិច មានឈ្មោះដូចតទៅនេះ ៖*

រូបទី១- ឈ្មោះថា **ចក្ខុបសាទរូប** *គឺរូបបសាទភ្នែក (កែវភ្នែកប្រហែលកញ្ចក់) ។*

រូបទី២- ឈ្មោះថា **សោតបសាទរូប** *គឺរូបបសាទត្រចៀក (កែវត្រចៀកប្រហែលរន្ធង់លួសទង់ដែង) ។*

រូបទី៣- ឈ្មោះថា **ឃានបសាទរូប** *គឺរូបឃានបសាទច្រមុះ (ប្រហែលក្រចកដើងពពែ) ។*

រូបទី៤- ឈ្មោះថា **ជិវ្ហាបសាទរូប** *គឺរូបបសាទអណ្តាត (ប្រហែលត្រចកស្រទាប់ឈូក) ។*

រូបទី៥- ឈ្មោះថា **កាយបសាទរូប** *គឺរូបបសាទកាយ (ប្រហែលសំឡីជាជាន់ៗ) ។*

៣- **គោបរូប** ៤ គឺរូបដែលមានការត្រាច់ទៅជាអារម្មណ៍ ដូចគោយ៉ាងពិស្តារមាន ៧ ដែលរួមនឹងមហាភូតរូប ៣ (រៀរអាបោធាតុ) ដែលចូលក្នុងផោដ្ឋព្វារម្មណ៍ តែមានឈ្មោះស្រាប់ហើយក្នុងមហាភូតរូប ទើបមិននាំមកសម្តែងឈ្មោះក្នុងទីនេះ សម្តែងឈ្មោះត្រឹម ៤ ប៉ុណ្ណោះ ដូចមានចែងតទៅនេះ ៖

រូបទី១- ឈ្មោះថា **រូបារម្មណ៍** (វណ្ណា) គឺរូបពណ៌ (ពន្ធឺរស្មី) ។

រូបទី២- ឈ្មោះថា **សទ្ទារម្មណ៍** គឺរូបសំឡេង (រលកសំឡេងយ៉ាងល្អិត) ។

រូបទី៣- ឈ្មោះថា **គន្ធារម្មណ៍** គឺរូបក្លិន (ទឹកប្រេងរហើយ) ។

រូបទី៤- ឈ្មោះថា **រសារម្មណ៍** គឺរូបរស (ជ័រប្រភេទមួយ) ។

៤- **សភាវរូប** ២ បានដល់រូបដែលជាហេតុឲ្យកើតភេទជាស្រី និងភេទជាប្រុស ដែលមានកម្មជាទីតាំង មានឈ្មោះដូចតទៅនេះ ៖

រូបទី១- ឈ្មោះថា **ឥត្ថីភាវរូប** គឺរូបស្រី (លក្ខណៈ និងកិរិយាអាការរបស់ស្រី) ។

រូបទី២- ឈ្មោះថា **បុរិសភាវរូប** គឺរូបប្រុស (លក្ខណៈ និងកិរិយាអាការរបស់ប្រុស) ។

៥- **ហទយរូប** ១ បានដល់ហទយវត្ថុ គឺវត្ថុដែលអាស្រ័យរបស់ចិត្ត និងចេតសិក ឈ្មោះថា ហទយរូប ។

៦- **ជីវិតរូប** ១ គឺរូបធម៌ដែលរក្សាសហជាតិរបស់រូបក្នុងរាងកាយ ឲ្យទ្រង់នៅបាន ជារូបដែលរក្សាជីវិតទុក ហៅថា ជីវិតរូប ។

៧- **អាហាររូប** ១ បានដល់ឱជារស បណ្តាដែលមានក្នុងអាហារដែលបរិភោគប្រចាំជានិច្ច អាចធ្វើឲ្យរូបចម្រើននៅបាន ឈ្មោះថា អាហាររូប ។

៨- **បរិច្ឆេទរូប** ១ គឺអាកាសធាតុដែលមានឡើងចន្ទោះរូប និងរូប ហៅថា អាកាសរូប គឺរូបទទេក៏ហៅ ។

៩- **វិញ្ញត្តិរូប** ២ គឺរូបដែលសម្តែងចេញមកផ្លូវកាយនិងផ្លូវវាចា ឲ្យជាគ្រឿងសម្គាល់ឲ្យដឹងបាន មានឈ្មោះដូចតទៅនេះ៖

រូបទី១- ឈ្មោះថា **កាយវិញ្ញត្តិរូប** *គឺរូបកម្រើកផ្លូវកាយ ។*

រូបទី២- ឈ្មោះថា **វចីវិញ្ញត្តិរូប** *គឺរូបកម្រើកផ្លូវវាចា ។*

១០- **វិការរូប** ៣ បានដល់សេចក្តីផ្ទាស់ប្តូរនូវអាការៈរបស់រូប មានឈ្មោះដូចតទៅនេះ

រូបទី១- ឈ្មោះថា **លហុតារូប** *គឺរូបស្រាល ។*

រូបទី២- ឈ្មោះថា **មុទុតារូប** *គឺរូបដែលទន់ ។*

រូបទី៣- ឈ្មោះថា **កម្មញ្ញតារូប** *គឺរូបដែលគួរដល់ការងារ ។*

១១- **លក្ខណរូប** ៤ បានដល់លក្ខណៈរបស់រូប មានឈ្មោះដូចតទៅនេះ ៖

រូបទី១- ឈ្មោះថា **ឧប្ចយរូប** *គឺរូបដែលកើត ។*

រូបទី២- ឈ្មោះថា **សន្ទតិរូប** *គឺរូបដែលចម្រើនឡើង ។*

រូបទី៣- ឈ្មោះថា **ជរតារូប** *គឺរូបដែលគ្រាំគ្រា ។*

រូបទី៤- ឈ្មោះថា **អនិច្ចតារូប** *គឺរូបដែលរលត់ (មិនទៀង) ។*

ព្រះនិព្វាន ១

ព្រះនិព្វានជាកំពូលបរមត្ត ដែលមាននាមថា ***"អនុត្តរធម៌"*** *រមែងជាអារម្មណ៍របស់មគ្គញ្ញាណ ផលញ្ញាណ ដែលបានផុតចាកតណ្ហាគ្រឿងចាក់ស្រេះហើយ និងរលត់នូវបញ្ចក្ខន្ធ ពោលដោយសភាវៈព្រះនិព្វានរមែងមានតែមួយប្រការ តែបើចែកដោយការណូបចារន័យ ព្រះនិព្វានរមែងមាន ២ គឺ ៖*

១- **សឧបាទិសេសនិព្វានធាតុ** *គឺនិព្វានរលត់កិលេស ដែលមានបញ្ចក្ខន្ធសល់ ។*

២- **អនុបាទិសេសនិព្វាន** *គឺនិព្វានដែលរលត់អស់ទាំងកិលេស និងបញ្ចក្ខន្ធ ។*

ក្រៅចាកនេះ ដោយប្រភេទរបស់អាការព្រះនិព្វានរមែងមាន ៣ គឺ

១- **អនិមិត្តនិព្វាន** *គឺនិព្វានរលត់រូបនាម មិនមាននិមិត្ត ។*

២- **អប្បណិហិតនិព្វាន** *គឺនិព្វានដែលរលត់រូបនាម ឥតកិលេសឡើយ ។*

៣- **សុញ្ញតនិព្វាន** *គឺនិព្វានរលត់រូបនាម ទំនេរចាកកិលេស ។*

រូបនាមក្នុងវិបស្សនាភូមិ

ពោលអំពីខន្ធ ៥

ធម្មតាការបណ្តុះពូជធញ្ញាហារ មានស្រូវខ្ទាយ ស្រូវដំណើប ជាដើម ត្រូវអាស្រ័យផែនដីមានស្រែជាដើម ជាទីព្រោះបណ្តុះ ដូចម្តេច? សូម្បីវិបស្សនាកម្មដ្ឋាននេះ ក៏ត្រូវអាស្រ័យភូមិ ផ្ទៃ ទីកន្លែងបណ្តុះ ដូច្នោះ ដូចគ្នា ភូមិផ្ទៃដែលព្រោះបណ្តុះឲ្យវិបស្សនាចម្រើនលូតលាស់ឡើងនោះ បើពោលដោយសង្ខេបទីបំផុតហើយមាន ២ យ៉ាងគឺ

១- **រូបធម៌** *របស់ដែលស្ថិតនៅឲ្យដឹង ។*

២- **នាមធម៌** *របស់ដែលចូលទៅដឹង ។*

រូបធម៌ នាមធម៌ (រឿងលោកុត្តរធម៌) ជាភូមិ ជាផ្ទៃ ដែលស្ថិតនៅ ឲ្យវិបស្សនាឃើញជាក់ច្បាស់រហូតដល់ការពិសោធ វិបស្សនាទើបយក រូបនាមជាកម្មដ្ឋាន យករូបនាមជាអារម្មណ៍ យករូបនាមជាផ្លូវដើរ វិបស្សនាសម្ងឹង ដឹងរូបនាម រូបនាមទើបជាភូមិរបស់វិបស្សនា ជាកម្មដ្ឋាន របស់វិបស្សនា រូបនាមជាអារម្មណ៍របស់វិបស្សនា រូបនាមជាផ្លូវដើររបស់ វិបស្សនា រូបនាមស្ថិតនៅឲ្យវិបស្សនាសម្ងឹង ។

រូបធម៌ *បានដល់រូបបរមត្ត ។*

នាមធម៌ *បានដល់ចិត្តបរមត្ត និងចេតសិកបរមត្ត ។*

ចំណែកវិបស្សនាបានដល់បញ្ញាចេតសិក និងសហជាតធម៌ ព្រោះដូច្នោះ រូបនាមនេះមិនមែនដទៃ បានដល់ចិត្ត ចេតសិក និងរូបនោះឯង (ចំណែកព្រះនិញ្ជានសង្គ្រោះចូលជានាមធម៌ ដែលផុតចាកខន្ធ) វិបស្សនាភូមិដែលព្រះអង្គទ្រង់សម្តែងមាន ៦ ភូមិគឺ ៖

១- **ខន្ធ** ៥ (គឺគំនរទាំង ៥) ។

២- **អាយតន:** ១២ (គឺស្ពានគ្រឿងភ្ជាប់ គ្រឿងតឲ្យកើតសេចក្តីដឹងមាន ១២) ។

៣- **ធាតុ** ១៨ (គឺរបស់ដែលទ្រង់ទុកនូវសភាពរបស់ខ្លួនមាន ១៨) ។

៤- **ឥន្ទ្រិយ** ២២ (គឺភាពជាធំមាន ២២) ។

៥- **អរិយសច្ច** ៤ (គឺសេចក្តីពិតដ៏ប្រសើរមាន ៤) ។

៦- **បដិច្ចសមុប្បាទ** ១២ (គឺសេចក្តីប្រជុំព្រមរបស់ហេតុផលមាន ១២) ។

ដែលបានឈ្មោះថាខន្ធនោះ ព្រោះជាគំនរដែលប្រជុំដោយប្រាកដការណ៍ ១១ គឺ ជាសភាពដែលមានមកហើយក្នុងអតីត ១ ជាសភាពដែលនឹងប្រព្រឹត្តទៅក្នុងអនាគត ១ ជាសភាពដែលមាននៅក្នុងបច្ចុប្បន្ន ១ ជាសភាពដែលនៅខាងក្នុង ១ ជាសភាពដែលនៅខាងក្រៅ ១ ជាសភាពដែលគ្រោតគ្រាត ១ ជាសភាពដែលល្អិត ១ ជាសភាពដែលថោកទាប ១

ជាសភាពដែលប្រណីត ១ ជាសភាពដែលឆ្ងាយ ១ ជាសភាពដែលជិត ១ រួមជាសភាពដែលប្រាកដ ១១ ប្រការ ហៅថា ខន្ធ បានដល់ បញ្ចកូន្ធមាន ៥ គឺ៖

១- **រូបក្ខន្ធ** (គំនររូប មាននាទីបែករលត់) ។

២- **វេទនាខន្ធ** (គំនរវេទនា មាននាទីសោយរូបបែករលត់) ។

៣- **សញ្ញាខន្ធ** (គំនរសញ្ញា មាននាទីចាំរូបបែករលត់) ។

៤- **សង្ខារក្ខន្ធ** (គំនរសង្ខារ មាននាទីប្រុងតែងរូបបែករលត់) ។

៥- **វិញ្ញាណក្ខន្ធ** (គំនរវិញ្ញាណ មាននាទីដឹងរូបបែករលត់) ។

ខន្ធទាំង ៥ នេះក៏មិនមែនដទៃឆ្ងាយ បានដល់ព្រះបរមត្ថធម៌ន៉ុះឯង ឧបមាដូចព្រៃឈើ កាលនៅក្នុងព្រៃហៅថាដើមឈើ កាលនាំមកប្រើធ្វើផ្ទះ កុដិ សាលា ហៅថាសសរខ្ទះ ផ្ទោងខ្ទះ ផ្ទានខ្ទះ បង្ក៉ង់ខ្ទះ ដែរណែងខ្ទះ ជាដើម ដូចម្តេច សូម្បីខន្ធ ៥ ក៏យកបរមត្ថធម៌ ៣ (រឿរនិញ្ចាន) មកប្រើដូច្នោះ ។

សង្ត្រោះបរមត្ថធម៌ចុះជាខន្ធ ៥ ដូច្នេះ

រូបក្ខន្ធ គឺរូប ២៨ ។

វេទនាខន្ធ គឺវេទនាចេតសិកមួយ ។

សញ្ញាខន្ធ គឺសញ្ញាចេតសិកមួយ ។

សង្ខារក្ខន្ធ គឺចេតសិកដែលសល់ ៥០ ។

វិញ្ញាណក្ខន្ធ *គឺចិត្ត ៨៩ ឬ ១២១ ។*

ចំណែកព្រះនិព្វានមិនរាប់ចូលជាខន្ធ ហៅថា **"ខន្ធវិមុត្តិ"** *ផុតចាកខន្ធ ៥ ។*

ខន្ធ ៥ នេះគឺរូបនាមនុ៎ះឯង មានការសង្គ្រោះដូច្នេះ

រូបក្ខន្ធ *គឺរូបធម៌ ។*

វេទនាខន្ធ *គឺនាមធម្មចេតសិក ។*

សញ្ញាខន្ធ *គឺនាមធម្មចេតសិក ។*

សង្ខារក្ខន្ធ *គឺនាមធម្មចេតសិក ។*

វិញ្ញាណក្ខន្ធ *គឺនាមធម្មចិត្ត ។*

រួមនាមធម្មចេតសិក ៣ និងនាមធម្មចិត្ត ១ ជានាមខន្ធ ៤ ហៅថា **"នាមធម៌"** *រូបខន្ធ គង់ជា* **"រូបធម៌"** *។*

(ចប់ភូមិខន្ធ ៥)

ពោលអំពីអាយតនៈ ១២

ស្ថានគ្រឿងភ្ជាប់ គ្រឿងតឲ្យកើតសេចក្តីដឹងផ្សេងៗ នោះហៅថា អាយតនៈ ១២ ជាភូមិដែលឲ្យកើតវិបស្សនាញាណ ដឹងច្បាស់ឃើញពិតដូចគ្នានឹងខន្ធ ៥ ។ ឯអាយតនៈ ១២ នេះ មិនមែនដទៃឆ្ងាយឡើយ បានដល់បរមត្ថធម៌នុ៎ះឯង ដែលនឹងសម្តែងអង្គធម៌ដូចតទៅនេះ

អាយតនៈ ១២ គឺខាងក្នុង ៦ ខាងក្រៅ ៦

ខាងក្នុង ៦

១- ចក្ខាយតនៈ *អាយតនៈ គឺភ្នែក ។*

២- សោតាយតនៈ *អាយតនៈ គឺត្រចៀក ។*

៣- ឃានាយតនៈ *អាយតនៈ គឺច្រមុះ ។*

៤- ជិវ្ហាយតនៈ *អាយតនៈ គឺអណ្តាត ។*

៥- កាយាយតនៈ *អាយតនៈ គឺកាយ ។*

៦- មនាយតនៈ *អាយតនៈ គឺចិត្ត ។*

ខាងក្រៅ ៦

១- រូបាយតនៈ *អាយតនៈ គឺរូប ។*

២- សទ្ទាយតនៈ *អាយតនៈ គឺសំឡេង ។*

៣- គន្ធាយតនៈ *អាយតនៈ គឺក្លិន ។*

៤- រសាយតនៈ *អាយតនៈ គឺរស ។*

៥- ផោដ្ឋព្វាយតនៈ *អាយតនៈ គឺគ្រឿងខ្ទប់ ឬប៉ះ ។*

៦- ធម្មាយតនៈ *អាយតនៈ គឺធម៌ ។*

សង្គ្រោះបរមត្ថធម៌ចុះក្នុងអាយតនៈ ១២ ដូច្នេះ

ខាងក្នុង ៦

១- ចក្ខាយតនៈ (ភ្នែក) *គឺចក្ខុបសាទរូប ។*

២- សោតាយតន: (ត្រចៀក) គឺសោតបសាទរូប ។

៣- ឃានាយតន: (ច្រមុះ) គឺឃានបសាទរូប ។

៤- ជិវ្ហាយតន: (អណ្តាត) គឺជិវ្ហាបសាទរូប ។

៥- កាយាយតន: (កាយ) គឺកាយបសាទរូប ។

៦- មនាយតន: (ចិត្ត) គឺចិត្ត ៨៩ ។

ទាងក្រៅ ៦

៧- រូបាយតន: គឺរូបារម្មណ៍ (វណ្ណពណិ) ។

៨- សទ្ទាយតន: គឺសទ្ទារម្មណ៍ (សំឡេង) ។

៩- គន្ធាយតន: គឺគន្ធារម្មណ៍ (ក្លិន) ។

១០- រសាយតន: គឺរសារម្មណ៍ (រស) ។

១១- ផោដ្ឋព្វាយតន: គឺផោដ្ឋព្វារម្មណ៍ (គ្រឿងខ្ទប់ប្ទប៉ះ) ។

១២- ធម្មាយតន: គឺសុខុមរូប ១៦ ចេតសិក ៥២ និព្វាន ១ ។

សង្រ្គោះអាយតន: ១២ បុះជារូបនាមដូច្នេះ

១- បក្ខ្ទាយតន: ជារូបធមិ ។

២- សោតាយតន: ជារូបធមិ ។

៣- ឃានាយតន: ជារូបធមិ ។

៤- ជិវ្ហាយតន: ជារូបធមិ ។

៥- កាយាយតន: ជារូបធមិ ។

៦- **មនាយតន:** *ជានាមធម៌ ។*

៧- **រូបាយតន:** *ជារូបធម៌ ។*

៨- **សទ្ទាយតន:** *ជារូបធម៌ ។*

៩- **គន្ធាយតន:** *ជារូបធម៌ ។*

១០- **រសាយតន:** *ជារូបធម៌ ។*

១១- **ផោដ្ឋព្វាយតន:** *ជារូបធម៌ ។*

១២- **ធម្មាយតន:** *ជារូបធម៌ នាមធម៌ ។*

អាយតន: ១២ ជាធម្មជាតដែលកើតក្នុងទ្វារទាំង ៦ និងអារម្មណ៍ ៦ ជាអណ្តូងកើតរបស់ធម៌ដទៃ ជាទីហូរមកនៃបុណ្យ និងបាប មានចិត្តនិងចេតសិកចូលចិត្តនៅទីនេះ រមែងហូរនាំទៅកាន់ទុក្ខក្នុងសង្សារវដ្ត អាយតន: នេះជាសញ្ញាតិ ឬប្រទេសរបស់ចិត្ត និងចេតសិក ជាទីនៅ ទីអាស្រ័យរបស់ចិត្ត និងចេតសិក ជាទីលាយឡំគ្នា ជាទីសមោសររបស់ចិត្ត និងចេតសិក សរុបហើយ ទីកើតចំពោះរូបធម៌ ១០ ចំពោះនាមធម៌ ១ ទាំងជារូបធម៌ នាមធម៌ ១ ព្រោះដូច្នោះ អាយតន: ១២ ក៏គឺរូបនាមនុ៎ះឯង ។

ភូមិអាយតន: ១២ ចប់

ពោលអំពីធាតុ ១៨

របស់ដែលទ្រង់ទុកនូវសភាពរបស់ខ្លួនពិតៗ ជាសភាវ:ដែលស្ថិតនៅឲ្យពិសោធ ស្ថិតនៅឲ្យដឹង ស្ថិតនៅឲ្យឃើញ មិនមែនសត្ត

មិនមែនជីវ: សម្គាល់សេចក្តីថា ប្រាសចាកអាការរបស់សត្ត ប្រាស-ចាកអាការរបស់ជីវ: គឺមិនមានការទៅ ការមក ការបរិភោគ ការដេក និងការប្រកបកិច្ចដទៃ មិនមានជីវិតដែលទៀងនៅជានិច្ច ដូច្នោះទើប ហៅថាធាតុមាន ១៨ គឺ៖

១- **បក្ខុធាតុ** (*ធាតុភ្នែក*) ។

២- **សោតធាតុ** (*ធាតុត្រចៀក*) ។

៣- **ឃានធាតុ** (*ធាតុច្រមុះ*) ។

៤- **ជិវ្ហាធាតុ** (*ធាតុអណ្តាត*) ។

៥- **កាយធាតុ** (*ធាតុកាយ*) ។

៦- **មនោធាតុ** (*ធាតុចិត្ត*) ។

៧- **រូបធាតុ** (*ធាតុពណ៌*) ។

៨- **សទ្ទធាតុ** (*ធាតុសំឡេង*) ។

៩- **គន្ធធាតុ** (*ធាតុក្លិន*) ។

១០- **រសធាតុ** (*ធាតុរស*) ។

១១- **ផោដ្ឋព្វធាតុ** (*ធាតុខ្ទប់ប្ទប៉ះ*) ។

១២- **ធម្មធាតុ** (*ធាតុធម៌*) ។

១៣- **បក្ខុវិញ្ញាណធាតុ** (*ធាតុឃើញ*) ។

១៤- **សោតវិញ្ញាណធាតុ** (*ធាតុបានឮ*) ។

១៥- ឃានវិញ្ញាណធាតុ (ធាតុដឹងក្លិន) ។

១៦- ជិវ្ហាវិញ្ញាណធាតុ (ធាតុដឹងរស) ។

១៧- កាយវិញ្ញាណធាតុ (ធាតុដឹងពាល់ត្រូវផ្លូវកាយ) ។

១៨- មនោវិញ្ញាណធាតុ (ធាតុដឹងផ្លូវចិត្ត) ។

ធាតុ ១៨ នេះ បើកាន់យកតាមសភាវបរមត្ថ ដូចគ្នានឹងខន្ធ ៥ អាយតនៈ ១២ នឹងសម្តែងសង្គ្រោះចូលគ្នាដូច្នេះ

១- ចក្ខុធាតុ គឺចក្ខុបសាទរូប ។

២- សោតធាតុ គឺសោតបសាទរូប ។

៣- ឃានធាតុ គឺឃានបសាទរូប ។

៤- ជិវ្ហាធាតុ គឺជិវ្ហាបសាទរូប ។

៥- កាយធាតុ គឺកាយបសាទរូប ។

៦- មនោធាតុ គឺសម្បដិច្ឆន្នចិត្ត ២ និងបញ្ចទ្វារាវជ្ជន ១ ។

៧- រូបធាតុ គឺរូបារម្មណ៍ ។

៨- សទ្ទធាតុ គឺសទ្ទារម្មណ៍ ។

៩- គន្ធធាតុ គឺគន្ធារម្មណ៍ ។

១០- រសធាតុ គឺរសារម្មណ៍ ។

១១- ផោដ្ឋព្វធាតុ គឺផោដ្ឋព្វារម្មណ៍ ។

១២- ធម្មធាតុ គឺចេតសិក ៥២ សុខុមរូប ១៦ និព្វាន ១ ។

១៣- **ចក្ខុវិញ្ញាណធាតុ** *គឺចក្ខុវិញ្ញាណចិត្ត ២ ។*

១៤- **សោតវិញ្ញាណធាតុ** *គឺសោតវិញ្ញាណចិត្ត ២ ។*

១៥- **ឃានវិញ្ញាណធាតុ** *គឺឃានវិញ្ញាណចិត្ត ២ ។*

១៦- **ជិវ្ហាវិញ្ញាណធាតុ** *គឺជិវ្ហាវិញ្ញាណចិត្ត ២ ។*

១៧- **កាយវិញ្ញាណធាតុ** *គឺកាយវិញ្ញាណចិត្ត ២ ។*

១៨- **មនោវិញ្ញាណធាតុ** *គឺមនោវិញ្ញាណចិត្ត ៧៦ ។*

ធាតុ ១៨ នេះ ចាត់ជាពួកៗ បាន ៣ ដំពូកគឺ៖

១- **ធាតុទទួល** *(ទ្វារ ៦) ។*

២- **ធាតុខ្ជប់ ឬប៉ះ** *(អារម្មណ៍ ៦) ។*

៣- **ធាតុដឹង** *(ចិត្ត ៨៩) ។*

ដូចនឹងសម្តែងតទៅនេះ

ធាតុទទួល	ធាតុខ្ជប់ឬប៉ះ	ធាតុដឹង
ចក្ខុធាតុ (កែវភ្នែក)	*រូបធាតុ (គឺពណ៌)*	*ចក្ខុវិញ្ញាណធាតុ (ឃើញ)*
សោតធាតុ (កែវត្រចៀក)	*សទ្ទធាតុ (សំឡេង)*	*សោតវិញ្ញាណធាតុ (ឮ)*
ឃានធាតុ (ប្រសាទច្រមុះ)	*គន្ធធាតុ (ក្លិន)*	*ឃានវិញ្ញាណធាតុ (ដឹងក្លិន)*
ជិវ្ហាធាតុ (ប្រសាទអណ្តាត)	*រសធាតុ (រស)*	*ជិវ្ហាវិញ្ញាណធាតុ (ដឹងរស)*
កាយធាតុ (ប្រសាទកាយ)	*ផោដ្ឋព្វធាតុ (ខ្ជប់)*	*កាយវិញ្ញាណធាតុ (ដឹងសម្ផស្ស)*
មនោធាតុ (ទទួលដឹង)	*ធម្មធាតុ (ធម៌)*	*មនោវិញ្ញាណធាតុ (ដឹង)*

ធាតុ ១៨ នេះ កាលបង្រួញចុះហើយ គង់ជារូប ជានាមប៉ុណ្ណោះ ដូច្នេះ ៖

ចក្ខុធាតុ-រូបធាតុ ជា **រូបធម៌**, ចក្ខុវិញ្ញាណធាតុ ជា **នាមធម៌**, សោតធាតុ-សទ្ទធាតុ ជា **រូបធម៌**, សោតវិញ្ញាណធាតុ ជា **នាមធម៌**, ឃានធាតុ-គន្ធធាតុ ជា **រូបធម៌**, ឃានវិញ្ញាណធាតុ ជា **នាមធម៌**, ជិវ្ហាធាតុ-រសធាតុ ជា **រូបធម៌**, ជិវ្ហាវិញ្ញាណធាតុ ជា **នាមធម៌**, កាយធាតុ-ផោដ្ឋព្វធាតុ ជា **រូបធម៌**, កាយវិញ្ញាណធាតុ ជា **នាមធម៌**, មនោធាតុ ជា **នាមធម៌**, ធម្មធាតុ ជា **រូបធម៌ នាមធម៌**, មនោវិញ្ញាណ-ធាតុ ជា **នាមធម៌** ។

ធាតុទាំង ១៨ ចាត់ជារូបធម៌ ១០ ជានាមធម៌ ៧ ទាំងជារូបធម៌ នាមធម៌ ១ ឬនឹងហៅធាតុនោះថា "**រូបធាតុ នាមធាតុ**" ក៏បាន ។

ភូមិធាតុ ១៨ ចប់

ពោលអំពីឥន្ទ្រិយ ២២

ធម្មជាតដែលជាធំ គ្រប់គ្រងក្នុងកិច្ចផ្សេងៗ ក្នុងនាទីរបស់ខ្ជួនៗ ហៅថា "**ឥន្ទ្រិយ**" មាន ២២ ធម្មជាតិជាភូមិជាផ្ទៃវិបស្សនាដែលឲ្យ ចម្រើនលូតលាស់ល្អវិបុលលើសឡើងទៅ ដរាបបានលុះលោកុត្តរធម៌ជាទី បំផុតបាន ដូចនឹងសម្តែងឲ្យប្រាកដតទៅនេះ ៖

១- **បក្ខុន្ទ្រិយ** គឺភាពជាធំរបស់ភ្នែក មាននាទីទទួលពណ៌ ។

២- សោតិន្ទ្រិយ គឺភាពជាធំរបស់ត្រចៀក មាននាទីទទួលសំឡេង ។

៣- ឃានិន្ទ្រិយ គឺភាពជាធំរបស់ច្រមុះ មាននាទីទទួលក្លិន ។

៤- ជិវ្ហិន្ទ្រិយ គឺភាពជាធំរបស់អណ្តាត មាននាទីទទួលរស ។

៥- កាយិន្ទ្រិយ គឺភាពជាធំរបស់កាយ មាននាទីទទួលសម្ផស្ស ។

៦- ឥត្ថិន្ទ្រិយ គឺភាពជាធំរបស់ស្រី មាននាទីសម្តែងលក្ខណៈ
កិរិយាអាការរបស់ស្រី ។

៧- បុរិសិន្ទ្រិយ គឺភាពជាធំរបស់ប្រុស មាននាទីសម្តែងលក្ខណៈ
កិរិយាអាការរបស់ប្រុស ។

៨- ជីវិតិន្ទ្រិយ គឺភាពជាធំរបស់ជីវិត មាននាទីរក្សារូបនាម ។

៩- មនិន្ទ្រិយ គឺភាពជាធំរបស់ចិត្ត មាននាទីដឹងអារម្មណ៍ ។

១០- សុខិន្ទ្រិយ គឺភាពជាធំរបស់សុខវេទនា មាននាទីសប្បាយ ។

១១- ទុក្ខិន្ទ្រិយ គឺភាពជាធំរបស់ទុក្ខវេទនា មាននាទីមិនសប្បាយ ។

១២- សោមនស្សិន្ទ្រិយ គឺភាពជាធំរបស់សោមនស្សវេទនា មាននាទី
ត្រេកអរ ។

១៣- ទោមនស្សិន្ទ្រិយ គឺភាពជាធំរបស់ទោមនស្សវេទនា មាននាទី
ក្តុចចិត្ត ។

១៤- ឧបេក្ខិន្ទ្រិយ គឺភាពជាធំរបស់ឧបេក្ខាវេទនា មាននាទីព្រងើយៗ ។

១៥- សទ្ធិន្ទ្រិយ គឺភាពជាធំរបស់សទ្ធា មាននាទីជឿជ្រះថ្លា ។

១៦- **វីរិយិន្ទ្រិយ** *គឺភាពជាធំរបស់វីរិយៈ មានន័យ៖ ១ ។*

១៧- **សតិន្ទ្រិយ** *គឺភាពជាធំរបស់សតិ មានន័យ៖ ដឹងទាន់ប្រច្ចុប្បន្ន ។*

១៨- **សមាធិន្ទ្រិយ** *គឺភាពជាធំរបស់សមាធិ មានន័យ៖ តាំងមាំ ។*

១៩- **បញ្ញិន្ទ្រិយ** *គឺភាពជាធំរបស់បញ្ញា មានន័យ៖ ដឹងត្រៃលក្ខណ៍ ។*

២០- **អញ្ញតុញ្ញស្សាមីតិន្ទ្រិយ** *គឺភាពជាធំរបស់សោតាបត្តិមគ្គញ្ញាណ មានន័យ៖ ដឹងព្រះនិព្វាន កាត់អកុសលចិត្តបាន ៥ ។*

២១- **អញ្ញិន្ទ្រិយ** *គឺភាពជាធំរបស់សោតាបត្តិផលញ្ញាណ ដល់អរហត្តមគ្គញ្ញាណ មានន័យ៖ ដឹងព្រះនិព្វាន កាត់អកុសលតាមលំដាប់ ។*

២២- **អញ្ញាតាវិន្ទ្រិយ** *គឺភាពជាធំរបស់អរហត្តផលញ្ញាណ មានន័យ៖ ដឹងព្រះនិព្វាន និងកាត់អកុសលចិត្ត ១២ អស់រលីង ។*

ឥន្ទ្រិយ ២២ ក៏ជាសភាវបរមត្តធម៌ ដូចគ្នានឹងខន្ធ ៥ ដោយសង្ក្រោះ ដូចតទៅនេះ ៖

១- **ចក្ខុន្ទ្រិយ** *បានដល់ ចក្ខុបសាទរូប ។*

២- **សោតិន្ទ្រិយ** *បានដល់ សោតបសាទរូប ។*

៣- **ឃានិន្ទ្រិយ** *បានដល់ ឃានបសាទរូប ។*

៤- **ជិវ្ហិន្ទ្រិយ** *បានដល់ ជិវ្ហាបសាទរូប ។*

៥- **កាយិន្ទ្រិយ** *បានដល់ កាយបសាទរូប ។*

៦- **ឥត្ថិន្ទ្រិយ** *បានដល់ ឥត្ថីភាវរូប ។*

៧- បុរិសិន្ទ្រិយ បានដល់ បុរិសភាវរូប ។

៨- ជីវិតិន្ទ្រិយ បានដល់ ជីវិតរូប ជីវិតនាម ។

៩- មនិន្ទ្រិយ បានដល់ ចិត្តទាំងអស់ ។

១០- សុខិន្ទ្រិយ បានដល់ សុខវេទនាចេតសិក ។

១១- ទុក្ខិន្ទ្រិយ បានដល់ ទុក្ខវេទនាចេតសិក ។

១២- សោមនស្សិន្ទ្រិយ បានដល់ សោមនស្សវេទនាចេតសិក ។

១៣- ទោមនស្សិន្ទ្រិយ បានដល់ ទោមនស្សវេទនាចេតសិក ។

១៤- ឧបេក្ខិន្ទ្រិយ បានដល់ ឧបេក្ខាវេទនាចេតសិក ។

១៥- សទ្ធិន្ទ្រិយ បានដល់ សទ្ធាចេតសិក ។

១៦- វីរិយិន្ទ្រិយ បានដល់ វីរិយចេតសិក ។

១៧- សតិន្ទ្រិយ បានដល់ សតិចេតសិក ។

១៨- សមាធិន្ទ្រិយ បានដល់ ឯកគ្គតាចេតសិក ។

១៩- បញ្ញិន្ទ្រិយ បានដល់ បញ្ញាចេតសិក (លោកិយ) ។

២០- អញ្ញតញ្ញស្សាមីតិន្ទ្រិយ បានដល់ បញ្ញាចេតសិក (លោកុត្តរៈ) ។

២១- អញ្ញិន្ទ្រិយ បានដល់ បញ្ញាចេតសិក (លោកុត្តរៈ) ។

២២- អញ្ញាតាវិន្ទ្រិយ បានដល់ បញ្ញាចេសិក (លោកុត្តរៈ) ។

ឥន្ទ្រិយ ២២ នេះ កាលសរុបហើយ បានដល់រូបធម៌ និងនាមធម៌ ដូចនឹងភូមិដទៃៗ មានសង្គ្រោះដូច្នេះ ៖

១- ចក្ខុន្ទ្រិយ ជារូបធម៌ ។

២- សោតិន្ទ្រិយ ជារូបធម៌ ។

៣- ឃានិន្ទ្រិយ ជារូបធម៌ ។

៤- ជិវ្ហិន្ទ្រិយ ជារូបធម៌ ។

៥- កាយិន្ទ្រិយ ជារូបធម៌ ។

៦- ឥត្ថិន្ទ្រិយ ជារូបធម៌ ។

៧- បុរិសិន្ទ្រិយ ជារូបធម៌ ។

៨- ជីវិតិន្ទ្រិយ ទាំងជារូបធម៌ និងជានាមធម៌ ។

៩- មនិន្ទ្រិយ ជានាមធម៌ ។

១០- សុខិន្ទ្រិយ ជានាមធម៌ ។

១១- ទុក្ខិន្ទ្រិយ ជានាមធម៌ ។

១២- សោមនស្សិន្ទ្រិយ ជានាមធម៌ ។

១៣- ទោមនស្សិន្ទ្រិយ ជានាមធម៌ ។

១៤- ឧបេក្ខិន្ទ្រិយ ជានាមធម៌ ។

១៥- សទ្ធិន្ទ្រិយ ជានាមធម៌ ។

១៦- វីរិយិន្ទ្រិយ ជានាមធម៌ ។

១៧- សតិន្ទ្រិយ ជានាមធម៌ ។

១៨- សមាធិន្ទ្រិយ ជានាមធម៌ ។

១៩- បញ្ញិន្ទ្រិយ ជានាមធម៌ ។

២០- អញ្ញតួញ្ញស្សាមីតិន្ទ្រិយ ជានាមធម៌ ។

២១- អញ្ញិន្ទ្រិយ ជានាមធម៌ ។

២២- អញ្ញាតាវិន្ទ្រិយ ជានាមធម៌ ។

ឥន្ទ្រិយ ២២ ចាត់ជារូបធម៌ ៧ ចាត់ជានាមធម៌ ១៤ ទាំងជារូបធម៌ ទាំងជានាមធម៌ ១ រូបនាមនេះឯង ដែលនាំមកជាអារម្មណ៍របស់វិបស្សនា ជាតួកម្មដ្ឋាន ។

ភូមិឥន្ទ្រិយ ២២ ចប់

ពោលអំពីអរិយសច្ច ៤

ព្រះសម្មាសម្ពុទ្ធជាម្ចាស់ ព្រះអង្គប្រសើរជាងអ្នកដែលពោលសេចក្ដីពិតទាំងឡាយថា សច្ចៈរមែងមាន ២ ប្រភេទគឺ លោកិយសច្ចៈ និង លោកុត្តរសច្ចៈ តែសច្ចៈទី ៣ នោះមិនមានឡើយ គ្រាន់តែសន្ទតគ្នាឡើងប៉ុណ្ណោះ សច្ចធម៌ជាបរមត្ថ ជាធម៌ដែលទៅចាកសត្រូវ ដែលព្រះអរិយៈបានដឹងហើយ បានលះហើយ បានធ្វើឲ្យច្បាស់ហើយ បានចម្រើនហើយ ដែលជាសភាព ជាសេចក្ដីពិតរបស់ព្រះអរិយៈទាំងឡាយ រមែង

ដឹង រមែងឃើញ ហៅថា អរិយសច្ច តាមដែលព្រះអង្គទ្រង់ទេសនាទុក មាន ៤ ប្រការគឺ:

១- **ទុក្ខអរិយសច្ច** (ទុក្ខពិតៗ)

២- **ទុក្ខសមុទយអរិយសច្ច** (ហេតុឲ្យកើតទុក្ខពិតៗ)

៣- **ទុក្ខនិរោធអរិយសច្ច** (រំលត់ទុក្ខពិតៗ)

៤- **ទុក្ខនិរោធគាមិនីបដិបទាអរិយសច្ច** (ផ្លូវរលត់ទុក្ខពិតៗ)

ឬហៅម៉ាងទៀតថា **ទុក្ខ សមុទយ និរោធ មគ្គ** ។

ទុក្ខ មាននាទីឲ្យដឹង យកមគ្គមកដឹង ។

សមុទយ មាននាទីឲ្យលះ យកមគ្គមកលះ ។

និរោធ មាននាទីឲ្យធ្វើឲ្យច្បាស់ យកមគ្គមកធ្វើឲ្យច្បាស់ ។

មគ្គ មាននាទីឲ្យចម្រើន យកមគ្គចម្រើនមគ្គឯង ។

ទុក្ខសច្ច សមុទយសច្ច និងមគ្គសច្ច (មគ្គសច្ចវៀរសច្ចវិមុត្តិ) ជាលោកិយសច្ច, និរោធសច្ច ជាលោកុត្តរសច្ច, អរិយសច្ចទាំង ៤ នេះ មិនមែនដទៃ គឺបរមត្ថធម៌ន៉ុះឯង យកសភាវៈរបស់បរមត្ថធម៌មកជាទីតាំង ដូចនឹងសម្តែងតទៅ:

សង្ត្រោះបរមត្ថធម៌បុះក្នុងអរិយសច្ចដូច្នេះ

ទុក្ខសច្ច គឺលោកិយចិត្ត ១៨ ចេតសិក ៥១ រូប ២៨ ។

សមុទយសច្ច គឺលោភចេតសិក ។

និរោធសច្ច *គឺនិញាន ។*

មគ្គសច្ច *គឺចេតសិកដែលជាអង្គមគ្គ ៨ ។*

អរិយសច្ច ជារូបធម៌ នាមធម៌ ដូបគ្នានឹងខន្ធ ៥ ដូច្នេះ

ទុក្ខសច្ច *ជារូបធម៌ នាមធម៌ ។*

សមុទយសច្ច *ជានាមធម៌ ។*

និរោធសច្ច *គឺរលត់រូបនាម ចាត់ជានាមធម៌ ។*

មគ្គសច្ច *ជានាមធម៌ ។*

(លោកុត្តរ: ៨ ជានាមធម៌ តែជាសច្ចវិមុត្តិ)

ទុក្ខ *គឺរូបនាមនេះជាខន្ធ ៥ ធន់មិនបាន កើតរលត់ជានិច្ច ។*

សមុទយ *គឺលោភតណ្ហាចង់បានទុក្ខ ។*

និរោធ *គឺរលត់ទុក្ខ ។*

មគ្គ *គឺផ្ទូវរលត់ទុក្ខ (សីល សមាធិ បញ្ញា) ។*

កាលសរុបហើយអរិយសច្ចទាំង ៤ ក៏គឺរូបធម៌និងនាមធម៌ប៉ុណ្ណោះ ។

ខណៈមគ្គសច្ចធ្វើការចារ

នាំយកទុក្ខសច្ច គឺរូបនាមខន្ធ ៥ មកជាផ្ទូវដើរ មគ្គសច្ច ៨ ជាអ្នកដើរផ្ទូវ ទាំងលះសមុទ័យបណ្តើរទៅផង គឺបដិបត្តិបណ្តើរ លះសមុទ័យបណ្តើរ លះបានអស់កាលណា ទុក្ខក៏រលត់ ជា **និរោធសច្ច**, *លើកតួយ៉ាងដូច មាត់និយាយជា* **ទុក្ខសច្ច**, *សតិដឹងទាន់ជា* **មគ្គសច្ច**,

លះសមុទ័យគឺចង់និយាយបាន រៀរវង្វេងជា សម្មាវាចា និយាយត្រូវ ។ កាលឈរ ដើរ អង្គុយ ដេក បត់ លាត កម្រើក ធ្វើការងារណាៗ ជា ទុក្ខសច្ច, សតិដឹងទាន់ជា មគ្គសច្ច, លះសមុទ័យសេចក្តីចង់ដើរ ឈរ អង្គុយ ដេក ជាដើម រៀរតួមោហៈគ្រប់ខណៈដែលធ្វើការងារ ជា សម្មាកម្មន្តៈ ធ្វើការងារត្រូវ ។

កាលខណៈឃើញ ខណៈបានឲ្ម ខណៈដឹងកូិន ខណៈដឹងរស ខណៈដឹងសម្ផស្ស ខណៈនឹកគិត ខណៈទទួលទានអាហារ ខណៈ ស្ងៀកដណ្តប់ ខណៈបរិភោគ ជា ទុក្ខសច្ច, មានសតិដឹងទាន់ ជា មគ្គសច្ច, លះសមុទ័យសេចក្តីចង់ឃើញ ចង់បានឲ្ម ចង់បរិភោគជាដើម រៀរតួមោហៈ គឺវង្វេង ជា សម្មាអាជីវៈ រស់នៅប្រពៃ ។

អង្គមគ្គទាំង ៣ គឺ សម្មាវាចា សម្មាកម្មន្តៈ សម្មាអាជីវៈ ចាត់ជា សីល ព្រោះរៀរអាក្រក់មានមោហៈជាដើម ។

សតិ ដឹងទាន់គ្រប់ខណៈនោះ ជា សម្មាសតិ រឲ្ចកប្រពៃ ។

វីរិយៈ សេចក្តីព្យាយាមតាំងសតិដឹងទាន់រឿយៗជា សម្មាវាយាមោ ព្យាយាមប្រពៃ ។

សមាធិ នឹងនមិនរាយមាយនោះ ជា សម្មាសមាធិ តាំងចិត្តមាំ ប្រពៃ ។

បញ្ញា ការឃើញរូបនាមកើតរលត់នោះជា សម្មាទិដ្ឋិ ឃើញប្រពៃ ។

វិតក្ក: ដ៏ងឃើញព្រះត្រៃលក្ខណ៍ **អនិច្ចំ** មិនទៀង **ទុក្ខំ** ធន់នៅមិនបាន **អនត្តា** បង្ខាំបញ្ជាមិនបាន ដែលជាប់នៅនឹងរូបនាមនោះ ជា **សម្មាសង្កប្ប** តម្រិះប្រពៃ ។

កាលឃើញរូបនាមរលត់ទៅនឹងត្រៃលក្ខណ៍ព្រមៗ គ្នាដូច្នោះ លុះអស់អាសវ: ដែលជាតួសមុទ័យកាលណា កាលនោះទុក្ខនឹងរលត់ទៅមិនមានសល់ឲ្យឃើញ ហៅថា **និរោធសច្ច** *រមែងសម្ការហើយដល់ព្រះអរិយ:យ៉ាងពិតប្រាកដ ។*

(អរិយសច្ច ៤ ចប់)

ពោលអំពីបដិច្ចសមុប្បាទ ១២

សេចក្ដីប្រជុំព្រមនៃផល អាស្រ័យសេចក្ដីសាមគ្គីរបស់បច្ច័យទាំង-ឡាយធ្វើឲ្យកើតផលដោយព្រមព្រៀងគ្នា និងស្នោះស្ទើគ្នា ហៅថាបដិច្ចសមុប្បាទមាន ១២ ជាហេតុជាផលតជាប់គ្នា ដូចសម្ដែងតទៅនេះ ៖

១- **អវិជ្ជា** *ជាបច្ច័យឲ្យកើត* **សង្ខារ** *។*

២- **សង្ខារ** *ជាបច្ច័យឲ្យកើត* **វិញ្ញាណ** *។*

៣- **វិញ្ញាណ** *ជាបច្ច័យឲ្យកើត* **នាមរូប** *។*

៤- **នាមរូប** *ជាបច្ច័យឲ្យកើត* **សឬាយតន:** *។*

៥- **សឬាយតន:** *ជាបច្ច័យឲ្យកើត* **ផស្ស:** *។*

៦- **ផស្ស:** *ជាបច្ច័យឲ្យកើត* **វេទនា** *។*

៧- **វេទនា** ជាបច្ចយ្យឲ្យកើត **តណ្ហា** ។

៨- **តណ្ហា** ជាបច្ចយ្យឲ្យកើត **ឧបាទាន** ។

៩- **ឧបាទាន** ជាបច្ចយ្យឲ្យកើត **ភព** ។

១០- **ភព** ជាបច្ចយ្យឲ្យកើត **ជាតិ** ។

១១- **ជាតិ** ជាបច្ចយ្យឲ្យកើត **ជរាមរណៈ** ។

១២- **ជរាមរណៈ** ជាបច្ចយ្យឲ្យកើត **អវិជ្ជា** ។

បដិច្ចសមុប្បាទនេះ អង្គធម៌បានដល់បរមត្ថធម៌ ដែលនាំមកប្រើជាភូមិរបស់វិបស្សនា មានសង្ត្រោះនាំមកជាឯ។ ដូចតទៅនេះ ៖

១- **អវិជ្ជា** *គឺធម្មជាតិដែលមិនដឹង រ៉ង្វេង ភ្ជេចភ្ជាំងងងឹតជ្រប់ក្នុងធម៌ដែលគួរបាន រមែងមិនបាន ធម៌ដែលមិនគួរបាន រមែងបានសម្គាល់សេចក្តីថា មិនដឹងបរមត្ថ តែទៅដឹងបញ្ញត្តិ បានដល់មោហ-ចេតសិកនោះឯង ។*

២- **សង្ខារ** *គឺធម៌ដែលប្រុងតែង បានដល់សង្ខារ ៣ ឬសង្ខារ ៦ អង្គបរមត្ថ គឺចេតនា ២៩ ។*

៣- **វិញ្ញាណ** *គឺសេចក្តីដឹងក្នុងអារម្មណ៍ បានដល់ចិត្តជាលោកិយវិបាក ៣២ ។*

៤- **នាមរូប** *គឺសភាពដែលបែករលត់ ស្ថិតនៅឲ្យដឹង ហៅថា រូបបានដល់រូបបរមត្ថ ២៨ សភាពដែលបង្អោនទៅរករូបដែលបែក*

រលត់គឺអ្នកចូលទៅដឹង ហៅថា នាម បានដល់ចេតសិកទាំងអស់ ។

៥- **សឡាយតន:** គឺអាយតន: ៦ ដែលជាចំណែកខាងក្នុង អង្គបរមត្ថធម៌បានដល់បសាទរូប ៥ និងចិត្តទាំងអស់ ។

៦- **ផស្ស:** គឺធម្មជាតិដែលខ្ជប់អារម្មណ៍ ដែលជាប់ចាកការប្រជុំរបស់អារម្មណ៍ខ្ជប់នឹងបសាទរូប នឹងកើតវិញ្ញាណឡើង អង្គបរមត្ថ-ធម៌ បានដល់ផស្សចេតសិក ។

៧- **វេទនា** គឺធម្មជាតិដែលសោយអារម្មណ៍ សុខខ្ទះ ទុក្ខខ្ទះ ព្រងើយៗ ខ្ទះ មាន ៣ ឬ ៥ ដែលកើតចាកផស្ស:ជាបច្ច័យមាន ៦ បានដល់វេទនាចេតសិក ។

៨- **តណ្ហា** គឺសេចក្តីចង់បាន តណ្ហា ៦ អង្គបរមត្ថធម៌ គឺ លោភចេតសិកនោះឯង ដែលញែកចេញតាមហេតុបច្ច័យមាន ៣ ខ្ទះ ១០៨ ខ្ទះ (៣ x ៦ x ២ x ៣ = ១០៨) ។

៩- **ឧបាទាន** គឺសភាពដែលប្រកាន់មាំ កាន់ខ្ជាប់ គឺប្រកាន់អារម្មណ៍ទុក ដោយអំណាចនៃតណ្ហាដែលដុះក្រាស់ឡើងនោះឯង អង្គបរមត្ថធម៌ បានដល់លោភចេតសិក ។

១០- **ភព** គឺកម្មភព ដែលជាចេតនារបស់កុសលនិងអកុសលដែលធ្វើឲ្យកើតវិបាកនិងកតត្តារូប កើតក្នុងកាមភព រូបភព និងអរូបភព បានដល់ឧប្បត្តិភពទាំង ៩ មានកាមភពជាដើម ។ ពាក្យថា **ភព** ទើប

បានដល់ "កម្ម" ក្នុង ៣១ ភូមិន៉ុះឯង អង្គបរមត្ថធម៌ បានដល់ចេតនា ដែលប្រកបដោយចិត្ត ២៩ ។

១១- **ជាតិ** គឺសេចក្តីកើត សេចក្តីប្រសូត សេចក្តីរស់ សេចក្តីប្រាកដនៃខន្ធទាំង ៥ បានដល់បដិសន្ធិតាមកំណើត ៤ អង្គបរមត្ថធម៌ បានដល់និប្ផន្នរូប ១៨ (រូបជាតិ) វិបាកចិត្ត ១៩ (នាមជាតិ) ។

១២- **ជរាមរណៈ** គឺសេចក្តីចាស់ សេចក្តីស្លាប់ ដែលជាផលរបស់ជាតិ ដែលមានរួមជាមួយគ្នា ៥ ប្រការ បានដល់ **ជរា** សេចក្តីចាស់ **មរណៈ** សេចក្តីស្លាប់ **សោកៈ** សេចក្តីសោយសោក **បរិទេវៈ** សេចក្តីយំរៀបរាប់ **ឧបាយាសៈ** សេចក្តីចង្អៀតចង្អល់ចិត្ត លុះនិយាយមិនចេញ ដែលសំដៅយក **ឋិតិ** តាំងនៅ **ភង្គៈ** រលត់ទៅ តាមសេចក្តីប្រែប្រួលរបស់ចិត្ត ចេតសិក និងរូប ដែលមិនមានទីបំផុត ។

បដិច្ចសមុប្បាទចាត់ជាអទ្ធា ៣ (កាល ៣)

១- **អតីតធម៌** គឺអវិជ្ជា សង្ខារ ។

២- **អនាគតធម៌** គឺជាតិ ជរា មរណៈ ។

៣- **បច្ចុប្បន្នធម៌** គឺវិញ្ញាណ នាមរូប សឡាយតនៈ ផស្សៈ វេទនា តណ្ហា ឧបាទាន ភព ។

បដិច្ចសមុប្បាទចាត់ជាអង្គបាន ១២ ដូចសម្តែងមកហើយខាងដើម បើចាត់តាមអាការបាន ២០ ចែកជា ៤ ពួកគឺ

១- អតីតហេតុ ៥ គឺអវិជ្ជា សង្ខារ តណ្ហា ឧបាទាន ភព ។

២- បច្ចុប្បន្នផល ៥ គឺវិញ្ញាណ នាមរូប សឡាយតនៈ ផស្សៈ វេទនា ។

៣- បច្ចុប្បន្នហេតុ ៥ គឺតណ្ហា ឧបាទាន ភព អវិជ្ជា សង្ខារ ។

៤- អនាគតផល ៥ គឺវិញ្ញាណ នាមរូប សឡាយតនៈ ផស្សៈ វេទនា ។

ចាត់តាមសង្ខេប ៤ គឺ

១- អតីតកាលសង្ខេប បានដល់អវិជ្ជា សង្ខារ ។

២- បច្ចុប្បន្នផលសង្ខេប បានដល់វិញ្ញាណ នាមរូប សឡាយតនៈ ផស្សៈ វេទនា ។

៣- បច្ចុប្បន្នហេតុសង្ខេប បានដល់តណ្ហា ឧបាទាន ភព ។

៤- អនាគតកាលសង្ខេប បានដល់ជាតិ ជរា មរណៈ ។

ចាត់តាមវដ្ដៈ ៣ គឺ

១- កិលេសវដ្ដៈ បានដល់អវិជ្ជា តណ្ហា ឧបាទាន ។

២- កម្មវដ្ដៈ បានដល់ភព សង្ខារ ។

៣- វិបាកវដ្ដៈ បានដល់វិញ្ញាណ នាមរូប សឡាយតនៈ ផស្សៈ វេទនា ។

បាត់ជាមូលមាន ២ គឺ

១- អវិជ្ជា គឺមោហ: សេចក្តីវង្វេងភ្លេចមិនដឹងធម៌ ។

២- តណ្ហា គឺលោភ: សេចក្តីចង់បានក្នុងវត្ថុកាម ។

កាលបាននាំយកបដិច្ចសមុប្បាទដែលជាភូមិ ផ្ទៃ ដែលចម្រើនវិបស្សនានោះមក ហៅថា រូប និងនាម ដូចនឹងសង្ត្រោះឲ្យឃើញប្រាកដច្បាស់តទៅនេះ ៖

១- អវិជ្ជា ជានាមធម៌ ។

២- សង្ខារ ជានាមធម៌ ។

៣- វិញ្ញាណ ជានាមធម៌ ។

៤- នាមរូប ជានាមធម៌ និងរូបធម៌ ។

៥- សឡាយតន: ជានាមធម៌ និងរូបធម៌ ។

៦- ផស្ស: ជានាមធម៌ ។

៧- វេទនា ជានាមធម៌ ។

៨- តណ្ហា ជានាមធម៌ ។

៩- ឧបាទាន ជានាមធម៌ ។

១០- ភព ជានាមធម៌ ។

១១- ជាតិ ជារូបធម៌ នាមធម៌ ។

១២- ជរាមរណ: ជាអាការរបស់រូបនាម ។

អ្នកបដិបត្តិវិបស្សនា យករូបនាមជាកម្មដ្ឋាន ដឹងរូបនាម ក៏គឺដឹងបដិច្ចសមុប្បាទ លុះលះមូលគឺអវិជ្ជា តណ្ហា បានពិតហើយ ក៏បានឈ្មោះថា ជាអ្នកមានជាតិ ជរា បានអស់ហើយ ហេតុដែលសេចក្តីប្រជុំព្រមនៃហេតុបច្ច័យនោះឯង កាលអវិជ្ជារលត់ សង្ខារក៏រលត់ កាលសង្ខាររលត់ វិញ្ញាណក៏រលត់ កាលវិញ្ញាណរលត់ នាមរូបក៏រលត់ កាលនាមរូបរលត់ អាយតនៈក៏រលត់ កាលអាយតនៈរលត់ ផស្សៈក៏រលត់ កាលផស្សៈរលត់ វេទនាក៏រលត់ កាលវេទនារលត់ តណ្ហាក៏រលត់ កាលតណ្ហារលត់ ឧបាទានក៏រលត់ កាលឧបាទានរលត់ ភពក៏រលត់ កាលភពរលត់ ជាតិក៏រលត់ កាលជាតិរលត់ ជរាមរណៈក៏រលត់ កាលជរាមរណៈរលត់ហើយ មិនកើតទៀត មិនត្រូវសោយសោក ស្រែកយំ ទុក្ខកាយ ទុក្ខចិត្ត ជាបរមសុខ ។

បច្ចុប្បន្នធម៌

រូបធម៌ នាមធម៌ដែលស្ថិតនៅឲ្យពិសោធ ដែលហៅបានច្រើនន័យតាមវិបស្សនាភូមិទាំង ៦ ដូចសម្តែងហើយនោះ ប្រាកដនៅទីបច្ចុប្បន្នខណៈអាយតនៈខាងក្នុង ៦ និងអាយតនៈខាងក្រៅ ៦ មកខ្ទប់គ្នា ក្នុងអតីតកាលដែលកន្លងទៅហើយ រូបនាមរលត់ទៅហើយ ពិសោធមិនបាន ក្នុងអនាគតកាលដែលនៅមិនទាន់មកដល់ រូបនាមនៅមិនកើតឡើង ពិសោធមិនបាន នឹងពិសោធបានតែរូបនាមដែលកំពុងប្រាកដ

នៅក្នុងបច្ចុប្បន្នកាល ដែលហៅថា "បច្ចុប្បន្នធម៌" ប៉ុណ្ណោះ ដូចនឹងបានលើកមកសម្តែងឲ្យឃើញច្បាស់ក្នុងទ្វារទាំង ៦ ដូចតទៅនេះ ៖

១- **បច្ចុប្បន្នធម៌ផ្លូវភ្នែក** កើតឡើងខណៈដែលរូប គឺពណ៌មកខ្ទប់កែវភ្នែក ការឃើញក៏ប្រាកដឡើង ក្នុងអតីតកាល លុះដែលកន្ទុងទៅហើយ ឃើញរលត់ទៅហើយ ដឹងមិនបាន ចំណែកក្នុងអនាគតក៏នៅមិនឃើញដឹងមិនបាន ដឹងបានតែបច្ចុប្បន្នរបស់រូបធម៌ នាមធម៌ ខណៈឃើញប៉ុណ្ណោះ ។

២- **បច្ចុប្បន្នធម៌ផ្លូវត្រចៀក** កើតឡើងខណៈដែលសំឡេងមកខ្ទប់កែវត្រចៀក ការបានឮក៏ប្រាកដឡើង ក្នុងអតីតកាល លុះដែលកន្ទុងទៅហើយ បានឮរលត់ទៅហើយ ដឹងមិនបាន ចំណែកក្នុងអនាគតក៏នៅមិនបានឮ ដឹងមិនបាន ដឹងបានតែបច្ចុប្បន្នរបស់រូបធម៌ នាមធម៌ ខណៈបានឮប៉ុណ្ណោះ ។

៣- **បច្ចុប្បន្នធម៌ផ្លូវប្រមុះ** កើតឡើងខណៈដែលក្លិនមកខ្ទប់បសាទប្រមុះ ការដឹងក្លិនក៏ប្រាកដឡើង ក្នុងអតីតកាល លុះដែលកន្ទុងទៅហើយ ដឹងក្លិនរលត់ទៅហើយ ដឹងមិនបាន ចំណែកក្នុងអនាគតក៏នៅមិនបានដឹងក្លិន ដឹងមិនបាន ដឹងបានតែក្នុងបច្ចុប្បន្នរបស់រូបធម៌ នាមធម៌ ខណៈដឹងក្លិនប៉ុណ្ណោះ ។

៤- **បច្ចុប្បន្នធម៌ផ្លូវអណ្ដាត** កើតឡើងខណៈដែលរសមកខ្ទប់

បសាទអណ្ណាត ការដឹងរសក៏ប្រាកដឡើង ក្នុងអតីតកាល រៀលាដែល កន្ទងទៅហើយ ដឹងរសរលត់ទៅហើយ ដឹងមិនបាន ចំណែកក្នុង អនាគតក៏នៅមិនបានដឹងរស ដឹងមិនបាន ដឹងបានតែបច្ចុប្បន្នរបស់រូបធម៌ នាមធម៌ ខណៈបានរសប៉ុណ្ណោះ ។

៥- **បច្ចុប្បន្នធម៌ផ្លូវកាយ** កើតឡើងខណៈដែលគ្រឿងខ្ទប់មាន ត្រជាក់ ក្តៅ ទន់ រឹង ជាដើម មកខ្ទប់បសាទកាយ ការដឹងសម្ផស្សក៏ ប្រាកដឡើង ក្នុងអតីតកាល រៀលាកន្ទងទៅហើយ ដឹងផ្លូវកាយរលត់ទៅ ហើយ ពិសោធមិនបាន ចំណែកក្នុងអនាគតក៏នៅមិនប្រាកដសេចក្តីដឹង ទើបពិសោធមិនបាន នឹងពិសោធឲ្យដឹងបាន ក៏តែខណៈដឹងផ្លូវកាយ ដែលជាបច្ចុប្បន្នរបស់រូបធម៌ នាមធម៌ ដែលកំពុងប្រាកដនៅប៉ុណ្ណោះ ។

៦- **បច្ចុប្បន្នធម៌ផ្លូវបិត្ត** កើតឡើងខណៈដែលនឹកគិត ឬខណៈ ដែលចិត្តបង្គាប់ឲ្យរូបដើរ ឈរ អង្គុយ ដេក កង្ពុញ លាត កម្រើក អតីតកាលដែលធ្លាប់នឹក ធ្លាប់គិត រលត់ទៅហើយ ពិសោធឲ្យដឹងឲ្យ ឃើញមិនបាន នឹងដឹងបាន ក៏ចំពោះសញ្ញា សេចក្តីចាំដែលកើតឡើង ខណៈនឹកជាបច្ចុប្បន្នប៉ុណ្ណោះ ចំណែកក្នុងអនាគតដែលនៅមិនបាន នឹកគិត ក៏ពិសោធឲ្យដឹងឲ្យឃើញមិនបាន ដឹងបានតែបច្ចុប្បន្នរបស់ រូបធម៌ នាមធម៌ ដែលប្រាកដនៅខណៈនឹកគិត ខណៈឈរ ខណៈឈាន ខណៈអង្គុយ ខណៈដេក ខណៈនិយាយ ខណៈបត់ចូល-លាតចេញ

ខណៈកម្រើក ខណៈបម្រះននៀលប៉ុណ្ណោះ ។

បច្ចុប្បន្នធម៌ ស្ថិតនៅឲ្យវិបស្សនាពិសោធ ស្ថិតនៅឲ្យវិបស្សនាដឹងឃើញ ដែលជាភាវនាញាណដោយចំពោះ អ្នកប្រាថ្នានឹងចម្រើនវិបស្សនាទាំងឡាយ នឹងចោលបច្ចុប្បន្នធម៌ចេញមិនបាន ឧបមាដូចទូកដែលនឹងនាំម្ចាស់ទូកទៅកាន់កោះ ឬច្រាំងដែលជាទីដៅចុងផ្ទូវបានដូច្នោះ ។

សតិនិងមោហៈ

បច្ចុប្បន្នធម៌ដែលសម្តែងមកហើយ ជាស្នាមចម្បាំងរបស់សតិនិងមោហៈ ឧបមាដូចការសង្គ្រាម សត្រូវនិងសត្រូវ រមែងច្បាំងគ្នាក្នុងទីណា ទីនោះឈ្មោះថាស្នាមចម្បាំងដូច្នោះ វិបស្សនានឹងយកសម្មាសតិដែលជាមេទ័ពចំណែកបុណ្យ មកដឹងទាន់បច្ចុប្បន្នធម៌ជាមុនសិន មានសម្មាវាយាមោ វីរិយៈសេចក្តីព្យាយាមជាគ្រឿងឧបត្ថម្ភ មានសោភណ-ចេតសិកដទៃ ជាគ្រឿងគាំទ្រឲ្យសតិសម្ឃរ អាចយកជ័យជម្នះមោហៈ តស៊ូគ្នានឹងកន្ទែងបច្ចុប្បន្នធម៌ដូចសម្តែងតទៅនេះ ៖

១- **កាលខណៈឃើញ** សតិរព្ចកដឹងទាន់ មោហៈតួវង្វេងចូលមិនបាន កាលខណៈឃើញ មិនមានសតិដឹងទាន់ បុណ្យកុសលទាំង-ឡាយ ក៏កើតឡើងមិនបាន មានតែមោហៈ សេចក្តីវង្វេងក៏មានឡើងបាបទាំងពួងដែលជាតួអកុសលក៏ចូលមកបាន ។

២- **កាលខណៈបានឲ** សតិរព្ចកដឹងទាន់ មោហៈតួវង្វេងចូល

មិនបាន កាលខណៈបានញ សតិដឹងមិនទាន់ បុណ្យកុសលទាំងឡាយ ក៏កើតឡើងមិនបាន មានតែមោហៈ សេចក្តីវង្វេង និងបាបអកុសល ទាំងពួងកើតឡើង ។

៣- **កាលខណៈដឹងក្លិន** សតិរពុកដឹងទាន់ មោហៈតួវង្វេងចូល មិនបាន កាលខណៈដឹងក្លិន សតិដឹងមិនទាន់ បុណ្យកុសលទាំងពួង ក៏កើតឡើងមិនបាន មានតែមោហៈ សេចក្តីវង្វេង និងបាបអកុសលទាំង-ពួងប៉ុណ្ណោះ ។

៤- **កាលខណៈដឹងរស** សតិដឹងទាន់ មោហៈតួវង្វេងចូលមិនបាន កាលខណៈដឹងរស សតិដឹងមិនទាន់ មោហៈតួវង្វេង ក៏កើតមានឡើង ជាហេតុឲ្យចិត្តសៅហ្មង ។

៥- **កាលខណៈដឹងផ្ទូវកាយ** សម្ជស្សត្រជាក់ ក្តៅ ទន់ រឹង សតិដឹងទាន់ ចិត្តស្អាតបរិសុទ្ធ មោហៈតួវង្វេងចូលមិនបាន ខណៈ ដឹងផ្ទូវកាយ សតិដឹងមិនទាន់ មោហៈ សេចក្តីវង្វេង ក៏ចូលបាន ចិត្ត សៅហ្មង ។

៦- **កាលខណៈនឹកគិត** ការឈរ ដើរ អង្គុយ ដេក កង្គុញ លាត កម្រើក សតិដឹងទាន់ មោហៈសេចក្តីវង្វេងចូលមិនបាន ខណៈ ណាដឹងមិនទាន់ គឺមិនបានតាំងសតិ មោហៈសេចក្តីវង្វេងក៏បានឱកាស ចូលមកព្រមដោយអកុសលទាំងពួង ធ្វើចិត្តឲ្យសៅហ្មង ។

ដូច្នេះ អ្នកចម្រើនវិបស្សនាទាំងឡាយគប្បីផ្គងសតិ បម្រុងសតិឲ្យសម្ប្ស ដោយការខ្សប់ហ៍ព្យាយាមតាំងសតិរឿយៗ មោហៈសេចក្តីវង្វេងភ្ញេចជាសត្រូវរបស់សតិ ក៏ថយចុះបន្តិចម្តងៗ ស្រាលស្តើងតាមលំដាប់ ដរាបរលត់អស់ប្រនេះអស់ប្រេងអស់ដ៏រនោះឯង ទើបនឹងបានឈ្មោះថា ជាអ្នកមានអាសវៈអស់ហើយបាន ឧបមាដូចការបណ្តុះដើមឈើ ត្រូវខ្សប់ស្រោចទឹកជ្រួយដីជានិច្ច ដើមឈើទើបចម្រើនលូតលាស់ល្អ ចេញផ្កា ចេញផ្លែបាន បើមិនយកចិត្តទុកដាក់ស្រោចទឹកជ្រួយដី យូរៗទៅដើមឈើនោះ ក៏នឹងស្ងិតស្រពោនរញ្ជម ចម្រើនធំឡើងមិនបាន ផ្លែផ្កានឹងលេចចេញមកឲ្យឃើញមិនបានដូចម្តេច សូម្បីសតិយើងនេះ មិនខ្សប់ហ៍បំពេញជានិច្ចហើយ អាចសាបសូន្យបានដូច្នោះ ទីបំផុតក៏នឹងមាននៅតែរូបនាម ដែលសៅហ្មងដោយមោហៈ និងបាបអកុសលទាំងពួង ក្នុងទីបំផុតក៏មិនអាចដែលនឹងរួចផុតទុក្ខបានតែអ្នកណាជាអ្នកមិនប្រមាទ បំពេញសតិឲ្យពេញកដ៏ងទាន់បច្ចុប្បន្នជាប្រក្រតី អ្នកនោះឈ្មោះថា ជាអ្នកដើរផ្លូវត្រមដោយវាសនាបារមី ដែលនឹងដល់មហាសន្តិសុខបាន ។

ត្រៃលក្ខណៈ ប្រហារអនុស័យ

ធម្មតា ឆ្នូតបង្ក្ដង់ខ្ទារមែងនៅនឹងខ្ជួនខ្ជា ឃើញខ្ជា ក៏ឃើញបង្ក្ដង់ដូចម្តេច សូម្បីអ្នកចម្រើនវិបស្សនា កាលដ៏ងទាន់បច្ចុប្បន្នធម៌ លុះ

ឃើញរូបនាមរលត់ទៅច្បាស់ក៏ដូច្នោះ នឹងឃើញលក្ខណៈរបស់រូបនាម ឯណាមួយហៅថាព្រះត្រៃលក្ខណៈគឺ ៖

១- **អនិច្ចំ** មិនទៀង (តាំងនៅមិនបាន ត្រូវរលត់ទៅ)

២- **ទុក្ខំ** ធន់បានដោយក្រ (ធន់នៅមិនបាន ត្រូវរលត់ទៅ)

៣- **អនត្តា** មិនមែនខ្លួន (មិនមានអំណាច បង្ហាប់បញ្ជាមិនបាន ត្រូវរលត់ទៅ) ។

លក្ខណៈទាំង ៣ ប្រការនេះ ជាទ្រង់ទ្រាយរបស់រូបនាម ជាគ្រឿងប្រកបដ៏សំខាន់ ដែលនឹងជីកទម្លាយអនុស័យ ដែលជាតួកិលេសដែលដេកត្រាំនៅក្នុងសន្ដាន ឧបមាដូចការទម្លាយសំបុក ឬជីកឫសរបស់ដើមស្នៅដូច្នោះ ព្រោះការទម្លាយបានអស់រលីងកាលណា ក៏នឹងមិនកើតមិនចម្រើនឡើងទៀតកាលនោះ ព្រោះហេតុថា វិបស្សនាញាណចូលទៅពិសោធដ៏ងឃើញតាមសេចក្ដីពិតរបស់ខន្ធ ៥ ហើយជាបច្ច័យទម្លាយតគ្នាទៅ លុះត្រាតែអស់អនុស័យ អនុស័យដែលដេកនៅក្នុងភវង្គបានយ៉ាងណា? ត្រៃលក្ខណៈប្រហារបានយ៉ាងណា? នឹងបានសម្ដែងដូចតទៅនេះ ៖

ធម្មតារបស់អនុស័យរមែងអាស្រ័យចិត្តកើតឡើង ដូច្នេះ កិលេសដែលកើតឡើងហើយ បវត្តិ ប្រព្រឹត្តទៅតាមវិថីរបស់ចិត្ត លុះចុះទៅនៅក្នុងសន្ដានជាតួអនុស័យដូច្នេះ ។

កាលវិញ្ញាណផ្លូវភ្នែកឃើញរូប ឬកាលវិញ្ញាណផ្លូវត្រចៀកបានឮសំឡេង ឬកាលវិញ្ញាណផ្លូវច្រមុះដឹងក្លិន ឬកាលវិញ្ញាណផ្លូវអណ្តាតដឹងរស ឬកាលវិញ្ញាណផ្លូវកាយដឹងសម្ផស្ស ឬកាលវិញ្ញាណផ្លូវចិត្ត នឹកគិតបង្ហាប់ហើយរលត់ចុះ គឺជាបច្ច័យឲ្យ **សម្ឆដិបួនៈ** *ទទួលអារម្មណ៍នោះតទៅ ... ហើយរលត់ចុះ ... ជាបច្ច័យឲ្យកើត* **សន្ធ្ជីរណៈ** *ពិចារណាអារម្មណ៍នោះតទៅ ... ហើយរលត់ចុះ ... ជាបច្ច័យឲ្យកើត* **ហ្ជ្ជ្ជ្ជ្ជ**ៈ *វិនិច្ឆ័យអារម្មណ៍នោះតទៅ ... ហើយរលត់ចុះ ... ជាបច្ច័យឲ្យកើត* **ជវនៈ** *សេពអារម្មណ៍នោះតទៅ ៧ ខណៈ ហើយរលត់ចុះ ... ជាបច្ច័យឲ្យកើត* **តទាលម្ពនៈ** *ទទួលអារម្មណ៍ទុកចុះកាន់ភវង្គតទៅ ។*

ភវង្គៈ *ធ្វើនាទីមានសេចក្ដីជំនាញជាអង្គសំខាន់នៅខាងក្នុងចិត្ដតទៅ ។*

បើ **រាគៈ** *សេចក្ដីស្រឡាញ់កើតឡើង កាលវៀជ្ជ្ជ្ជ្ជ:វិនិច្ឆ័យអារម្មណ៍ណាមួយ ជវនៈនោះក៏នឹងធ្វើនាទីសេពរាគៈ និងអារម្មណ៍នោះឲ្យតទាលម្ពនៈ ទទួលអារម្មណ៍ទុកចុះកាន់ភវង្គ ទាល់តែជាសន្ដាន ហៅថា* **រាគានុស័យ** *និង* **ភវរាគានុស័យ** *កាលវិបស្សនាកើតឡើង ឃើញ* **អនិច្ចំ ទុក្ខំ អនត្ដា** *ក្នុងកាលណា កាលនោះ ជវនៈទាំង ៧ ក៏នឹងសេពត្រៃលក្ខណៈ ចប់ហើយ តទាលម្ពនៈ ក៏ទទួលអារម្មណ៍ទុកចុះកាន់ភវង្គ កាត់រាគៈមិនបន្ដជាអនុស័យតទៅ ។*

បើ **ទោសៈ** *សេចក្ដីក្រោធកើតឡើង កាលវៀជ្ជពូនៈវិនិច្ឆ័យ អារម្មណ៍ណាមួយហើយ ជវនៈក៏ទ៉ឹងធ្វើនាទីសេពទោសៈ ទ៉ឹងអារម្មណ៍ (នោះ) ហើយតទាលម្ពនៈ ទទួលអារម្មណ៍ទុកចុះកាន់ភវង្គ ទាល់តែជាសន្ដាន ហៅថា* **បដិឃានុស័យ** *កាលវិបស្សនាកើតឡើង ឃើញ* **អនិច្ចំ ទុក្ខំ អនត្តា** *កាលណា កាលនោះ ជវនៈទាំង ៧ ក៏ទ៉ឹងសេពត្រៃ-លក្ខណៈចប់ហើយ តទាលម្ពនៈ ក៏ទទួលអារម្មណ៍ទុកចុះកាន់ភវង្គ កាត់ទោសៈមិនឲ្យចូលមកជាអនុស័យទៀត ។*

បើ **ទិដ្ឋិ** *សេចក្ដីឃើញខុស* **វិចិកិច្ឆា** *សេចក្ដីសង្ស័យ* **មានៈ** *សេចក្ដីប្រកាន់ខ្លួន* **អវិជ្ជា** *សេចក្ដីមិនដឹងកើតឡើង កាលវៀជ្ជពូនៈ វិនិច្ឆ័យអារម្មណ៍ណាមួយហើយ ជវនៈទាំង ៧ ក៏ធ្វើនាទីសេពទិដ្ឋិ វិចិកិច្ឆា មានៈ អវិជ្ជា ណាមួយហើយ ឲ្យតទាលម្ពនៈ ទទួលអារម្មណ៍ទុកចុះកាន់ភវង្គទាល់តែជាសន្ដាន ហៅថា* **ទិដ្ឋានុស័យ វិចិកិច្ឆានុស័យ មានានុស័យ អវិជ្ជានុស័យ** *តាមលំដាប់ កាលវិបស្សនាកើតឡើងឃើញ* **អនិច្ចំ** *តាំងនៅមិនបាន ឬឃើញ* **ទុក្ខំ** *ធន់នៅមិនបាន ឬឃើញ* **អនត្តា** *បង្ខាំបញ្ជាមិនបាន ខណៈវៀជ្ជពូនៈវិនិច្ឆ័យអារម្មណ៍នោះហើយ ជវនៈទាំង ៧ ក៏ទ៉ឹងសេពត្រៃលក្ខណៈ ឲ្យតទាលម្ពនៈ ទទួលអារម្មណ៍ទុកចុះកាន់ភវង្គ រាំងរាទប់មិនឲ្យទិដ្ឋិ វិចិកិច្ឆា មានៈ អវិជ្ជា មកជាអនុស័យបានទៀត ។*

កាលឃើញត្រៃលក្ខណៈច្រើនប៉ុនណា អនុស័យក៏នឹងស្រាលចុះ បន្តិចម្តងៗ លុះរលត់អស់ដោយមិនត្រូវបង្អង់កាលវេលា ។

ការចម្រើនវិបស្សនា លើករូបនាមឡើងកាន់ព្រះត្រៃលក្ខណៈណាមួយ ដែលត្រូវដល់អធ្យាស្រ័យ អាសវៈដែលហូរនិងត្រាំនៅនោះ គឺ **ទិដ្ឋាសវៈ** *អាសវៈគឺទិដ្ឋិ,* **កាមាសវៈ** *អាសវៈគឺកាម,* **ភវាសវៈ** *អាសវៈគឺភព,* **អវិជ្ជាសវៈ** *អាសវៈគឺអវិជ្ជា ក៏នឹងត្រូវទម្ងាយចុះ ហើយនឹងហូរចូលមកត្រាំនៅ ដូចកាលមុនទៀតមិនបាន ក៏នឹងបន្ទោបង់ស្រាលចុះទៅខ្ងះ បន្តិចម្តងៗ ដោយអំណាចរបស់វិបស្សនាញាណលុះអស់ទៅ កាលអស់អាសវៈខណៈណា ក៏នឹងបានលុះ* **សន្តិលក្ខណៈ** *លក្ខណៈដែលស្ងប់រលត់ចាកទុក្ខទាំងពួងគឺព្រះនិញ្ចាន ដោយអាស្រ័យលំដាប់ញាណទាំង ១៦ គឺ៖*

១- **នាមរូបបរិច្ឆេទញាណ** *ញាណឃើញទាំងរូបទាំងនាម ។*

២- **នាមរូបបច្ចយបរិគ្គហញាណ** *ញាណឃើញបច្ច័យរបស់នាមរូប ។*

៣- **សម្មសនញាណ** *ញាណឃើញត្រៃលក្ខណៈរបស់រូបនាម ។*

៤- **ឧទយព្ចយញាណ** *ញាណឃើញរូបនាមទាំងកើតទាំងរលត់ ។*

៥- **ភង្គញាណ** *ញាណឃើញរូបនាមរលត់ទៅៗ ។*

៦- **ភយតូបដ្ឋានញាណ** *ញាណឃើញរូបនាមជាភ័យ ។*

៧- **អាទីនវញាណ** *ញាណឃើញរូបនាមជាទោស ។*

៨- **និព្ចិទាញាណ** *ញាណឃើញរូបនាមគួរនឿយណាយ ។*

៩- មុញ្ចិតុកម្យតាញ្ញាណ ញ្ញាណឃើញរូបនាមប្រាជ្ញានឹងរត់ឲ្យផុត ។

១០- បដិសង្ខាញ្ញាណ ញ្ញាណឃើញរូបនាមរិះរកផ្លូវរត់ ។

១១- សង្ខារូបេក្ខាញ្ញាណ ញ្ញាណឃើញរូបនាមតាមពិត ថារត់មិនផុត ទើបព្រងើយកន្ដើយ ។

១២- អនុលោមញ្ញាណ ញ្ញាណឃើញរូបនាមតាមកម្លាំងកិច្ចក្នុង អរិយសច្ចលើសឡើង ។

១៣- គោត្រភូញ្ញាណ ញ្ញាណធ្លងគោត្រគោងយកព្រះនិញ្ជាន ។

១៤- មគ្គញ្ញាណ ញ្ញាណឃើញព្រះនិញ្ជាន ១ ខណៈ ។

១៥- ផលញ្ញាណ ញ្ញាណឃើញព្រះនិញ្ជាន ២-៣ ខណៈ ។

១៦- បច្ចវេក្ខណាញ្ញាណ ញ្ញាណឃើញមគ្គ ផល និញ្ជាន និង កិលេសដែលសល់ ។

(ត្រៃលក្ខណៈប្រហារអនុស័យចប់)

ពោលអំពីសមថយានិកៈ

ការអស់អាសវកិលេស ដល់សន្ទិលក្ខណៈនោះ មានអ្នកចម្រើនធ្វើឲ្យបានលុះបាន ២ ជំពូកគឺ ៖

១- **សមថយានិកៈ** *អ្នកកាន់សេចក្តីស្ងប់ជាគ្រឿងនាំជំពូក ១ បើជាព្រះអរហន្តហៅថា "ឈានលាភីបុគ្គល" ផុតដោយចេតោវិមុត្តិ ។*

២- **វិបស្សនាយានិកៈ** *អ្នកកាន់សេចក្តីឃើញច្បាស់ជាគ្រឿងនាំជំពូក ១ បើជាព្រះអរហន្ត ហៅថា* **"សុក្ខវិបស្សកៈ"** *ផុតដោយបញ្ញាវិមុត្តិ ។*

សមថយានិកៈ *នោះ ត្រូវធ្វើចិត្តឲ្យស្ងប់ដោយអំណាចនៃឈានមុនហើយ លើកឈានឡើងកាន់វិបស្សនាខាងក្រោយ ដោយនាំយកកម្មដ្ឋាន ៤០ មកជាអារម្មណ៍ កម្មដ្ឋានណាមួយ ។ ព្រះពុទ្ធអង្គទ្រង់បំណងឲ្យសមគួរដល់ចរិត ព្រោះកាលគួរដល់ចរិតហើយ ក៏សម្រេចបានងាយនិងរហ័ស ។*

ចរិត *គឺសេចក្តីប្រព្រឹត្តរបស់សត្វលោកមាន ៦ ប្រការ អាស្រ័យគោលសង្កេត ៥ យ៉ាងគឺ ៖*

១- **សង្ខេតកិរិយា** *គឺកិរិយាមារយាទ ។*

២- **សង្ខេតកិច្ច** *គឺធុរៈការងារដែលធ្វើ ។*

៣- **សង្ខេតភោជនៈ** *គឺរសអាហារដែលគាប់ចិត្ត ។*

៤- **សង្កេតទស្សនៈ** គឺសេចក្តីគិតឃើញ ។

៥- **សង្កេតធម្មបវត្តិ** គឺសេចក្តីប្រព្រឹត្តទៅក្នុងធម៌ ។

ដោយការប្រជុំព្រមនៃគោលសង្កេតនេះ ទើបអាចនឹងអានចរិតរបស់បុគ្គលបានដូចតទៅនេះ ៖

១- **រាគបរិត** មាន **ឥរិយាបថ** រៀបរយ មាន **កិច្ច** សង្រួមក្នុងការប្រុងតែង ធ្វើអ្វីមិនទៀងទាត់ ចាប់នោះ ចាប់នេះ មិនឆ្ពោះត្រង់ណា **ភោជនៈ** ចូលចិត្តអាហាររសក្រអូបផ្អែមគួរទទួលទាន **ទស្សនៈ** ចូលចិត្តមើលរបស់ដែលល្អស្រស់ **ធម្មបវត្តិ** ល្អិតល្អក្និកក្នក់ មានមាយាសាថេយ្យៈ មានលោភច្រើន ។

២- **ទោសបរិត** មាន **ឥរិយាបថ** រហ័ស រឹងរូស ទៅទទឹងទទែង មាន **កិច្ច** បំណងតែក្នុងរបស់ដែលប្រាថ្នា មិនត្រូវការសង្រួម មាន **ភោជនៈ** ចូលចិត្តអាហារជូរៗ មាន **ទស្សនៈ** ចូលចិត្តមើលការផ្ចាញ់ភ័យមានដាល់តប់ជាដើម មាន **ធម្មបវត្តិ** ចាយវាយខ្ជីខ្ជាអស់ប៉ុន្មានមិនថាក្រោធងាយ ចងអាឃាត អ្នកធំប្រដៅក្រ ។

៣- **មោហបរិត** មាន **ឥរិយាបថ** យឺតយូរ ទម្រន់ មាន **កិច្ច** ធ្វើឲ្យហើយ ក៏មិនដឹងថាធ្វើទៅយ៉ាងណា ឬទៅដាក់ទុកទីណា ទទីមទទាមកំណត់ធ្វើ ៣ ម៉ោង ទៅជា ៥ ម៉ោង ទើបហើយ មាន **ភោជនៈ** អាហារយ៉ាងណាមិនថា ចូលចិត្តទទួលទានទាំងអស់ អ្នកណាឃើញល្អ ល្អផង

អ្នកណាឃើញមិនល្អ មិនល្អផង មាន **ធម្មបវិត្ត** *គឺបីនមិទ្ធ: ដោកងក់ ងុយដេក មិនជារឿងរ៉ាវអ្វី ។*

៤- **សទ្ធាបរិត** *មាន* **ឥរិយាបថ** *សុខុម ទ៏មនួន* មាន **កិច្ច** *ខ្ទ ល់ ខ្ទាយក្នុងការបុណ្យការកុសល* មាន **ភោជន:** *ចូលចិត្តអាហារមានរស ផ្អែម ឆ្ងាញ់ និងក្រអូប* មាន **ទស្សន:** *ចូលចិត្តក្នុងអារម្មណ៍ដែលល្អ* មាន **ធម្មបវិត្ត** *រីករាយនៅក្នុងការបុណ្យ បំណងនៅក្នុងសទ្ធា ជឿជ្រះថ្លា* មាន *ចេតនាល្អ ។*

៥- **វិតក្ខបរិត** *មាន* **ឥរិយាបថ** *មិនរៀបរយ* មាន **កិច្ច** *ការងារ មិនជាលក្ខណៈមាំទាំ* មាន **ភោជន:** *រសអាហារមិនទ៏ងន* មាន **ទស្សន:** *ឃើញតាមពួកច្រើន* មាន **ធម្មបវិត្ត** *សេចក្ដីគិតរាយមាយ ។*

៦- **ពុទ្ធិបរិត** *មាន* **ឥរិយាបថ** *រហ័សរហួន* មាន **កិច្ច** *ការងារធាប់ យល់ ចូលចិត្តងាយ* មាន **ភោជន:** *ចូលចិត្តរសជូរ ប្រៃ ល្វីង ហ៊ីរ និង អាហារដែលមិនមានទោស* មាន **ទស្សន:** *ចូលចិត្តមើលដោយប្រើបញ្ញា ពិចារណា* មាន **ធម្មបវិត្ត** *ចូលចិត្តស្វែងរកសេចក្ដីដ៏ង ប្រើខន្ធ សេចក្ដី អត់ធន់ដោយបញ្ញារកហេតុ-ផល ចូលចិត្តប្រកបក្នុងការធ្វើកុសល ។*

កាលបុគ្គលណាមានចរិតយ៉ាងណា តាមក្រោយគោលសង្ខេតនេះ ហើយ ក៏ទ្រង់ប្រទានកម្មដ្ឋាន ៤០ ប្រភេទណាមួយ ឲ្យសមគួរដល់ចរិត ដើម្បីធ្វើសេចក្ដីព្យាយាមឲ្យកើតសមាធិ មានសេចក្ដីស្ងប់ចិត្តហើយលើក

ឡើងកាន់វិបស្សនាតទៅ ដូចនឹងសម្តែងតួយ៉ាងតទៅនេះ ៖

ពួកកសិណ ១០

១- **បឋវីកសិណ** ជាកម្មដ្ឋានដែលសាធារណៈដល់ចរិតទាំង ៦ ដោយការយកដីមកធ្វើជារូបវង់មូល ល្មមសមគួរដល់ខ្យែភ្នែកដែលនឹងមើល ហើយសម្ងឹងបរិកម្មថា "ដីៗ" លុះភាពដីនោះ ប្រាកដជិតជាប់ភ្នែកជាប់ចិត្តធ្មេចក៏ឃើញដូចបើកភ្នែក ហៅថា **ឧគ្គហនិមិត្ត** ហើយសម្ងឹងពង្រីកឲ្យធំឬតូច បានតាមត្រូវការ ហៅថា **បដិភាគនិមិត្ត** លុះវិធីសម្ងឹងយូរជាប់ប្រាកដមានពណ៌ក្រហមល្អស្រស់ ដូចកញ្ចក់ ជា **ឧបចារសមាធិ** សម្ងឹងយូរ ដោយបង្ខឹកឲ្យជាអង្គឈានគឺ **វិតក្ក:** នឹកដល់ដីកម្មដ្ឋាន, **វិចារ:** ផ្តង់ឲ្យដឹងចំពោះដីប៉ុណ្ណោះ, **ปีติ** ផ្ទែតចិត្ត ស្រួលចិត្តក្នុងអារម្មណ៍ដីនោះ, **សុ១** គឺសប្បាយចិត្ត ស្អាតចិត្តក្នុងអារម្មណ៍ដីនោះ, **ឯកគ្គតា** ដឹងចំពោះដីនោះនៅព្រងើយៗ រំលត់ចាកអារម្មណ៍ដទៃអស់ ជា **អប្បនាសមាធិ** មានសមាធិមាំមួនមិនញាប់ញ័រ ហៅថា **បឋមជ្ឈាន**, កាលនៅនឹងបឋវីកសិណសម្ងឹងដី លុះមិនត្រូវអាស្រ័យ**វិតក្ក:** ត្រិះរិះនឹកដល់ លះ**វិតក្ក:**ចេញបានឈានឡើងកាន់ **ទុតិយជ្ឈាន**, កាលសម្ងឹងដីទៅ លុះមិនត្រូវផ្តង់ចិត្តឲ្យដឹងអារម្មណ៍ដីនោះហើយ ក៏នឹងលះ**វិចារ:** ឈានឡើងកាន់ **ตติยជ្ឈាន**, កាលសម្ងឹងដីទៅ លុះលះ**ปีติ**សេចក្តីផ្ទែតចិត្តចេញបាន សល់តែ**សុ១** និង **ឯកគ្គតា**ក៏ឈ្មោះថាឈាន

ឡើងកាន់ **បតុត្ថជ្ឈាន**, លុះលះសុខបាន មាន ឧបេក្ខា និងឯកគ្គតាមាំមួន នៅនឹងបឋវីកសិណនោះ ឈ្មោះថាឈានឡើង កាន់ **បញ្ចមជ្ឈាន** យ៉ាងនេះចាត់ជា **សមថ:** សូប់ចាកនីវរណៈទាំងពួងគឺ **កាមច្ឆន្ទ:** សេចក្តីពេញចិត្តក្នុងកាមមិនកើតឡើង, **ព្យាបាទ** សេចក្តីព្យាបាទមិនកើតឡើង **ថីនមិទ្ធ:** សេចក្តីងោកងក់ងុយដេកមិនកើតឡើង, **ឧទ្ធច្ច:** **កុក្កុច្ច:** សេចក្តីរាយមាយរំខានចិត្តមិនកើតឡើង, **វិចិកិច្ឆា** សេចក្តីសង្ស័យមិនកើតឡើង មានចិត្តសូប់សុងចុះហើយកាន់អារម្មណ៍បឋវីកសិណជាបាទ ដែលនឹងឲ្យលើកឡើងកាន់វិបស្សនាបាន បើអ្នកចម្រើនសមថកម្មដ្ឋាននេះ ទៅចូលចិត្តក្នុងអារម្មណ៍ ជាប់ចិត្តនៅ មានតណ្ហាចូលទៅអាស្រ័យនៅ ក៏នឹងជាប់នៅត្រឹមនោះឬសម្ភាល់ខុសថា ដែលភ្ជឺស្វាងកើតចាកសម្ជឹងដី ទាល់តែជាអប្បនាសមាធិនោះជាទីបំផុតហើយ មិនចម្រើនវិបស្សនាដើម្បីឲ្យច្បាស់នូវព្រះនិញ្វានហើយ ក៏នឹងបានឈ្មោះថា ជាអ្នកនៅក្នុងវដ្ត: ជាអ្នកមានព្រហ្មលោកជាទីទៅ សូន្យឈានចាកព្រហ្ម និងអរូបព្រហ្មហើយ ក៏ត្រឡប់មកកើតជាទេវតាឬមនុស្សទៀត មកធ្វើអាក្រក់ ក៏នឹងឲ្យកើតក្នុងអបាយទៀត ដូច្នេះ ទើបជាការចាំបាច់ដល់អ្នកធ្វើឈានទាំងឡាយ នឹងត្រូវលើកឈានឡើងកាន់វិបស្សនា ឃើញរូបនាមក្នុងអង្គឈាននោះ ជា **អនិច្ចំ ទុក្ខំ អនត្តា** ដែលជាលក្ខណៈរបស់មហគ្គតចិត្តគឺចិត្តដែលបានឈាន ព្រោះថា អង្គឈាននោះជា **នាមខន្ធ** ដែល

សង្ត្រោះដូច្នេះ ៖

វិតក្ក: ជាសង្ខារក្ខន្ធ គឺនាមធម៌ ។

វិចារ: ជាសង្ខារក្ខន្ធ គឺនាមធម៌ ។

បីតិ ជាសង្ខារក្ខន្ធ គឺនាមធម៌ ។

សុខ ជាវេទនាខន្ធ គឺនាមធម៌ ។

ឯកគ្គតា ជាសង្ខារក្ខន្ធ គឺនាមធម៌ ។

ចិត្តដែលអង្គឈានទាំង ៥ ប្រកប ជា **វិញ្ញាណក្ខន្ធ** គឺនាមធម៌, សេចក្តីចាំអារម្មណ៍បឋវីកសិណជាដើមជា **សញ្ញាខន្ធ** ជានាមធម៌, ហទយ-វត្ថុរូបជា **រូបក្ខន្ធ** គឺរូបនាម ចំណែកបឋវីកសិណនោះ ជាបញ្ញត្តិអារម្មណ៍ មិនមែន រូបនាម ។

ព្រោះដូច្នោះ កាលនឹកដល់ដី រូបនាមក៏កើតឡើង កាលឈប់នឹកដល់ដី រូបនាមក៏រលត់ទៅ ជា **អនិច្ចំ** តាំងនៅមិនបាន ជា **ទុក្ខំ** ធន់ទ្រាំនៅមិនបាន ជា **អនត្តា** បង្គាប់បញ្ជាមិនបានដូច្នេះ កាលវិបស្សនាពិចារណាលុះមានញាណកើតឡើងតាមលំដាប់ទាំង ១៦ ញាណហើយ អស់អាសវកិលេស មានព្រះនិញ្ចានជាអារម្មណ៍ បានទទួលឆាយាថាជា **សមថយានិក:** អ្នកមានសេចក្តីស្ងប់ជាគ្រឿងនាំទៅ ជាព្រះអរិយ-បុគ្គលប្រភេទឈានលាភីបុគ្គល (មានបឋវីកសិណទាំងពួងជាកម្មដ្ឋាន អាចជ្រែកដីបាន ផ្ទូវវែងធ្វើឲ្យខ្ងីបាន ផ្ទូវខ្ងីធ្វើឲ្យវែងបាន និម្មិតវត្ថុផ្សេងៗ

បាន ដូចភ្នំ ព្រៃ ឈើ ស្រុក ប្រាសាទជាដើម) ។

២- **អាបោកសិណ** *សម្ងឹងទឹកទាំងពួងជាអារម្មណ៍កម្មដ្ឋាន ដោយនាំយកទឹកដ៏ថ្លាស្អាតមកសម្ងឹងថា* **"ទឹកៗ"** *សមគួរដល់ចរិតគ្រប់ចរិត សម្ងឹងលុះកើតឧគ្គហនិមិត្តជាប់ភ្នែក ទាំងធ្មេចភ្នែក និងបើកភ្នែក ក៏ឃើញទឹកនោះដូចគ្នា លុះកើតបដិភាគនិមិត្ត សម្ងឹងឲ្យធំបាន តូចបានតាមចិត្តប្រាថ្នាបរិកម្មថា* **"ទឹកៗ"** *ទៅ លុះកើត ឧបចារសមាធិ មានសមាធិដិតនឹងជាឈានបាន លុះដល់អប្បនាសមាធិ មានសមាធិមាំមួន កើតអង្គឈានប្រហារនីវរណៈ ឡើងអនុលោមទៅគោត្រភូ ឆ្លងចាកកាម-គោត្រកាន់បឋមជ្ឈានបានមាន* **វិតក្ក:** *ប្រហារ* **ថីនមិទ្ធ:,** **វិចារ:** *ប្រហារ* **វិបិកិច្ឆា,** **បីតិ** *ប្រហារ* **ឧទ្ធច្ច:** **កុក្កុច្ច:,** **សុឧ** *ប្រហារ* **ញ្ញាបាទ,** **ឯកគ្គតា** *ប្រហារ* **កាមច្ឆន្ទ:** *នៅជានិច្ច បង្វឹកឈានដែលហៅថា* **ឈានកីឡា** *លុះជា* **វសី** *គឺសេចក្តីស្ទាត់ជំនាញ បានដល់* **អាវជ្ជនវសិតា** *ជំនាញក្នុងការនឹកឃើញអាបោកសិណ រ៉ាងវៃរហ័សរហួនភ្លាមក្នុងគ្រានឹក ។* **សមាបជ្ជនវសិតា** *ជំនាញក្នុងការចូលឈានបានត្រង់តាមវេលាដែលត្រូវការ* **អធិដ្ឋានវសិតា** *ជំនាញក្នុងការតម្កល់ឈាន បង្គាប់មិនឲ្យភវង្គកើតតាមសេចក្តីត្រូវការក្នុងវេលាអធិដ្ឋានទុក* **វុដ្ឋានវសិតា** *ជំនាញក្នុងការចេញចាកឈាន វេលាណាក៏អាចចេញបានភ្លាម មិនត្រូវបង្អង់វេលា* **បច្ចវេក្ខណវសិតា** *ជំនាញក្នុងការពិចារណាអង្គឈាន លុះកន្លង*

បឋមជ្ឈាន កន្ធ៦ទុតិយជ្ឈាន កន្ធ៦តតិយជ្ឈាន កន្ធ៦ចតុត្ថជ្ឈាន ទៅដល់បញ្ចមជ្ឈាន តាមវិសីដែលលះអង្គឈានទៅតាមលំដាប់ អ្នកឃើញ ភ័យក្នុងវដ្ដ: មិនត្រេកអរនៅតែត្រឹមប៉ុណ្ណោះ ព្យាយាមរកផ្លូវចម្រើន វិបស្សនាតទៅ ដោយលើករូបនាមក្នុងអង្គឈានឡើងកាន់ព្រះត្រៃ-លក្ខណៈ គឺនឹកដល់ទឹក រូបនាមកើតឡើង ឈប់នឹក រូបនាមរលត់ទៅ មិនទៀង ធន់ទ្រាំនៅមិនបាន បង្ការ៉ាប់ចាញ្ជាមិនបាន ឃើញច្បាស់តាម សេចក្ដីពិត មានញាណ ១៦ ប្រាកដឡើងតាមលំដាប់ លុះឆ្លងចាកគោត្រ ចូលជួនទៅកាន់អរិយគោត្រ បានព្រះនិព្វានជាអារម្មណ៍ ជាព្រះអរិយ-បុគ្គលប្រភេទឈានលាភីបុគ្គល (មានអាបោកសិណជាកម្មដ្ឋាន អាចដើរ លើទឹកជ្រៃកទឹកបាន ធ្វើឲ្យភ្ញៀងធ្លាក់ និម្មិត ស្ទឹង មហាសមុទ្រ ធ្វើ ឲ្យទឹកហូរចេញចាកកាយ ធ្វើឲ្យភ្នំ ដី ព្រៃ ឈើ ក្រមើកញ៉ាវបាន ធ្វើ ដីជាទឹក ធ្វើទឹកជាដីបាន) ។

៣- **តេជោកសិណ** យកភ្លើងមកជាកម្មដ្ឋាន ធ្វើបានគ្រប់ចរិត ដោយការនាំយកដួងភ្លើងមកសម្ងឹង ឬចោះជាប្រហោងតូចៗ ល្មមឲ្យ ឃើញពន្ធឺភ្ជ្ជីហើយបរិកម្មថា "ភ្លើងៗ" រហូតទាល់តែកើតឧគ្គហ-និមិត្តជាប់ភ្នែក ឃើញច្បាស់ទាំងធ្មេចភ្នែក និងបើកភ្នែក បរិកម្មទៅ រហូតទាល់តែកើតបដិភាគនិមិត្តពង្រីកឲ្យធំបាន តូចបាន តាមអំណាច របស់បរិកម្ម ទាល់តែជាឧបចារសមាធិមានសមាធិធ្ងន់ ។ ជិតជាអង្គ

ឈាន សម្ធឹងទៅៗ ទាល់តែជាអប្បនាសមាធិមាំមួន មានអង្គឈាន ចូលប្រកប សង្កត់នីវរណៈមិនឲ្យកើតបានឡើយ បង្ហឹកលុះជាវសី ជំនាញ កន្ទងបឋមជ្ឈាន កន្ទងទុតិយជ្ឈាន កន្ទងតតិយជ្ឈាន កន្ទង ចតុត្ថជ្ឈាន ដល់បញ្ចមជ្ឈានតាមលំដាប់ អ្នកឈ្វាសរមែងមិនជាប់នៅ ត្រឹមប៉ុណ្ណោះ រមែងចម្រើនវិបស្សនាតទៅ លើរូបធម៌ នាមធម៌ក្នុងអង្គ ឈានឡើងកាន់ព្រះត្រៃលក្ខណៈ លុះមានញាណចូលទៅដឹងឃើញថា នឹកដល់ក្ងើង រូបនាមកើត ឈប់នឹកដល់ក្ងើង រូបនាមរលត់ ជា **អនិច្ចំ** មិនទៀង ជា **ទុក្ខំ** ធន់ទ្រាំនៅមិនបាន ជា **អនត្តា** បង្ខាំបញ្ជាមិន បានលុះកន្ទងញាណ ១៦ ទៅ អស់អាសវៈ ឆ្ងងចាកគោត្របុថុជ្ជនទៅ កាន់អរិយគោត្រ មានព្រះនិញ្ជានជាអារម្មណ៍ ជាព្រះអរិយៈប្រភេទឈាន-លាភីបុគ្គល (មានតេជោកសិណជាកម្មដ្ឋាន អាចធ្វើឲ្យក្ងើងចេញចាក កាយ ធ្វើឲ្យក្ងើងនេះ ធ្វើឲ្យផ្ទៃងហុយចេញ ធ្វើឲ្យក្តៅ ធ្វើឲ្យមនុស្ស ដទៃអស់កម្ចាំង ធ្វើឲ្យពន្ធឹកើតឡើងទូទៅទាំងលោក កាលស្ងាប់ធ្វើឲ្យ ក្ងើងនេះសពរបស់ខ្លួនឯងបាន) ។

៤- **វាយោកសិណ** យកខ្យល់មកជាកម្មដ្ឋាន សមគួរដល់ចរិត ទូទៅ ដោយការសម្ធឹងយកការកម្រើករបស់ខ្យល់ដែលមកប៉ះវត្ថុ ឬ ដើមឈើស្ងឹកឈើ ឈើកម្រើក ហើយបរិកម្មថា "**ខ្យល់ៗ**" រហូត ទាល់តែកើតឧគ្គហនិមិត្ត ខ្យល់ប្រាកដទាំងធ្មេចភ្នែកបើកភ្នែក បរិកម្ម

ទៅរហូតទាល់តែកើតបដិភាគនិមិត្ត ឲ្យខ្យល់ធំបាន តូចបាន ទាល់តែ ជាឧបចារសមាធិ មានសមាធិជិតភាពជាឈាន សម្ងឹងខ្យល់ទៅលុះ មាំទាំជាអប្បនាសមាធិ មានអង្គឈានចូលប្រកប សង្កត់នីវរណៈទុក បាន បង្វឹកទាល់តែជាវសីជំនាញ កន្ងងបឋមជ្ឈាន កន្ងងទុតិយជ្ឈាន កន្ងងតតិយជ្ឈាន កន្ងងចតុត្ថជ្ឈាន និងបញ្ចមជ្ឈានទៅរហូត លោកជា បណ្ឌិតមិនក្រាញនៅត្រឹមប៉ុណ្ណោះ ចម្រើនវិបស្សនាតទៅ ដោយយករូប នាមក្នុងអង្គឈាន លើកឡើងកាន់ព្រះត្រៃលក្ខណៈ មានញាណចូល ទៅដឹងឃើញថា កាលនឹកដល់ខ្យល់ រូបនាមកើត កាលឈប់នឹកដល់ ខ្យល់ រូបនាមរលត់ ឃើញមិនទៀង ជាទុក្ខ ជាអនត្តា នៅដូច្នោះ លុះកន្ងងញាណ ១៦ ទៅ ឆ្ងងចាកគោត្របុថុជ្ជនទៅកាន់អរិយគោត្រ មានព្រះ និញ្ចានជាអារម្មណ៍ ជាព្រះអរិយៈប្រភេទឈានលាភីបុគ្គល (មានវាយោ-កសិណជាកម្មដ្ឋាន អាចធ្វើឲ្យខ្យល់កើត ធ្វើឲ្យខ្យល់ឈប់បានភ្ងាម ទៅលើខ្យល់បានរហ័សដូចខ្យល់គ្រប់យ៉ាងបាន វត្ថុដែលមានទម្ងន់ ធ្វើ ឲ្យស្រាលបាន ដែលស្រាល ធ្វើឲ្យធ្ងន់បាន) ។

៥- **នីលកសិណ** ធ្វើកសិណពណិខៀវជាកម្មដ្ឋាន សមគួរ ដល់បុគ្គលអ្នកមានទោសចរិត ដោយនាំពណិខៀវមកសម្ងឹង ប្រហែល បឋវីកសិណ ឬ នឹងសម្ងឹងពណិខៀវរបស់ស្ងឹកឈើក៏បាន ហើយអង្គុយ ខាត់សមាធិ ជើងស្តាំសង្កត់ជើងឆ្វេង តាំងកាយឲ្យត្រង់ តាំងសតិកំណត់

ដ៏ង សម្ងឹងនីលកសិណបរិកម្មថា "ខៀវៗ" ទៅ រហូតទាល់តែ
កើតឧគ្គហនិមិត្តជាប់ភ្នែកឃើញច្បាស់ទាំងបិទភ្នែក និងបើកភ្នែក បរិកម្ម
សម្ងឹងទៅរហូតទាល់តែកើតបដិភាគនិមិត្ត ពង្រីកឲ្យធំបាន តូចបាន
ទាល់តែចូលដល់ឧបចារសមាធិ ជិតដល់ភាពជាឈាន សម្ងឹងតទៅ
លុះដល់អប្បនាសមាធិ អង្គ្គឈានចូលប្រកបសម្ងូរ សង្កត់នីវរណៈទុក
បាន ធ្វើទាល់តែជាវសីជំនាញ កន្ទ្ងបឋមជ្ឈាន កន្ទ្ងទុតិយជ្ឈាន កន្ទ្ង
តតិយជ្ឈាន កន្ទ្ងចតុត្ថជ្ឈាន លុះដល់បញ្ចមជ្ឈានតាមលំដាប់ កាលដល់
ទីបំផុតនៃឈានដូច្នេះ លោកជាអ្នកប្រាជ្ញមិនគប្បីក្រាញនៅត្រឹមប៉ុណ្ណោះ
ដោយចម្រើនវិបស្សនាតទៅ គឺលើកយករូបនាមក្នុងអង្គ្គឈានឡើងកាន់
ព្រះត្រៃលក្ខណៈ លុះឃើញច្បាស់ថា ទឹកដល់ពណ៌ខៀវ រូបនាមកើត
ឈប់ទឹកដល់ពណ៌ខៀវ រូបនាមរលត់ មានគតិមិនទៀងជាលក្ខណៈ
មានទុក្ខធន់ទ្រាំនៅមិនបានជាលក្ខណៈ មានអនត្តាបង្ក្រាប់បញ្ជាមិនបានជា
លក្ខណៈ មានញាណកើតឡើងតាមលំដាប់ញាណ ១៦ ឆ្ងងចាកគោត្រ
បុថុជ្ជនទៅកាន់អរិយគោត្រ បិទទ្វារអបាយទាំង ៤ ដល់ក្រសៃព្រះនិញ្ជាន
មានព្រះនិញ្ជានជាអារម្មណ៍ ចិត្តរមែងខ្ចិនទៅ បង្ហ្ងានទៅ ហូរទៅកាន់ព្រះ
និញ្ជានប៉ុណ្ណោះ បានឈ្មោះថាជាព្រះអរិយៈប្រភេទឈានលាភីបុគ្គល
(មាននីលកសិណជាកម្មដ្ឋាន អាចធ្វើឲ្យស្ម្ងីពណ៌ខៀវចេញចាកកាយ
ធ្វើឲ្យលោកងងឹត រ្ងុតផ្ទ្ងៃៗ ធ្វើឲ្យជាពណ៌ខៀវបានទាំងអស់) ។

៦- **បីតកសិណ** ធ្វើកសិណពណ៌មាស ឬពណ៌លឿង សមគួរដល់បុគ្គលដែលមានទោសចរិត ដោយការនាំយកពណ៌លឿងរបស់វត្ថុណាៗ ក៏បាន ឬនឹងសម្លឹងពណ៌មាសព្រះពុទ្ធរូបក៏បាន សម្លឹងបរិកម្មថា "លឿងៗ" រហូតទាល់តែកើតឧគ្គហនិមិត្តជាប់ភ្នែក ទាំងធ្មេចភ្នែក ទាំងបើកភ្នែក បរិកម្មសម្លឹងតទៅទាល់តែជាបដិភាគនិមិត្ត ពង្រីកឲ្យធំបាន តូចបាន សម្លឹងតទៅលុះចូលដល់ឧបចារសមាធិ ជិតដល់ភាពជាឈាន សម្លឹងតទៅលុះជាអប្បនាសមាធិមាំទាំ ជាឯកគ្គតាតែមួយ អង្គឈានចូលប្រកប សង្កត់នីវរណៈទុកបាន ធ្វើទាល់តែជាវសីជំនាញ លុះកន្លងបឋមជ្ឈាន ទុតិយជ្ឈាន តតិយជ្ឈាន ចតុត្ថជ្ឈាន រហូតទៅដល់បញ្ចមជ្ឈានតាមលំដាប់ មិនទម្រន់នៅត្រឹមប៉ុណ្ណោះ ចម្រើនតទៅ ដោយលើកយករូបនាមក្នុងអង្គឈានឡើងកាន់ព្រះត្រៃលក្ខណៈ លុះឃើញជាក់ច្បាស់ថាកាលនឹកដល់ពណ៌លឿង រូបនាមកើត ឈប់នឹក រូបនាមរលត់ ដែលជារូបនាមផ្លូវចិត្ត ឃើញលក្ខណៈមិនទៀង ធន់ទ្រាំនៅមិនបាន បង្គាប់បញ្ជាមិនបាន យ៉ាងនេះកន្លងញាណ ១៦ ឆ្លងចាកគោត្របុថុជ្ជនទៅកាន់អរិយៈជាអ្នកសម្រេចមគ្គផលដោយសមថយានិកៈ ជាព្រះអរិយបុគ្គលប្រភេទឈានលាភីបុគ្គល (មានបីតកសិណជាកម្មដ្ឋាន អាចធ្វើរស្មីពណ៌លឿងពណ៌មាសចេញចាកកាយ ធ្វើឲ្យវត្ថុផ្សេងៗ សម្រេចជាមាសបាន) ។

៧- **លោហិតកសិណ** ធ្វើកសិណពណ៌ក្រហម សមគួរដល់អ្នក

ដែលមានទោសចរិត ដោយនាំយកវត្ថុពណ៌ក្រហម ឬសំពត់ក្រហមមក បរិកម្មថា "ក្រហមៗ" ទាល់តែកើតឧគ្គហនិមិត្តជាប់ភ្នែក ទាំងបើកភ្នែក ទាំងបិទភ្នែក បរិកម្មតទៅទាល់តែកើតបដិភាគនិមិត្ត ពង្រីកឲ្យធំបាន តូចបានលុះជាឧបចារសមាធិ នឹងនជាអារម្មណ៍មួយ មានអង្គឈាន ចូលប្រកបលុះសម្ឃូរ សង្កត់នីវរណៈបាន ធ្វើទាល់តែជាវសីជំនាញ លុះកន្ងងបឋមជ្ឈាន ទុតិយជ្ឈាន តតិយជ្ឈាន ចតុត្ថជ្ឈាន លុះដល់ បញ្ចមជ្ឈាន ហើយលើករូបនាមក្នុងអង្គឈានឡើងកាន់ព្រះត្រៃលក្ខណៈ ជាវិបស្សនាតទៅ លុះឃើញជាក់ច្បាស់ថា នឹកដល់របស់ក្រហម រូបនាម កើត ឈប់នឹក រូបនាមរលត់ជា **អនិច្ចំ ទុក្ខំ អនត្តា** លុះកន្ងងញាណ ១៦ ឆ្ងងចាកគោត្របុថុជ្ជនទៅកាន់អរិយៈ ឈ្មោះថា **សមឋយានិកៈ** ជាព្រះ អរិយៈប្រភេទឈានលាភីបុគ្គល (អាចធ្វើឲ្យរស្មីមានពណ៌ក្រហមចេញ ចាកកាយ និម្មិតកែវមណីទាំងវត្ថុផ្សេងៗ ឲ្យជាវត្ថុក្រហមបាន) ។

៨- **ឱទាតកសិណ** ធ្វើកសិណពណ៌ស សមគួរដល់អ្នកមាន ទោសចរិត ដោយនាំវត្ថុពណ៌សស្អាតមក ឬសំពត់សក៏បាន បរិកម្មថា "សៗ" ទាល់តែកើតឧគ្គហនិមិត្តជាប់ភ្នែក បរិកម្មទៅទាល់តែកើត បដិភាគនិមិត្តពង្រីកឲ្យធំបាន តូចបាន លុះជាឧបចារសមាធិ មាន សមាធិនឹងនតែមួយ មានអង្គឈានចូលប្រកប សង្កត់នីវរណៈទុកបាន ធ្វើទាល់តែជាវសីជំនាញ កន្ងងបឋមជ្ឈាន ទុតិយជ្ឈាន តតិយជ្ឈាន

ចតុត្ថជ្ឈាន និងបញ្ចមជ្ឈានតាមលំដាប់ ហើយចម្រើនវិបស្សនាតទៅ ដោយយករូបនាមគឺអង្គឈានឡើងកាន់ត្រៃលក្ខណ: ឲ្យឃើញជាក់ច្បាស់ ថា នឹកដល់ពណិស រូបនាមកើត ឈប់នឹក រូបនាមរលត់ ញាណ កើតឡើងតទៅ រហូតដល់ ១៦ ញាណ ឆ្ងងចាកគោត្របុថុជ្ជនទៅកាន់ អរិយ: មានព្រះនិញ្ចានជាអារម្មណ៍ ឈ្មោះថាសមថយានិក: ជាព្រះ អរិយ:ប្រភេទឈានលាភីបុគ្គល (មានឱទាតកសិណជាកម្មដ្ឋាន អាចធ្វើ ឲ្យរស្មីពណិសចេញចាកកាយ និម្មិតប្រាក់ កម្ចាត់សេចក្តីងងឹតរបស់លោក បាន ធ្វើឲ្យពន្ធឺរស្មីកើតឡើងបាន) ។

៩- **អាកាសកសិណ** ធ្វើកសិណអាកាស សមគួរដល់អ្នកមាន ចរិតបានគ្រប់ចរិត ដោយការសម្ងឹងកន្ទែងទំនេររបស់ប្រហោង និង រន្ធផ្សេងៗ ឬចោះប្រហោងមូលធំមួយចំអាម ហើយបរិកម្មថា "**អាកាសៗ**" ឬ "**ទំនេរៗ**" ទាល់តែកើតឧគ្គហនិមិត្តជាប់ភ្នែក បរិកម្មទៅទាល់តែកើត បដិភាគនិមិត្តពង្រីកប្រហោងឲ្យធំបាន តូចបាន លុះជាឧបចារសមាធិ ជិតដល់ភាពជាឈាន សម្ងឹងតទៅលុះជាអប្បនាសមាធិ នឹងន ជាអារម្មណ៍មួយ មានអង្គឈានចូលប្រកប សង្កត់នីវរណ:ទុកបាន លុះ កន្ងងបឋមជ្ឈាន ទុតិយជ្ឈាន តតិយជ្ឈាន ចតុត្ថជ្ឈាន ដល់បញ្ចមជ្ឈាន តាមលំដាប់ ហើយចម្រើនវិបស្សនាតទៅ ដោយលើកយករូបនាមឡើង កាន់ព្រះត្រៃលក្ខណ: លុះឃើញជាក់ច្បាស់ នឹកដល់អាកាស រូបនាម

កើត ឈប់នឹក រូបនាមរលត់ មាន **អនិច្ចំ ទុក្ខំ អនត្តា** *ជាលក្ខណៈ លុះកន្ធង៍ញាណ ១៦ ឆ្ធង៍ចាកគោត្របុថុជ្ជនទៅកាន់ព្រះអរិយៈ មានព្រះនិញ្ចានជាអារម្មណ៍ ឈ្មោះថា* **សមថយានិកៈ** *ជាព្រះអរិយៈប្រភេទឈានលាភីបុគ្គល (មានអាកាសកសិណជាកម្មដ្ឋាន អាចធ្វើឲ្យមានអាកាសក្នុង៍ដី ក្នុង៍ទឹកបាន ធ្វើវត្ថុផ្សេង៍ៗ ក្នុង៍ដី ក្នុង៍ទឹក ឬក្នុង៍ទីមិនមានអ្នកណាឃើញបាន បំបាំង៍កាយបាន) ។*

១០- **អាលោកកសិណ** *ធ្វើកសិណដោយពន្ធឺ សមគួរដល់ចរិតទូទៅ ដោយសម្ធឹង៍រស្មីរបស់ភ្ធើង៍ ឬពន្ធឺព្រះអាទិត្យ, ពន្ធឺព្រះចន្ទ ក៏បានហើយបរិកម្មថា* **"អាលោកៈៗ ពន្ធឺៗ"** *ទាល់តែកើតឧគ្គហនិមិត្តជាប់ភ្នែកបរិកម្មតទៅទាល់តែកើតបដិភាគនិមិត្ត ពង្រីកឲ្យពន្ធឺធំបាន តូចបានលុះជាឧបចារសមាធិ ជិតដល់ភាពជាឈាន សម្ធឹង៍លុះជាអប្បនាសមាធិនឹង៍នតែមួយ មានអង្គឈានចូលទៅប្រកប សង្កត់នីវរណៈទុកបាន ធ្វើទាល់តែជាវសីជំនាញ កន្ធង៍បឋមជ្ឈាន ទុតិយជ្ឈាន តតិយជ្ឈានចតុត្ថជ្ឈានលុះដល់បញ្ចមជ្ឈានរហូត ហើយចម្រើនវិបស្សនាតទៅ ដោយយករូបនាមក្នុង៍អង្គឈានឡើង៍កាន់ព្រះត្រៃលក្ខណៈ លុះមានញាណចូលទៅឃើញជាក់ច្បាស់ថា នឹកដល់ពន្ធឺ រូបនាមកើត ឈប់នឹក រូបនាមរលត់ មានលក្ខណៈមិនទៀង៍ ជាទុក្ខ ជាអនត្តា មានញាណ ១៦ ញាណកន្ធង៍ទៅ ឆ្ធង៍ចាកគោត្របុថុជ្ជនទៅកាន់អរិយៈ បានព្រះនិញ្ចានជាអារម្មណ៍*

ឈ្មោះថា **សមបិយាតិកៈ** ជាព្រះអរិយៈប្រភេទឈានលាភីបុគ្គល (មានអាលោកកសិណជាកម្មដ្ឋាន អាចធ្វើលោកនេះឲ្យភ្លឺបាន ភ្លុំ ឬកំពែងក្តី អាចមើលឃើញធ្ងុះបាន) ។

ពួកអសុភ ១០

១១- **ឧទ្ធុមាតកអសុភ** សម្ងឹងសាកសពដែលហើមប៉ោងឡើងគួរខ្ពើមជាកម្មដ្ឋាន សមគួរដល់រាគចរិត បរិកម្មថា "**ហើមប៉ោងៗគួរខ្ពើម**" ទាល់តែកើតឧគ្គហនិមិត្តឃើញសាកសពហើមប៉ោងជាប់ភ្នែក បរិកម្មទៅទាល់តែកើតបដិភាគនិមិត្តឃើញច្បាស់ឡើង ពង្រីកឲ្យតូច ឲ្យធំបានតាមត្រូវការ លុះជាឧបចារសមាធិ ជិតដល់ភាពជាឈាន សម្ងឹងតទៅលុះដល់អប្បនាសមាធិមានអង្គឈានចូលប្រកប សង្កត់នីវរណៈទុកបានធ្វើទាល់តែជាវសីជំនាញ បានត្រឹមបឋមជ្ឈានប៉ុណ្ណោះ ហើយលើកអង្គឈានដែលជារូបនាមឡើងកាន់ព្រះត្រៃលក្ខណៈ ជាវិបស្សនាឃើញជាក់ច្បាស់ថា ទឹកដល់សាកសពហើមប៉ោងឡើង រូបនាមកើត ឈប់ទឹករូបនាមរលត់ ជា **អនិច្ចំ ទុក្ខំ អនត្តា** ទៅតាមលំដាប់របស់ញាណ ១៦ ធ្វើចាកគោត្របុថុជ្ជនទៅកាន់អរិយៈ មានព្រះនិញ្ជានជាអារម្មណ៍ ឈ្មោះថា **សមបិយាតិកៈ** ជាព្រះអរិយៈប្រភេទឈានលាភីបុគ្គល ។

១២- **វិនីលកអសុភ** សម្ងឹងសាកសពដែលឡើងពណ៌ខៀវ គួរខ្ពើមជាកម្មដ្ឋាន សមគួរដល់រាគចរិត បរិកម្មថា "**ឡើងពណ៌ខៀវៗ គួរ**

ខ្ពើម" ទាល់តែកើតឧគ្គហនិមិត្តជាប់ភ្នែក បរិកម្មទៅទាល់តែកើតបដិ-ភាគនិមិត្ត ពង្រីកឲ្យធំ ឲ្យតូចបាន លុះជាឧបចារសមាធិ ជិតដល់ភាពជាឈាន សម្ធឹងទៅលុះជាអប្បនាសមាធិ នឹងនជាអារម្មណ៍តែមួយ មានអង្គឈានចូលប្រកប សង្កត់នីវរណៈទុកបាន ធ្វើទាល់តែជាវសីជំនាញបានត្រឹមបឋមជ្ឈានប៉ុណ្ណោះ លើករូបនាមក្នុងអង្គឈានឡើងកាន់ព្រះត្រៃលក្ខណៈ ជាវិបស្សនាឃើញជាក់ច្បាស់ថា នឹកដល់សាកសពឡើងពណ៌ខៀវ គួរខ្ពើម រូបនាមកើត ឈប់នឹក រូបនាមរលត់ មានលក្ខណៈមិនទៀង ជាទុក្ខ ជាអនត្តា កន្ធងញាណ ១៦ ឆ្ធងចាកគោត្របុថុជ្ជនទៅកាន់អរិយៈ មានព្រះនិញ្ជានជាអារម្មណ៍ ជាព្រះអរិយបុគ្គលប្រភេទឈានលាភី ឈ្មោះថា**សមថយានិកៈ** ។

១៣- **វិបុព្ធកអសុភ** សម្ធឹងសាកសពដែលមានខ្ទុះហូរចេញ គួរខ្ពើម ជាកម្មដ្ឋាន សមគួរដល់រាគចរិត ដោយបរិកម្មថា "**ខ្ទុះហូរចេញ គួរខ្ពើមៗ**" ទាល់តែកើតឧគ្គហនិមិត្ត ជាប់ភ្នែក បរិកម្មទៅទាល់តែកើតបដិភាគនិមិត្ត ឲ្យឃើញធំបាន តូចបាន លុះជាឧបចារសមាធិ ជិតដល់ភាពជាឈាន សម្ធឹងទៅលុះជាអប្បនាសមាធិ នឹងនជាអារម្មណ៍តែមួយ មានអង្គឈានចូលប្រកប សង្កត់នីវរណៈទុកបាន ធ្វើទាល់តែជាវសីជំនាញ បានត្រឹមបឋមជ្ឈានប៉ុណ្ណោះ ហើយលើករូបនាមក្នុងអង្គឈានឡើងកាន់ព្រះត្រៃលក្ខណៈ មានវិបស្សនាឃើញជាក់ច្បាស់ថា នឹកដល់

ខ្ទុះហូរចេញគួរខ្ពើម រូបនាមកើត ឈប់នឹក រូបនាមរលត់ មានលក្ខណៈ ជា **អនិច្ចំ ទុក្ខំ អនត្តា** ទៅតាមលំដាប់ញាណ ១៦ ឆ្ងន់ចាកគោត្រ បុថុជ្ជនទៅកាន់អរិយៈ មានព្រះនិញ្វាន ជាអារម្មណ៍ ឈ្មោះថា **សមថយានិកៈ** ជាព្រះអរិយៈប្រភេទឈានលាភីបុគ្គល ។

១៤- **វិប្ជិទ្ធកអសុភ** សម្ងឹងសាកសពដែលដាច់ជាកំណាត់ៗ គួរខ្ពើម ជាកម្មដ្ឋាន សមគួរដល់រាគចរិត ដោយបរិកម្មថា "**សពជា កំណាត់ៗ គួរខ្ពើម**" ទាល់តែកើតខគ្គហនិមិត្តជាប់ភ្នែក បរិកម្មទៅទាល់ តែកើតបដិភាគនិមិត្ត ពង្រីកឲ្យធំ ឬតូចបាន លុះជាខបចារសមាធិ ជិតដល់ភាពជាឈាន សម្ងឹងទៅលុះជាអប្បនាសមាធិ នឹងនជាអារម្មណ៍ តែមួយ មានអង្គឈានចូលប្រកប សង្កត់នីវរណៈទុកបាន ធ្វើទាល់តែជា វសីជំនាញ បានត្រឹមបឋមជ្ឈានប៉ុណ្ណោះ លើកអង្គឈានក្នុងរូបនាម ឡើងកាន់ព្រះត្រៃលក្ខណៈ វិបស្សនាកើតឃើញច្បាស់ថា នឹកដល់សាក សពជាកំណាត់ៗ គួរខ្ពើម រូបនាមកើត ឈប់នឹក រូបនាមរលត់ទៅ ជា **អនិច្ចំ ទុក្ខំ អនត្តា** កន្ងឹញាណ ១៦ ឆ្ងន់ចាកគោត្របុថុជ្ជនទៅកាន់ អរិយៈ មានព្រះនិញ្វានជាអារម្មណ៍ បិទទ្វារអបាយ ឈ្មោះថា **សមថយានិកៈ** ជាព្រះអរិយៈប្រភេទឈានលាភីបុគ្គល ។

១៥- **វិក្ខាយិតកអសុភ** សម្ងឹងសាកសពដែលធ្កែព្រៃខាំ គួរខ្ពើម ជាកម្មដ្ឋាន សមគួរដល់រាគចរិត ដោយបរិកម្មថា "**សាកសពត្រូវសុនខ**

ខាំស៊ី គួរខ្ពើម" ទាល់តែកើតឧគ្គហនិមិត្តជាប់ភ្នែក បរិកម្មទៅទាល់តែកើតបដិភាគនិមិត្ត ពង្រីកឲ្យធំ ឲ្យតូចបាន លុះជាឧបចារសមាធិ ជិតដល់ភាពជាឈាន សម្ធឹងទៅលុះជាអប្បនាសមាធិ មាំមួនជាអារម្មណ៍តែមួយ មានអង្គឈានចូលប្រកប សង្កត់នីវរណៈទុកបាន ធ្វើទាល់តែជាវសីជំនាញ បានត្រឹមបឋមជ្ឈានប៉ុណ្ណោះ ហើយលើករូបនាមក្នុងអង្គឈានឡើងកាន់ព្រះត្រៃលក្ខណៈ មានវិបស្សនាឃើញច្បាស់ថា នឹកដល់សពដែលធ្កែត្រៃ ខាំស៊ីគួរខ្ពើម រូបនាមកើតឡើង ឈប់នឹក រូបនាមរលត់ ជា **អនិច្ចំ ទុក្ខំ អនត្តា** កន្ធងញាណ ១៦ ធ្ងងចាកគោត្របុថុជ្ជនទៅកាន់អរិយៈ មានព្រះនិញ្ចានជាអារម្មណ៍ ឈ្មោះថា **សមថយានិកៈ** ជាព្រះអរិយៈប្រភេទឈានលាភីបុគ្គល ។

១៦- **វិទិត្តកអសុភ** សម្ធឹងសាកសពដែលចោលរាត់រាយ គួរខ្ពើមជាកម្មដ្ឋាន សមគួរដល់រាគចរិត ដោយបរិកម្មថា "**សពដែលចោលទុក គួរខ្ពើម**" ទាល់តែកើតឧគ្គហនិមិត្តជាប់ភ្នែក បរិកម្មទៅទាល់តែកើតបដិភាគនិមិត្ត ពង្រីកឲ្យធំបាន តូចបាន លុះជាឧបចារសមាធិ ជិតដល់ភាពជាឈាន សម្ធឹងតទៅលុះជាអប្បនាសមាធិ នឹងនជាអារម្មណ៍តែមួយ មានអង្គឈានចូលប្រកប សង្កត់នីវរណៈទុកបាន ធ្វើទាល់តែជាវសីជំនាញ បានត្រឹមបឋមជ្ឈានប៉ុណ្ណោះ ហើយលើករូបនាមក្នុងអង្គឈានឡើងកាន់ព្រះត្រៃលក្ខណៈ មានវិបស្សនាឃើញច្បាស់ថា

នឹកដល់សពដែលចោលទុក រូបនាមកើត ឈប់នឹក រូបនាមរលត់ ជា **អនិច្ចំ ទុក្ខំ អនត្តា** *កន្ធង្ញាណ ១៦ ឆ្ធង្ចាកគោត្របុថុជ្ជនទៅកាន់អរិយ: មានព្រះនិញ្ចានជាអារម្មណ៍ ឈ្មោះថា* **សមថយានិក:** *ជាព្រះអរិយ:ប្រភេទ ឈានលាភីបុគ្គល ។*

១៧- **ហតវិទិត្តកអសុភ** *ពិចារណាសាកសពដែលត្រូវចិញ្ច្រាំ ចោល គួរខ្ពើម ជាកម្មដ្ឋាន សមគួដល់រាគចរិត ដោយនាំមកបរិកម្មថា* **"សពត្រូវចិញ្ច្រាំចោលទុក គួរខ្ពើម"** *ទាល់តែកើតឧគ្គហនិមិត្តជាប់ភ្នែក បរិកម្មទៅទាល់តែកើតបដិភាគនិមិត្ត សម្ធឹងទៅលុះជាឧបចារសមាធិ ជិត ដល់ភាពជាឈាន សម្ធឹងទៅលុះជាអប្បនាសមាធិ នឹងនជាអារម្មណ៍តែ មួយ មានអង្គឈានចូលប្រកប សង្កត់នីវរណ:ទុកបាន ធ្វើទាល់តែជាវសី ជំនាញ បានត្រឹមបឋមជ្ឈានប៉ុណ្ណោះ ហើយលើកឈានឡើងកាន់ព្រះត្រៃ-លក្ខណ: មានវិបស្សនាឃើញជាក់ច្បាស់ក្នុងរូបនាមរបស់ឈានថា នឹក ដល់សពដែលត្រូវចិញ្ច្រាំចោលទុក គួរខ្ពើម រូបនាមកើតឡើង ឈប់នឹក រូបនាមរលត់ទៅ ជា* **អនិច្ចំ ទុក្ខំ អនត្តា** *លុះកន្ធង្ញាណ ១៦ ឆ្ធង្ចាក គោត្របុថុជ្ជនទៅកាន់អរិយ: មានព្រះនិញ្ចានជាអារម្មណ៍ ឈ្មោះថា* **សមថយានិក:** *ជាព្រះអរិយ:ប្រភេទឈានលាភីបុគ្គល ។*

១៨- **លោហិតកអសុភ** *ការពិចារណាសាកសពដែលមាន លោហិតហូរចេញ គួរខ្ពើម ជាកម្មដ្ឋាន សមគួរដល់រាគចរិត ដោយនាំមក*

បរិកម្មថា **"សពដែលប្រឡាក់លោហិត គួរខ្ពើម"** *ទាល់តែកើតឧគ្គហ-និមិត្តជាប់ភ្នែក បរិកម្មទៅទាល់តែកើតបដិភាគនិមិត្ត ពង្រីកធ្វើឲ្យធំបាន តូចបាន លុះជាឧបចារសមាធិ ជិតដល់ភាពជាឈាន សម្ងឹងទៅលុះជាអប្បនាសមាធិ នឹងនជាអារម្មណ៍តែមួយ មានអង្គឈានចូលប្រកប សង្កត់នីវរណៈទុកបាន ធ្វើទាល់តែជាវសីជំនាញ បានត្រឹមបឋមជ្ឈានប៉ុណ្ណោះ ហើយលើករូបនាមក្នុងអង្គឈានឡើងកាន់ព្រះត្រៃលក្ខណៈ មានវិបស្សនាឃើញច្បាស់ថា នឹកដល់សពដែលប្រឡាក់លោហិត គួរខ្ពើម រូបនាមកើត ឈប់នឹក រូបនាមរលត់ ជា* **អនិច្ចំ ទុក្ខំ អនត្តា** *កន្ទងញ្ញាណ ១៦ ឆ្ងងចាកគោត្របុថុជ្ជនទៅកាន់អរិយៈ មានព្រះនិញ្ជានជាអារម្មណ៍ ឈ្មោះថា* **សមឋយានិកៈ** *ជាព្រះអរិយៈប្រភេទឈានលាភី-បុគ្គល ។*

១៩- **បុឡុវកអសុភ** *ពិចារណាសពដែលមានដង្កូវ គួរខ្ពើមជាកម្មដ្ឋានសមគួរដល់រាគចរិត ដោយនាំមកបរិកម្មថា* **"សពមានដង្កូវ គួរខ្ពើម"** *ទាល់តែកើតនិមិត្តជាប់ភ្នែក ហៅថា ឧគ្គហនិមិត្ត បរិកម្មទៅទាល់តែកើតបដិភាគនិមិត្ត ពង្រីកឲ្យធំ ឬឲ្យតូចបាន លុះជាឧបចារសមាធិ ជិតដល់ភាពជាឈាន សម្ងឹងទៅលុះជាអប្បនាសមាធិ នឹងនជាអារម្មណ៍តែមួយ មានអង្គឈានចូលប្រកប សង្កត់នីវរណៈទុកបាន ធ្វើទាល់តែជាវសីជំនាញ បានត្រឹមបឋមជ្ឈានប៉ុណ្ណោះ ហើយលើករូបនាមក្នុងអង្គឈាន*

ឡើងកាន់ព្រះត្រៃលក្ខណៈ មានវិបស្សនាកើតឡើងឃើញច្បាស់ គឺនឹកដល់សពមានដង្កូវ គួរខ្ពើម រូបនាមកើត ឈប់នឹក រូបនាមរលត់ ជា **អនិច្ចំ ទុក្ខំ អនត្តា** កន្ទងញាណ ១៦ ធ្លងចាកគោត្របុថុជ្ជនទៅកាន់អរិយៈ មានព្រះនិញ្ជានជាអារម្មណ៍ ឈ្មោះថា **សមុច្ឆេទ**ៈ ជាព្រះអរិយៈប្រភេទឈានលាភីបុគ្គល ។

២០- **អដ្ឋិកអសុភ** ពិចារណាសពមានតែធ្ពុ៉ង គួរខ្ពើម ជាកម្មដ្ឋាន សមគួរដល់រាគចរិត ដោយនាំមកបរិកម្មថា **"សពមានតែធ្ពុ៉ង គួរខ្ពើម"** ទាល់តែកើតឧគ្គហនិមិត្តជាប់ភ្នែក បរិកម្មទៅទាល់តែកើតបដិភាគនិមិត្ត ពង្រីកឲ្យធំបាន តូចបាន លុះជាឧបចារសមាធិ ដិតដល់ភាពជាឈាន សម្ធឹងទៅលុះជាអប្បនាសមាធិ នឹងនជាអារម្មណ៍តែមួយ មានអង្គឈានចូលប្រកប សង្កត់នីវរណៈទុកបាន ធ្វើទាល់តែជាវសីជំនាញ បានត្រឹមបឋមជ្ឈានប៉ុណ្ណោះ ហើយលើករូបនាមក្នុងអង្គឈានឡើងកាន់ព្រះត្រៃលក្ខណៈ មានវិបស្សនាឃើញច្បាស់ថា នឹកដល់សពមានតែធ្ពុ៉ង គួរខ្ពើម រូបនាមកើត ឈប់នឹក រូបនាមរលត់ ជា **អនិច្ចំ ទុក្ខំ អនត្តា** កន្ទងញាណ ១៦ ធ្លងចាកគោត្របុថុជ្ជនទៅកាន់អរិយៈ មានព្រះនិញ្ជានជាអារម្មណ៍ ឈ្មោះថា **សមុច្ឆេទ**ៈ ជាព្រះអរិយៈប្រភេទឈានលាភីបុគ្គល ។

ពួកអនុស្សតិ ១០

២១- **ពុទ្ធានុស្សតិ** *រឭកដល់គុណព្រះពុទ្ធរឿយៗ ជាកម្មដ្ឋានសមគួរដល់សទ្ធាចរិត ដោយនាំយកគុណរបស់ព្រះពុទ្ធបទណាមួយ មកបរិកម្មថា* **"ពុទ្ធោៗ អ្នកដឹងៗ"** *ជាដើម ទាល់តែកើតឧគ្គហនិមិត្តជាប់ចិត្តចូលដល់ឧបចារសមាធិ ជិតជាឈាន តែមិនដល់ឈាន ហើយលើកឡើងកាន់ព្រះត្រៃលក្ខណៈ ដោយវិបស្សនាឃើញច្បាស់គ្រប់ខណៈ ដែលនឹកដល់ពុទ្ធោ អ្នកដឹង រូបនាមកើត ឈប់នឹក រូបនាមរលត់ កន្ទុងតាមលំដាប់របស់ញាណ ១៦ ធ្វើចាកគោត្របុថុជ្ជនទៅកាន់អរិយគោត្រ ឈ្មោះថា* **សមថយានិកៈ** *។*

២២- **ធម្មានុស្សតិ** *រឭកដល់គុណព្រះធម៌រឿយៗ ជាកម្មដ្ឋានសមគួរដល់សទ្ធាចរិត ដោយនាំយកគុណរបស់ព្រះធម៌បទណាមួយ មកបរិកម្មថា* **"ធម្មោៗ ធម៌ៗ"** *ជាដើម ទាល់តែកើតឧគ្គហនិមិត្តជាប់ចិត្តចូលដល់ឧបចារសមាធិ ជិតភាពជាឈាន តែមិនដល់ឈាន ហើយលើកឡើងកាន់ព្រះត្រៃលក្ខណៈ ដោយវិបស្សនាឃើញច្បាស់ថានឹកដល់ធម្មោ ធម៌ៗ រូបនាមកើត ឈប់នឹក រូបនាមរលត់ ជា* **អនិច្ចំ ទុក្ខំ អនត្តា** *កន្ទុងញាណ ១៦ ធ្វើចាកគោត្របុថុជ្ជនទៅកាន់អរិយគោត្រ ឈ្មោះថា* **សមថយានិកៈ** *។*

២៣- **សង្ឆានុស្សតិ** *រឭកដល់គុណរបស់ព្រះសង្ឆរឿយៗ*

ជាកម្មដ្ឋាន សមគួរដល់សទ្ធាចរិត ដោយនាំយកគុណរបស់ព្រះសង្ឆ បទណាមួយ មកបរិកម្មថា "សង្ឆោៗ ពួកសង្ឆៗ" ជាដើម ទាល់តែកើតឧគ្គហនិមិត្តជាប់ចិត្ត បរិកម្មទៅលុះជាឧបចារសមាធិ ជិតភាពជាឈាន តែមិនជាឈាន ហើយលើករូបនាមឡើងកាន់ព្រះត្រៃលក្ខណៈ ដោយវិបស្សនាឃើញ ច្បាស់ថា នឹកដល់ សង្ឆោ ពួកសង្ឆ រូបនាមកើតឈប់នឹក រូបនាមរលត់ ជា **អនិច្ចំ ទុក្ខំ អនត្តា** កន្ធង្ញាណ ១៦ ឆ្ងង់ចាកគោត្របុថុជ្ជន ទៅកាន់អរិយគោត្រ ឈ្មោះថា **សមថយានិកៈ** ។

២៤- **សីលានុស្សតិ** រព្ធកដល់គុណរបស់សីលរឿយៗ ជាកម្មដ្ឋាន សមគួរដល់សទ្ធាចរិត ដោយនាំយកគុណរបស់សីលមកបរិកម្មថា "**សីលំៗ សីលៗ**" ជាដើម ទាល់តែកើតឧគ្គហនិមិត្តជាប់ចិត្ត បរិកម្មទៅលុះជាឧបចារសមាធិ ជិតដល់ភាពជាឈាន តែមិនជាឈាន ហើយលើកឡើងកាន់ព្រះត្រៃលក្ខណៈ ដោយមានវិបស្សនាឃើញច្បាស់ថា នឹកដល់សីលៗ រូបនាមកើត ឈប់នឹក រូបនាមរលត់ ជា **អនិច្ចំ ទុក្ខំ អនត្តា** លុះកន្ធង្ញាណ ១៦ ឆ្ងង់ចាកគោត្របុថុជ្ជនទៅកាន់អរិយគោត្រ ជាព្រះអរិយបុគ្គលដោយអាស្រ័យ **សមថយានិកៈ** ។

២៥- **ចាគានុស្សតិ** រព្ធកដល់គុណរបស់ការបរិច្ចាគរឿយៗ ជាកម្មដ្ឋាន សមគួរដល់សទ្ធាចរិត ដោយនាំយកការបរិច្ចាគ មកបរិកម្មថា "**ចាគៈៗ ការបរិច្ចាគៗ**" ទាល់តែកើតឧគ្គហនិមិត្តជាប់ចិត្ត បរិកម្ម

ទៅលុះជាឧបចារសមាធិ ជិតភាពជាឈាន តែមិនដល់ឈាន ហើយ លើកឡើងកាន់វិបស្សនាឃើញច្បាស់ក្នុងព្រះត្រៃលក្ខណៈថា នឹកដល់ចាគៈ រូបនាមកើត ឈប់នឹក រូបនាមរលត់ ជា **អនិច្ចំ ទុក្ខំ អនត្តា** កនូងញាណ ១៦ ធូងចាគគោត្របុថុជ្ជនទៅកាន់អរិយៈ មានព្រះនិញ្ចានជាអារម្មណ៍ ឈ្មោះថា ព្រះអរិយបុគ្គលដោយអាស្រ័យ **សមឋយានិកៈ** ។

២៦- **ទេវតានុស្សតិ** រពុកដល់គុណរបស់ទេវតារឿយៗ ជាកម្មដ្ឋាន សមគួរដល់សទ្ធាចរិត ដោយនាំយកគុណរបស់ទេវតា មកបរិកម្ម ថា "**ទេវតាៗ**" ទាល់តែកើតឧគ្គហនិមិត្តជាប់ចិត្ត បរិកម្មទៅលុះជាឧបចារសមាធិ ជិតភាពជាឈាន តែនៅមិនដល់ឈាន ហើយលើកឡើងកាន់វិបស្សនាឃើញច្បាស់ក្នុងព្រះត្រៃលក្ខណៈថា នឹកដល់ទេវតា រូបនាមកើត ឈប់នឹក រូបនាមរលត់ ជា **អនិច្ចំ ទុក្ខំ អនត្តា** លុះកនូងញាណទាំង ១៦ ធូងចាគគោត្របុថុជ្ជនទៅកាន់អរិយៈ មានព្រះនិញ្ចានជាអារម្មណ៍ ឈ្មោះថាជាព្រះអរិយបុគ្គលដោយអាស្រ័យ **សមឋយានិកៈ** ។

២៧- **ឧបសមានុស្សតិ** រពុកដល់គុណរបស់ព្រះនិញ្ចានរឿយៗ ជាកម្មដ្ឋាន សមគួរដល់ពុទ្ធិចរិត ដោយនាំយកគុណរបស់ព្រះនិញ្ចាន បទណាមួយ មកបរិកម្មថា "**និញ្ចានៗ**" ជាដើម ទាល់តែកើតឧគ្គហនិមិត្ត ជាប់ចិត្ត បរិកម្មទៅលុះជាឧបចារសមាធិ ជិតភាពជាឈាន តែនៅមិនបានឈាន ហើយលើកឡើងកាន់វិបស្សនាឃើញច្បាស់ថា នឹកដល់ព្រះ

និញ្ជាន រូបនាមកើត ឈប់ទឹក រូបនាមរលត់ ជា **អនិច្ចំ ទុក្ខំ អនត្តា** កន្ទ្ធ៦ញ្ញាណទាំង ១៦ ធ្ងន់ចាកគោត្របុថុជ្ជនទៅកាន់អរិយៈ បានព្រះនិញ្ជានជាអារម្មណ៍ ជាព្រះអរិយបុគ្គលដោយអាស្រ័យ **សមបិយាតិកៈ** ។

២៨- **មរណានុស្សតិ** រឭកដល់សេចក្ដីស្លាប់រឿយៗ ជាកម្មដ្ឋានសមគួរដល់ពុទ្ធិចរិត ដោយនាំយកសេចក្ដីស្លាប់មកបរិកម្មថា **"មរណៈៗ សេចក្ដីស្លាប់ៗ"** ទាល់តែកើតឧគ្គហនិមិត្តជាប់ចិត្ត បរិកម្មទៅលុះជាឧបចារសមាធិ ជិតភាពជាឈាន តែមិនដល់ឈាន ហើយលើកឡើងកាន់វិបស្សនា ឃើញច្បាស់ក្នុងព្រះត្រៃលក្ខណៈរបស់រូបនាមថា ទឹកដល់សេចក្ដីស្លាប់ រូបនាមកើត ឈប់ទឹក រូបនាមរលត់ ជា **អនិច្ចំ ទុក្ខំ អនត្តា** កន្ទ្ធ៦ញ្ញាណ ១៦ ធ្ងន់ចាកគោត្របុថុជ្ជនទៅកាន់អរិយៈ បានព្រះនិញ្ជានជាអារម្មណ៍ ជាព្រះអរិយបុគ្គលដោយអាស្រ័យ **សមបិយាតិកៈ** ។

២៩- **កាយគតាសតិ** រឭកដល់កាយកោដ្ឋាសៈ (ចំណែកកាយ) គឺកេសា លោមា ជាដើម សមគួរដល់រាគចរិត ដោយនាំយកសក់មកបរិកម្មថា **"កេសា សក់ៗ"** ជាដើម ទាល់តែកើតឧគ្គហនិមិត្តជាប់ភ្នែកបរិកម្មទៅៗ លុះកើតបដិភាគនិមិត្ត ពង្រីកឲ្យតូចបាន ឲ្យធំបាន ច្រើនបានតិចបាន បរិកម្មទៅលុះជាឧបចារសមាធិ ជិតភាពជាឈានសម្ធឹងទៅលុះជាអប្ប្ឯនាសមាធិ ទ្ធឹងនជាអារម្មណ៍តែមួយ មានអង្គឈានចូលប្រកបសង្ក្ដត់នីវរណៈទុកបាន ធ្លើទាល់តែជាវសីជំនាញ បាន

ត្រឹមបឋមជ្ឈានប៉ុណ្ណោះ ហើយលើកឡើងកាន់ព្រះត្រៃលក្ខណៈ កើត វិបស្សនាញាណឃើញច្បាស់ក្នុងរូបនាមរបស់អង្គឈានថា នឹកដល់សក់ រូបនាមកើត ឈប់នឹក រូបនាមរលត់ ជា **អនិច្ចំ ទុក្ខំ អនត្តា** កន្ទុងញាណ ១៦ ធ្វើចាកគោត្របុថុជ្ជនទៅកាន់អរិយៈ បានព្រះនិញ្ជានជាអារម្មណ៍ ជាព្រះអរិយៈប្រភេទឈានលាភីបុគ្គល ដោយអាស្រ័យ **សមថយានិកៈ** ។

៣០- **អានាបានាសតិ** រាវកដឹងខ្យល់ដង្ហើមចូល-ចេញ ជាកម្មដ្ឋាន សមគួរដល់មោហចរិត និងវិតក្កចរិត ដោយកំណត់យកខ្យល់ដង្ហើមចូល-ចេញ មកបរិកម្មថា "**ចូល-ចេញ**" ជាដើម ទាល់តែកើតឧគ្គហនិមិត្តជាប់ចិត្ត បរិកម្មទៅទាល់តែកើតបដិភាគនិមិត្ត ញែកជាចំណែកៗ បាន សម្ធឹងទៅលុះជាឧបចារសមាធិ កំណត់ដោយគណនា-នយ ឬអនុពន្ធនានយ លុះជាអប្បនាសមាធិ មានសមាធិនឹងន មានអង្គឈានចូលប្រកប សង្កត់នីវរណៈទុកបាន បង្ហឹកទាល់តែជាវសីជំនាញ កន្ទុងបឋមជ្ឈាន ទុតិយជ្ឈាន តតិយជ្ឈាន ចតុត្ថជ្ឈាន និងបញ្ចមជ្ឈាន ហើយលើកយករូបនាមក្នុងអង្គឈានឡើងកាន់វិបស្សនា ពិចារណាឃើញច្បាស់ដោយផ្ទុសន្ធនយ៉ាថា ដង្ហើមចូលប៉ះទង្គិច រូបនាមកើត ឈប់ប៉ះទង្គិច រូបនាមរលត់ ជា **អនិច្ចំ ទុក្ខំ អនត្តា** កន្ទុងញាណ ១៦ ធ្វើចាកគោត្របុថុជ្ជនទៅកាន់អរិយគោត្រ មានព្រះនិញ្ជានជាអារម្មណ៍ ជាព្រះអរិយៈប្រភេទឈានលាភីបុគ្គល ដោយអាស្រ័យ **សមថយានិកៈ** ។

ពួកអប្បមញ្ញ ៤

៣១- **មេត្តា** *សេចក្តីស្រឡាញ់ក្នុងសត្វទាំងឡាយ ជាកម្មដ្ឋានសមគួរដល់ទោសចរិត ដោយនាំយកមេត្តាមកចម្រើនមិនមានប្រមាណ បរិកម្មថា* **"ចូរជាសុខៗ"** *ទាល់តែកើតខគ្គហនិមិត្តជាប់ចិត្ត បរិកម្មទៅលុះជាឧបចារសមាធិ ជិតភាពជាឈាន សម្ធឹងទៅលុះជាអប្បនាសមាធិ នឹងនជាអារម្មណ៍មួយ មានអង្គឈានចូលប្រកប សង្កត់នីវរណៈទុកបាន បង្ហឹកទាល់តែជាវសីជំនាញ កន្ទងបឋមជ្ឈាន ទុតិយជ្ឈាន តតិយ-ជ្ឈាន ដល់ចតុត្ថជ្ឈាន មិនដល់បញ្ចមជ្ឈាន និងមិនបានបដិភាគនិមិត្ត កាលដល់ចតុត្ថជ្ឈានហើយ លើករូបនាមក្នុងអង្គឈានឡើងកាន់វិបស្សនាពិចារណា ដោយព្រះត្រៃលក្ខណៈឃើញច្បាស់ថា នឹកដល់ចូរជាសុខ រូបនាមកើតឡើង ឈប់នឹក រូបនាមរលត់ទៅជា* **អនិច្ចំ ទុក្ខំ អនត្តា** *កន្ទងញាណទាំង ១៦ ធ្វងចាកគោត្របុថុជ្ជនទៅកាន់អរិយៈ មានព្រះនិញ្ជានជាអារម្មណ៍ ជាព្រះអរិយៈប្រភេទឈានលាភីបុគ្គល ដោយអាស្រ័យ* **សមបិយានិកៈ** *។*

៣២- **ករុណា** *សេចក្តីអាណិតអាសូរក្នុងសត្វទាំងឡាយ ជាកម្មដ្ឋាន សមគួរដល់ទោសចរិត ដោយនាំយកករុណាមកចម្រើន មិនមានប្រមាណដោយបរិកម្មថា* **"ចូរផុតទុក្ខៗ"** *ទាល់តែកើតខគ្គហ-និមិត្តជាប់ចិត្ត មិនដល់បដិភាគនិមិត្ត បរិកម្មទៅលុះជាឧបចារសមាធិ ជិត*

ភាពជាឈាន សម្ងឹងទៅលុះជាអប្បនាសមាធិនឹងនជាអារម្មណ៍មួយ មានអង្គឈានចូលប្រកប សង្កត់នីវរណៈទុកបាន ធ្វើទាល់តែជាវសីជំនាញ កន្ងងបឋមជ្ឈាន ទុតិយជ្ឈាន តតិយជ្ឈាន ដល់ចតុត្ថជ្ឈាន តែមិនដល់បញ្ចមជ្ឈាន ហើយលើករូបនាមក្នុងអង្គឈានឡើងកាន់វិបស្សនាពិចារណាដោយព្រះត្រៃលក្ខណៈ ឃើញច្បាស់ថា នឹកដល់ចូរផុតទុក្ខ រូបនាមកើត ឈប់នឹក រូបនាមរលត់ជា **អនិច្ចំ ទុក្ខំ អនត្តា** កន្ងងញាណ ១៦ ឆ្ងងចាកគោត្របុថុជ្ជនទៅកាន់អរិយៈ មានព្រះនិញ្ចានជាអារម្មណ៍ ជាព្រះអរិយៈប្រភេទឈានលាភីបុគ្គល ឈ្មោះថា **សមថយានិកៈ** ។

៣៣- **មុទុតា** សេចក្តីត្រេកអរចំពោះសត្វទាំងឡាយដែលបានសុខជាកម្មដ្ឋាន សមគួរដល់ទោសចរិត ដោយនាំយកមុទុតាចំពោះសត្វទាំងពួង ដោយមិនមានប្រមាណមកបរិកម្មថា **"ចូរជាសុខបម្រើនឡើងទៅ"** ទាល់តែកើតខគ្គហនិមិត្តជាប់ចិត្ត មិនដល់បដិភាគនិមិត្ត បរិកម្មទៅលុះជាខបចារសមាធិ ជិតភាពជាឈាន សម្ងឹងទៅលុះជាអប្បនាសមាធិនឹងនជាអារម្មណ៍មួយ មានអង្គឈានចូលប្រកប សង្កត់នីវរណៈទុកបាន ធ្វើទាល់តែជាវសីជំនាញ កន្ងងឈានទី ១ ឈានទី ២ ឈានទី ៣ ឈានទី ៤ គឺចតុត្ថជ្ឈាន តែមិនដល់បញ្ចមជ្ឈាន ឈានទី ៥ ហើយលើករូបនាមក្នុងអង្គឈានឡើងកាន់វិបស្សនា ពិចារណាឃើញច្បាស់ក្នុងព្រះត្រៃលក្ខណៈថា នឹកដល់ការត្រេកអរឲ្យសត្វជាសុខ

ចម្រើនឡើងទៅៗ រូបនាមកើត ឈប់នឹក រូបនាមរលត់ ជា **អនិច្ចំ ទុក្ខំ អនត្តា** កន្ធងញាណ ១៦ ធ្ងងចាកគោត្របុថុជ្ជនទៅកាន់អរិយ: មានព្រះនិញ្ចានជាអារម្មណ៍ ជាព្រះអរិយ:ប្រភេទឈានលាភីបុគ្គល សម្រេចដោយអាស្រ័យ **សមថយានិក:** ។

៣៤- **ឧបេក្ខា** សេចក្តីព្រងើយចំពោះសត្វទាំងឡាយ ជាកម្មដ្ឋានសមគួរដល់ទោសចរិត ដោយនាំយកឧបេក្ខាក្នុងសត្វទាំងឡាយ ទាំងដែលជាសុខនិងទុក្ខមិនមានប្រមាណ មកបរិកម្មថា "ព្រងើយៗ" ទាល់តែកើតឧគ្គហនិមិត្តជាប់ចិត្ត មិនបានបដិភាគនិមិត្ត បរិកម្មទៅលុះជាឧបចារសមាធិ ជិតដល់ភាពជាឈាន សម្ងឹងតទៅលុះជាអប្បនាសមាធិនឹងនជាអារម្មណ៍មួយ មានអង្គឈានចូលប្រកប សង្កត់នីវរណ:ទុកបានធ្វើទាល់តែជាវសីជំនាញ មានអង្គឈានអំពីឧបេក្ខា និងឯកគ្គតា បានចំពោះបញ្ចមជ្ឈាន ហើយលើករូបនាមក្នុងអង្គឈានឡើងកាន់វិបស្សនាពិចារណាព្រះត្រៃលក្ខណ: ឃើញច្បាស់ថា នឹកដល់ព្រងើយៗ រូបនាមកើត ឈប់នឹករូបនាមរលត់ ជា **អនិច្ចំ ទុក្ខំ អនត្តា** កន្ធងញាណ ១៦ ធ្ងងចាកគោត្របុថុជ្ជនទៅកាន់អរិយ: បានព្រះនិញ្ចានជាអារម្មណ៍ ជាព្រះអរិយ:ប្រភេទឈានលាភីបុគ្គល សម្រេចដោយអាស្រ័យ **សមថយានិក:** ។

ពួកអាហារេបដិកូលសញ្ញា ១

៣៥- **អាហារេបដិកូលសញ្ញា** ពិចារណាកំណត់ចំណាំយក

អាហារដែលគួរខ្ពើម ជាកម្មដ្ឋាន សមគួរដល់ពុទ្ធិចរិត ដោយនាំយក អាហារដែលទទួលទានហើយ មានសភាពគួរខ្ពើមបដិកូល ដូចអាហារ ដែលក្អួតចេញមក នាំមកបរិកម្មថា "**បដិកូល គួរខ្ពើមៗ**" ទាល់តែកើត ឧគ្គហនិមិត្តជាប់ភ្នែក បរិកម្មទៅលុះជាឧបចារសមាធិ ជិតភាពជាឈាន តែមិនដល់ឈាននិងមិនកើតបដិភាគនិមិត្ត ហើយលើកឡើងកាន់ព្រះ ត្រៃលក្ខណៈ កើតវិបស្សនាញាណ ដឹងឃើញច្បាស់ថា នឹកដល់អាហារ គួរខ្ពើម រូបនាមកើត ឈប់នឹក រូបនាមរលត់ ជា **អនិច្ចំ ទុក្ខំ អនត្តា** កនូងញាណ ១៦ ធ្វងចាកគោត្របុថុជ្ជនទៅកាន់អរិយៈ បានព្រះនិញ្ចាន ជាអារម្មណ៍ ជាព្រះអរិយបុគ្គលសម្រេចដោយអាស្រ័យ **សមថយានិកៈ** ។

,ញ្ចកបតុធាតុវវត្ថានៈ ១

៣៦- **បតុធាតុវវត្ថានៈ** ពិចារណាធាតុទាំង ៤ ដែលប្រជុំគ្នាជា រាងកាយនេះ ជាកម្មដ្ឋាន សមគួរដល់ពុទ្ធិចរិត ដោយនាំយកសសម្ភារៈ បឋវី ២០ មាន **កេសា** "សក់" ជាដើម សសម្ភារៈអាបោ ១២ មាន **លោហិតំ** "ឈាម" ជាដើម សសម្ភារៈតេជោ ៤ មាន **សន្តប្បគ្គិ** "ភ្លើង ធ្វើឲ្យក្តៅជាដើម" និងសសម្ភារៈវាយោ ៦ មាន **អង្គមង្គានុសារីវាតា** ឧ្យល់ដែលផាត់ទៅក្នុង អវយវៈតូច-ធំ ជាដើមមកបរិកម្មថា "**កេសា សក់ៗ**" ជាដើម ទាល់ តែកើតឧគ្គហនិមិត្តជាប់ភ្នែក បរិកម្មទៅលុះជាឧបចារសមាធិ ជិតភាព ជាឈាន តែនៅមិនដល់ឈាន មានចិត្តដ៏ស្ងប់ ហើយលើកឡើងកាន់

វិបស្សនា ពិចារណាឃើញព្រះត្រៃលក្ខណៈច្បាស់ថា នឹកដល់កេសា-សក់ រូបនាមកើត ឈប់នឹក រូបនាមរលត់ ជា **អនិច្ចំ ទុក្ខំ អនត្តា** *កន្ធង្ញាណ ១៦ ឆ្ធង្ចាកគោត្របុថុជ្ជនទៅកាន់អរិយបុគ្គលប្រភេទ* **សមឋយានិកៈ** *គឺ ធ្វើសេចក្តីស្ងប់មុនហើយ ទើបចម្រើនវិបស្សនាខាងក្រោយ ។*

ពួកអរូប ៤

៣៧- **អាកាសានញ្ចាយតនៈ** *ពិចារណាអាកាសមិនមានទីបំផុត ជាកម្មដ្ឋាន សមគួរដល់ចរិតគ្រប់ចរិត ដោយអាស្រ័យចម្រើនកម្មដ្ឋាន ដែលសម្តែងមកហើយ មានកសិណជាដើម លុះដល់បដិភាគនិមិត្តជា អប្បនាសមាធិ ធ្វើទាល់តែជាវសីជំនាញ កន្ធង្ចបឋមជ្ឈាន ទុតិយជ្ឈាន តតិយជ្ឈាន ចតុត្ថជ្ឈាន លុះដល់បញ្ចមជ្ឈាន ហើយលះនិមិត្តកសិណ ជាដើមចេញសម្ធឹងសេចក្តីទំនេរ ចាកនិមិត្តនោះ បរិកម្មថា* **"អាកាសោ អនន្តោ អាកាសមិនមានទីបំផុត"** *ដែលមានឧបេក្ខា ឯកគ្គតា ជា អង្គឈានប្រកបចូលនៅហើយ ដល់បញ្ចមជ្ឈានហើយ សម្ធឹងអាកាស សេចក្តីទំនេរ ធ្វើទាល់តែជាវសីជំនាញ ហៅថា អរូបជ្ឈាន ជាអប្បនា-សមាធិ ដល់ឧគ្គហនិមិត្តជាប់ចិត្តនៅប៉ុណ្ណោះ ហើយលើករូបនាមឡើង កាន់វិបស្សនា ពិចារណាឃើញច្បាស់ក្នុង្ព្រះត្រៃលក្ខណៈ គឺនឹកដល់ អាកាសសេចក្តីទំនេរ រូបនាមកើត ឈប់នឹក រូបនាមរលត់ជា* **អនិច្ចំ ទុក្ខំ អនត្តា** *កន្ធង្ញាណ ១៦ ឆ្ធង្ចាកគោត្របុថុជ្ជនទៅកាន់អរិយៈ*

បានព្រះនិញ្វានជាអារម្មណ៍ ជាព្រះអរិយៈប្រភេទឈានលាភីបុគ្គល ដោយ អាស្រ័យ **សមឋយានិកៈ** ។

៣៨- **វិញ្ញាណញ្ចាយតនៈ** ពិចារណាវិញ្ញាណសេចក្តីដឹងមិនមានទីបំផុត ជាកម្មដ្ឋាន សមគួរដល់ចរិតគ្រប់ចរិត ដោយលះចាកអាកាស មកសម្ចឹងវិញ្ញាណដែលដឹងអាកាស យកសេចក្តីទំនេរជាអារម្មណ៍ បរិកម្ម ថា "**វិញ្ញាណំ អនន្តំ វិញ្ញាណសេបក្តីដឹងមិនមានទីបំផុត**" ទាល់តែ កើតឧគ្គហនិមិត្តជាប់ចិត្ត តែមិនដល់បដិភាគនិមិត្ត ជាអប្បនាសមាធិនឹងន មានឧបេក្ខា ឯកគ្គតា ចូលប្រកបក្នុងបញ្ចមជ្ឈាន ហៅថា អរូបជ្ឈាន ហើយលើករូបនាមក្នុងអរូបជ្ឈានឡើងកាន់វិបស្សនា ពិចារណាឃើញ ច្បាស់ក្នុងព្រះត្រៃលក្ខណៈថា នឹកដល់សេចក្តីដឹង រូបនាមកើត ឈប់នឹក រូបនាមរលត់ ជា **អនិច្ចំ ទុក្ខំ អនត្តា** កន្ធងញាណ ១៦ ឆ្ងងចាកគោត្រ បុថុជ្ជនទៅកាន់អរិយៈ បានព្រះនិញ្វានជាអារម្មណ៍ ជាព្រះអរិយៈប្រភេទ ឈានលាភីបុគ្គល សម្រេចដោយអាស្រ័យ **សមឋយានិកៈ** ។

៣៩- **អាកិញ្ចញ្ញាយតនៈ** ពិចារណាសម្ចឹងសេចក្តីមិនមានអ្វី ជាកម្មដ្ឋាន សមគួរដល់ចរិតគ្រប់ចរិត នាំមកពិចារណាដោយអាស្រ័យ ជាប់មកចាកសម្ចឹងវិញ្ញាណ លះចាកការសម្ចឹងវិញ្ញាណសេចក្តីដឹងជា អារម្មណ៍ហើយ មកពិចារណាសេចក្តីមិនមានអ្វីជាអារម្មណ៍ ដោយបរិកម្ម ថា "**នត្ថិ កិញ្ចិ ។ បន្តិបបន្ទូបក៏មិនមាន ត្ចបម្ជយក៏មិនមាន**" ទាល់

តែកើតឧគ្គហនិមិត្តជាប់ចិត្ត តែមិនជាបដិភាគនិមិត្ត សម្ងឹងទៅលុះជាអប្បនាសមាធិ មានឧបេក្ខា និងឯកគ្គតា ជាអារម្មណ៍ចូលប្រកប ដែលតជាប់មកចាកបញ្ចមជ្ឈាន មកក្នុងទីនេះ ហៅថា អរូបជ្ឈាន ហើយលើករូបនាមក្នុងអរូបជ្ឈានឡើងកាន់វិបស្សនា ពិចារណាឃើញច្បាស់ក្នុងព្រះត្រៃលក្ខណៈថា នឹកដល់សេចក្តីមិនមានអ្វី រូបនាមកើត ឈប់នឹក រូបនាមរលត់ ជា **អនិច្ចំ ទុក្ខំ អនត្តា** កន្ទងញាណ ១៦ ឆ្លងចាកគោត្របុថុជ្ជនទៅកាន់អរិយគោត្រ បានព្រះនិព្វានជាអារម្មណ៍ ជាព្រះអរិយៈប្រភេទឈានលោកីបុគ្គល មានការសម្រេចដោយអាស្រ័យ **សមថយានិកៈ** ។

៤០- **ឧវិសញ្ញានាសញ្ញាយតនៈ** ពិចារណាសេចក្តីប្រាកដនៃសញ្ញាខ្លះ សេចក្តីមិនប្រាកដនៃសញ្ញាខ្លះ ដែលជាសញ្ញាសេចក្តីចាំស្ងួតជាកម្មដ្ឋាន សមគួរដល់ចរិតគ្រប់ចរិត ដោយការតជាប់មកពិចារណាសេចក្តីមិនមានអ្វីក្នុងអរូបជ្ឈានទី ៣ លះចាកសេចក្តីមិនមានអ្វី មកពិចារណាសញ្ញាសេចក្តីដឹងដ៏ស្ងួតទន់ បរិកម្មថា **"ឯតំ សន្តំ ឯតំ បណីតំ ឆេះសូប់ ឆេះប្រណីត"** ទាល់តែកើតឧគ្គហនិមិត្តនឹងន លុះជាអប្បនាសមាធិ មានឧបេក្ខា និងឯកគ្គតា ចូលប្រកបជាបញ្ចមជ្ឈានហៅថា អរូបជ្ឈាន ព្រោះបានសញ្ញាសេចក្តីមិនមែនរូបជាអារម្មណ៍ ហើយលើករូបនាមក្នុងអរូបជ្ឈានឡើងកាន់វិបស្សនា ពិចារណាព្រះត្រៃ-

លក្ខណៈឃើញច្បាស់ថា នឹកដល់សញ្ញាដែលសូប់ល្អិត រូបនាមកើត ឈប់នឹក រូបនាមរលត់ ជា **អនិច្ចំ ទុក្ខំ អនត្តា** *កនូវញាណ ១៦ ឆ្ងវចាកគោត្របុថុជ្ជនទៅកាន់អរិយៈ មានព្រះនិញ្ចានជាអារម្មណ៍ ជាព្រះអរិយៈប្រភេទឈានលាភីបុគ្គល សម្រេចដោយអាស្រ័យ* **សមថយានិកៈ** *។*

សមថយានិកៈចប់

ពោលអំពីវិបស្សនាយានិក:

បុគ្គលណា *កាន់យកនូវសេចក្ដីដ៏ច្បាស់ចាក់ធ្ងុះរហូតក្នុងរូបធម៌នាម-ធម៌* *ដោយមិនត្រូវអាស្រ័យសមថភាវនាមកមុន* *បានសមាធិត្រឹមខណិក-សមាធិ* *គឺដ៏ទាន់បច្ចុប្បន្នគ្រប់លក្ខណ: ជាគ្រឿងនាំទៅកាន់* **មគ្គ ផល និព្វាន** *បុគ្គលនោះឈ្មោះថា* **"វិបស្សនាយានិក:"** *បើអស់អាសវ-កិលេសជាអរហន្តបុគ្គលក្នុងជាតិនោះ* *ក៏ឈ្មោះថា* **"សុក្ខវិបស្សក:"** *ផ្ទុតដោយ* **បញ្ញាវិមុត្ដិ** *វិបស្សនានេះ* *មានឈ្មោះសម្រាប់ហៅបានច្រើនយ៉ាងច្រើនន័យ* *ហៅថា* **បញ្ញា** *ក៏មាន* *ហៅថា* **ញាណ** *ក៏មាន* *ហៅថា* **វិជ្ជា** *ក៏មាន* *ហៅថា* **បក្ខុបញ្ញា** *(ដួងភ្នែកឃើញធម៌)* *ក៏មាន* *ហៅថា* **អាលោក:** *ពន្លឺក្ដីក៏មាន* *ព្រោះវិបស្សនា* *ជាសេចក្ដីឃើញជាក់ច្បាស់ក្នុងលោកធាតុ* *ជាវិធីនាំផ្លូវទៅកាន់ដែន* **អមត:** *ដ៏ជាបរមសុខគឺព្រះនិព្វាន* *រលត់ទុក្ខអស់រលីងមិនមានចំណែកសល់ ។*

វិបស្សនាញាណនេះ *ប្រព្រឹត្ដទៅក្នុងផ្លូវ* **អដ្ឋង្គិកមគ្គ ៨ វិសុទ្ធិ ៧** *និង* **ពោធិបក្ខិយធម៌ ៣៧** *។* *ពោលដោយសង្ខេប* *គឺសិក្ខា ៣* *ពោលដោយថ្នាក់កណ្ដាល* *គឺវិសុទ្ធិ ៧* *ពោលដោយពិស្ដារ* *គឺពោធិបក្ខិយធម៌ ៣៧* *ដូចនឹងសម្ដែងល្មមជាទីចូលចិត្ដក្នុងភាគបរិយត្ដិតទៅនេះ ៖*

របស់ដែលកំណត់ *ឲ្យកំណត់រូបធម៌* *នាមធម៌* *ជាតួកម្មដ្ឋានវិបស្សនា* *គឺសតិបញ្ញា* *ជាអ្នកធ្វើកម្មដ្ឋាន* *ធ្វើទីអាយតន:ខាងក្នុង* *និងអាយតន:ខាង*

ក្រៅខ្ទប់គ្នា ធ្វើក្នុងវេលាដែលរូបនាមកើតជាបច្ចុប្បន្នកាល ។

របស់ដែលត្រូវពិសោធ ត្រូវពិសោធថា រូបនាមមានលក្ខណៈ ៣ ពិត ឲ្យផុតដោយវិមោក្ខ ៣ បានពិត នឹងដល់ព្រះនិញ្ចានធាតុ ធាតុរលត់ទុក្ខបានពិត ។

គោលពិសោធ ពិសោធដោយវិបស្សនាញាណ ដែលមានវិធីពិសោធ ៣ វិធីដូច្នេះ ៖

១- សិក្ខា ៣ ខបដិបត្តិ ឬហៅថាការសិក្សា ៣

ក- **សីលសិក្ខា** បដិបត្តិសីល រៀរអាក្រក់ គឺវិបស្សនានាំយកសតិ រព្ចកដឹងទាន់ខណៈរូបនាមនិយាយ (រៀរមោហៈជាដើម ជា **សម្មាវាចា** និយាយត្រូវ) វិបស្សនានាំយកសតិ រព្ចកដឹងទាន់ខណៈរូបនាមធ្វើការឈរ ដើរ អង្ក្ុយ ដេក បត់ កង្ក្ុញ កម្រើក ក្នុងការងារគ្រប់យ៉ាង រាប់តាំងអំពីភ្ញាក់ពីដេក លុះចូលដេក (រៀរមោហៈជាដើម ជា **សម្មាកម្មន្តោ** ធ្វើការងារត្រូវ) ។

វិបស្សនា គឺតួសតិរព្ចកដឹងទាន់បច្ចុប្បន្នរបស់រូបនាម ខណៈនិយាយ ខណៈរូបនាមធ្វើការងារ ដឹងទាន់រូបនាមខណៈឃើញ ដឹងទាន់រូបនាមខណៈបានព្ទ ដឹងទាន់រូបនាមខណៈដឹងក្ខិន ដឹងទាន់រូបនាមខណៈដឹងរស ដឹងទាន់រូបនាមខណៈដឹងសម្ផស្សត្រជាក់ ក្តៅ ទន់ រឹង (រៀរមោហៈជាដើម ជាសីល ហៅថា **សម្មាអាជីវោ** រស់នៅប្រពៃ) ។

ឯវិបស្សនាដែលយកសតិដឹងទាន់បច្ចុប្បន្នរបស់រូបនាមគ្រប់ខណៈ ដែលសម្តែងហើយនេះចាត់ជា **សីលសិក្ខា** សីលក្នុងមគ្គ ៨, រៀវ **មោហៈ** សេចក្តីវង្វេង **លោភៈ** សេចក្តីចង់បាន **ទោសៈ** សេចក្តីក្រោធ ចាត់ជាសីលក្នុងវិបស្សនា, រៀវមូលនៃសេចក្តីអាក្រក់ទាំងពួងចេញបាន សេចក្តីអាក្រក់ដែលធ្វើផ្លូវកាយ វាចា និងផ្លូវចិត្តក៏មិនកើត ជាបច្ច័យឲ្យកើតសមាធិដែលជាតួចិត្តសិក្ខាតទៅ ។

១- **ចិត្តសិក្ខា** បដិបត្តិសមាធិឲ្យចិត្តស្ងប់បរិសុទ្ធ គឺវិបស្សនាព្យាយាមយកសតិដឹងទាន់រូបនាមដែលជាបច្ចុប្បន្នរឿយៗ កាលវង្វេងក៏ព្យាយាមតាំងសតិរឿយៗ ជា **សម្មាវាយាមោ** ព្យាយាមប្រពៃ សតិដឹងទាន់បច្ចុប្បន្នរបស់រូបនាមជានិច្ច គ្រប់ខណៈនោះជា **សម្មាសតិ** រឭកដឹងទាន់ប្រពៃ វិបស្សនាអាស្រ័យសេចក្តីព្យាយាម មានសតិរឭកដឹងទាន់រូបនាមគ្រប់ខណៈ មានសម្បជញ្ញៈ ដឹងទាន់គ្រប់ឥរិយាបថយ៉ាងនេះ ហើយជាបច្ច័យឲ្យមានសមាធិគ្រប់ៗខណៈ ជាខណិកសមាធិ គឺមិនវង្វេងគ្រប់ខណៈ ជា **សម្មាសមាធិ** តាំងចិត្តមាំប្រពៃ រាគៈ ទោសៈ មោហៈជារបស់ដែលធ្វើឲ្យចិត្តសៅហ្មង មិនមានឱកាសចូលទៅធ្វើឲ្យចិត្តមានមន្ទិលសៅហ្មងឡើយ ចិត្តទើបស្អាតបរិសុទ្ធ ក្នុងចិត្តសិក្ខានេះ ទើបចិត្តដែលចូលដល់សមាធិក្នុងអដ្ឋង្គិកមគ្គ ជាបច្ច័យឲ្យកើតបញ្ញាសិក្ខា ។

គ- **បញ្ញាសិក្ខា** សិក្សាបដិបត្តិឲ្យវិបស្សនាញាណកើតឡើងឃើញ

ច្បាស់ក្នុងរូបធម៌ នាមធម៌ ដោយមានលក្ខណៈ ៣ ជាគោលជាប់នៅ ដោយទីវិបស្សនា នាំយកសតិរុកដឹងទាន់បច្ចុប្បន្នរបស់រូបនាមច្រើន លុះមានសមាធិមិនវង្វេង លះបញ្ញត្តិបាន ខណៈឃើញ ក៏ដឹងត្រឹមឃើញពណ៌ប៉ុណ្ណោះ មិនហួសទៅដល់បញ្ញត្តិដទៃ ខណៈបានឮ ក៏ដឹងត្រឹមបានឮសំឡេងមិនហួសទៅដល់បញ្ញត្តិដទៃ ខណៈដឹងក្លិន ក៏ដឹងត្រឹមក្លិន មិនហួសទៅដល់សម្មតិបញ្ញត្តិដទៃ ខណៈដឹងរស ក៏ដឹងត្រឹមរស មិនហួសទៅដល់សម្មតិបញ្ញត្តិដទៃ ខណៈដឹងសម្ផស្ស ក៏ដឹងត្រឹមត្រជាក់ ក្តៅ ទន់ រឹង ដឹងខណៈខ្ទប់ (ប៉ះពាល់) ប៉ុណ្ណោះ មិនហួសទៅដល់បញ្ញត្តិដទៃ ខណៈនឹកគិត ឈរ ដើរ អង្គុយ បត់ លាត កម្រើក ក៏ដឹងត្រឹមអវយវៈកម្រើកទៅ នឹងដឹងនឹកគិតប៉ុណ្ណោះ មិនហួសទៅដល់បញ្ញត្តិដទៃ ទើបមានវិបស្សនាដឹងឃើញរូបនាមកើតរលត់ទាំង ៦ ទ្វារ (ជា **សម្មាទិដ្ឋិ** មានបញ្ញាដែលឃើញប្រពៃ) លុះដឹងឃើញរូបនាមរលត់ទៅៗ ច្បាស់ មានលក្ខណៈប្រាកដនៅ ៣ ប្រការគឺ ៖

១- **អនិច្ចំ** មានលក្ខណៈតាំងនៅមិនបាន (មិនទៀង) ត្រូវរលត់ទៅ ។

២- **ទុក្ខំ** មានលក្ខណៈធន់នៅមិនបាន (ធន់បានដោយក្រ) ត្រូវរលត់ទៅ ។

៣- **អនត្តា** មានលក្ខណៈបង្គាប់បញ្ជាមិនបាន (មិនមែនខ្លួន) ត្រូវរលត់ទៅ ។

ប្រាកដនៅយ៉ាងនោះ ប្រហារអនុស័យដែលដេកជាប់នៅក្នុងសន្តានឲ្យ តិចចុះស្រាលស្តើងទាល់តែអស់រលីង កាលណា កាលនោះ ក៏បានឈ្មោះថា **វិមោក្ខ** សេចក្តីផុតយ៉ាងណាមួយ ក្នុង ៣ យ៉ាងគឺ ៖

១- អ្នកមានវិបស្សនា ឃើញរូបនាមមានលក្ខណៈ **អនិច្ចំ** តាំងនៅមិនបាន គួរដល់និស្សយដែលមានសីលជាបុញ្ញាធិការ(១) មកអំពីមុនខ្ទះ ផុតដោយ **អនិមិត្តវិមោក្ខ** មិនមានសង្ខារនិមិត្ត ជារបស់ទៀងនៅបានដាច់ខាត ដល់ **អនិមិត្តនិញ្ចាន** គឺនិញ្ចានរលត់រូបនាម មិនមានគ្រឿងសម្គាល់ ។

២- អ្នកមានវិបស្សនា ឃើញរូបនាមមានលក្ខណៈ **ទុក្ខំ** ធន់នៅមិនបាន គួរដល់និស្សយដែលមានសមាធិជាបុញ្ញាធិការមក ផុតដោយ **អប្បណិហិតវិមោក្ខ** ឥតមានរាគៈ ទោសៈ មោហៈ ឡើយ ប្រហារតណ្ហាដែលត្រេកអរក្នុងសុខចេញបានដាច់ខាត ដល់ **អប្បណិហិតនិញ្ចាន** គឺនិញ្ចានរលត់រូបនាមឥតតណ្ហារាគៈ ទោសៈ មោហៈឡើយ ។

៣- អ្នកមានវិបស្សនា ឃើញរូបនាមមានលក្ខណៈ **អនត្តា** មិនមានអំណាចនឹងបង្គាប់បញ្ជាបាន គួរដល់និស្សយដែលមានបញ្ញាជាបុញ្ញាធិការមក ផុតដោយ **សុញ្ញតវិមោក្ខ** ទំនេរទទេ មិនមានអត្តាតួខ្ជួនឡើយ ដល់និញ្ចានដោយ **សុញ្ញតនិញ្ចាន** គឺនិញ្ចានរលត់រូបនាម ទំនេរមិនមានអ្វី ។

---

(១) និស្សយកសាងពីដើម ។

ទាំង ៣ ដែលសម្តែងមកហើយ អ្នកបដិបត្តិ បដិបត្តិលុះបានព្រះនិញ្ចានជាអារម្មណ៍ ឈ្មោះថា **វិបស្សនាយានិក:** *កនូងញ្ញាណ ១៦ ហើយដោយបរិបូណ៌ ។*

២- វិសុទ្ធិ ៧ ប្រការ

ផ្លូវដែលប្រព្រឹត្តទៅដើម្បីសេចក្តីបរិសុទ្ធម៉ត់ចត់ គឺវិសុទ្ធិមគ្គទាំង ៧ ប្រការ ជាវិធីទី ២ ដែលនឹងនាំអ្នកបដិបត្តិឲ្យដល់អមតមហានិញ្ចានបានតាមលំដាប់ ដូចនឹងសម្តែងតទៅគឺ ៖

១- **សីលវិសុទ្ធិ** *សេចក្តីបរិសុទ្ធម៉ត់ចត់នៃសីល ដែលចែកជា ២ ប្រភេទគឺ ចតុបារិសុទ្ធិសីលមួយយ៉ាង និងសីលក្នុងអដ្ឋង្គិកមគ្គមួយយ៉ាង ។ សីលវិសុទ្ធិនេះ បំណងសំដៅយកសីលក្នុងមគ្គ ៨ ជាប្រការសំខាន់ ព្រោះជាមូលបុសគល់ឲ្យមានចតុបារិសុទ្ធិសីលបានបរិបូរ និងចតុបារិសុទ្ធិសីលក៏ជាបច្ច័យឲ្យកើតសីលវិសុទ្ធិក្នុងអង្គមគ្គ ៨ ឬនឹងថាជាមួយគ្នាក៏បាន មកញ្ញែកសម្តែងជា ២ ផ្នែក ក៏ដើម្បីនឹងបានសេចក្តីច្បាស់ប៉ុណ្ណោះ កាលចង្អុលអង្គធម៌ហើយ បានដល់* **វិរតិបេតសិក** *រៀរបាបធម៌ដែលជាផ្លូវកាយ និងផ្លូវវាចានោះឯង ពោលគឺ ៖*

(១)- **បាតិមោក្ខសំវរសីល** *សម្រាប់ភិក្ខុ សម្រាប់យរាវាសបានដល់សីល ៥ សីល ៨ សីល ១០ ។*

(២)- **ឥន្ទ្រិយសំវរសីល** ការសង្រួមឥន្ទ្រីយ៍ផ្សេងៗ បានទាំងយរាវាស និងភិក្ខុ ។

(៣)- **អាជីវបារិសុទ្ធិសីល** រកចិញ្ចឹមជីវិតដោយសម្មាជីព គឺយរាវាសបានដល់ រៀរមិច្ឆាអាជីវៈផ្សេងៗ ក្នុងសម្មាអាជីវវិរតិ ចំណែកភិក្ខុនោះ រៀរកុលទូសកៈ និងអនេសនាផ្សេងៗ តាមព្រះវិន័យ ។

(៤)- **បច្ចយសន្និស្សិតសីល** គឺពិចារណាចតុបច្ច័យដែលទាយកទាយិកាថ្វាយ ខណៈបរិភោគ ។

ព្រះយោគាវចរអ្នកបដិបត្តិវិបស្សនាកម្មដ្ឋាននោះ គប្បីបដិបត្តិក្នុងចតុបារិសុទ្ធិសីល គឺឲ្យបរិសុទ្ធម៉ត់ចត់ជាមុន ដោយតាំងនៅក្នុងសុទ្ធិ ៤ ប្រការគឺ ៖

(១)- **ទេសនាសុទ្ធិ** ប្រែថា សេចក្តីបរិសុទ្ធដោយការសម្តែងសម្តាល់សេចក្តីថា ភិក្ខុដែលត្រូវលហុកាបត្តិ ត្រូវកែខៃដោយទេសនាបត្តិ ភិក្ខុដែលត្រូវគរុកាបត្តិ ដូចសង្ឃាទិសេស នៅបរិវាស-មានត្ត ភិក្ខុដែលត្រូវបារាជិកាបត្តិ ត្រូវកែខៃដោយសឹកចេញចាកព្រះវិន័យ ។ ចំណែកយរាវាសនោះ រក្សាសីលថ្មីក៏បាន ។

(២)- **សំវរសុទ្ធិ** ប្រែថា ការបរិសុទ្ធដោយសេចក្តីសង្រួម សំដៅសេចក្តីថា អ្នកដែលសង្រួមឥន្ទ្រីយ៍ កាលភ្ជាំងភ្ជាត់ទៅហើយ តាំងចិត្តសង្រួមឥន្ទ្រីយ៍ថ្មី ហើយអធិដ្ឋានថា អំពីនេះទៅ មិនឲ្យដូចយ៉ាងមុនទៀត

ឡើយ (បើមិនឲ្យដូចកាលមុនដូច្នេះហើយ) រក្សាតទៅបាន ។

(៣)- **ឯដ្ឋិសុទ្ធិ** ប្រែថា ការមានអាជីវបរិសុទ្ធ សំដៅសេចក្តីថា ភិក្ខុត្រូវវៀរកុលទូសក: អាការដែលធ្វើឲ្យត្រកូលខូចចេតនា ខូចសទ្ធា អនេសនា អាការដែលមិនគួរស្វែងរកផ្សេងៗ សំដៅសេចក្តីថា ត្រូវ រកចិញ្ចឹមជីវិតដោយប្រពៃដោយព្រះវិន័យ សម្រាប់យរាវាសនោះ វៀរ ចាកមិច្ចាជីពផ្សេងៗ ប៉ុណ្ណោះ ។

(៤)- **បច្ចវេក្ខណសុទ្ធិ** ប្រែថា បរិសុទ្ធិដោយការពិចារណា សំដៅ សេចក្តីថា ភិក្ខុ ឬយរាវាសក៏ដោយ ការបរិភោគនោះ ត្រូវមានការ ពិចារណាក្នុងបច្ច័យ ៤ ដោយបទថា **"បដិសង្ខា យោនិសោ បីវរំ, បិណ្ឌបាតំ, សេនាសនំ, ភេសជ្ជំ"** ជាដើម ។

កាលតាំងនៅក្នុងសុទ្ធិ ៤ ប្រការ របស់ចតុបារិសុទ្ធិសីលហើយ ជា អ្នកគួរដល់ការបដិបត្តិវិបស្សនា កាលដល់វេលាក៏ចូលបដិបត្តិវិបស្សនា ដោយអាការតាំងនៅក្នុងសីលរបស់មគ្ត ៨ គឺ ការមានសតិរព្ចកដឹងទាន់ បច្ចុប្បន្នគ្រប់ខណៈដែលរូបនាមនិយាយ គ្រប់ខណៈដែលរូបនាមធ្វើការងារ ព្យាយាមយកសតិដឹងទាន់បច្ចុប្បន្នរបស់រូបនាម ខណៈឃើញ ខណៈ បានឮ ខណៈដឹងក្ងិន ខណៈដឹងរស ខណៈដឹងសម្ផស្សផ្ទូវកាយ ខណៈ នឹកគិត និងខណៈឈរ ដើរ អង្គុយ ដេក បត់ លាត កម្រើក គឺរស់ នៅដោយការមានសតិ វៀរមោហៈសេចក្តីវង្វេង ជាសីលវិសុទ្ធិ ហើយ

ជាបច្ច័យឲ្យឈានឡើងកាន់ចិត្តវិសុទ្ធិបានដោយស្រួលតទៅ ។

២- **ចិត្តវិសុទ្ធិ** គឺសេចក្តីបរិសុទ្ធម៉ត់ចត់នៃចិត្ត បានដល់ចិត្តដែលចូលដល់សមាធិ ដោយខណិកសមាធិ ឬឧបចារសមាធិ ឬអប្បនាសមាធិ ក៏ឈ្មោះថាចូលដល់ចិត្តវិសុទ្ធិ មានចិត្តដ៏សស្អាតមិនសៅហ្មងកករល្អក់ ដោយអំណាចរបស់កិលេស ដោយការសម្ជឹងពិចារណាក្នុងកម្មដ្ឋាន ៤០ ដែលសម្តែងមកហើយណាមួយ លុះជាឧបចារសមាធិ ជិតភាពជាឈាន ឬអប្បនាសមាធិ ជាឈានតែម្តងក៏បាន ឬមិនដល់យ៉ាងនោះ គ្រាន់តែត្រឹមសតិដឹងទាន់រូបនាមគ្រប់ខណៈមិនវង្វេង កិលេសគឺលោភៈ ទោសៈ មោហៈ ចូលមិនបានឡើយ ជាខណិកសមាធិ មានចិត្តបរិសុទ្ធ ក៏ឈ្មោះថាជាចិត្តវិសុទ្ធិ អាចដែលនឹងញ្ញាំងបញ្ញាដឹងច្បាស់ឃើញពិតក្នុងសភាវធម៌ ដែលជាទិដ្ឋិវិសុទ្ធិសេចក្តីឃើញដ៏បរិសុទ្ធតទៅដោយស្រួល ។

៣- **ទិដ្ឋិវិសុទ្ធិ** គឺសេចក្តីបរិសុទ្ធម៉ត់ចត់នៃទិដ្ឋិ គឺមានសេចក្តីឃើញប្រពៃ ឃើញត្រូវតាមសេចក្តីពិត ជាសម្មាទិដ្ឋិ គឺបានកើតញាណឡើងដឹងនឹងរូបនាម ដឹងនឹងលក្ខណៈរបស់រូបនាម ដឹងនឹងនាទីរបស់រូបនាម ដឹងនឹងផលរបស់រូបនាម ដឹងនឹងហេតុជិតរបស់រូបនាម ឧបមាលក្ខណៈរបស់ចិត្តនោះគឺដឹងអារម្មណ៍ អាការដែលចិត្តជាប្រធាន ឬទៅមុននោះ ហៅថា **កិច្ច** របស់ចិត្ត ការដែលចិត្តមួយរលត់ តចិត្តមួយ ហៅថា **ផល** គឺ **បច្ចុប្បដ្ឋានៈ** ឯធម្មជាតិចិត្ត និងចេតសិក និងហទយវត្ថុរូប ហៅថា

បទដ្ឋាន: ដូច្នេះជាដើម ។ កាលព្រះយោគាវចរអ្នកបំពេញវិបស្សនា មានញាណកើតឡើងឃើញរូបនាមដូច្នេះហើយ ប្រហារទិដ្ឋិ ដែលប្រកាន់ថា **រូប** ជា **អត្ត:** **នាម** ជា **អត្ត:** បាន ការដែលប្រាសចាកអត្តទិដ្ឋិបានដូច្នេះ ហៅថា ទិដ្ឋិវិសុទ្ធិ ជាហេតុឲ្យឈានឡើងកាន់កង្ខាវិតរណវិសុទ្ធិបាន ក្នុងទិដ្ឋិវិសុទ្ធិនេះ បើចាត់ជាញាណ ក៏បានដល់នាមរូបបរិច្ឆេទញាណ ។

៤- **កង្ខាវិតរណវិសុទ្ធិ** សេចក្តីបរិសុទ្ធម៉ត់ចត់នៃការឆ្លងផុតសេចក្តីសង្ស័យ ជាញាណដែលអាចដឹងឃើញហេតុនៃនាមរូប គឺអវិជ្ជា តណ្ហា ឧបាទាន កម្ម និងអាហារ ទាំងនេះឯងដែលជាបច្ច័យឲ្យកើតរូប-នាម ផុតចាកសេចក្តីសង្ស័យបាន ក៏ព្រោះអាស្រ័យសេចក្តីដឹងមកចាកទិដ្ឋិវិសុទ្ធិ ឃើញថាខន្ធ ៥ រូបនាមនេះ មិនមែនជាអត្តាឡើយ មានការកើតរលត់ជាប្រក្រតី លុះដឹងច្បាស់ថា រូបនាមនេះ ក្នុងអតីតកាលក៏រស់នៅយ៉ាងនេះ ក្នុងបច្ចុប្បន្នកាលក៏កំពុងកើតរលត់នៅយ៉ាងនេះ ក្នុងអនាគតកាលគង់រស់នៅយ៉ាងនេះ កាលដឹងបានថា រូបនាមរស់នៅយ៉ាងនេះ សេចក្តីសង្ស័យផ្សេងៗ ក៏អន្តរធានទៅ គឺសង្ស័យថា ៖

១- យើងនេះ ធ្លាប់កើតមកក្នុងអតីតកាលឬ?

២- យើងនេះ មិនធ្លាប់កើតមកក្នុងអតីតកាលឬ?

៣- យើងធ្លាប់កើតមកជាជាតិអ្វីក្នុងអតីត?

៤- យើងធ្លាប់កើតមកជារូបរាងយ៉ាងណាខ្លះ?

៥- យើងធ្លាប់កើតជាអ្វីមកហើយ ជាអ្វីមកហ្ន៎?

៦- យើងនេះ នឹងទៅកើតក្នុងអនាគតកាលទៀតឬ?

៧- យើងនេះ នឹងមិនទៅកើតក្នុងអនាគតកាលទៀតឬ?

៨- យើងនឹងកើតជាជាតិអ្វីក្នុងអនាគត?

៩- យើងនឹងកើតជារូបរាងយ៉ាងណាខ្លះ?

១០- យើងនឹងកើតជាអ្វីទៀតហ្ន៎?

១១- ឥឡូវនេះ ជាយើងឬ?

១២- ឥឡូវនេះ មិនជាយើងឬ?

១៣- ឥឡូវនេះ យើងជាជាតិអ្វីហ្ន៎?

១៤- ឥឡូវនេះ យើងកើតជារូបរាងយ៉ាងណាហ្ន៎?

១៥- យើងមកពីណាហ្ន៎?

១៦- យើងនឹងទៅណាហ្ន៎?

កាលមិនមានការសង្ស័យដូចសម្តែងមកហើយនេះ សំដៅសេចក្តីថា ឃើញរូបនាមកើតរលត់ អស់សេចក្តីសង្ស័យក្នុងរឿងបច្ច័យរបស់រូបនាម និងអតីត-អនាគត ព្រោះមកដឹងបច្ចុប្បន្ន ជាកង្ខាវិតរណវិសុទ្ធិ នៅក្នុងលំដាប់របស់ **នាមរូបបច្ចយបរិគ្គហញាណ** និង **សម្មសនញាណ** ជាហេតុឲ្យឈានឡើងកាន់មគ្គាមគ្គញាណទស្សនវិសុទ្ធិតទៅ ។

៥- **មគ្គាមគ្គញាណទស្សនវិសុទ្ធិ** សេចក្តីបរិសុទ្ធម៉ត់ចត់នៃការ

ដឹងថាផ្លូវឬមិនមែនផ្លូវ ញាណដែលដឹងឃើញថាផ្លូវព្រះនិញ្ជាន ឬមិនមែនផ្លូវព្រះនិញ្ជាន កាលវិបស្សនាញាណកើតហើយ **វិបស្សូបក្កិលេស** ក៏រមែងកើតគឺ **ឱភាសៈ** ឃើញពន្លឺ, **ปีติ** មានសេចក្តីត្រេកអរចាស់ក្លា, **ปัสสัทธิ** មានសេចក្តីស្ងប់កាយស្ងប់ចិត្តចាស់ក្លាច្រើន, **អធិមោក្ខោ** មានសទ្ធាបង្អោនចិត្តជឿចាស់ក្លា, **ปัคคหะ** មានសេចក្តីព្យាយាមចាស់ក្លា, **សុខៈ** មានសេចក្តីសុខចាស់ក្លា, **ญาณะ** មានសេចក្តីដឹងចាស់ក្លា, **ឧปัฏฐานะ** មានសតិប្រាកដច្បាស់គ្រប់យ៉ាង, **ឧเบกฺขา** មានសេចក្តីព្រងើយៗច្រើន, **นิกนฺติ** មានសេចក្តីពេញ(ចិត្ត)ក្នុងពន្លឺជាដើម រួមវិបស្ស-នូបក្កិលេសនេះ ជាទីតាំងទីអាស្រ័យរបស់តណ្ហា មានៈ នោះឯង ព្រោះដូច្នោះអ្នកបដិបត្តិវិបស្សនាត្រូវមានសេចក្តីដឹងថា **อมคฺคะ** មិនមែនផ្លូវជារឿងរបស់កិលេស ក្នុងវិបស្សនាញាណប៉ុណ្ណោះ កាលផុតចាកវិបស្ស-នូបក្កិលេសហើយ ទើបជាបដិបទាផ្លូវទៅព្រះនិញ្ជាន ហៅថា **มคฺค** ឯបញ្ញាដែលអាចដឹងផ្លូវ និងមិនមែនផ្លូវទម្លាយសេចក្តីចូលចិត្តខុសចេញ គង់ធ្វើសេចក្តីឃើញឲ្យត្រង់ផ្លូវ គឺរូបនាមដែលមានលក្ខណៈ **อนิจฺจํ ทุกฺขํ อนตฺตา** កើតរលត់នៅគ្រប់ខណៈ ឃើញជាភ័យ ជាទោស គួរនឿយណាយចង់នឹងគេចរត់ ចង់នឹងរួចផុត ព្យាយាមរកផ្លូវរត់ តែកាលរត់មិនផុត ក៏ត្រូវមើលព្រងើយនៅដូច្នេះ ឈ្មោះថាមគ្គាមគ្គញាណទស្សនវិសុទ្ធិ បរិសុទ្ធិម៉ត់ចត់ដោយសេចក្តីដឹងឃើញថាផ្លូវឬមិនមែនផ្លូវ តាមលំដាប់របស់

វិបស្សនាញាណ តាំងអំពី **ឧទយព្វយញាណ** *ដល់* **សង្ខារុបេក្ខាញាណ** *ជាហេតុឲ្យឈានឡើងកាន់បដិបទាញាណទស្សនវិសុទ្ធិតទៅ ។*

៦- **បដិបទាញាណទស្សនវិសុទ្ធិ** *សេចក្តីបរិសុទ្ធម៉ត់ចត់នៃសេចក្តីដឹង សេចក្តីឃើញ ក្នុងបដិបទា ផ្ទូវទៅកាន់ព្រះនិញ្វានដោយទៀងទាត់អាស្រ័យមគ្គាមគ្គញាណទស្សនវិសុទ្ធិ ជាបច្ចុ័យឲ្យផុតចាកអន្តរាយផ្សេងៗ ដែលកើតអំពីវិបស្សនូបក្កិលេសនោះ សម្ចឹងដល់សេចក្តីកើតរលត់របស់រូបនាមតាមន័យត្រៃលក្ខណៈតទៅទៀត ឃើញរូបនាមរលត់ទៅៗ ជាភ័យ ជាទោស គួរនឿយណាយប្រាថ្នានឹងរត់ចាករូបនាម រកផ្ទូវរត់ចាករូបនាម លុះវិធីក្រសែចិត្តមាំក្នុងអរិយសច្ចធម៌ មានចិត្តបង្អោនទៅកាន់ព្រះនិញ្វាន ដោយចំណែកមួយ ឧបមាដូចបុរសដែលរត់អំពីភ័យផ្សេងៗ ក្នុងកាលដល់ទន្ទេ ស្ទឹង នឹងលោតឆ្ងងទន្ទេ ស្ទឹង ឬឡើងដើមឈើផុតចុង ឬដូចខ្សែដែលតឹងជិតនឹងដាច់ដូច្នេះ កន្ងញាណតាំងអំពី* **ឧទយព្វយញាណ** *ដល់* **គោត្រភូញាណ** *មានសេចក្តីដឹង សេចក្តីឃើញថា ផុតចាកទុក្ខបានពិតប្រាកដ ផ្ទូវនេះ ហៅថា បដិបទាញាណទស្សនវិសុទ្ធិ ជាហេតុជាបច្ចុ័យឲ្យឈានកន្ងឡើងកាន់ញាណទស្សនវិសុទ្ធិតទៅ ។*

៧- **ញាណទស្សនវិសុទ្ធិ** *សេចក្តីបរិសុទ្ធម៉ត់ចត់នៃការដឹង ការឃើញព្រះនិញ្វាន ជាវិសុទ្ធិដែលប្រាសចាកកិលេសតណ្ហាគ្រឿងមន្ទិល*

ទាំងមូលដោយវិបស្សនាញាណចាស់ក្លាឡើង អាស្រ័យកម្លាំងដែលបានទទួលចាកបដិបទាញាណទស្សនវិសុទ្ធិ ជាបច្ច័យឲ្យកើតមគ្គវិថីដែលជាអប្បនាវិថីហើយកាលណា ក៏រមែងមិនឡើងដល់កាលវេលាឡើយ ត្រូវកន្ទ្រងលំដាប់របស់វិថីភ្ជាមដោយកើតចិត្តឡើងគ្រាដំបូងចាកកវង្ក ជា **ភវង្គ**ចលនៃ: កវង្ក្ខកម្រើក ជាបច្ច័យឲ្យកើត **ភវង្គុបច្ឆេទ**: កាត់ខ្សែកវង្ក ហើយរលត់ចុះឲ្យកើត **មនោទ្វារាវជ្ជនៃ**: វិបស្សនាពិចារណាត្រៃលក្ខណៈ ជាអារម្មណ៍ហើយរលត់ចុះ បញ្ជូនឲ្យដល់ ** បរិកម្ម** មានត្រៃលក្ខណៈជាអារម្មណ៍ហើយរលត់ចុះ បញ្ជូនឲ្យកើត **ឧបចារ:** បានត្រៃលក្ខណៈជាអារម្មណ៍ហើយរលត់ចុះ បញ្ជូនឲ្យ **អនុលោមញ្ញាណ** វិបស្សនារបស់ព្រះយោគាវចរ ខណៈដែលដល់អនុលោមញ្ញាណនេះហៅថា **រូដ្ឋានគামិ-នីវិបស្សនា** គឺដល់កំពូលវិបស្សនាកម្មដ្ឋានហើយរលត់ចុះ បញ្ជូនដល់ នាទីរបស់ **គោត្រភូ** ផ្ទើកិច្ចធ្ងន់ចាកគោត្របុថុជ្ជនមានព្រះនិញ្ជានជាអារម្មណ៍ ហូរទៅកាន់អរិយមគ្គ អរិយផល កាលគោត្រភូរលត់ចុះហើយ បញ្ជូនឲ្យអរិយមគ្គកើតម្តង ដឹងឃើញព្រះនិញ្ជាន រលត់តណ្ហាជាទីបំផុតនៃទុក្ខ មានមគ្គសច្ចប្រជុំព្រមបរិបូរទាំង ៨ ហើយរលត់ចុះ បញ្ជូនឲ្យអរិយ-ផលកើត ២-៣ ដង មានព្រះនិញ្ជានជាអារម្មណ៍ ហើយរលត់ចុះកាន់ភវង្ក-ចិត្ត តអំពីនោះ បច្ចវេក្ខណវិថីកើត ក៏កើតឡើងពិចារណាមគ្ត ផលនិញ្ជាន និងកិលេសដែលសល់ ដែលលះហើយតទៅ ដែលហៅថា **បច្ចវេក្ខណ-**

ញាណ ញាណទី ១៦ ឧបមាដូចបុរសមួយនាក់ ចេញទៅមើលព្រះច័ន្ទ ក្នុងកណ្តាលយប់ ដំបូងមិនឃើញព្រះច័ន្ទ ព្រោះផ្ទៃមេឃពេញទៅដោយ សេចក្តីងងឹត ពពកខ្មៅ គ្រាកាលខ្យល់ផាត់ទៅ ៣ ដង អាចដែលនឹង សម្លឹងមើលឃើញព្រះច័ន្ទបានដូចម្តេច ក្នុងមគ្គវិថីក៏ដូច្នោះ ដូចគ្នា ក្នុង ខណៈដែលមគ្គញាណផលញាណ និងបច្ចវេក្ខណញាណ បានព្រះ និព្វានជាអារម្មណ៍ ឃើញច្បាស់ដឹងពិតក្នុងព្រះនិព្វាន ព្រះនិព្វានជាទីបាន ទីដល់ ទីបានលុះ របស់អរិយមគ្គអរិយផល ទើបចាត់ចូលក្នុងញាណ-ទស្សនវិសុទ្ធិ សេចក្តីបរិសុទ្ធនៃសេចក្តីដឹងសេចក្តីឃើញព្រះនិព្វានដូច្នេះ កន្ទងញាណ ១៦ ហើយផុតចាកបុថុជ្ជនដោយការឃើញ **អនិច្ចំ** របស់ រូបនាមជាបច្ច័យដល់ព្រះនិព្វាន ដោយអនិមិត្តវិមោក្ខ ផុតដោយការរលត់ មិនមាននិមិត្ត អ្នកឃើញ **ទុក្ខំ** ផុតដោយអប្បណិហិតវិមោក្ខ អ្នកឃើញ **អនត្តា** ផុតដោយសុញ្ញតវិមោក្ខ បានទាំងសមថយានិក: និងវិបស្សនា-យានិក: ។

៣- ពោធិបក្ខិយធម៌ ៣៧ ប្រការ

ធម៌ដែលជាបក្ខពួក (ចំណែក) នៃសេចក្តីត្រាស់ដឹង គឺពោធិបក្ខិយ-ធម៌ ៣៧ ប្រការនេះ រមែងប្រជុំព្រម កាលវិបស្សនាញាណកើតបរិបូរ ក្នុងយោគីអ្នកបដិបត្តិវិបស្សនាកម្មដ្ឋាន ជាទេសនាវិធីយ៉ាងពិស្តារ ដែល ជាផ្លូវទៅកាន់ព្រះនិព្វាន របស់អង្គសម្តេចព្រះសម្មាសម្ពុទ្ធជាអម្ចាស់ ដែល

ជាពួកធម៌ ៧ ពួកគឺ ៖

១- **ពួកសតិបដ្ឋាន** ៤ បានដល់សតិចេតសិកមួយ ដែលគ្រប់គ្រងកាយានុបស្សនា ១ វេទនានុបស្សនា ១ ចិត្តានុបស្សនា ១ ធម្មានុបស្សនា ១ ដែលជាទីតាំងរបស់សតិគឺ

ក- **កាយានុបស្សនាសតិបដ្ឋាន** គឺពិចារណាកាយរឿយៗ ដោយមានសតិជាទីតាំង ដើម្បីប្រហារ **សុភសញ្ញា** ដែលជាសញ្ញាវិបល្ចាសសម្ចឹងពិចារណាកាយថា **អានាបាណស្សតិ** សតិកំណត់ដឹងខ្យល់ដង្ហើមចូល-ចេញក្តី **ឥរិយាបថបព្វ:** មានសតិរព្ចកដឹងទាន់ក្នុងឥរិយាបថធំគឺ ឈរ ដើរ អង្គុយ ដេកក្តី **សម្បជញ្ញបព្វ:** មានសតិដឹងទាន់ឥរិយាបថតូចគឺ បត់ លាត កម្រើកក្តី **បដិកូលធាតុ** និង **នវសីវថិកា** ក្តី មានសតិកំណត់ក្នុងកាយ តាមន័យរបស់មហាសតិបដ្ឋានហើយ ក៏នឹងដឹងបានថា រាងកាយនេះមិនស្រស់ មិនល្អ មិនគួរមើល មិនគួរស្រឡាញ់ មិនគួររីករាយ ជាអសុភពិតៗ ដូច្នេះជាដើម ហើយលើកឡើងកាន់វិបស្សនាពិចារណាព្រះត្រៃលក្ខណៈរបស់រូបនាម ឃើញកើតរលត់ច្បាស់ កន្ធងញាណ ១៦ បានព្រះនិព្វានជាអារម្មណ៍ ដោយការចម្រើនកាយានុបស្សនា-សតិបដ្ឋាននេះបាន ។

ខ- **វេទនានុបស្សនាសតិបដ្ឋាន** សម្ចឹងពិចារណាវេទនារឿយៗ ដោយមានសតិកំណត់ដឹងទាន់ជាទីតាំង សុខក៏ដឹងទាន់ ទុក្ខក៏ដឹងទាន់ ឧបេក្ខា

ក៏ដឹងទាន់ ដើម្បីប្រហារវិបល្ចាសក្នុងការសោយសុខ ទុក្ខ ឧបេក្ខាវេទនា ថាមានសេចក្តីសុខ មានសេចក្តីសប្បាយ គួររីករាយ គួរចង់បានជាដើម តណ្ហាដែលប្រកបនឹងវេទនាទាំងអស់ ហៅថា **សុខវិបល្លាស** កាលបើ មានសតិកំណត់ ក៏ដឹងថា ការសោយវេទនាទាំងអស់ ឥតមានសេចក្តីសុខ ឡើយ មានតែទុក្ខ ធន់មិនបានទាំងនោះ លើកឡើងកាន់ព្រះត្រៃលក្ខណៈ វិបស្សនាឃើញជាក់ច្បាស់ក្នុងនាមវេទនាថា កើតឡើងហើយរលត់ទៅ ជា **អនិច្ចំ ទុក្ខំ អនត្តា** កន្ធងញាណ ១៦ បានព្រះនិញ្ចានជាអារម្មណ៍ ដោយមានវេទនានុបស្សនាសតិបដ្ឋានជាបច្ច័យបាន ។

គ- **ចិត្តានុបស្សនាសតិបដ្ឋាន** គឺតាំងសតិពិចារណាចិត្តរឿយៗ បានដល់ការដឹងទាន់ថា ចិត្តជារាគៈ ចិត្តជាទោសៈ ឬចិត្តជាមានះជាដើម លុះដឹងច្បាស់ថា ចិត្តនេះរមែងកើតហើយរលត់ សូន្យបាត់ទៅគ្រប់ខណៈ ដូចនឹងផ្ទេកបន្ទោរឥតទៀងឡើយ ដក **និច្ចសញ្ញា** ប្រហារ **និច្ចវិបល្លាស** សេចក្តីឃើញថា ចិត្តទៀង ចិត្តមិនរលត់ចេញបាន ដោយឃើញ **អនិច្ចំ** មិនទៀង ត្រូវកើតរលត់ទទួលអារម្មណ៍ផ្សេងៗ នៅគ្រប់ខណៈវិបស្សនា ឃើញជាក់ច្បាស់ដោយត្រៃលក្ខណៈដូច្នោះហើយ ញាណក៏កើតឡើង តាមលំដាប់របស់ញាណ ១៦ បាននិញ្ចានជាអារម្មណ៍ ព្រោះអាស្រ័យ ចិត្តានុបស្សនាសតិបដ្ឋានជាខាងដើម ។

ឃ- **ធម្មានុបស្សនាសតិបដ្ឋាន** តាំងសតិកំណត់ពិចារណាធម៌

រឿយៗ ថាគ្រាន់តែជាធម៌ មិនមែនសត្ត បុគ្គល ត្ថខ្ជួន យើង គេ គឺមាន សតិរព្ធកដឹងទាន់ លុះកើតបញ្ញាយើញ **អនត្តាធម៌** ការសម្ជឹងធម្មា-នុបស្សនាសតិបដ្ឋាន ដើម្បីប្រហារ **អត្តសញ្ញា** សេចក្តីយើញថាជាខ្ជួន ជាប្រាណដែលជា **អត្តវិបល្លាស** គឺកាន់ថា ជាអត្តាត្ថខ្ជួន ជាបុគ្គល ជាសត្ត ខ្ជួនយើង ខ្ជួនរបស់យើង មាននៅជាប្រក្រតី មានសតិកំណត់ដឹងទាន់ក្នុង នីវរណៈ៥ក្តី ក្នុងឧបាទានក្ខន្ធក្តី ដោយអាស្រ័យសម្មប្បធាន ព្យាយាម ពិចារណាលុះកើតបញ្ញា មានពោជ្ឈង្ត ៧ ចូលប្រកប ដឹងអរិយសច្ចទាំង៤ យើញតែរូបធម៌ នាមធម៌ មានកើតឡើងហើយរលត់ទៅទាំងអស់ជាអនត្តា ពិតបង្តាប់បញ្ជាមិនបានឡើយ ក៏ដឹងថាអត្តាត្ថខ្ជួននោះមិនមាន មានតែធម៌ គឺ រូបធម៌នាមធម៌ កើតរលត់ ជា **អនិច្ចំ ទុក្ខំ អនត្តា** កន្ធងញាណ ១៦ បានព្រះនិញ្ជានជាអារម្មណ៍ ព្រោះអាស្រ័យធម្មានុបស្សនាសតិបដ្ឋាន ជាបច្ចុ័យ ទើបផុតលោកិយ បានដោយវិមោក្ខ ៣ ណាមួយ ។

សតិបដ្ឋាននេះ ព្រះពុទ្ធអង្គទ្រង់សម្តែងឲ្យគួរដល់ចរិតរបស់អ្នក ប្រាថ្នាក្នុងធម៌ នឹងប្រព្រឹត្តបដិបត្តិ ដោយចាត់ជា ៤ ប្រភេទ គួរដល់ **តណ្ហាបរិត** និង **ទិដ្ឋិបរិត** គឺ

(១)- **កាយានុបស្សនាសតិបដ្ឋាន** គួរដល់តណ្ហាចរិតយ៉ាង គ្រោតគ្រាតសម្ជឹងរូបធម៌ជាកម្មដ្ឋាន ។

(២)- **វេទនានុបស្សនាសតិបដ្ឋាន** គួរដល់តណ្ហាចរិតយ៉ាងល្អិត

សម្ធឹងនាមធម៌ជាកម្មដ្ឋាន ។

(៣)- **បិត្តានុបស្សនាសតិបដ្ឋាន** *គួរដល់ទិដ្ឋិចរិតយ៉ាងគ្រោតគ្រាត សម្ធឹងនាមចិត្តជាកម្មដ្ឋាន ។*

(៤)- **ធម្មានុបស្សនាសតិបដ្ឋាន** *គួរដល់ទិដ្ឋិចរិតយ៉ាងល្អិតសម្ធឹងរូបធម៌ នាមធម៌ ជាកម្មដ្ឋាន ។*

២- **ពួកសម្មប្បធាន ៤** *បានដល់វីរិយចេតសិកមួយ ដែលឃុំគ្រង ឲ្យកើតសេចក្តីព្យាយាមគឺ*

ក- **សំវរបធាន** *ព្យាយាមរារាំងដើម្បីមិនឲ្យកើតអកុសលថ្មី ។*

ខ- **បហានបធាន** *ព្យាយាមលះអកុសលដែលកើតឡើងហើយ ។*

គ- **ភាវនាបធាន** *ព្យាយាមដើម្បីឲ្យកុសលចម្រើនឡើង ។*

ឃ- **អនុរក្ខនាបធាន** *ព្យាយាមរក្សាកុសលដែលកើតឡើងហើយ មិនឲ្យសូន្យទៅ ។*

សម្មប្បធាននេះ មានអត្ថាធិប្បាយថា **វីរិយ:** *ព្យាយាមតាំងសតិដ៏ធាន់ចំពោះបច្ចុប្បន្នរបស់រូបនាមគ្រប់ខណ: កាលដ៏ធាន់ខណ:ណា ក៏ឈ្មោះថាបានបិទរាំង មិនឲ្យអកុសល គឺរាគ: ទោស: មោហ: ហូរចូលមកតាមទ្វារទាំង ៦ ចំណែកអនុស័យដែលដេកវឿយៗ ជាប់នៅក្នុងភវង្គសន្តានក៏កើតឡើងមិនបាន កាលមានសតិ ដែលជាកំពូលរបស់កុសលកើតឡើង កុសលធម៌ពួកដទៃក៏កើតឡើងផង ឈ្មោះថា កុសលធម៌*

ចម្រើនឡើង ការព្យាយាមតាំងសតិដឹងទាន់បច្ចុប្បន្នធម៌រឿយៗ នោះឯងជាការរក្សាកុសលធម៌ទាំងឡាយឲ្យតាំងនៅ អាស្រ័យសេចក្ដីព្យាយាមនេះជាបទដ្ឋាន ឲ្យកើតវិបស្សនាបញ្ញាឡើង ដឹងជាក់ច្បាស់ក្នុងរូបធម៌នាមធម៌ កើតៗ រលត់ៗ មានលក្ខណៈមិនទៀង ជាទុក្ខ ជាអនត្តា កន្ទងញាណ ១៦ បានព្រះនិព្វានជាអារម្មណ៍ អ្នកឃើញ **អនិច្ចំ** ក៏ផុតចាកលោកិយ ដោយអនិមិត្តវិមោក្ខ អ្នកឃើញ **ទុក្ខំ** ក៏ផុតចាកលោកិយ ដោយអប្បណិហិតវិមោក្ខ អ្នកឃើញ **អនត្តា** ក៏ផុតចាកលោកិយ ដោយសុញ្ញតវិមោក្ខ ព្រោះអាស្រ័យសម្ផប្បធានទាំង ៤ នេះ ។

៣- **ពួកឥទ្ធិបាទ** ៤ គឺធម៌ដែលជាហេតុរបស់សេចក្ដីសម្រេចជាផ្លូវនៃសេចក្ដីសម្រេចរបស់លោកុត្តរៈ បានដល់

ក- **ឆន្ទៈ** សេចក្ដីពេញចិត្តក្នុងផ្លូវលោកុត្តរៈ ។

ខ- **វីរិយៈ** សេចក្ដីព្យាយាមក្នុងផ្លូវលោកុត្តរៈ ។

គ- **ចិត្តៈ** សេចក្ដីយកចិត្តទុកដាក់ក្នុងផ្លូវលោកុត្តរៈ ។

ឃ- **វិមំសា** សេចក្ដីពិចារណាដឹងច្បាស់ក្នុងផ្លូវលោកុត្តរៈ ។

ឥទ្ធិបាទក្នុងចំណែកពោធិបក្ខិយធម៌នេះ បានដល់ឆន្ទចេតសិក វីរិយ-ចេតសិក កុសលចិត្ត និងបញ្ញាចេតសិក រួមទាំងចិត្តនិងចេតសិកជាកម្លាំងឲ្យសម្រេច ដោយមានឆន្ទៈពេញចិត្តក្នុង **អមតបទ** ផ្លូវទៅកាន់ព្រះនិព្វាន គឺពេញចិត្តក្នុងការមានសតិ ដឹងទាន់បច្ចុប្បន្នធម៌រូបនាម

ត្រឹមតាំងសតិនៅជានិច្ច យកចិត្តចុចដោតនៅនឹងរូបនាមគ្រប់ខណៈ ទាល់តែកើតបញ្ញាវិមំសា ឃើញព្រះត្រៃលក្ខណៈរបស់រូបនាម ទាល់តែកន្ទុងញ្ញាណ ១៦ បានព្រះនិព្វានជាអារម្មណ៍ ផុតចាកលោកិយដោយវិមោក្ខ ៣ ណាមួយ ព្រោះអាស្រ័យឥទ្ធិបាទនេះជាមូល ។

៤- **ពួកឥន្ទ្រិយ ៥** គឺធម៌ដែលជាធំ គ្រប់គ្រងកុសលធម៌ទាំងពួងគឺ

ក- **សទ្ធិន្ទ្រិយ** បានដល់សទ្ធាចេតសិក ជាឥន្ទ្រីយ៍គ្រប់គ្រងជាធំក្នុងសេចក្ដីជឿ សេចក្ដីជ្រះថ្លា កាត់ចិត្តជាច់ស្រឡះចំពោះផ្លូវទៅកាន់ដែនលោកុត្តរៈគឺជឿចំពោះផ្លូវវិបស្សនាកម្មដ្ឋាន ។

ខ- **វីរិយិន្ទ្រិយ** បានដល់វីរិយចេតសិក ព្យាយាមបដិបត្តិវិបស្សនាដោយភាពជាធំ ជាកំពូលក្ងៀវក្ងា ដើម្បីនឹងឲ្យបានលុះដល់លោកុត្តរធម៌ ។

គ- **សតិន្ទ្រិយ** បានដល់សតិចេតសិក ដែលជាធំគ្រប់គ្រងនៅក្នុងសេចក្ដីរឭកបាន និងដឹងទាន់បច្ចុប្បន្នរបស់រូបនាម ដើម្បីនឹងនាំកុសលដែលជាមាគ៌ាទៅកាន់លោកុត្តរធម៌ ។

ឃ- **សមាធិន្ទ្រិយ** បានដល់ឯកគ្គតាចេតសិក ដែលគ្រប់គ្រងភាពជាធំក្នុងការធ្វើនាទីឲ្យដឹងតែអារម្មណ៍មួយ ដោយមិនឃ្លាតចាកបច្ចុប្បន្នធម៌ ដែលជាបច្ច័យឲ្យដល់លោកុត្តរធម៌ ។

ង- **បញ្ញិន្ទ្រិយ** បានដល់បញ្ញាចេតសិក ដែលធ្វើនាទីគ្រប់គ្រងជាធំ ក្នុងសេចក្ដីដឹងច្បាស់ឃើញពិត ក្នុងព្រះត្រៃលក្ខណៈរបស់រូបធម៌

នាមធម៌ កន្ធ៦ញ្ញាណ ១៦ ដល់លោកុត្តរធម៌ បានព្រះនិញ្ជានជាអារម្មណ៍ ផុតចាកលោកិយបានដោយវិមោក្ខ ៣ ណាមួយ ព្រោះអាស្រ័យសទ្ធា វីរិយ: សតិ សមាធិ ជាបច្ច័យឲ្យ ទើបជាឥន្ទ្រីយ៍ជាធំ គ្រប់គ្រង សហជាតធម៌ក្នុងពោធិបក្ខិយធម៌ឲ្យបរិបូរ ហុចឲ្យដល់លោកុត្តរធម៌ ឆ្ងាយចាកទុក្ខទាំងពួងបាន ។

៥- **ពួកពល:** ៥ គឺកម្លាំងធម៌ដែលជាកុសល ចំណែកពោធិបក្ខិ-យធម៌ នឹងនាំឆ្ងងអន្ទង់ដ៏ធំ ឬជាមេទ័ពដែលនឹងច្បាំងសត្រូវ គឺកិលេសឲ្យវិនាសសាបសូន្យទៅដោយកម្លាំង ៥ ប្រការគឺ

ក- **សទ្ធាពល:** កម្លាំងគឺសទ្ធា ជឿមាំចំពោះបដិបទាផ្លូវបដិបត្តិ ដើម្បីមគ្គផល និញ្ជាន បានដល់ការជឿក្នុងវិបស្សនាកម្មដ្ឋាននោះឯង ។

ខ- **វីរិយពល:** កម្លាំងគឺសេចក្តីព្យាយាមដ៏ក្លៀវក្លា ដែលនឹងបដិបត្តិធ្វើសតិរព្ធកដ៏ងទាន់បច្ចុប្បន្នធម៌របស់រូបធម៌ នាមធម៌ បង្ក្រាបសត្រូវគឺកិលេសឲ្យសាបសូន្យ ដើម្បីដ៏ងច្បាស់នូវលោកុត្តរធម៌ ។

គ- **សតិពល:** កម្លាំងគឺសតិ រព្ធកដ៏ងទាន់បច្ចុប្បន្នរបស់រូបនាម រាំងរាសេចក្តីភ្លេចភ្លាំង ដើម្បីជាបច្ច័យដល់មគ្ត ផល និញ្ជាន ។

ឃ- **សមាធិពល:** កម្លាំងគឺសមាធិ មានសតិមាំមួនមិនភ្លេចភ្លាំង នឹងនក្នុងបច្ចុប្បន្នធម៌គ្រប់ខណ: ដើម្បីនឹងឲ្យជាកម្លាំងយ៉ាងខ្ជង់ខ្ជស់ ឈានឡើងកាន់លោកុត្តរធម៌ ។

ង- **បញ្ញាពល:** *កម្ចាំងគឺបញ្ញា សេចក្ដីដឹងក្នុងបច្ចុប្បន្នធម៌ ដែលជាអារម្មណ៍របស់វិបស្សនា ឃើញលក្ខណៈរបស់រូបនាម ជា* **អនិច្ចំ ទុក្ខំ អនត្តា** *កន្ទងញាណ ១៦ បានព្រះនិព្វានជាអារម្មណ៍ ផុតចាកលោកិយ ដោយវិមោក្ខ ៣ ណាមួយ ដោយមានសទ្ធា វីរិយ: សតិ សមាធិ ជាកម្ចាំងឧបត្ថម្ភ ។*

៦- **ពួកពោជ្ឈង្គ ៧** *គឺអង្គនៃសេចក្ដីត្រាស់ដឹង បានដល់ចេតសិក ៧ ជាអង្គរបស់អរិយមគ្គបញ្ញា ដឹងច្បាស់ចាក់ធ្ងុះក្នុងលោកុត្តរធម៌គឺ*

ក- **សតិសម្ពោជ្ឈង្គ** *បានដល់សតិចេតសិក ដែលប្រកបជាអង្គនៃសេចក្ដីត្រាស់ដឹងរូបធម៌ នាមធម៌ និងលោកុត្តរអារម្មណ៍ គ្រប់ខណៈរបស់សេចក្ដីប្រព្រឹត្តទៅនៃចិត្តជាកុសល ។*

ខ- **ធម្មវិចយសម្ពោជ្ឈង្គ** *បានដល់បញ្ញាចេតសិក ជាអង្គនៃសេចក្ដីត្រាស់ដឹង ដឹងចំពោះរូបធម៌ នាមធម៌ ដោយព្រះត្រៃលក្ខណៈ និងប្រកបដោយមគ្គញាណ ផលញាណ បានព្រះនិព្វានជាអារម្មណ៍ ។*

គ- **វីរិយសម្ពោជ្ឈង្គ** *បានដល់វីរិយចេតសិក ជាអង្គនៃសេចក្ដីព្យាយាមដើម្បីដឹងក្នុងរូបធម៌ នាមធម៌ កើតរលត់ជា* **អនិច្ចំ ទុក្ខំ អនត្តា** *កន្ទងញាណលុះដល់មគ្គញាណ ផលញាណ ។*

ឃ- **ប៉ីតិសម្ពោជ្ឈង្គ** *បានដល់ប៉ីតិចេតសិក ជាអង្គប្រកបនឹងសេចក្ដីដឹងរូបធម៌ នាមធម៌ ហើយប្រកបនឹងមគ្គចិត្ត ផលចិត្ត មានសេចក្ដី*

ផ្ទៃតចិត្ត ស្រួលចិត្ត ជាលក្ខណៈ បានព្រះនិញ្ជានជាអារម្មណ៍ ។

ង- **បស្សទ្ធិសម្ពោជ្ឌង្គ** បានដល់បស្សទ្ធិចេតសិក សេចក្តីស្ងប់ជាអង្គប្រកបនឹងសេចក្តីដឹងក្នុងវិបស្សនា និងលោកុត្តរបញ្ញា បានព្រះនិញ្ជានជាអារម្មណ៍ ។

ច- **សមាធិសម្ពោជ្ឌង្គ** បានដល់ឯកគ្គតាចេតសិក ប្រកបនឹងអង្គសេចក្តីដឹងរូបនាមដោយព្រះត្រៃលក្ខណៈ ហើយប្រកបនឹងមគ្គចិត្ត បានព្រះនិញ្ជានជាអារម្មណ៍ ជាសមាធិ ។

ឆ- **ឧបេក្ខាសម្ពោជ្ឌង្គ** បានដល់តត្រមជ្ឈតាចេតសិក ភាពជាកណ្តាលប្រកបដោយអង្គសេចក្តីដឹងរូបនាម ហើយព្រងើយចំពោះសហជាតធម៌ដែលកើតព្រមនឹងវិបស្សនា មានញាណសេចក្តីដឹងជាដើមលុះត្រាតែកន្ទងញាណ ១៦ បានព្រះនិញ្ជានជាអារម្មណ៍ មានឧបេក្ខាសេចក្តីដាក់ចិត្តព្រងើយប្រកបនឹងលោកុត្តរចិត្ត ។

៧- **ពួកមគ្គ ៨** គឺផ្លូវទៅកាន់ព្រះនិញ្ជាន បានដល់ចេតសិកធម៌ ៨ រួមហៅថា អដ្ឋង្គិកមគ្គ មគ្គសមង្គី សេចក្តីប្រជុំព្រមរបស់មគ្គទាំង ៨ នេះរមែងមានក្នុងលោកុត្តរចិត្ត កើតខណៈបាននិញ្ជានជាអារម្មណ៍ ៖

ក- **សម្មាទិដ្ឋិ** មានសេចក្តីឃើញត្រូវ បានដល់បញ្ញាចេតសិកកើតវិបស្សនាញាណ ឃើញរូបនាមកើតរលត់នៅជានិច្ច ទាំងឃើញព្រះនិញ្ជានព្រមដោយមគ្គចិត្តបានដោយងាយ ។

ខ- **សម្មាសង្កប្បោ** សេចក្តីត្រិះរិះត្រូវបានដល់វិតក្កចេតសិក លើក រូបនាមឡើងកាន់ព្រះត្រៃលក្ខណៈណាមួយ ឲ្យទាន់ព្រមនឹងរូបនាមរលត់ ទៅថា ជា **អនិច្ចំ ទុក្ខំ អនត្តា** ។

គ- **សម្មាវាចា** និយាយត្រូវ បានដល់វិរតិចេតសិក នឹងនិយាយឬមិននិយាយក៏ដោយ រៀរនិយាយខុសនៅជានិច្ច មានសតិគ្រប់ខណៈ ។

ឃ- **សម្មាកម្មន្តៈ** ធ្វើការងារត្រូវ បានដល់វិរតិចេតសិក រៀរធ្វើអាក្រក់ នឹងធ្វើឬមិនធ្វើក៏ដោយ រៀរនៅជានិច្ច ព្រោះមានសតិដឹងទាន់បច្ចុប្បន្នធម៌ ។

ង- **សម្មាអាជីវៈ** រស់នៅប្រពៃ បានដល់វិរតិចេតសិក ដែលរៀរចាកការនិយាយខុសក្តី រៀរចាកការធ្វើការងារខុសក្តី មានការរក្សាជីវិត ឲ្យប្រព្រឹត្តទៅក្នុងការបរិភោគអាហារ គ្រឿងស្ងៀកដណ្តប់ ទីនៅទីអាស្រ័យ និងថ្នាំរក្សារោគ ដោយការមានសតិនៅជានិច្ច ហៅថារស់នៅប្រពៃ ។

ច- **សម្មាវាយាមោ** ព្យាយាមត្រូវ បានដល់វីរិយចេតសិក គឺ ព្យាយាមតាំងសតិដឹងទាន់បច្ចុប្បន្នរបស់នាមរូបរឿយៗ នោះឯង ។

ឆ- **សម្មាសតិ** រព្ចកត្រូវ បានដល់សតិចេតសិក ដែលដឹងទាន់បច្ចុប្បន្នរបស់រូបនាមគ្រប់ខណៈនោះឯង ។

ជ- **សម្មាសមាធិ** តាំងចិត្តមាំប្រពៃ បានដល់ឯកគ្គតាចេតសិក ដែលមានសតិដ៏ងទាន់បច្ចុប្បន្នរបស់រូបនាម មិនប្រែប្រួល ហើយប្រកបនឹងអរិយមគ្គចិត្តបានផង ខ្ជាប់ខ្ជួនក្នុងអារម្មណ៍តែមួយ គឺព្រះនិព្វាន ផុតដោយវិមោក្ខ ៣ ណាមួយ ។

រួមពោធិបក្ខិយធម៌ទាំង ៧ ពួក មានចំនួន ៣៧ បរិបូរទាំងនេះ រមែងកើតបរិបូរ បានចំពោះក្នុងលោកុត្តរចិត្ត តែវិតក្កចេតសិក និងបីតិ-ចេតសិក ទាំងពីរនេះ ទីខ្ទះមិនបានកើតក្នុងលោកុត្តរៈក៏មានខ្ទះ កាលព្រះយោគាវចរបដិបត្តិវិសុទ្ធិ ៥ ប្រការ ដែលនៅជាលោកិយនោះ ពោធិបក្ខិយ-ធម៌ក៏កើតបានខ្ទះ តាមហានៈដែលគួរបាន ដូចចិត្តជាញាណវិប្ប យុត្ត បញ្ញារមែងមិនកើត ចិត្តជាទុតិយជ្ឈាន វិតក្ក:រមែងមិនកើតជាដើម ។

អស់អាសវ:ដ៏ល់សត្ត្ថិលក្ខណ:

កាលព្រះយោគាវចរបុគ្គលណា បានចូលពិសោធដើម្បីចម្រើនព្រះ*វិបស្សនាកម្មដ្ឋាន* មានសេចក្ដីព្យាយាម *សតិរ*ឭកដ៏ងទាន់ព្រមគ្រប់ពេល*រ*បស់*រូ*ប*ធ*ម៌ *នាម*ធ*ម*៌ លុះ*កើ*ត*ញ*ាណ*ដ*ឹ*ង*ច*្ប*ាស*់*ចាក*ធ*ុ*ះ*ក*ុ*ង*ព*្រ*ះ*ត*្រ*ៃ*ល*ក*្ខ*ណ:ថា *រ*ូ*ប*នាម*ក*ើ*ត*ឡ*ើ*ង*ហ*ើ*យ*រ*ល*ត*់*ទ*ៅ*ជ*ា **អ*ន*ិ*ច*្ច*ំ** *តាំ*ង*នៅ*ម*ិ*ន*ប*ាន *ជ*ា **ទ*ុ*ក*្ខ*ំ** *ទ្រ*ាំ*នៅ*ម*ិ*ន*ប*ាន *ជ*ា **អ*ន*ត*្ត*ា** *ប*ង*្ក*ាប*់*ប*ញ*្ញ*ាម*ិ*ន*ប*ាន *អ*ាស*ៈ*ដ*ែ*ល*ហ*ូ*រ*ហ*ើ*យ *ទ*ៅ*ត្រ*ាំ*នៅ *ប*ាន*ដ*ល*់ **ទ*ិ*ដ*្ឋ*ាសវ:** *អ*ាស*ៈ*ក*ើ*ទ*ិ*ដ*្ឋ*ិ*យ*ើ*ញ*ខ*ុ*ស *ហ*ូ*រ*ចូ*ល*ក*ាន*់ *ចិ*ត*្ត*ហ*ើ*យ *រ*ួ*ម*ចុ*ះ*ក*ាន*់*ក*ង*្ក **ក*ាម*ាសវ:** *អ*ាស*ៈ*ក*ើ*ក*ាម *ស*េ*ច*ក*ី*ប្រ*ាថ*្ន*ក*ុ*ង

វត្ថុកាម ហូរចូលកាន់ចិត្តហើយ រួមចុះកាន់ភវង្គជាប្រក្រតី **ភវាសវៈ** អាសវៈគឺភព ចង់មាន ចង់កើត ហូរចូលកាន់ចិត្តហើយ រួមចុះកាន់ភវង្គ ត្រាំទុក កាលវិបស្សនាញាណកើតឡើងហើយ មានព្រះត្រៃលក្ខណៈជាអារម្មណ៍ ប្រហារអាសវៈទាំងនេះនៅជានិច្ច ខាងក្រៅហូរចូលមកមិនបាន ខាងក្នុងក៏ត្រូវ **អនិច្ចំ ទុក្ខំ អនត្តា** ហូរចូលកាន់ចិត្តហើយ រួមចុះកាន់ភវង្គ ចូលមកជំនួសច្រើនប៉ុណ្ណា អាសវៈក៏តិចចុះប៉ុណ្ណោះ ទាល់តែអស់អាសវៈ កាលណា កាលនោះបានកន្ធងញាណ ១៦ ឆ្ងងចាកគោត្របុថុជ្ជនទៅកាន់អរិយៈ ដោយ **សន្តិលក្ខណៈ** មានលក្ខណៈស្ងប់ចាកកិលេសាសវៈ និងកងទុក្ខទាំងពួង គឺព្រះនិញ្ចាន ផុតចាកលោកិយ ទៅកាន់លោកុត្តរៈ ដោយអនិមិត្តវិមោក្ខ ព្រោះឃើញ **អនិច្ចំ** ច្បាស់ ផុតដោយអប្បណិហិត-វិមោក្ខព្រោះឃើញ **ទុក្ខំ** ច្បាស់ ផុតដោយសុញ្ញតវិមោក្ខ ព្រោះឃើញ **អនត្តា** ច្បាស់ នឹងដល់ព្រះនិញ្ចានរលត់នាម ដល់សន្តិដ៏មាំមួន ទៀងជាបរមសុខពិតប្រាកដ ព្រះយោគាវចរបុគ្គលនោះ ឈ្មោះថា ជាអ្នកបានដល់ បានលុះព្រះនិញ្ចាន បានព្រះនិញ្ចានជាអារម្មណ៍ ដល់ **ធម្មរតនៈ** កែវគឺ ព្រះធម៌ **ចតូហបាយេហិ** បិទទ្វារអបាយទាំង ៤ រាប់តាំងអំពីចូលដល់ ក្រសែព្រះនិញ្ចាន ។

ព្រះនិញ្ចាននេះ មានសេចក្តីស្ងប់ជា **លក្ខណៈ** មានសេចក្តីមិនឃ្ងៀង ឃ្ងាត ប្រែប្រួលជា **កិច្ច** ជា **រស** មានសេចក្តីមិនមាននិមិត្តជា គ្រឿង **ប្រាកដ**

(គឺផល) មានឈ្មោះច្រើនយ៉ាងដូច្នេះ ៖

១- **វិរាគោ** *សេចក្ដីប្រាសចាករាគ:* (តម្រេក) ។

២- **និរោធោ** *សេចក្ដីរលត់* ។

៣- **បាគោ** *សេចក្ដីលះ* ។

៤- **បដិនិស្សគ្គោ** *សេចក្ដីលើក* (ចោះចោល) ។

៥- **មុត្តិ** *សេចក្ដីផុត* ។

៦- **អនាលយោ** *សេចក្ដីមិនមានអាល័យ* (មិនជាប់ជំពាក់) ។

៧- **មទនិម្មទនោ** *ការញ៉ាំញ៉ីសេចក្ដីស្រវឹង* ។

៨- **បិបាសវិនយោ** *ការកម្ចាត់សេចក្ដីស្រេកឃ្លាន* ។

៩- **អាលយសមុគ្ឃាដោ** *ការដោះគ្រឿងជាប់ជំពាក់ចេញ* ។

១០- **វដ្ដូបច្ឆេទោ** *ការកាត់គ្រឿងវិលវល់* ។

ព្រះពុទ្ធជាម្ចាស់ទាំងឡាយត្រាស់ថា **និព្វានជារបស់កំពូលបំផុត**

និព្វានទំនេរបំផុត

និព្វានជាសុខបំផុត

សេចក្ដីសុខក្រៅចាកព្រះនិព្វានមិនមាន ព្រះពុទ្ធអង្គត្រាស់ថា "ម្នាលភិក្ខុទាំងឡាយ មានអាយតន:ប្រភេទមួយតាំងនៅ មិនមែនដី មិនមែនទឹក មិនមែនភ្លើង មិនមែនខ្យល់ មិនមែនអាកាសានញ្ចាយតន: មិនមែនវិញ្ញាណញ្ចាយតន: មិនមែនអាកិញ្ចញ្ញាយតន: មិនមែននេវសញ្ញានា-

សញ្ញាយតនៈ មិនមែនលោកនេះ មិនមែនលោកដទៃ មិនមែនដួងព្រះចន្ទ មិនមែនដួងព្រះអាទិត្យ អាយតនៈប្រភេទនោះ យើងមិនពោលថាជាទីមកដល់ ជាទីទៅដល់ ជាទីតាំងនៅ មិនកម្រើក មិនកើត មិនមានទីតាំង មិនប្រព្រឹត្តទៅ មិនមានអារម្មណ៍ អាយតនៈប្រភេទនោះឯងជាទីបំផុតរបស់ទុក្ខគឺ "ព្រះនិញ្ជាន" ធម៌ គឺព្រះនិញ្ជានជារបស់ជ្រៅ ដែលបុគ្គលឃើញបានដោយក្រ ដែលបុគ្គលត្រាស់ដឹងបានដោយក្រ ដែលបុគ្គលត្រាស់ដឹងតាមដោយក្រ ជារបស់រំងាប់ ជារបស់ប្រណីត មិនជាទីត្រាប់ទៅនៃសេចក្ដីវិតក្ក: គឺថា បុថុជ្ជនត្រិះរិះគិតគ្នេរយកខ្លួនឯងមិនបានជារបស់ល្អិត ជារបស់បណ្ឌិត គឺព្រះអរិយៈគប្បីដឹងច្បាស់ បុថុជ្ជនមិនដឹងច្បាស់ទេ" ។

ធម្មជាតនោះ មាននៅដោយពិតគឺ **អជាតំ** *មិនកើតទៀត* **អភូតំ** *មិន (មាន) ទៀត* **អកតំ** *មិនធ្វើទៀតតទៅ* **អសង្ខតំ** *មិនប្រុងតែងទៀតតទៅ* **អជរា** *មិនចូលដល់សេចក្ដីចាស់* **អមរណំ** *មិនស្លាប់ទៀតតទៅ នោះឯងជា* **មហាសន្តិសុខ** *គឺព្រះនិញ្ជាន ។*

ភាគ១ចប់

ភាគ២

ភាគនេះជាភាគនៃបដិបត្តិធម៌ ដែលនឹងនាំព្រះយោគាវចរអ្នកបដិបត្តិ ឲ្យធ្ងន់ផុតចាកវដ្តសង្សារបាន ជារបស់សំខាន់លំដាប់ទីពីរឯចាកភាគ បរិយត្តិ គឺវិបស្សនាភូមិ និងជាមូលហេតុដ៏សំខាន់បំផុត ដែលនឹងឲ្យ បង្កើតបដិវេធធម៌នាំមកនូវសន្តិសុខ ជាស្ថាពរបាន សូម្បីអង្គសម្តេចព្រះ បរមសាស្តាចារ្យ ក៏ទ្រង់សរសើរការបដិបត្តិនេះថា ជាការបូជាយ៉ាង ខ្ពង់ខ្ពស់ កាលបានសិក្សាក្នុងភាគទ្រឹស្តីដឹងច្បាស់ថា គន្ថធម៌ផ្លូវវិបស្សនា នេះ កាន់យក **រូបធម៌ នាមធម៌** ជាកម្មដ្ឋាន យក **រូបនាម** ជាអារម្មណ៍ យក **រូបនាម** ជាផ្លូវដើរ យក **សតិបញ្ញា** ជាអ្នកធ្វើកម្មដ្ឋាន យក **សតិបញ្ញា** ជាអ្នកសម្លឹង ដូច្នេះហើយក៏ឈានឡើងកាន់ភាគពិសោធន៍ គឺបដិបត្តិ តទៅដើម្បីឲ្យដឹងច្បាស់ ចាក់ធ្លុះក្នុងសភាវធម៌តាមសេចក្តីពិត កាលបាន ពិសោធឲ្យឃើញពិតហើយ ក៏នឹងបាននាំ **អមតបទ** នោះមកពោល ប្រកាសឲ្យបានឃើញ បានស្តាប់ បានគិត បានដឹងដល់ពពួកពុទ្ធ-បរិស័ទតទៅ ដោយមិនមានថ្លៃសាបសូន្យ ។

ករណីយកិច្ចក្នុងវិបស្សនាធុរៈនេះ ដើម្បីនឹងបដិបត្តិឲ្យត្រូវត្រង់តាម ស្នាមយុគលបាទ(១) ព្រះតម្រាស់បញ្ជាផ្តាំរបស់ព្រះបរមសាស្តាសម្មាសម្ពុទ្ធ ព្រះពុទ្ធអង្គត្រាស់ថា "ភិក្ខុទាំងឡាយ កិច្ចណាដែលព្រះសាស្តាទ្រង់ អាណិតអាសូរ ទ្រង់ប្រាថ្នាប្រយោជន៍ទំនុកបម្រុង អាស្រ័យសេចក្តី

(១) ព្រះបាទទាំងគូ ។

អាណិតអាសូរនោះហើយ នឹងគប្បីធ្វើដល់សាវ័កទាំងឡាយ កិច្ចនោះ យើងបានធ្វើហើយដល់ពួកលោកទាំងឡាយ ភិក្ខុទាំងឡាយ នុ៎ះគល់ឈើ, នុ៎ះទីស្ងាត់, លោកទាំងឡាយចូរបំពេញ, លោកទាំងឡាយចូរកុំជាអ្នកប្រមាទ, លោកទាំងឡាយនឹងមិនត្រូវក្តៅចិត្តក្នុងខាងក្រោយ នេះឯងគឺវាចាគ្រឿងប្រៀនប្រដៅលោកទាំងឡាយរបស់យើង" កាលពិចារណាតាមន័យដែលទ្រង់ព្រះតម្រាស់ដូច្នេះហើយ ។ សរុបខ្ញុំបានសេចក្តីថា ៖

១- ត្រូវមានអ្នកណែនាំប្រៀនប្រដៅ គឺកល្យាណមិត្ត ។

២- ត្រូវមានកន្លែងបដិបត្តិ គឺទីស្ងាត់ ។

៣- ត្រូវមានធម៌ គឺសេចក្តីមិនប្រមាទ បានដល់សតិបញ្ញានោះឯង ។

ពោលអំពីការលះបលិពោធ

ការបដិបត្តិធម៌ក្នុងបវរពុទ្ធសាសនា ដែលបានឈ្មោះថា វិបស្សនាកម្មដ្ឋាននេះ ជាការបដិបត្តិដែលនឹងត្រូវឆ្ងាយពួកគណៈ លះបលិពោធ កង្វល់ជាប់ជំពាក់គ្រប់វត្ថុរបស់គ្រប់យ៉ាង ព្រោះជាផ្លូវមួយ ធ្វើម្នាក់ឯងសម្រេចម្នាក់ឯង សូម្បីព្រះបរមសាស្តាព្រះអង្គជាកល្យាណមិត្ត រហូតដល់អ្នកឧបត្ថម្ភឧបការៈ ឲ្យសេចក្តីទំនុកបម្រុង ក៏គ្រាន់ត្រឹមតែជាអ្នកចង្អុលផ្លូវ និងឧបត្ថម្ភគាំទ្រប៉ុណ្ណោះ អ្នកបដិបត្តិត្រូវមានចិត្តជាឥស្សរៈ ដាក់ការកិច្ចទាំងពួងចេញ គឺមិនមានបលិពោធ ១០ ប្រការគឺ ៖

១- មិនកង្វល់ដោយកិច្ចគ្រប់គ្រងផ្ទះឬអាវាស (**អាវាសបលិពោធោ**) ។

២- *មិនកង្វល់ដោយត្រកូល* (កុលបលិពោធោ) ។

៣- *មិនកង្វល់ដោយលាភ* (លាភបលិពោធោ) ។

៤- *មិនកង្វល់ដោយពួកគណ:* (គណបលិពោធោ) ។

៥- *មិនកង្វល់ដោយកិច្ចធុរ:* (ការងារ) (កម្មបលិពោធោ) ។

៦- *មិនកង្វល់ដោយការដើរផ្លូវ* (អទ្ធានបលិពោធោ) ។

៧- *មិនកង្វល់ដោយញាតិ* (ញាតិបលិពោធោ) ។

៨- *មិនកង្វល់ដោយលោក* (លោកបលិពោធោ)[១] ។

៩- *មិនកង្វល់ដោយការរៀនសូត្រ* (គន្ថបលិពោធោ) ។

១០- *មិនកង្វល់ដោយការសម្តែងឫទ្ធិ* (ឥទ្ធិបលិពោធោ) ។

ពោលអំពីកល្យាណមិត្ត គឺអាចារ្យ

កាលលះបលិពោធ គ្រឿងកង្វល់ផ្សេងៗបានហើយ ក៏ជានាទីដែលនឹងត្រូវទៅកាន់សំណាក់អាចារ្យ ជាកល្យាណមិត្ត ។ កល្យាណ-មិត្តនោះមាន ២ ជំពូកគឺ ៖

១- កល្យាណមិត្ត ដែលឲ្យកម្មដ្ឋានតាមបែបអណ្តាប់ គឺការសិក្សាសូត្ររៀនវិបស្សនាភូមិ ៦ ហើយទើបចូលបដិបត្តិវិបស្សនា ។

២- កល្យាណមិត្ត ដែលឲ្យកម្មដ្ឋានតាមបែបសន្ទ្ធាស ដោយឲ្យបទណាមួយ តាមគួរដល់អធ្យាស្រ័យ ហើយចូលបដិបត្តិវិបស្សនា ។

---

(១) *វិសុទ្ធិមគ្គពោលថា* មិនកង្វល់ដោយសេចក្តីឈឺចាប់ (អាពាធបលិពោធោ) ។

កល្យាណមិត្តនោះ ជាអាចវិយបុគ្គលដ៏សំខាន់ ដែលនឹងចង្អុលផ្លូវខុស និងផ្លូវត្រូវឲ្យដល់សិស្ស អ្នកនឹងចូលជាសិស្ស ទើបត្រូវប្រើគោលសង្គ្រិតឲ្យច្រើន តែមិនគួរពិចារណាទៅក្នុងផ្លូវខូចខាត ព្រោះអាចារ្យគ្រប់រូបរមែងប្រាថ្នាប្រយោជន៍ និងការអនុគ្រោះដល់សិស្ស ដោយសេចក្តីមេត្តាករុណាពិត ទើបនឹងតាំងខ្លួនជាកល្យាណមិត្តបាន អ្នកដែលនឹងចូលទៅកាន់សំណាក់ ឬនឹងថ្វាយខ្លួនជាសិស្ស ឲ្យអប់រំប្រៀនប្រដៅនោះ គួរសង្គ្រិតអង្គគុណកល្យាណមិត្ត ១៥ ប្រការដូចតទៅនេះ ៖

*១- **ปิโย** ជាអ្នកដែលមានសីលជាទីស្រឡាញ់ គួរជ្រះថ្លា ។*

*២- **ครุ** ជាអ្នកដែលមានសេចក្តីធ្ងន់ក្នុងធម៌ គួរគោរពកោតក្រែង ។*

*៣- **ภาวนีย:** ជាអ្នកដែលគេគោរពកោតក្រែង សរសើរ ។*

*៤- **วตฺต:** ជាអ្នកដែលអាចសម្តែងឲ្យឃើញទោសរបស់កាមគុណទាំងឡាយ ។*

*៥- **วจนกฺขม:** ឱវាទរបស់លោកដែលពោលនោះ ធ្វើឲ្យកើតសេចក្តីជ្រះថ្លា រមែងអត់ធន់ចំពោះការបដិបត្តិ ក្នុងគ្រាលំបាកបាន សូម្បីនឹងត្រូវស្តាប់ក็ព្រម ។*

*៦- **คมฺภีรญฺจ กถํ กตฺตา** ជាអ្នកដែលអាចសម្តែងអរិយសច្ច ៤ ឲ្យជាទីចូលចិត្តច្បាស់បាន ។*

*៧- **โน ฐาเน นิโยชเย** ជាអ្នកពន្យល់ក្នុងកន្លែងត្រូវ ។*

៨- **សីលៈ** ជាអ្នកដែលទ្រទ្រង់ទុកនូវចតុបារិសុទ្ធិសីល ។

៩- **សុតៈ** ជាអ្នកដឹងជ្រៅវិញក្នុងព្រះត្រៃបិដកយ៉ាងទូលាយ ។

១០- **ចាគៈ** ជាអ្នកស្ងួលៈដើម្បីសិស្ស សូម្បីនឹងត្រូវខូចជីវិត សាច់ឈាម ក៏ព្រម ។

១១- **សតិ** ជាអ្នកដែលមាំមួនដោយស្មារតី ។

១២- **បញ្ញា** ជាអ្នកដែលមាំមួនដោយបញ្ញា ។

១៣- **សមាធិ** ជាអ្នកដែលមាំមួនដោយសមាធិ ។

១៤- **សទ្ធា** ជាអ្នកដែលប្រកបដោយសទ្ធាដ៏ខ្ជាំងក្លា ។

១៥- **វីរិយៈ** ជាអ្នកដែលមាំមួនដោយសេចក្តីព្យាយាម ។

កល្យាណមិត្ត រមែងមាន **ធម្មសប្បាយៈ** ដែលជាវត្ថុធម៌ ពាក្យពោលដែលពោលចេញមកដល់អ្នកស្តាប់ក៏ជាធម៌ ដែលប្រព្រឹត្តទៅដើម្បីសេចក្តីសន្តិសុខដោយពិត បានដល់កថាវត្ថុ ១០ ប្រការគឺ ៖

១- ពាក្យនិយាយដែលនាំឲ្យចូលចិត្តក្នុងការប្រាថ្នាតិច (**អប្ប្ជ្ជិតកថា**) ។

២- ពាក្យនិយាយដែលនាំឲ្យមានសេចក្តីសន្ធោសក្នុងបច្ច័យ ៤ ដែលមាននៅ (**សន្ធុដ្ឋិកថា**) ។

៣- ពាក្យនិយាយទាក់ទងក្នុងកាយវិវេក និងចិត្តវិវេក (**បវិវេកកថា**)

៤- ពាក្យនិយាយមិនទាក់ទងក្នុងផ្លូវលោកិយសុខ (**អសំសគ្គកថា**) ។

៥- ពាក្យនិយាយនាំឲ្យកើតសេចក្តីព្យាយាមផ្លូវបដិបត្តិ (**វីរិយារម្ភកថា**)

៦- ពាក្យនិយាយដែលនាំឲ្យកើតការបដិបត្តិសីល (សីលកថា) ។

៧- ពាក្យនិយាយដែលនាំឲ្យកើតការបដិបត្តិសមាធិ (សមាធិកថា) ។

៨- ពាក្យនិយាយដែលនាំឲ្យកើតការធ្វើភាវនាកិច្ច (បញ្ញាកថា) ។

៩- ពាក្យនិយាយដែលនាំឲ្យធ្វើចិត្តឲ្យផុតពីកិលេស (វិមុត្តិកថា) ។

១០- ពាក្យនិយាយដែលនាំឲ្យកើតបច្ចវេក្ខណញាណ ពិចារណា មគ្គ ផល និញ្ចាន និងកិលេសដែលសល់នៅ (វិមុត្តិញាណទស្សនកថា) ។

ពោលអំពីសប្បាយ ៧

កាលចូលកាន់សំណាក់កល្យាណមិត្ត ដែលប្រកបទៅដោយអង្គ ១៥ ប្រការ និងមានកថាវត្ថុ ១០ រាប់ថាបានធម៌ជាទីសប្បាយថា លោកគ្រូនេះនឹងឲ្យផ្ទូវបដិបត្តិដែលត្រូវដល់យើងពិត កាលបានចូលសិក្សាអប់រំស្គាល់គោលវិបស្សនាភូមិល្អហើយ ក៏នឹងត្រូវរកទីដែលជាទីសប្បាយ ឬកល្យាណមិត្ត ជាអ្នករកឲ្យតាមតែស្រួលសប្បាយ ព្រោះថារបស់ដែលប្រកបជាទីសប្បាយនោះឯង ជាបច្ច័យឲ្យធម៌ចំណែកកុសលមានកម្ចាំងគាំទ្រការបដិបត្តិឲ្យល្អវិសេសឡើង ។

សប្បាយ ៧ ប្រការនោះគឺ

១- ស្ថានទីប្រកបដោយហេតុ ៥ គឺមិនមានមនុស្សឈូធរ មិនមានមូសចោមរោម, មានរបងព័ទ្ធជុំវិញ, មានទីចង្ក្រមផ្ទាស់ប្តូរឥរិយាបថ មានអាកាសចេញចូល និងមានទឹកប្រើ ទឹកទទួលទានស្រួល ទីនោះនឹង

តាំងនៅជាយព្រៃក្តី គល់ឈើក្តី ឬផ្ទះស្ងាត់ក្តី ដែលជាស្ថានទីស្ងប់ស្ងាត់ ប្រាសចាកសំឡេងគឹកកងនៃមនុស្សបរិភោគកាម ។

២- ស្ថានទីដែលស្វែងរកអាហារបាន មិនជាទីដាច់ស្រយាល ។

៣- ស្ថានទីដែលត្រូវប្រកបដោយកថាវត្ថុ ១០ ។

៤- ស្ថានទីដែលបរិបូរដោយភោជនាហារ ។

៥- ស្ថានទីដែលមានឧតុ គឺអាកាសល្អស្រួលដល់ការបដិបត្តិ ។

៦- ស្ថានទីដែលមានអ្នកអាចសម្តែងកថាវត្ថុ ១០ ។

៧- ស្ថានទីដែលស្រួលចំពោះការបដិបត្តិ សមគួរក្នុងការប្រែប្រួលផ្ទាស់ប្តូរ និងដើរចង្ក្រមជាដើម ។

ដោយបំពេះបច្ចុប្បន្ននេះ គួរចាត់ដូច្នេះ ៖

១- ទីកន្លែងដែលធ្វើជាកុដិ ខ្នាតទទឹង ៧ ចំអាមព្រះសុគត បណ្តោយ ១២ ចំអាមព្រះសុគត (គឺបណ្តោយ ៤ម,០៨ ទាំងហោណាំង ទទឹង ២ម, ៣៨) មានបន្ទប់ទឹក មានវច្ចកុដិ មានទីដើរចង្ក្រមខាងក្នុង មានរបងព័ទ្ធជុំវិញ ធ្វើជាប់តគ្នាទៅ ផ្ទៃដីប្រមាណ ២០ ព្យាម ៤ ជ្រុង មានរបងខាងក្រៅ មានទ្វារចូលទាំង ៤ ទិស មានថ្នល់ជាប់គ្នា និងសាលាអប់រំ ទីកន្លែងគួរតាំងជិតមាត់ស្ទឹង ជើងភ្នំ មានអាកាសល្អ មានដើមឈើដែលមានម្លប់ត្រជាក់ ។

២- អាហារ គួរចាត់ជាមូលនិធិឡើង យកការដែលជាផលមូល-

និធិនោះ មកបម្រុងតម្លៃអាហារ និងឧបករណ៍ដទៃៗ ខាងក្នុងកុដិ ដែលចាំបាច់ត្រូវប្រើ ។

៣- បុគ្គលដែលចាំឧបត្ថម្ភឧបការ: គួរឲ្យប្រាក់ជារាល់ខែ ប្រាក់ដែលបានមកអំពីការប្រាក់មូលនិធិ ។

៤- កល្យាណមិត្ត ជាអ្នកដែលមានធម្មសប្បាយ: និងមានអង្គគុណគួរដល់ការជាអាចារ្យ ដូចសម្តែងមកហើយ ។

៥- ចំណែកអ្នកបដិបត្តិនោះ ត្រូវប្រកបដោយអង្គគុណដូច្នេះ ៖

ក- ត្រូវជាអ្នកមានសទ្ធាពិត មានអាយុតាំងអំពី ៧ ឆ្នាំឡើងទៅ ។

ខ- បើជាភិក្ខុ សាមណេរ នឹងមកបដិបត្តិក្នុងសម្នាក់ ត្រូវធ្វើតាមរបៀបគណៈសង្ឆ គឺមានសន្ទឹកសង្ឆដីកា ឬធាយា ឬសំបុត្រគ្រឿងសម្គាល់អំពីលោកចៅអាវាសរបស់ខ្លួនជាលក្ខហាន ។

គ- បើជាឃរាវាស ត្រូវបានទទួលអនុញ្ញាតអំពីមាតាបិតា ភរិយាស្វាមី បុត្ត ធីតា និងញាតិបងប្អូនឯណាមួយ ដែលខ្លួនអាស្រ័យនៅជាមុន ។

ឃ- ជាអ្នកមិនមានបំណុល ។

ង- មិនមានរោគអន្តរាយ ឬរោគធ្ងន់ ដែលពេទ្យរ៉ាប់រងសុខភាពឲ្យធ្វើសេចក្តីព្យាយាមបាន ។

៧- ត្រូវជាមនុស្សដែលមិនមានរោគចិត្ត ធ្លាប់ជាមនុស្សឆ្លួតមកអំពីមុន ។

៨- ត្រូវជាអ្នកមិនធ្វើសេចក្តីខុស លបរត់អំពីអាជ្ញាផែនដី ឬគេចវេះពីរាជការ ឬជាប់ចោទក្នុងតុលាការ ។

៩- ត្រូវជាអ្នកដែលមហាជនមិនរង្កៀស ។

១០- ត្រូវមានអ្នករ៉ាប់រងនាំទៅផ្ញើម្ចាស់សំណាក់ ។

១១- កាលវេលាចេញចាកកម្មដ្ឋាន ត្រូវបានទទួលអនុម័តិអំពីអាចារ្យ អ្នកប្រដៅ និងម្ចាស់សំណាក់ជាមុន ។

សម្គាល់ហេតុ: សំបុត្រសុំចូលធ្វើវិបស្សនា គួរមានឈ្មោះត្រកូលសញ្ជាតិ ថ្ងៃកើត ខែ...ព.ស.... ឈ្មោះឧបជ្ឈាយ៍ អាចារ្យ ឈ្មោះបិតា មាតា ភរិយា ស្វាមី អាជីពបិតា មាតា ទីកន្ទែងដែលកើត ខែត្រ ស្រុក វត្ត ទីកន្ទែងនៅនាបច្ចុប្បន្ន ខែត្រ ស្រុក និងប្រាប់រឿងចិត្ត សេចក្តីឃើញជាប់នឹងការបដិបត្តិ ។

ពោលអំពីវិធីថ្ងៃចូលបដិបត្តិវិបស្សនា

កាលថ្ងៃ វេលា កន្ទងទៅដោយការសិក្សាវិបស្សនា និងចាត់កន្ទែងឲ្យជាទីសប្បាយហើយ ក៏ដល់វេលាចូលបដិបត្តិ ទៅកាន់សំណាក់អាចារ្យ ជាកល្យាណមិត្រ ដែលបានយល់ព្រមអនុញ្ញាតឲ្យចូលបដិបត្តិបាន ទើបផ្តើមធ្វើវិធីកម្មក្នុងចំណែកបុព្វភាគ ចំពោះព្រះភក្ត្រព្រះពុទ្ធបដិមា ដូចតទៅនេះ ៖

១- អុជធូបទៀនបូជាព្រះសិរីរតនត្រៃហើយ អង្គុយច្រហោងប្រណម្យ

ដៃ បញ្ចេញវាចានមស្សការដោយបាលីថា ៖

អរហំ សម្មាសម្ពុទ្ធោ ភគវា, ពុទ្ធំ ភគវន្តំ អភិវាទេមិ (ក្រាបថ្វាយបង្គំដោយបញ្ចង្គប្រតិស្ឋាន) ។

ស្វាក្ខាតោ ភគវតា ធម្មោ, ធម្មំ នមស្សामិ (ក្រាបថ្វាយបង្គំដោយបញ្ចង្គប្រតិស្ឋាន) ។

សុបដិបន្នោ ភគវតោ សាវកសង្ឆោ, សង្ឆំ វន្ទាមិ (ក្រាបថ្វាយបង្គំដោយបញ្ចង្គប្រតិស្ឋាន) ។

២- ការនមស្សការអង្គសម្តេចព្រះបរមសាស្តាសម្មាសម្ពុទ្ធជាម្ចាស់ ព្រះអង្គទ្រង់ប្រទានវិបស្សនាកម្មដ្ឋានជាបឋម ដោយព្រះបាលីថា ៖

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស (៣ដង) ។

ចម្រើនព្រះពុទ្ធគុណដោយបទថា ៖

ឥតិបិ សោ ភគវា អរហំ សម្មាសម្ពុទ្ធោ វិជ្ជា-ចរណសម្បន្នោ សុគតោ លោកវិទូ អនុត្តរោ បុរិស-ធម្មសារថិ សត្ថា ទេវមនុស្សានំ ពុទ្ធោ ភគវាតិ ។

(ក្រាបចុះហើយសូត្រតិចៗ ថា) ៖

កាយេន វាចាយ វ ចេតសា វា, ពុទ្ធេ ការុកម្មំ បកតំ មយា យំ, ពុទ្ធោ បដិក្ខណ្ហាតុ អច្ចយន្តំ, កាលន្តរេ សំវរិតុំ វ ពុទ្ធេ ។

ចម្រើនព្រះធម្មគុណដោយបទថា ៖

ស្វាក្ខាតោ ភគវតា ធម្មោ សន្ទិដ្ឋិកោ អកាលិកោ ឯហិបស្សិកោ ឱបនយិកោ បច្ចត្តំ វេទិតព្វោ វិញ្ញូហីតិ ។

(ក្រាបចុះហើយសូត្រតិចៗ ថា៖

កាយេន វាចាយ វ ចេតសា វា, ធម្មេ កុកម្មំ បកតំ មយា យំ, ធម្មោ បដិក្តណ្ហាតុ អច្ចយន្តំ, កាលន្តរេ សំវរិតុំ វ ធម្មេ ។

ចម្រើនព្រះសង្ឆគុណដោយបទថា ៖

សុបដិបន្នោ ភគវតោ សាវកសង្ឆោ ឧជុបដិ-បន្នោ ភគវតោ សាវកសង្ឆោ ញាយបដិបន្នោ ភគវតោ សាវកសង្ឆោ សាមីចិបដិបន្នោ ភគវតោ សាវកសង្ឆោ យទិទំ ចត្តារិ បុរិសយុគានិ អដ្ឋ បុរិសបុក្តលា ឯស ភគវតោ សាវកសង្ឆោ អាហុ-នេយ្យោ ចាហុនេយ្យោ ទក្ខិណេយ្យោ អញ្ជលិ-ការណីយោ អនុត្តរំ បុញ្ញក្ខេត្តំ លោកស្សាតិ ។

(ក្រាបចុះហើយសូត្រតិចៗ ថា) ៖

កាយេន វាចាយ វ ចេតសា វា, សង្ឆេ កុកម្មំ

បកតំ មយា យំ, សដ្ឌ្យា បដិក្តណ្ហាតុ អចូយន្តំ, កាលន្តរេ សំវរិតុំ វ សដ្ឌ្យ ។

៣- ការបដិបត្តិក្នុងសីលវិសុទ្ធិ ឲ្យជាអ្នកបរិសុទ្ធគួរដល់ការបដិបត្តិក្នុងចំណែកខាងដើមគឺ ៖

ក- បើជាភិក្ខុ ត្រូវអាបត្តិ បន្តិចបន្តួច (តូចៗ) ដូចជា បាចិត្តិយ ថុលូច្ចយ ឬអាបត្តិទុព្ភាសិត ឬបដិបត្តិមិនគួរដល់ភិក្ខុភាវ: ជាលោកវជ្ជ: លោកតិះដៀល ឲ្យទេសនាបត្តិ (សម្តែងអាបត្តិ) ចេញ ចំពោះមុខសង្ឆ ឬចំពោះមុខគណ: ឬចំពោះមុខបុគ្គល បើជាអាបត្តិសង្ឆាទិសេស ត្រូវនៅបរិវាសកម្មជាមុនបើជាអាបត្តិបារាជិក ឲ្យសឹកចេញ ហើយបួសថ្មីបាន ត្រឹមតែជាសាមណេរ ទើបចូលបដិបត្តិវិបស្សនាបាន ។

ខ- បើជាសាមណេរ ឲ្យសមាទានសីល ១០ ជាថ្មី ។

គ- បើជា ឧបាសក ឧបាសិកា ឲ្យសមាទានសីល ៥ ឬ សីល ៨ ឬអាជីវដ្ឋមកសីល ហើយទើបចូលបដិបត្តិវិបស្សនាបាន ។

ពាក្យអារាធនាអាជីវដ្ឋមកសីលថាដូច្នេះ

អហំ ភន្តេ តិសរណេន សហ អាជីវដ្ឋមកសីលំ យាចាមិ, ឧតិយម្ឯិ អហំ ភន្តេ តិសរណេន សហ អាជីវដ្ឋមកសីលំ យាចាមិ, តតិយម្ឯិ អហំ ភន្តេ តិសរណេន សហ អាជីវដ្ឋមកសីលំ យាចាមិ ។

ពាក្យសមាទានអាជីវដ្ឋមកសីលថាដូច្នេះ

ចាណាតិចាតា វេរមណីសិក្ខាបទំ សមាទិយាមិ ។
អទិន្នាទានា វេរមណីសិក្ខាបទំ សមាទិយាមិ ។
កាមេសុមិច្ឆាចារា វេរមណីសិក្ខាបទំ សមាទិយាមិ ។
មុសាវាទា វេរមណីសិក្ខាបទំ សមាទិយាមិ ។
បិសុណាវាចា វេរមណីសិក្ខាបទំ សមាទិយាមិ ។
ផរុសវាចា វេរមណីសិក្ខាបទំ សមាទិយាមិ ។
សម្ផប្បលាចា វេរមណីសិក្ខាបទំ សមាទិយាមិ ។
មិច្ឆាអាជីវា វេរមណីសិក្ខាបទំ សមាទិយាមិ ។
ពាក្យសរុបថា ឥមានិ អាជីវដ្ឋមកសីលំ សមាទិយាមិ ។

៦- ថ្វាយអត្តភាពរាងកាយចំពោះព្រះមានព្រះភាគ ដែលជាសង្ឃបិតា ទ្រង់ប្រទានវិបស្សនាធុរៈដល់អ្នកឃើញក័យក្នុងវដ្តៈថាដូច្នេះ ៖

ឥមាហំ ភន្តេ ភគវា អត្តភាវំ ភគវតោ បរិចូជាមិ ។

បពិត្រព្រះមានព្រះភាគដ៏ចម្រើន ខ្ញុំព្រះអង្គសូមបង្អោនថ្វាយអត្តភាពរាងកាយនេះ ចំពោះព្រះមានព្រះភាគ ។

៥- ថ្វាយអត្តភាពរាងកាយចំពោះអាចារ្យអ្នកប្រដៅកម្មដ្ឋាន ដើម្បីនឹងបានអប់រំប្រៀនប្រដៅទៅដោយល្អ មិនមានទោសដល់អាចារ្យអ្នកប្រដៅជាការព្រមខ្ជូន ព្រមទាំងកាយ និងចិត្តឲ្យប្រៀនប្រដៅ គ្រាសម័យ

ពុទ្ធកាល កាលព្រះពុទ្ធអង្គទ្រង់ព្រះជន្មនៅ ក៏សូមកម្មដ្ឋានអំពីព្រះពុទ្ធអង្គ កាលព្រះពុទ្ធអង្គមិនមាន ក៏សូមអំពីព្រះអគ្គសាវ័កខាងស្តាំ កាលព្រះអគ្គសាវ័កខាងស្តាំមិនមាន ក៏សូមអំពីព្រះអគ្គសាវ័កខាងឆ្វេង កាលព្រះអគ្គសាវ័កខាងឆ្វេងមិនមាន ក៏សូមអំពីព្រះអរហន្តខីណាស្រព កាលព្រះអរហន្តខីណាស្រពមិនមាន ក៏សូមអំពីព្រះអនាគាមី កាលព្រះអនាគាមីមិនមាន ក៏សូមអំពីព្រះសកទាគាមី កាលព្រះសកទាគាមីមិនមាន ក៏សូមអំពីព្រះសោតាបន្ន កាលព្រះសោតាបន្នមិនមាន ក៏សូមអំពីព្រះអាចារ្យអ្នកជំនាញក្នុងព្រះកម្មដ្ឋានដែលប្រកបដោយអង្គគុណ ១៥ ប្រការ ។

ពាក្យថ្វាយខ្លួនបំពោះអាចារ្យថាដូច្នេះ

ឥមាហំ ភន្តេ អាចរិយ អត្តភាវំ អាចរិយស្ស បរិចូជាមិ ។

បពិត្រលោកអាចារ្យដ៏ចម្រើន ខ្ញុំសូមថ្វាយអត្តភាពរាងកាយនេះបំពោះលោកអាចារ្យ ។

៦- សូមកម្មដ្ឋាននឹងលោកអាចារ្យ ក្រោយអំពីដែលបានបង្អោនកាយថ្វាយខ្លួនហើយ ថាដូច្នេះ ៖

និព្វានស្ស មេ ភន្តេ សច្ឆិករណាត្ថាយ កម្មដ្ឋានំ ទេហិ ។

បពិត្រលោកអាចារ្យដ៏ចម្រើន សូមព្រះករុណាឲ្យកម្មដ្ឋានដល់ខ្ញុំ ដើម្បី

ធ្វើឲ្យជាក់ច្បាស់នូវព្រះនិញ្ជាន ។

៧- កាលបានទទួលព្រះកម្មដ្ឋានអំពីអាចារ្យហើយ ចូលកាន់បន្ទប់កម្មដ្ឋាន ដែលស្ងប់ស្ងាត់ អុជធូបទៀនបូជាព្រះស្រីរតនត្រ័យ ដែលជាអាមិសបូជាគ្រាចុងបំផុត ព្រោះរហូតវេលានៃការបដិបត្តិ ឲ្យប្រព្រឹត្តទៅដោយការបដិបត្តិបូជាមួយយ៉ាង តាំងចិត្តរឹងប៉ឹងមាំមួន បង្ហោនរពុកដល់គុណរបស់ព្រះពុទ្ធ គុណរបស់ព្រះធម៌ និងគុណរបស់ព្រះសង្ឆ រហូតដល់គុណរបស់មាតាបិតាគ្រូឧបជ្ឈាយ៍ អាចារ្យ និងអ្នកមានបុណ្យគុណទាំងឡាយ និងរពុកដល់គុណរបស់ពពួកទេព្តាដែលស្ថិតនៅទីជិត និងទីឆ្ងាយ ក្នុងទីផ្សេងៗ ដែលជាសម្មាទិដ្ឋិ រហូតបុព្វបុរសដែលបានរក្សាព្រះសាសនាតមក ហើយតាំងសច្ចាធិដ្ឋានទុកយ៉ាងមាំមួនថា ៖

"បើមិនបានលុះផលដែលគួរនឹងបាន គួរនឹងដល់ ហើយកាលណាដោយកម្លាំងនៃសេចក្ដីព្យាយាម ដោយសេចក្ដីប្រឹងប្រែង មិនរួញរាថយ ក្រោយសូម្បីសាច់គ្រប់ដុំ ឈាមគ្រប់តំណក់ នឹងរីងស្ងួតទៅ សល់នៅតែស្បែកសរសៃ ឆ្អឹង ក៏ដោយចុះ កាលនោះ យើងនឹងលះកម្លាំងគ្រប់ចំណែកដើម្បីធ្វើឲ្យច្បាស់នូវព្រះនិញ្ជាន សូមអំណាចគុណព្រះស្រី-រតនត្រ័យ គុណរបស់អ្នកមានគុណ និងគុណរបស់ទេព្តា រហូតសេចក្ដីសច្ចៈ សេចក្ដីពិតដែលតាំងទុកនេះ ចូលមកជាពលវបច្ច័យ និងឃុំគ្រងការពារអន្ដរាយទាំងពួង ឲ្យការបដិបត្តិយើញធម៌ ដឹងធម៌ តាម

ពាក្យប្រៀនប្រដៅរបស់ព្រះបរមសាស្តាសម្មាសម្ពុទ្ធពិត" ។

៨- កាលអធិដ្ឋានស្រេចហើយ ក៏ផ្សាយមេត្តាឲ្យដល់ខ្លួនឯង និង អ្នកដទៃ រហូតសព្វសត្វទូទៅ ៖

ក- ផ្សាយឱ្យខ្លួនឯងថាដូច្នេះ

អហំ សុខិតោ ហោមិ *សូមឲ្យខ្ញុំមានសេចក្តីសុខ*

អហំ និទ្ទុក្ខো ហោមិ *សូមឲ្យខ្ញុំប្រាសចាកទុក្ខ*

អហំ អវេរো ហោមិ *សូមឲ្យខ្ញុំប្រាសចាកពៀរ*

អហំ អព្យាបជ្ជো ហោមិ *សូមឲ្យខ្ញុំប្រាសចាកសេចក្តីលំបាក*

អហំ អនីឃো ហោមិ *សូមឲ្យខ្ញុំប្រាសចាកឧបសគ្គ*

អហំ អត្តានំ បរិហរামិ *សូមឲ្យខ្ញុំរក្សាខ្លួនឲ្យមានសេចក្តីសុខ។*

ខ- ផ្សាយមេត្តាឱ្យដល់មនុស្សដទៃថាដូច្នេះ

សព្វេ សត្តা *ពួកសត្វទាំងពួង*

សព្វេ ចាណា *ពួកសត្វដែលមានខ្យល់ប្រាណទាំងពួង*

សព្វេ ភូតা *ពួកភូតទាំងពួង*

សព្វេ បុគ្គលা *បុគ្គលទាំងឡាយទាំងពួង*

សព្វេ អត្តភាវបរិយាបន្នা *ពួកសត្វដែលជាប់ដោយអត្តភាពទាំងពួង*

សព្វេ ឥត្ថិយো *ស្ត្រីទាំងឡាយទាំងពួង*

សព្វេ បុរិសা *បុរសទាំងឡាយទាំងពួង*

សព្វេ អរិយា *ព្រះអរិយៈទាំងឡាយទាំងពួង*

សព្វេ ទេវា *ទេព្តាទាំងឡាយទាំងពួង*

សព្វេ វិនិចាតិកា *ពួកសត្វនរកទាំងឡាយទាំងពួង*

អវេរា ហោន្តុ អព្យាបជ្ជា អនីឃា សុខី អត្តានំ បរិហរន្តុ *ចូរប្រាសចាកពៀរ ប្រាសចាកសេចក្តីលំបាក ប្រាសចាកឧបសគ្គ រក្សាខ្លួនឲ្យមានសេចក្តីសុខចុះ ។*

គ-ផ្សាយមេត្តាទៅក្នុងទិស ១០ ឋាដ្ឋប្នេះ

បុរត្ថិមាយ ទិសាយ សព្វេ សត្តា សុខិតា ហោន្តុ ។ *សូមពួកសត្វទាំងពួងក្នុងទិសបូពា (ខាងកើត) ចូរជាអ្នកមានសេចក្តីសុខចុះ ។*

ទក្ខិណាយ ទិសាយ សព្វេ សត្តា សុខិតា ហោន្តុ ។ *សូមពួកសត្វទាំងពួងក្នុងទិសទក្សិណ (ខាងត្បូង) ចូរជាអ្នកមានសេចក្តីសុខចុះ ។*

បច្ឆិមាយ ទិសាយ សព្វេ សត្តា សុខិតា ហោន្តុ ។ *សូមពួកសត្វទាំងពួងក្នុងទិសបស្ចិម (ខាងលិច) ចូរជាអ្នកមានសេចក្តីសុខចុះ ។*

ឧត្តរាយ ទិសាយ សព្វេ សត្តា សុខិតា ហោន្តុ ។ *សូមពួកសត្វទាំងពួងក្នុងទិសឧត្តរ (ខាងជើង) ចូរជាអ្នកមានសេចក្តីសុខចុះ ។*

បុរត្ថិមាយ អនុទិសាយ សព្វេ សត្តា សុខិតា ហោន្តុ ។ *សូមពួកសត្វទាំងពួងក្នុងទិសអគ្នេយ៍ (ខាងកើតឆៀងខាងត្បូង) ចូរជាអ្នកមាន*

សេចក្ដីសុខចុះ ។

ឧក្ខិណាយ អនុឧិសាយ សព្វេ សត្តា សុខិតា ហោន្តុ ។

សូមពួកសត្វទាំងពួងក្នុងទិសនិរតី (ខាងត្ឈូងធ្វៀងខាងលិច) ចូរជាអ្នកមានសេចក្ដីសុខចុះ ។

បច្ឆិមាយ អនុឧិសាយ សព្វេ សត្តា សុខិតា ហោន្តុ ។

សូមពួកសត្វទាំងពួងក្នុងទិសពាយ័ព្យ (ខាងលិចធ្វៀងខាងជើង) ចូរជាអ្នកមានសេចក្ដីសុខចុះ ។

ឧត្តរាយ អនុឧិសាយ សព្វេ សត្តា សុខិតា ហោន្តុ ។

សូមពួកសត្វទាំងពួងក្នុងទិសឈ្សសាន (ខាងជើងធ្វៀងខាងកើត) ចូរជាអ្នកមានសេចក្ដីសុខចុះ ។

ហេដ្ឋិមាយ អនុឧិសាយ សព្វេ សត្តា សុខិតា ហោន្តុ ។

សូមពួកសត្វទាំងពួងក្នុងទិសខាងក្រោម ចូរជាអ្នកមានសេចក្ដីសុខចុះ ។

ឧបរិមាយ អនុឧិសាយ សព្វេ សត្តា សុខិតា ហោន្តុ ។

សូមពួកសត្វទាំងពួងក្នុងទិសខាងលើ ចូរជាអ្នកមានសេចក្ដីសុខចុះ ។

ង- ពោលដោយទហាម គិងទបដិបត្តិក្នុងវេលាបំពេញវិបស្សនា

កាលផ្សាយមេត្តាស្រេបហើយ ក៏តាំងសតិកំណត់រូបនាមភ្លាម ដោយ

តាំងនៅក្នុងគោលទហាមដូច្នេះ

១- ហាមមិនឲ្យឈប់សម្រាកការបដិបត្តិវៀរលែងតែភ្ជុចភ្ជាំងឬលក់ ។

២- ហាមនិយាយនឹងមនុស្សខាងក្រៅ ក្រៅចាកអាចារ្យអ្នក ប្រដៅកម្មដ្ឋាន បើចាំបាច់នឹងត្រូវនិយាយជាមួយមនុស្សខាងក្រៅខ្ទះ ក៏ និយាយតែបន្តិចបន្ពួចដោយអាការសង្រួម គឺធ្មេចក្នែក ហើយតាំងសតិ កំណត់ត្រង់មាត់កម្រើកគ្រប់ពាក្យនិយាយ ។

៣- ហាមធ្វើកិច្ចតូចៗ ដែលមិនចាំបាច់ ដូចអានសៀវភៅ សរសេរសៀវភៅជាដើម ។

៤- ហាមដេកវេលាថ្ងៃ វេលាយប់ដេកតិច ព្យាយាមច្រើន ។

៥- ហាមរបស់ដែលញៀនគ្រប់ជំពូក បើលះមិនទាន់បាន ព្យាយាម លះឲ្យស្រាលចុះ ។

៦- ហាមនិយាយនឹងអ្នកបដិបត្តិជាមួយគ្នា ។

និងគប្បីតាំងនៅក្នុងគោល ៣ ប្រការគឺ

១- **ឧបនិស្សយ:** ត្រូវមិននៅប្រាសចាកអាចារ្យ ។

២- **អារក្ខ:** ត្រូវរក្សាកម្មដ្ឋានដែលអាចារ្យឲ្យ ។

៣- **ឧបនិពទ្ធ:** ត្រូវចងចិត្តទុកក្នុងការចម្រើនសតិ និងតាំងនៅក្នុង អបណ្ណកបដិបទា បដិបត្តិមិនខុស ៣ យ៉ាងគឺ ៖

១- ***ឥន្ទ្រិយសំវរ:*** សង្រួមឥន្ទ្រីយ៍ ៦ គឺក្នែក ត្រចៀក ច្រមុះ អណ្ណាត កាយ ចិត្ត មានសតិដឹងទាន់ខណៈឃើញរូប មានសតិដឹងទាន់ ខណៈស្តាប់សំឡេង មានសតិដឹងទាន់ខណៈធុំក្លិន មានសតិដឹងទាន់

ខណៈលិឃរស មានសតិដឹងទាន់ខណៈពាល់ត្រូវផោដ្ឋព្វៈ មានសតិដឹងទាន់ធម្មារម្មណ៍ ខណៈដឹងទាន់ គឺដឹងឈរ ដើរ អង្ក្ពុយ ដេក កង្ក្ពុញ លាតកម្រើក ជាដើម មិនឲ្យស្ទុះទៅដល់ត្រេកអរ(ទោមនស្ស) ចំពោះអារម្មណ៍ដែលមកខ្ទប់-ប៉ះ ។

២- **ភោជនេ មត្តញ្ញតា** *ដឹងប្រមាណក្នុងការបរិភោគអាហារ ល្មមសមគួរមិនច្រើន មិនតិច ។*

៣- **ជាគរិយានុយោគ** *ប្រកបសេចក្តីព្យាយាម ដើម្បីនឹងជម្រះចិត្តឲ្យម៉ត់ចត់ មិនឃើញដល់ការដេកច្រើន ។*

ប- ពោលអំពីវិធីតាំងសតិដឹងទាន់បច្ចុប្បន្នរបស់រូបនាម

"បែបបដិបត្តិទី១"

ខណៈអង្ក្ពុយ អង្ក្ពុយជា **រូប** *ដឹងជា* **នាម** *សតិដឹងទាន់ តាំងសតិទុកត្រង់រូបអង្ក្ពុយ កំណត់ដឹងថា អង្ក្ពុយ ។*

ខណៈឈរ ឈរជា **រូប** *ដឹងជា* **នាម** *សតិដឹងទាន់ តាំងសតិទុកត្រង់រូបឈរ កំណត់ដឹងថា ឈរ (ជាក់ដៃទុកខាងមុខ ឬខាងក្រោយ ក្រសៃភ្នែកបើកត្រឹមរយៈ ៣ ជំហាន) ។*

ខណៈដើរឈានទៅ ឈានជា **រូប** *ដឹងជា* **នាម** *សតិដឹងទាន់ តាំងសតិទុកត្រង់រូបកែងជើង កំណត់ដឹងថា ជំហាន (បែរក្រសៃភ្នែកមើលមួយជួរនឹម) ។*

ខណៈដេក ដេកជា **រូប** ដឹងជា **នាម** សតិដឹងទាន់ តាំងសតិទុកត្រង់រូបដេក កំណត់ដឹងថា ដេក ។

សម្គាល់ហេតុ: បើចិត្តរាយមាយច្រើន នឹងអង្គុយធ្មេចភ្នែក កំណត់ខ្យល់ដង្ហើមចូល-ចេញខ្លះក៏បាន ដោយតាំងសតិទុកត្រង់ច្រមុះ ខណៈខ្យល់ដង្ហើមចូល-ចេញ ប៉ះពាល់ ខ្យល់ដង្ហើមប៉ះពាល់ជា **រូប** សេចក្ដីដឹងជា **នាម** កំណត់ដឹងថា ប៉ះពាល់ទាំងចេញ និងចូល ។

"បៃបបដិបត្តិទី២"

ធ្វើតាមបៃបបដិបត្តិទី១ និងធ្មេចភ្នែកចុះហើយ ខណៈនិយាយ កម្រើកវាចាជា **រូប** ដឹងជា **នាម** សតិដឹងទាន់គ្រប់ពាក្យនិយាយ តាំងសតិទុកត្រង់ទងប្រណាកក្រោមកម្រើកចុះ កម្រើកឡើង (មិនត្រូវពោល) ។

ខណៈទំពា ទំពាជា **រូប** ដឹងជា **នាម** សតិដឹងទាន់ តាំងសតិទុកត្រង់ទងប្រណាក កម្រើកញ័រ កំណត់ដឹងថា ទំពា ។

"បៃបបដិបត្តិទី៣"

ធ្វើតាមបដិបត្តិទី ១-២ និង

ខណៈឃើញ ពណ៌ជា **រូប** ឃើញជា **នាម** សតិដឹងទាន់ តាំងសតិទុកត្រង់កែវភ្នែក កំណត់ដឹងថា ឃើញ ។

"បៃបបដិបត្តិទី៤"

ធ្វើតាមបៃបបដិបត្តិទី១-២-៣- និង

ខណៈបានឮ សំឡេងជា រូប បានឮជា នាម សតិដឹងទាន់ តាំងសតិទុកត្រង់កែវត្រចៀក កំណត់ដឹងថា បានឮ ។

"បែបបដិបត្តិទី៥"

ធ្វើតាមបែបបដិបត្តិទី ១-២-៣-៤- ផង និង

ខណៈដឹងពាល់ត្រូវត្រជាក់ ក្តៅ ទន់ រឹង គ្រឿងខ្ទប់ (ប៉ះពាល់)កាយ ត្រជាក់ ក្តៅ ទន់ រឹង ជា រូប ដឹងជា នាម សតិដឹងទាន់ តាំងសតិទុកត្រង់ដឹងរបស់កាយ កំណត់ដឹងថា ត្រជាក់ ក្តៅ ទន់ រឹង ឬកំណត់ដឹងថា ពាល់ត្រូវ (ប៉ះពាល់) ។

"បែបបដិបត្តិទី៦"

ធ្វើតាមបែបបដិបត្តិទី១-២-៣-៤-៥ ផង និង

ខណៈដឹងកូន កូនជា រូប ដឹងជា នាម សតិដឹងទាន់ តាំងសតិទុកត្រង់ច្រមុះ កំណត់ដឹងថា ដឹងកូន ។

ខណៈដឹងរស រសជា រូប ដឹងជា នាម សតិដឹងទាន់ តាំងសតិទុកត្រង់អណ្តាត កំណត់ដឹងថា ដឹងរស ។

"បែបបដិបត្តិទី៧"

ធ្វើតាមបែបបដិបត្តិទី ១-២-៣-៤-៥-៦ និង

ខណៈកង្គុញ កង្គុញជា រូប ដឹងជា នាម សតិដឹងទាន់ តាំងសតិទុកត្រង់ក១ម្រើក (បត់) ចូល កំណត់ដឹងថា កង្គុញ ។

ខណៈលាត លាតជា រូប ដឹងជា នាម សតិដឹងទាន់ តាំងសតិទុកត្រង់កម្រើកលាតចេញ កំណត់ដឹងថា លាត ។

ខណៈកម្រើក កម្រើកជា រូប ដឹងជា នាម សតិដឹងទាន់ តាំងសតិទុកត្រង់រញ្ជួយកម្រើក កំណត់ដឹងថា កម្រើក ។

ខណៈញ័រ ញ័រជា រូប ដឹងជា នាម សតិដឹងទាន់ តាំងសតិទុកត្រង់ញ័រ កំណត់ដឹងថា ញ័រ ឬ កម្រើក ។

ខណៈងាកឆ្វេង ងាកស្តាំ ងាកជា រូប ដឹងជា នាម សតិដឹងទាន់ តាំងសតិទុកត្រង់កម្រើកងាក កំណត់ដឹងថា ងាក ។

ខណៈលេប លេបជា រូប ដឹងជា នាម សតិដឹងទាន់ តាំងសតិទុកត្រង់យ៉ាងកម្រើក កំណត់ដឹងថា លេប ។

"បៃបបដិបត្តិទី៨"

ធ្វើតាមបៃបបដិបត្តិទី ១-២-៣-៤-៥-៦-៧ និង

ខណៈឃើ បេះដូងជា រូប ឃើជា នាម សតិដឹងទាន់ តាំងសតិទុកត្រង់ឃើ កំណត់ដឹងថា ឃើ បើរមាស់ កំណត់ដឹងថា រមាស់ ។

ខណៈសប្បាយ បេះដូងជា រូប សប្បាយជា នាម សតិដឹងទាន់ តាំងសតិទុកត្រង់ដឹងសប្បាយ កំណត់ដឹងថា សប្បាយ ។

ខណៈមិនសប្បាយ បេះដូងជា រូប មិនសប្បាយជា នាម សតិដឹងទាន់ តាំងសតិទុកត្រង់ដឹងមិនសប្បាយ កំណត់ដឹងថា មិនសប្បាយ ។

ខណៈដឹងព្រងើយៗ បេះដូងជា រូប ព្រងើយៗ ជា នាម សតិដឹងទាន់ តាំងសតិទុកត្រង់ដឹងព្រងើយៗ កំណត់ដឹងថា ព្រងើយៗ ។

ខណៈដឹងចង់បាន បេះដូងជា រូប ចង់បានជា នាម សតិដឹងទាន់ តាំងសតិទុកត្រង់ដឹងចង់បាន កំណត់ដឹងថា ចង់បាន ។

ខណៈដឹងមិនគាប់ចិត្ត បេះដូងជា រូប មិនគាប់ចិត្តជា នាម សតិដឹងទាន់ តាំងសតិទុកត្រង់ដឹងមិនគាប់ចិត្ត កំណត់ដឹងថា មិនគាប់ចិត្ត ។

ខណៈងុយដេក បេះដូងជា រូប ងុយដេកជា នាម សតិដឹងទាន់ តាំងសតិទុកត្រង់ដឹងងុយដេក (ឬត្រង់កាយញ័រៃបើមាន) កំណត់ដឹងថា ងុយដេក ។

ខណៈចិត្តដឹងរយមាយ បេះដូងជា រូប រយមាយជា នាម សតិដឹងទាន់ តាំងសតិទុកត្រង់ចិត្តរយមាយ កំណត់ដឹងថា រយមាយ ។

ខណៈដឹងសង្ស័យស្ទាក់ស្ទើរ បេះដូងជា រូប សង្ស័យជា នាម សតិដឹងទាន់ តាំងសតិទុកត្រង់ចិត្តសង្ស័យ កំណត់ដឹងថា សង្ស័យ ។

ខណៈវង្វេង បេះដូងជា រូប វង្វេងជា នាម សតិដឹងទាន់ តាំងសតិទុកត្រង់ចិត្តវង្វេង កំណត់ដឹងថា វង្វេង ។

ខណៈនឹកគិត តាំងសតិទុកត្រង់ចិត្តនឹកគិត កំណត់ដឹងថា គិត ។

"បៃបបដិបត្តិទី៩"

ធ្វើតាមបៃបដិបត្តិទី១-២-៣-៤-៥-៦-៧-៨ និង

ហ្វឹកហាត់ ដើម្បីឲ្យសតិរពុកដឹងទាន់ ជំនាញក្នុងឥរិយាបថធំ និង ឥរិយាបថតូច ដូចតទៅនេះ ៖

ក- **វេលាភ្លាក់ពីដេក:**

ខណៈភ្លាក់ បេះដូងជា រូប ដឹងភ្លាក់ជា នាម សតិដឹងទាន់ តាំងសតិទុកត្រង់ចិត្តភ្លាក់ កំណត់ដឹងថា ភ្លាក់ ។

ខណៈបើកភ្នែក ត្របកភ្នែកកម្រើក បើកចេញជា រូប ដឹងជា នាម សតិដឹងទាន់ តាំងសតិទុកត្រង់ត្របកភ្នែកកម្រើក កំណត់ដឹងថា បើកភ្នែក ។

ខណៈឃើញ សតិដឹងទាន់ កំណត់ដឹងថា ឃើញ ។

ខណៈខិត កម្រើកខិតជា រូប ដឹងជា នាម សតិដឹងទាន់ តាំងសតិទុកត្រង់កាយញ័រកម្រើកខិត កំណត់ដឹងថា ខិត (ខិតចេញ ខិតចូល) ។

ខណៈក្រឡាប់ ក្រឡាប់ជា រូប ដឹងជា នាម សតិដឹងទាន់ តាំងសតិទុកត្រង់កាយក្រឡាប់ កំណត់ដឹងថា ក្រឡាប់ ។

ខណៈនឹកនឹងក្រោក កំណត់ដឹងថា នឹក ។

ខណៈត្រឡប់ដៃ តាំងសតិដឹងទាន់ត្រង់កម្រើកត្រឡប់ កំណត់ដឹងថាត្រឡប់ ។

ខណៈលើកដៃ លើកជា រូប ដឹងជា នាម តាំងសតិដឹងទាន់ត្រង់កម្រើកលើក កំណត់ដឹងថា លើក ។

ខណៈដៃទៅ ទៅជា រូប ដឹងជា នាម តាំងសតិដឹងទាន់ទុកត្រង់

ករម្រើកទៅ កំណត់ដឹងថា ទៅ ។

ខណៈដៃពាល់ត្រូវមុង រឹង ឬទន់ជា **រូប** *ដឹងជា* **នាម** *តាំងសតិដឹងទាន់ទុកត្រង់ដៃពាល់ត្រូវ កំណត់ដឹងថា ត្រូវ ។*

ខណៈដៃចាប់មុង ករម្រើកចាប់ជា **រូប** *ដឹងជា* **នាម** *តាំងសតិដឹងទាន់ទុកត្រង់ករម្រើកចាប់ កំណត់ដឹងថា ចាប់ ។*

ខណៈលើកមុង សតិដឹងទាន់ត្រង់ករម្រើកលើក កំណត់ដឹងថា លើក ។

ខណៈលើកមុងមក សតិដឹងទាន់ត្រង់ករម្រើកមក កំណត់ដឹងថា មក ។

ខណៈលែងមុង តាំងសតិដឹងទាន់ត្រង់ករម្រើកលែង កំណត់ដឹងថា លែង ។

ខណៈករម្រើកក្រោកឡើង តាំងសតិដឹងទាន់ត្រង់ករម្រើកក្រោកឡើង កំណត់ដឹងថា ក្រោកឡើង ។

ខណៈអង្គុយ កំណត់ដឹងថា អង្គុយ ។

ខណៈ ទិតចេញពីមុង កំណត់ដឹងថា ទិត ។ល។

សម្គាល់ហេតុ: *ធ្វើការកំណត់ទៅគ្រប់ៗ ខណៈ ដែលករម្រើកញ័រ ទាល់តែស្ងាត់ជំនាញ ។*

១- វេលាលុបមុខ:

ខណ:ទឹកទឹងលុបមុខ តាំងសតិដឹងទាន់ត្រង់ចិត្តទឹក កំណត់ដឹងថា ទឹក ។

ខណ:ឃើញផ្តិលទឹក ខណ:ឃើញប្រេង កំណត់ដឹងថា ឃើញ ។

ខណ:ងាក កំណត់ដឹងថា ងាក ។

ខណ:អង្គុយ កំណត់ដឹងថា អង្គុយ ។

ខណ:ក្រោក កំណត់ដឹងថា ក្រោក ។

ខណ:ឈរ កំណត់ដឹងថា ឈរ ។

ខណ:ឈាន កំណត់ដឹងថា ឈាន ។

ខណ:ឃើញ កំណត់ដឹងថា ឃើញ ។

ខណ:យកដៃចេញ កំណត់ដឹងថា ចេញ ។

ខណ:យកដៃទៅ កំណត់ដឹងថា ទៅ ។

ខណ:យកដៃពាល់ត្រូវផ្តិលទឹក ឬកែវទឹក កំណត់ដឹងថា ពាល់ត្រូវ

ខណ:ចាប់ផ្តិលទឹក កំណត់ដឹងថា ចាប់ ។

ខណ:លើកផ្តិលទឹក កំណត់ដឹងថា លើក ។

ខណ:លើកផ្តិលទៅ កំណត់ដឹងថា ទៅ ។

ខណ:ដាក់ផ្តិលចុះ កំណត់ដឹងថា ចុះ ។

ខណ:ដល់ កំណត់ដឹងថា ដល់ ។

ខណ:លែងផ្តិលទឹក កំណត់ដឹងថា លែង ។

ខណៈយកដៃទៅបើកក្បាលម៉ាស៊ីន កំណត់ដឹងថា យកដៃទៅ ។

ខណៈត្រូវ កំណត់ដឹងថា ត្រូវ ។

ខណៈចាប់ កំណត់ដឹងថា ចាប់ ។

ខណៈបង្វិល កំណត់ដឹងថា បង្វិល ។

ខណៈឃើញទឹកហូរចេញពីក្បាលម៉ាស៊ីនទឹក កំណត់ដឹងថា ឃើញ ។

ខណៈបានញ្ចូទឹកហូរអំពីម៉ាស៊ីន ប៉ះផ្តិលទឹក ឬភាជនៈត្រង់ទឹកកំណត់ដឹងថា បានញ្ចូ ។

ខណៈនឹកថាលួម កំណត់ដឹងថា នឹក ។

ខណៈមួលក្បាលម៉ាស៊ីនទឹកបិទ កំណត់ដឹងថា មួល ។

ខណៈលែងក្បាលម៉ាស៊ីន កំណត់ដឹងថា លែង ។

ខណៈយកដៃទៅចាប់ភាជនៈទឹក កំណត់ដឹងថា យកដៃទៅ ។

ខណៈត្រូវ កំណត់ដឹងថា ត្រូវ ។

ខណៈចាប់ កំណត់ដឹងថា ចាប់ ។

ខណៈលើក កំណត់ដឹងថា លើក ។

ខណៈមក កំណត់ដឹងថា មក ។

ខណៈចុះ កំណត់ដឹងថា ចុះ ។

ខណៈដល់ កំណត់ដឹងថា ដល់ ។

ខណៈលែង កំណត់ដឹងថា លែង ។

ខណៈលើកដៃទៅចាប់សំពត់ជូតមុខ *កំណត់ដឹងថា លើក ។*

ខណៈទៅ *កំណត់ដឹងថា ទៅ ។*

ខណៈចុះក្នុងទឹកខាងក្នុងភាជនៈ *កំណត់ដឹងថា ចុះ ។*

ខណៈត្រូវទឹកត្រជាក់ *កំណត់ដឹងថា ត្រជាក់ ។*

ខណៈពូតសំពត់ *កំណត់ដឹងថា ពូត ។*

ខណៈលើកសំពត់ *កំណត់ដឹងថា លើក ។*

ខណៈយកសំពត់ជូតមុខមកត្រង់មុខ *កំណត់ដឹងថា មក ។*

ខណៈត្រូវមុខ *កំណត់ដឹងថា ត្រូវ ។*

ខណៈដឹងត្រជាក់ *កំណត់ដឹងថា ត្រជាក់ ។*

ខណៈជូតទៅ *កំណត់ដឹងថា ជូត ។ល ។*

សម្គាល់ហេតុ: *តាំងសតិដឹងទាន់បច្ចុប្បន្នគ្រប់ៗ ខណៈ តាមស្ថាត់គួរដល់វិបាកសម្បត្តិ លុះត្រាតែសម្រេចការលុបមុខរាល់ថ្ងៃ ។*

ក- វេលាជម្រះធ្មេញ:

ខណៈនឹកនឹងជម្រះធ្មេញ *កំណត់ដឹងថា នឹក ។*

ខណៈឃើញច្រាសដុសធ្មេញ ឬថ្នាំដុសធ្មេញ *កំណត់ដឹងថា ឃើញ ។*

ខណៈក្រោក *កំណត់ដឹងថា ក្រោក ។*

ខណៈឈរ *កំណត់ដឹងថា ឈរ ។*

១ណៈ:ឈានទៅ	កំណត់ដឹងថា ឈាន ។
១ណៈ:ដល់	កំណត់ដឹងថា ដល់ ។
១ណៈ:យកដៃចេញ	កំណត់ដឹងថា ចេញ ។
១ណៈ:យកដៃទៅ	កំណត់ដឹងថា ទៅ ។
១ណៈ:ចុះ	កំណត់ដឹងថា ចុះ ។
១ណៈ:ប៉ះជ្រាស ឬថ្នាំដុសធ្មេញ	កំណត់ដឹងថា ប៉ះ ។
១ណៈ:ចាប់	កំណត់ដឹងថា ចាប់ ។
១ណៈ:លើក	កំណត់ដឹងថា លើក ។
១ណៈ:មក	កំណត់ដឹងថា មក ។
១ណៈ:បង្ខិត	កំណត់ដឹងថា បង្ខិត ។
១ណៈ:ឃើញ	កំណត់ដឹងថា ឃើញ ។
១ណៈ:យកជ្រាសទៅជូតថ្នាំដុសធ្មេញ	កំណត់ដឹងថា ជូត ។
១ណៈ:លើកជ្រាស	កំណត់ដឹងថា លើក ។
១ណៈ:នាំជ្រាសមក	កំណត់ដឹងថា មក ។
១ណៈ:ជ្រាសប៉ះបបូរមាត់	កំណត់ដឹងថា ប៉ះ ។
១ណៈ:ដុសធ្មេញ	កំណត់ដឹងថា ដុស ។
១ណៈ:ដុសទៅ	កំណត់ដឹងថា ទៅ ។

ខណៈដុសមក កំណត់ដឹងថា មក ។

សម្គាល់ហេតុ: តាំងសតិដឹងទាន់គ្រប់ខណៈ តាមអធ្យាស្រ័យលុះស្រេចរាល់ថ្ងៃ ។

ឃ- **វេលាងូតទឹក:**

ខណៈគិតនឹងងូតទឹក កំណត់ដឹងថា គិត ។

ខណៈក្រោក កំណត់ដឹងថា ក្រោក ។

ខណៈដើរឈានទៅ កំណត់ដឹងថា ឈាន ។

ខណៈឃើញកន្ទែងងូតទឹក កំណត់ដឹងថា ឃើញ ។

ខណៈដល់ កំណត់ដឹងថា ដល់ ។

ខណៈឈរ កំណត់ដឹងថា ឈរ ។

ខណៈយកដៃចេញ កំណត់ដឹងថា ចេញ ។

ខណៈយកដៃទៅ កំណត់ដឹងថា ទៅ ។

ខណៈយកដៃពាល់ត្រូវទ្វារបន្ទប់ទឹក កំណត់ដឹងថា ត្រូវ ។

ខណៈចាប់ទ្វារ កំណត់ដឹងថា ចាប់ ។

ខណៈទាញទ្វារ កំណត់ដឹងថា ទាញ ។

ខណៈមក កំណត់ដឹងថា មក ។

ខណៈលែង កំណត់ដឹងថា លែង ។

ខណៈយកដៃមក កំណត់ដឹងថា មក ។

១ណ:យកដៃពាល់ត្រូវ	កំណត់ដឹងថា ពាល់ត្រូវ ។
១ណ:ឈាន	កំណត់ដឹងថា ឈាន ។
១ណ:ឃើញ	កំណត់ដឹងថា ឃើញ ។
១ណ:ទឹកទឹងផ្ទាស់សំពត់	កំណត់ដឹងថា ទឹក ។
១ណ:យកដៃចេញ	កំណត់ដឹងថា ចេញ ។
១ណ:យកដៃទៅ	កំណត់ដឹងថា ទៅ ។
១ណ:ដៃពាល់ត្រូវសំពត់ផ្ងួតទឹក	កំណត់ដឹងថា ពាល់ត្រូវ ។
១ណ:ចាប់សំពត់	កំណត់ដឹងថា ចាប់ ។
១ណ:ទាញសំពត់	កំណត់ដឹងថា ទាញ ។
១ណ:មក	កំណត់ដឹងថា មក ។
១ណ:ត្រូវកាយ	កំណត់ដឹងថា ត្រូវ ។
១ណ:បង្ខិត	កំណត់ដឹងថា បង្ខិត ។
១ណ:ទាញ	កំណត់ដឹងថា ទាញ ។
១ណ:ចាប់	កំណត់ដឹងថា ចាប់ ។
១ណ:រលាស់	កំណត់ដឹងថា រលាស់ ។
១ណ:ត្រូវ	កំណត់ដឹងថា ត្រូវ ។
១ណ:ទាញសំពត់ស្ងៀកចេញ	កំណត់ដឹងថា ទាញ ។
១ណ:ចេញ	កំណត់ដឹងថា ចេញ ។

ខណ:ឱន	កំណត់ដឹងថា ឱន ។
ខណ:ដៃចាប់សំពត់ស្ងៀក	កំណត់ដឹងថា ចាប់ ។
ខណ:ក្រោកឡើងឈរ	កំណត់ដឹងថា ក្រោក ។
ខណ:យកសំពត់ទៅ	កំណត់ដឹងថា ទៅ ។
ខណ:ឃើញស្នូ ឬកន្ទែងហាលសំពត់	កំណត់ដឹងថា ឃើញ ។
ខណ:សំពត់ដល់	កំណត់ដឹងថា ដល់ ។
ខណ:បង្ខិតយកសំពត់ពាក់ស្នូឬព្យូរ	កំណត់ដឹងថា បង្ខិត ។
ខណ:លែង	កំណត់ដឹងថា លែង ។
ខណ:យកដៃមក	កំណត់ដឹងថា មក ។
ខណ:ឃើញអាងទឹក	កំណត់ដឹងថា ឃើញ ។
ខណ:ឈរ	កំណត់ដឹងថា ឈរ ។
ខណ:ងាក-បែរ	កំណត់ដឹងថា ងាក-បែរ ។
ខណ:ឈានទៅត្រង់អាងទឹក	កំណត់ដឹងថា ឈាន ។
ខណ:ដល់	កំណត់ដឹងថា ដល់ ។
ខណ:លើកជើង	កំណត់ដឹងថា លើក ។
ខណ:យកជើងទៅ	កំណត់ដឹងថា ទៅ ។
ខណ:យកជើងចុះ	កំណត់ដឹងថា ចុះ ។
ខណ:ជើងត្រូវទឹក	កំណត់ដឹងថា ត្រូវ ។

ខណៈដើងត្រជាក់ កំណត់ដើងថា ត្រជាក់ ។

ខណៈជើងត្រូវបាតអាងទឹក កំណត់ដើងថា ត្រូវ ។

ខណៈលើកជើងក្រោយ កំណត់ដើងថា លើក ។

ខណៈយកជើងក្រោយមក កំណត់ដើងថា មក ។

ខណៈជើងចុះ កំណត់ដើងថា ចុះ ។

ខណៈត្រូវទឹក កំណត់ដើងថា ត្រូវ ។

ខណៈដល់បាតអាង កំណត់ដើងថា ដល់ ។

ខណៈឈរ កំណត់ដើងថា ឈរ ។

ខណៈអង្គុយ កំណត់ដើងថា អង្គុយ ។

ខណៈទឹកត្រូវកាយត្រជាក់ កំណត់ដើងថា ត្រជាក់ ។

ខណៈត្រូវកាយ កំណត់ដើងថា ត្រូវ ។

ខណៈដេក កំណត់ដើងថា ដេក ។

ខណៈទឹកស្រក់ចុះមកត្រូវខ្លួន កំណត់ដើងថា ត្រូវ ។

សម្គាល់ហេតុ: តាំងសតិកំណត់គ្រប់ខណៈរបស់រូបនាម ដែលប្រាកដជាបច្ចុប្បន្នតាមអធ្យាស្រ័យរហូតទៅរាល់ថ្ងៃ ដរាបហើយ ។

ជ- **វេលាទទួលទានអាហារ:**

ខណៈឃើញ កំណត់ដើងថា ឃើញ ។

ខណៈបានពួ កំណត់ដើងថា បានពួ ។

១ណៈ:ឃ្លាន	កំណត់ដឹងថា ឃ្លាន ។
១ណៈ:ក្រោក	កំណត់ដឹងថា ក្រោក ។
១ណៈ:បង្ខិត	កំណត់ដឹងថា បង្ខិត ។
១ណៈ:ឈរ	កំណត់ដឹងថា ឈរ ។
១ណៈ:ឈានទៅ	កំណត់ដឹងថា ឈាន ។
១ណៈ:ដល់	កំណត់ដឹងថា ដល់ ។
១ណៈ:អង្គុយ	កំណត់ដឹងថា អង្គុយ ។
១ណៈ:ឃើញ	កំណត់ដឹងថា ឃើញ ។
១ណៈ:យកដៃចេញ	កំណត់ដឹងថា ចេញ ។
១ណៈ:យកដៃទៅ	កំណត់ដឹងថា ទៅ ។
១ណៈ:យកដៃដាក់ចុះត្រង់ក្បាលជង្គង់	កំណត់ដឹងថា ចុះ ។
១ណៈ:ត្រឡប់ដៃ	កំណត់ដឹងថា ត្រឡប់(ក្រឡាស់) ។
១ណៈ:លើកដៃ	កំណត់ដឹងថា លើក ។
១ណៈ:យកដៃទៅ	កំណត់ដឹងថា ទៅ ។
១ណៈ:យកដៃចុះ	កំណត់ដឹងថា ចុះ ។
១ណៈ:យកដៃត្រូវចាន	កំណត់ដឹងថា ត្រូវ ។
១ណៈ:យកដៃចាប់ចាន	កំណត់ដឹងថា ចាប់ ។
១ណៈ:លើកចាន	កំណត់ដឹងថា លើក ។

១ណ:យកចានមក	កំណត់ដឹងថា មក ។
១ណ:យកចានចុះ	កំណត់ដឹងថា ចុះ ។
១ណ:ចានដល់ទីវង	កំណត់ដឹងថា ដល់ ។
១ណ:លែងដៃចាកចាន	កំណត់ដឹងថា លែង ។
១ណ:យកដៃចេញ	កំណត់ដឹងថា ចេញ ។
១ណ:យកដៃទៅចាប់ស្វាបញ្ជ្រា	កំណត់ដឹងថា ទៅ ។
១ណ:ចុះ	កំណត់ដឹងថា ចុះ ។
១ណ:ប៉ះស្វាបញ្ជ្រា	កំណត់ដឹងថា ប៉ះ ។
១ណ:ចាប់ស្វាបញ្ជ្រា	កំណត់ដឹងថា ចាប់ ។
១ណ:បង្ខិត	កំណត់ដឹងថា បង្ខិត ។
១ណ:លើក	កំណត់ដឹងថា លើក ។
១ណ:យកស្វាបញ្ជ្រាទៅ	កំណត់ដឹងថា ទៅ ។
១ណ:យកស្វាបញ្ជ្រាចុះ	កំណត់ដឹងថា ចុះ ។
១ណ:ដល់	កំណត់ដឹងថា ដល់ ។
១ណ:ដួស	កំណត់ដឹងថា ដួស ។
១ណ:លើក	កំណត់ដឹងថា លើក ។
១ណ:មក	កំណត់ដឹងថា មក ។
១ណ:ចុះ	កំណត់ដឹងថា ចុះ ។

១ណ:ដល់	កំណត់ដឹងថា ដល់ ។
១ណ:ដួស	កំណត់ដឹងថា ដួស ។
១ណ:លើក	កំណត់ដឹងថា លើក ។
១ណ:មក	កំណត់ដឹងថា មក ។
១ណ:ស្វាបព្រាប៉ះមាត់	កំណត់ដឹងថា ប៉ះ ។
១ណ:ហា	កំណត់ដឹងថា ហា ។
១ណ:ផ្ទៀង	កំណត់ដឹងថា ផ្ទៀង ។
១ណ:ដាក់	កំណត់ដឹងថា ដាក់ ។
១ណ:បៀម	កំណត់ដឹងថា បៀម ។
១ណ:ប្រាកដរស	កំណត់ដឹងថា រស ។
១ណ:យកស្វាបព្រាចេញ	កំណត់ដឹងថា ចេញ ។
១ណ:យកស្វាបព្រាទៅ	កំណត់ដឹងថា ទៅ ។
១ណ:យកស្វាបព្រាចុះ	កំណត់ដឹងថា ចុះ ។
១ណ:ដល់	កំណត់ដឹងថា ដល់ ។
១ណ:លៃងដៃ	កំណត់ដឹងថា លៃង ។
១ណ:លើកដៃឡើងមក	កំណត់ដឹងថា លើក ។
១ណ:យកដៃមក	កំណត់ដឹងថា មក ។
១ណ:លូកដៃចុះប្រមូលបាយ	កំណត់ដឹងថា ចុះ ។

ខណៈត្រូវ កំណត់ដឹងថា ត្រូវ ។

ខណៈផ្អាប់ដៃ កំណត់ដឹងថា ផ្អាប់ ។

ខណៈធ្មេចភ្នែក កំណត់ដឹងថា ធ្មេច ។

ខណៈទំពា កំណត់ដឹងថា ទំពា ។

ខណៈលេប កំណត់ដឹងថា លេប ។

សម្គាល់ហេតុ: ធ្វើដោយន័យនេះ មានសតិដឹងទាន់គ្រប់ខណៈដែលទទួលទានអាហារ រហូតទៅតាមស្ថាត់រាល់ថ្ងៃ ។

ប- វេលាពាក់គ្រឿងស្លៀកដណ្ដប់

ខណៈនឹកនឹងពាក់អាវ កំណត់ដឹងថា នឹក ។

ខណៈយើញអាវ កំណត់ដឹងថា យើញ ។

ខណៈក្រោក កំណត់ដឹងថា ក្រោក ។

ខណៈឈរ កំណត់ដឹងថា ឈរ ។

ខណៈឈានទៅ កំណត់ដឹងថា ឈាន ។

ខណៈដល់ កំណត់ដឹងថា ដល់ ។

ខណៈដៃចេញទៅ កំណត់ដឹងថា ចេញ ។

ខណៈដៃទៅ កំណត់ដឹងថា ទៅ ។

ខណៈពាល់ត្រូវអាវ កំណត់ដឹងថា ត្រូវ ។

ខណៈចាប់អាវ កំណត់ដឹងថា ចាប់ ។

១ណ:លើកអាវ	កំណត់ដឹងថា លើក ។
១ណ:ទាញអាវ	កំណត់ដឹងថា ទាញ ។
១ណ:យកអាវមក	កំណត់ដឹងថា មក ។
១ណ:អាវត្រូវខ្ជូន	កំណត់ដឹងថា ត្រូវ ។
១ណ:បង្ហិតចាប់លាត	កំណត់ដឹងថា បង្ហិត ។
១ណ:ឃើញអាវចំណែកណាមួយ	កំណត់ដឹងថា ឃើញ ។
១ណ:លើកអាវ	កំណត់ដឹងថា លើក ។
១ណ:យកមកនឹងពាក់ដៃ	កំណត់ដឹងថា មក ។
១ណ:ត្រូវដៃ	កំណត់ដឹងថា ត្រូវ ។
១ណ:បង្ហិតដៃ	កំណត់ដឹងថា បង្ហិត ។
១ណ:យកដៃមួយទៅជួយទាញ	កំណត់ដឹងថា ទៅ ។
១ណ:ត្រូវ	កំណត់ដឹងថា ត្រូវ ។
១ណ:ចាប់	កំណត់ដឹងថា ចាប់ ។
១ណ:ទាញ	កំណត់ដឹងថា ទាញ ។
១ណ:លៃង	កំណត់ដឹងថា លៃង ។
១ណ:យកដៃទៅចាប់ដៃអាវម្ខាងទៀត	កំណត់ដឹងថា យកដៃទៅ ។
១ណ:ត្រូវ	កំណត់ដឹងថា ត្រូវ ។
១ណ:ចាប់	កំណត់ដឹងថា ចាប់ ។

ខណៈទាញ	កំណត់ដឹងថា ទាញ ។
ខណៈប៉ះកាយ	កំណត់ដឹងថា ប៉ះ ។
ខណៈលែង	កំណត់ដឹងថា លែង ។
ខណៈដៃមកដាក់ឡេវ	កំណត់ដឹងថា មក ។
ខណៈត្រូវ	កំណត់ដឹងថា ត្រូវ ។
ខណៈចាប់	កំណត់ដឹងថា ចាប់ ។
ខណៈរុញ	កំណត់ដឹងថា រុញ ។
ខណៈលែង	កំណត់ដឹងថា លែង ។

សម្គាល់ហេតុ: សូម្បីការកំណត់ស្រៀកខោ ទ្រង់ស្បង់ចីពរ ក៏ត្រូវ កំណត់ដឹងទាន់គ្រប់ខណៈ តាមតែស្ថាត់ រហូតទាល់តែសម្រេច និងតាំង សតិកំណត់គ្រប់វេលា ដែលស្រៀកដណ្តាប់ លុះជំនាញ ទាំងនេះតាមគួរដល់ ឋានៈរបស់ខ្ញុន ។

ឆ- វេលាបន្ទោបង់ឧច្ចារៈ-បស្សាវៈ

ខណៈឈឺពោះណាស់	កំណត់ដឹងថា ឈឺ ។
ខណៈនឹកនឹងទៅបង្គន់	កំណត់ដឹងថា នឹក ។
ខណៈក្រោក	កំណត់ដឹងថា ក្រោក ។
ខណៈឈរ	កំណត់ដឹងថា ឈរ ។
ខណៈឈានទៅ	កំណត់ដឹងថា ឈាន ។

ខណៈដល់	កំណត់ដឹងថា ដល់ ។
ខណៈយើញ	កំណត់ដឹងថា យើញ ។
ខណៈយកដៃចេញ	កំណត់ដឹងថា ចេញ ។
ខណៈយកដៃទៅ	កំណត់ដឹងថា ទៅ ។
ខណៈត្រូវទ្វារបង្គន់	កំណត់ដឹងថា ត្រូវ ។
ខណៈចាប់	កំណត់ដឹងថា ចាប់ ។
ខណៈទាញ	កំណត់ដឹងថា ទាញ ។
ខណៈលែង	កំណត់ដឹងថា លែង ។
ខណៈដៃមក	កំណត់ដឹងថា មក ។
ខណៈត្រូវ	កំណត់ដឹងថា ត្រូវ ។
ខណៈយើញ	កំណត់ដឹងថា យើញ ។
ខណៈឈាន	កំណត់ដឹងថា ឈាន ។
ខណៈបង្ខិតបង្ខិលខ្ជូនត្រឡប់ដើម្បីបិទទ្វារ	កំណត់ដឹងថា បង្ខិត ។
ខណៈងាក	កំណត់ដឹងថា ងាក ។
ខណៈយើញ	កំណត់ដឹងថា យើញ ។
ខណៈដៃចេញ	កំណត់ដឹងថា ចេញ ។
ខណៈដៃទៅ	កំណត់ដឹងថា ទៅ ។
ខណៈដៃត្រូវ	កំណត់ដឹងថា ត្រូវ ។

១ណៈចាប់	កំណត់ដឹងថា ចាប់ ។
១ណៈទាញ	កំណត់ដឹងថា ទាញ ។
១ណៈដល់	កំណត់ដឹងថា ដល់ ។
១ណៈលៃង	កំណត់ដឹងថា លៃង ។
១ណៈបែរទៅរកទីបន្ទោបង់	កំណត់ដឹងថា បែរ ។
១ណៈឈាន	កំណត់ដឹងថា ឈាន ។
១ណៈឈរ	កំណត់ដឹងថា ឈរ ។
១ណៈដៃចេញ	កំណត់ដឹងថា ចេញ ។
១ណៈទៅ	កំណត់ដឹងថា ទៅ ។
១ណៈចាប់	កំណត់ដឹងថា ចាប់ ។
១ណៈទាញ	កំណត់ដឹងថា ទាញ ។
១ណៈអង្គុយ	កំណត់ដឹងថា អង្គុយ ។
១ណៈឈឺ	កំណត់ដឹងថា ឈឺ ។
១ណៈឧច្ចារៈរំលងមាត់ទ្វារធ្ងន់ប៉ះត្រូវគ្នា	កំណត់ដឹងថា ត្រូវ ។
១ណៈបន្ទោរបង់ផុតចុះ	កំណត់ដឹងថា ផុត ។
១ណៈឃើញក្រដាសជម្រះ ឬទឹកជម្រះ	កំណត់ដឹងថា ឃើញ ។
១ណៈយកដៃចេញទៅ	កំណត់ដឹងថា ចេញ ។
១ណៈទៅ	កំណត់ដឹងថា ទៅ ។

ខណៈចុះ	*កំណត់ដឹងថា ចុះ ។*
ខណៈត្រូវ	*កំណត់ដឹងថា ត្រូវ ។*
ខណៈចាប់	*កំណត់ដឹងថា ចាប់ ។*
ខណៈលើក	*កំណត់ដឹងថា លើក ។*
ខណៈមក	*កំណត់ដឹងថា មក ។*
ខណៈត្រូវ	*កំណត់ដឹងថា ត្រូវ ។*
ខណៈដូត	*កំណត់ដឹងថា ដូត ។*
ខណៈលាង	*កំណត់ដឹងថា លាង ។*

សម្គាល់ហេតុ: *ឲ្យកំណត់ដឹងទាន់គ្រប់ខណៈ តាមស្មាត់រហូតដល់ការបស្សាវៈ ក៏មានន័យជាមួយគ្នា បើសតិដឹងមិនទាន់ ឲ្យធ្វើយឺតៗ ឲ្យព្យាយាមតាំងសតិដឹងទាន់ លុះជំនាញ ។*

ជ- វេលាចូលដេកៈ

ខណៈនឹកចង់នឹងដេក	*កំណត់ដឹងថា នឹក ។*
ខណៈក្រោក	*កំណត់ដឹងថា ក្រោក ។*
ខណៈឈរ	*កំណត់ដឹងថា ឈរ ។*
ខណៈឈាន	*កំណត់ដឹងថា ឈាន ។*
ខណៈដល់	*កំណត់ដឹងថា ដល់ ។*
ខណៈអង្គុយ	*កំណត់ដឹងថា អង្គុយ ។*

១ណ:យកដៃចេញ	កំណត់ដឹងថា ចេញ ។
១ណ:យកដៃទៅ	កំណត់ដឹងថា ទៅ ។
១ណ:យកដៃចុះ	កំណត់ដឹងថា ចុះ ។
១ណ:ដៃពាល់ត្រូវទីរង	កំណត់ដឹងថា ត្រូវ ។
១ណ:លាតភ្ជៀចេញ	កំណត់ដឹងថា លាត ។
១ណ:ផ្តេក ឬទម្រេតកាយចុះ	កំណត់ដឹងថា ចុះ ។
១ណ:ខ្នងត្រូវទីរង	កំណត់ដឹងថា ត្រូវ ។
១ណ:ក្រឡាស់ (ត្រឡប់)	កំណត់ដឹងថា ក្រឡាស់ ។
១ណ:ដេក	កំណត់ដឹងថា ដេក ។

"វេលាចូលមុងដេក"

១ណ:ឃើញមុង	កំណត់ដឹងថា ឃើញ ។
១ណ:ឈានទៅ	កំណត់ដឹងថា ឈាន ។
១ណ:ដល់	កំណត់ដឹងថា ដល់ ។
១ណ:អង្គុយ	កំណត់ដឹងថា អង្គុយ ។
១ណ:យកដៃចេញទៅនឹងចាប់មុង	កំណត់ដឹងថា ចេញ ។
១ណ:យកដៃទៅ	កំណត់ដឹងថា ទៅ ។
១ណ:ត្រូវ	កំណត់ដឹងថា ត្រូវ ។
១ណ:ចាប់	កំណត់ដឹងថា ចាប់ ។

ខណៈទាញ កំណត់ដឹងថា ទាញ ។

ខណៈទាញមក កំណត់ដឹងថា មក ។

ខណៈលៃង កំណត់ដឹងថា លៃង ។

ខណៈត្រូវ កំណត់ដឹងថា ត្រូវ ។

ខណៈបង្ខិត កំណត់ដឹងថា បង្ខិត ។

ខណៈផ្ដេកកាយចុះ កំណត់ដឹងថា ផ្ដេក ។

ខណៈត្រូវទីដេក កំណត់ដឹងថា ត្រូវ ។

ខណៈដេក កំណត់ដឹងថា ដេក ។

ខណៈក្រឡាស់ កំណត់ដឹងថា ក្រឡាស់ ។

សម្គាល់ហេតុ: តាំងសតិដឹងទាន់គ្រប់ខណៈ តាមគួរដល់ភាវៈរបស់ខ្លួន រហូតទៅលុះដំនាញ ។

ឈ- វេលាក្រាបសំពះអាចារ្យ:

ខណៈនឹកនឹងទៅរកអាចារ្យ កំណត់ដឹងថា នឹក ។

ខណៈក្រោក កំណត់ដឹងថា ក្រោក ។

ខណៈឈរ កំណត់ដឹងថា ឈរ ។

ខណៈឈាន កំណត់ដឹងថា ឈាន ។

ខណៈឃើញអាចារ្យ កំណត់ដឹងថា ឃើញ ។

ខណៈឈប់ កំណត់ដឹងថា ឈប់ ។

ខណ:ឈានទៅកន្ទះជំហានដើម្បីនឹងអង្ពុយស៊ប់ កំណត់ដឹងថា ឈាន ។

ខណ:អង្ពុយ	កំណត់ដឹងថា អង្ពុយ ។
ខណ:បង្ខិតជើង	កំណត់ដឹងថា បង្ខិត ។
ខណ:ត្រូវផ្ទៃដី	កំណត់ដឹងថា ត្រូវ ។
ខណ:យកដៃចេញ	កំណត់ដឹងថា ចេញ ។
ខណ:យកដៃទៅ	កំណត់ដឹងថា ទៅ ។
ខណ:យកដៃចុះត្រង់ជង្គង់	កំណត់ដឹងថា ចុះ ។
ខណ:ត្រូវ	កំណត់ដឹងថា ត្រូវ ។
ខណ:ផ្ការប់ដៃ	កំណត់ដឹងថា ផ្ការប់ ។
ខណ:ផ្ទាដៃ	កំណត់ដឹងថា ផ្ទា ។
ខណ:លើកដៃ	កំណត់ដឹងថា លើក ។
ខណ:យកដៃមកប្រណម្យចន្ទោះទ្រូង	កំណត់ដឹងថា មក ។
ខណ:យកដៃទីពីរមកត្រូវសម្ជស្យ	កំណត់ដឹងថា ត្រូវ ។
ខណ:ឱន	កំណត់ដឹងថា ឱន ។
ខណ:ងើយ	កំណត់ដឹងថា ងើយ ។
ខណ:យកដៃចេញ	កំណត់ដឹងថា ចេញ ។
ខណ:យកដៃទៅ	កំណត់ដឹងថា ទៅ ។
ខណ:យកដៃចុះ	កំណត់ដឹងថា ចុះ ។

ខណៈត្រូវជង្គង់ កំណត់ដឹងថា ត្រូវ ។

ខណៈផ្ការប់ដៃ កំណត់ដឹងថា ផ្ការប់ ។

ខណៈធ្មេចភ្នែក កំណត់ដឹងថា ធ្មេច ។

ខណៈបានញ្ជ កំណត់ដឹងថា បានញ្ជ ។

ខណៈនិយាយ កំណត់ដឹងថា និយាយ ។

សម្គាល់ហេតុ: ការក្រាបសំពះអាចារ្យ ក្នុងវេលាបដិបត្តិព្រះកម្មដ្ឋាន គប្បីក្រាបសំពះដោយវិធីដែលមិនភ្ជាចភ្ជាំង ឬភ្ជាចភ្ជាំងតិចតួចនិងធ្វើម្តងម្យ៉ាងកំណត់ដឹងទាន់តាមចង្វាក់ដែលបង្ខឹកហាត់ លុះត្រាតែស្ទាត់ជំនាញ ចំណែកវិធីបដិបត្តិយ៉ាងដទៃ ដែលនៅមិនទាន់សម្តែងទុកក្នុងទីនេះ ក៏នៅមានច្រើនទៀត ដែលអាចារ្យ ឬអ្នកជួយ ត្រូវអប់រំបង្ខឹកហាត់ចំពោះដោយសេចក្តីជិតស្និទ្ធធ្វើគម្រូឲ្យមើល ទាំងឥរិយាបថធំ និងឥរិយាបថតូច រហូតវិធីតាំងសតិរព្ធកដឹងទាន់បច្ចុប្បន្នធម៌ លុះត្រាតែស្ទាត់ជំនាញមិនភ្ជាចភ្ជាំង ។

"បែបបដិបត្តិទី១០"

តាមបែបបដិបត្តិទី ១ ដល់ទី ៩ លុះមានសតិដឹងទាន់ដោយបរិបូរ អាស្រ័យសេចក្តីព្យាយាម និងសតិ ដឹងទាន់ព្រមគ្រប់ខណៈ ដោយអាស្រ័យបញ្ញត្តិ ២ យ៉ាង ដើម្បីជាទីតោងចាប់របស់សតិ ការពារបញ្ញត្តិយ៉ាងដទៃគឺ

១- បញ្ញត្តិដែលបរិកម្មថា "...រូប...នាម..." ដែលមានសភាវ:រ៉ាប់រង ។

២- បញ្ញត្តិដែលបរិកម្មថា "...ហ្នុ៉" ដែលជាពាក្យរំពឹង ។

ពាក្យបរិកម្មទាំង ២ ប្រការនេះ នឹងចោលចេញមិនបាន បើសតិនៅទន់ (ខ្ចី) ព្រោះជាទីចាប់របស់សតិ ព្រមនឹងការពារមិនឲ្យចិត្តស្ទុះទៅកាន់បញ្ញត្តិដទៃ និងជាផ្ទូវនាំមកឲ្យកើតខណិកសមាធិ សតិដឹងទាន់ និងចាស់ក្លាឡើងបានគ្រប់ខណ: ។

កាលសតិចូលដល់សភាវ:ពិតៗ នឹងបរិកម្មថា "រូបនាម" និង "ហ្នុ៉" បានឯង កាលនោះព្រះយោគាវចរ ក៏អស់សេចក្តីចាំបាច់ក្នុងពាក្យបរិកម្មថា "រូបនាម" និង "ហ្នុ៉" ដែលជាបញ្ញត្តិដោយលះបង់ មិនមានតណ្ហាចូលទៅស្រឡាញ់បញ្ញត្តិថា "រូបនាម" និង "ហ្នុ៉" បើលះបរិកម្មហើយ សតិ សមាធិ បញ្ញា នឹងទន់ចុះ ក៏គប្បីមកបរិកម្មឬ បានតាមសេចក្តីចាំបាច់ កាលឥន្ទ្រីយ៍ចាស់ក្លាឡើងទៀត គឺមានសេចក្តីជឿលើសឡើង មានសេចក្តីព្យាយាមចាស់ឡើង មានសតិដឹងទាន់មិនភ្លេចជាសមាធិដឹងសភាវ:ច្បាស់ ហើយគប្បីលះបរិកម្មនោះចេញ ។

"បែបបដិបត្តិទី១១"

កាលសតិបញ្ញាចូលដល់សភាវ: ដឹងនឹងរូបនាមក្នុងទស្សន:ដែលពិតប្រាសចាកការគិតយក ដៅយក ឬគ្នេរគ្នាន់យក ដឹងដោយភាវនា-

ញ្ញាណពិតៗ លះបញ្ញត្តិក្នុងលោកទាំងអស់បាន និងលះបរិកម្មបានផងហើយ ក៏នឹងប្រាកដដឹងច្បាស់ឡើង មកឃើញច្បាស់ក្នុងចិត្តៗ ថា:

១- រូបនាមទាំងពីរនេះម្យ៉ាងម្នាក់ ។

២- អ្នកដឹងរូបនាមក៏ជាកិរិយាមួយ ។

៣- រូបនាមទាំងពីរនេះជាបច្ច័យដល់គ្នានិងគ្នាគឺ

ក- ផ្លូវភ្នែក ត្រចៀក ច្រមុះ អណ្ដាត កាយ រូបជាបច្ច័យឲ្យកើតនាម ។

ខ- ផ្លូវចិត្ត នាមជាបច្ច័យឲ្យកើតរូប ។

៤- រូបនាមទាំងពីរនេះ កើតឡើងមកហើយរលត់ទៅព្រមគ្នា ។

៥- រូបនាមរលត់ទៅព្រមនឹងដឹងក្នុងចិត្តថា មិនទៀងក៏មាន ។

៦- រូបនាមរលត់ទៅព្រមនឹងដឹងក្នុងចិត្តថា ធន់នៅមិនបានក៏មាន ។

៧- រូបនាមរលត់ទៅព្រមនឹងដឹងក្នុងចិត្តថា បង្ក្រាប់បញ្ជាមិនបានក៏មាន ។

កាលដូច្នេះ ឲ្យពិនិត្យពិចារណាឲ្យឃើញរូបនាមរលត់ទៅៗ ព្រមនឹងដឹងថា មិនទៀង ឬធន់នៅមិនបាន ឬបង្ក្រាប់បញ្ជាមិនបាន ទាន់គ្នាជានិច្ចដោយមិនឲ្យភ្ញេចឡើយ កាលដឹងស្គាត់ជំនាញហើយឈប់ពិនិត្យពិចារណាគង់ដឹងចំពោះសភាវ:រូបធម៌ នាមធម៌ រលត់ទៅព្រមនឹងលក្ខណ:

ដែលមិនទៀង ឬធន់នៅមិនបាន ឬបង្គាប់បញ្ជាមិនបានប៉ុណ្ណោះរហូតទៅ ។

"បែបបដិបត្តិទី១២"

កាលវិបស្សនាឃើញច្បាស់ក្នុងរូបធម៌ នាមធម៌ ជាសភាវៈសុទ្ធៗ មិនមានបញ្ញត្តិលាយឡំដូច្នោះហើយ សេចក្តីដឹងចាស់ក្លាឡើងក៏នឹងដឹងច្បាស់ថា:

១- វិបស្សនាអ្នកដឹងនេះ ក៏រលត់ទៅព្រមនឹងរូបនាមផងគ្រប់ៗ ខណៈ ។

២- ចិត្តផ្សេងចាកធម្មតា មានកម្លាំងឡើងយ៉ាងប្លែកចំឡែក ។

៣- ចិត្តចង្អៀតនឹងជាទុក្ខ ។

កាលបើដូច្នេះ ឲ្យព្យាយាម ឲ្យឃើញអ្នកដឹងនោះរលត់ទៅៗ ព្រមនឹងរូបនាមញាប់ឡើងជានិច្ច ។

"បែបបដិបត្តិទី១៣"

កាលញាណសេចក្តីដឹងចូលទៅឃើញរូបនាម និងអ្នកដឹង កើតរលត់ព្រមៗ គ្នា យូរទៅៗ ឃើញតែអ្នកដឹងរលត់ទៅៗ ញឹកជាប់នឹងរូបនាម លុះគណនារាប់មិនទាន់ ដូចនឹងព្រិញថ្ងៃ ឬគ្រាប់ភ្ងៀង ឬចាប់គ្រាប់ក្រូស ឬគ្រាប់ខ្សាច់បាចដូច្នោះ ច្បាស់ពិតៗ ដូច្នេះគឺ

១- រូបនាមកើតរលត់ជាចង្វាក់ មិនផ្ទួនគ្នា បើដឹងផ្ទូវទ្វារណាមួយហើយ ផ្ទូវទ្វារដទៃមិនកើត ។

២- ឃើញរូបនាមផ្ទូវភ្នែករលត់ញាប់ ទាំងបើកភ្នែកនិងបិទភ្នែក ។

៣- ឃើញរូបនាមផ្ទូវត្រចៀក រលត់ញាប់ កាលបានឮសំឡេង គ្រប់ប្រភេទ ។

៤- ឃើញរូបនាមផ្ទូវច្រមុះ រលត់ញាប់ កាលបានទទួលក្ងិនគ្រប់ ប្រភេទ ។

៥- ឃើញរូបនាមផ្ទូវអណ្តាត រលត់ញាប់ កាលបានទទួលរស គ្រប់ប្រភេទ ។

៦- ឃើញរូបនាមផ្ទូវចិត្តនេះ រលត់ញាប់ច្រើន ឈានទៅមួយ ជំហាននោះនឹងឃើញ ការរលត់តាំងអំពីលើកជើងឡើង ខណៈផុតផ្ទៃ ផែនដីខណៈយកជើងទៅ ខណៈយកជើងចុះ ខណៈជើងពាល់ត្រូវផែនដី ខណៈលោត ញឹកញាប់ លុះរាប់មិនគ្រប់ ។

៧- នឹងឃើញរូបនាមត្រង់បេះដូងលោតច្បាស់ជាប់គ្រប់ខណៈ ។

៨- នឹងឃើញរូបនាម ដែលកំពុងកើតរលត់ក្នុងគ្រប់ចំណែក របស់រាងកាយ រលត់ច្បាស់ជាប់ កាលខណៈប្រើវិបស្សនាញាណសម្ងឹង មើលតាំងអំពីក្បាលដល់ផ្ទៃជើង ។

៩- នឹងឃើញរូបនាមកើតរលត់ជាប់ ខណៈដង្ហើមសម្ជស្ស ចាក ចុងច្រមុះដល់សួត សួតច្រានដើមទ្រូង និងពោះឲ្យប៉ោង ឲ្យផត ជាក់ ច្បាស់ៗរលត់ញាប់ទីបំផុត ល្អិតទីបំផុត នៅគ្រប់ខណៈ ដូចឃើញលម្អង អណ្តែតកាត់ពន្ធឺព្រះអាទិត្យដូច្នោះ ។

កាលឃើញដូច្នេះហើយ ឲ្យព្យាយាមសម្ធឹងមើលឃើញតែរលត់ៗជានិច្ច សូម្បីថាចិត្តនឹងមានអាល័យញ៉ាតក់ស្ងុត ក៏កុំឲ្យក្រែងខ្ទាចឡើយ ឲ្យមើលរូបនាមរលត់ទៅដូច្នោះ មិនលះបង់ លើលះបង់ហើយ ចាប់អារម្មណ៍ដទៃក្រៅចាករូបនាមក្នុងខណៈនេះ ក៏ឲ្យកាន់ថា មិនមែនផ្លូវអស់ទុក្ខឡើយ ។

"បែបបដិបត្តិទី១៤"

កាលវិបស្សនាញាណដឹងច្បាស់ក្នុងរូបធម៌ នាមធម៌ រលត់ទៅៗ ព្រមគ្នាដូច្នេះ ក៏នឹងកើតសេចក្ដីដឹងឡើងមកក្នុងចិត្ត យ៉ាងមិនធ្លាប់មានមកក្នុងកាលមុនគឺ

១- ឃើញរូបនាម និងអ្នកដឹងរលត់ទៅៗ ដឹងថាជាភ័យ គួរខ្ទាចក្រែលង ។

២- ឃើញរូបនាម និងអ្នកដឹងរលត់ទៅៗ ដឹងថាជាទោសក្រែលង ។

៣- ឃើញរូបនាម និងអ្នកដឹងរលត់ទៅៗ ដឹងថាគួរនឿយណាយក្រែលង ។

៤- ឃើញរូបនាម និងអ្នកដឹងរលត់ទៅៗ ដឹងប្រាថ្នានឹងរត់ចេញ ។

៥- ឃើញរូបនាម និងអ្នកដឹងរលត់ទៅៗ ដឹងរកផ្លូវរត់ចេញ ។

៦- ឃើញរូបនាម និងអ្នកដឹងរលត់ទៅៗ ដឹងថានេះ រត់មិនផុត

ចាំបាច់សម្ងឹងមើលព្រងើយៗ ទៅ ។

កាលដូច្នេះហើយ ឲ្យរូបរួមកម្ចាំងចិត្តតស៊ូនឹងសេចក្តីរួញរា សេចក្តីតក់ស្ងុតរន្ធត់ ចិត្តញ័រ នឹងដាច់ខ្យល់ មានអាការប្រហែលមនុស្ស ជួនជិតនឹងស្ងាប់ ដូចត្រូវសង្កត់ឲ្យលិចទឹកក៏ដោយចុះ ព្រះយោគាវចរអ្នកបដិបត្តិវិបស្សនានឹងត្រូវរឹងប៉ឹងដាច់ខាត សុខចិត្តព្រមលះជីវិត ឈាមសាច់កាត់អាល័យក្នុងលោកនេះចេញ ដើម្បីសម្ងឹងមើលរូបនាម ដែលរលត់ទៅព្រមៗនឹងមានលក្ខណៈមិនទៀង ឬមានលក្ខណៈធន់នៅមិនបាន ឬមានលក្ខណៈបង្គាប់បញ្ជាមិនបាន ចាប់លក្ខណៈ ៣ ណាមួយរបស់រូបនាមស្ងាត់ ជាគូជីវិតពុះពារឧបសគ្គទាំងឡាយឲ្យវិនាសទៅជានិច្ច ។

"បៃបបដិបត្តិទី១៥"

កាលឃើញរូបនាមរលត់ទៅៗ ព្រមទាំងអាការដែលរត់មិនផុតសម្ងឹងមើលព្រងើយនៅដូច្នោះ លុះកម្ចាំងញាណសេចក្តីដឹងនេះបរិបូរឡើងមានអាការដូច្នេះ

១- ទុក្ខទីបំផុត គឺចង្អៀតចិត្តស្ងើរដាច់ខ្យល់ ដូចនៅក្នុងរណ្តៅដែលមានដីសង្កត់គ្រប ប្រហែលនឹងនៅក្នុងគំនរភ្ងើង ។

២- មិនមានសេចក្តីចង់បានអ្ងីឡើយ ចិត្តក្រៀមក្រំ ទឹកមាត់រីងស្ងួតដូចឈាមសាច់មិនមានក្នុងរាងកាយ ។

៣- ចិត្តនោះមានសង្ឃឹមជាទីបំផុតដែលផុតចាកទុក្ខនេះ ។

៤- ញាណសេចក្តីដឹងមោះមុត ដូចសស្ត្រាដ៏មុតក្លា ។

កាលដូច្នេះ ក៏មិនត្រូវការ រៀលាយើញរូបនាម និងអ្នកដឹងរលត់ទៅៗមានលក្ខណៈ ៣ ណាមួយ គឺតាំងនៅមិនបាន គឺមិនទៀងប្ចធន់នៅមិនបានប្ចបង្ត្រាប់មិនបានថែមឡើងៗ ដូចការស្ទុះរត់គេចសត្វកាចដែលប្រព្រឹត្តទៅតាមលំដាប់ខណៈរបស់វិបីជវនចិត្តដូច្នេះ ៖

ខណៈទី១ រូបនាមរលត់ទៅៗ មិនទៀងពិត ។

ខណៈទី២ រូបនាមរលត់ទៅៗ មិនទៀងពិតខ្លាំងឡើងៗទៀត ។

ខណៈទី៣ រូបនាមរលត់ទៅៗ មិនទៀងពិតៗ ខ្លាំងទីបំផុត ។

ខណៈទី៤ មិនយើញរូបនាមហើយ សេចក្តីដឹងបង្អោនទៅកាន់សេចក្តីរលត់របស់រូបនាម ។

ខណៈទី៥ រូបនាមនិងលោកនេះរលត់អស់ ដូចសេចក្តីរលត់នៃភ្លើងរំសេវផ្ទុះ មិនមានអ្វីសល់ មិនមានទុកក្នុងទីដូច្នោះ ។

ខណៈទី៦ ឃើញរលត់នៅដូច្នោះ មិនមែនលោកនេះ មិនមែនលោកដទៃ តែទៀង ។

ខណៈទី៧ ឃើញរលត់នៅដូច្នោះ មិនមែនលោកនេះ មិនមែនលោកដទៃ តែទៀង ។

ខណៈទី៨ នឹងតៗទៅ ដឹងខ្ជូនថា មកកាន់លោកនេះតាមដើមមានក្នែកដែលទូលាយទទួលឃើញពណ៌ មានត្រចៀកបានទទួលស្តាប់

សំឡេងមានកិនមកខ្ទប់ច្រមុះ មានរសមកខ្ទប់អណ្ណាត មានកាយមកខ្ទប់ត្រឿងសម្ជស្សតាមដើម មានសេចក្តីដឹងក្នុងចំណែកផ្សេងៗ ប្រាកដឡើង មានចិត្តដ៏ស្រាលចេញហើយ រូបនាមល្អិត ។ អ្នកនោះ ដល់សេចក្តីអស់ទៅនៃសេចក្តីសង្ស័យ មានញាណដឹងច្បាស់ថា យើងបានដល់ហើយនូវសេចក្តីរលត់ទៅនៃរូបនាម ដល់ហើយនូវសេចក្តីរលត់ទុក្ខទាំងពួង ដល់ហើយនូវសភាវៈដែលទៀង ដល់ហើយនូវសន្តិធម៌ដែលមាំមួនជា **បរមោ សុខោ** ជាមហាសន្តិសុខយ៉ាងពិតប្រាកដ ។ អ្នកនោះ ជាអ្នកមានអារម្មណ៍ជាអធិបតី កាត់វដ្តៈបានហើយកើតទៀតយ៉ាងច្រើនត្រឹម ៧ ជាតិប៉ុណ្ណោះ **បត្ថហបាយេហិ** បិទទ្វារអបាយទាំង ៤ បានហើយ មិនទៅកាន់លទ្ធិសាសនាដទៃទៀត មានបញ្ចសីលដ៏បរិសុទ្ធដោយដាច់ខាត ហើយរាប់អំពីខណៈនេះតទៅ មានសន្តិធម៌ដ៏មាំមួនជាអារម្មណ៍ហើយ មិនបានក្រាញនៅត្រឹមប៉ុណ្ណោះ តាំងសតិកំណត់រូបនាមតាមសភាវៈដែលពិតតទៅ ជាអ្នកសិក្សាដើម្បីបរិញ្ញាជាន់ខ្ពស់ មិនថយក្រោយទៀតតទៅ អ្នកដល់ហើយប៉ុណ្ណោះ ជាអ្នកដឹង និងដឹងច្បាស់ចំពោះខ្លួនដឹងជួសគ្នាមិនបាន ។

"ឃែបបដិបត្តិទី១៦"

កាលត្រឡប់មកកាន់លោកិយទៀត គ្រងទុកនូវខន្ធ ៥ រូបនាមទៀត

ពិចារណាឃើញសេចក្ដីរលត់ អ្នកឃើញសេចក្ដីរលត់ និងពិចារណាសេចក្ដីស្រឡាញ់ សេចក្ដីស្អប់ សេចក្ដីភ្ញាក់ ដែលសល់នៅយ៉ាងស្រាលខ្លះ ឃើញទុក្ខ ឃើញភ័យក្នុងការដែលនឹងត្រូវបែករូបនាមទៀត ទើបផ្ដើមចម្រើនវិបស្សនាកម្មដ្ឋានទៀតតទៅ ដើម្បីលះកិលេសនិងរំលត់រូបនាមខាងលើឲ្យប្រាកដ លុះកើតញាណតាមលំដាប់ដូច្នេះ

១- ញាណដឹងរូបនាមកើតរលត់ មិនទៀង ធន់មិនបាន បង្ខាំមិនបាន ។

២- ញាណដឹងរូបនាមរលត់ទៅៗ ។

៣- ញាណដឹងរូបនាមរលត់ទៅៗ គួរខ្ជាប ។

៤- ញាណដឹងរូបនាមរលត់ទៅៗ ជាទោស ។

៥- ញាណដឹងរូបនាមរលត់ទៅៗ គួរនឿយណាយ ។

៦- ញាណដឹងរូបនាមរលត់ទៅៗ ចង់រត់ចោល ។

៧- ញាណដឹងរូបនាមរលត់ទៅៗ រកផ្លូវរត់ ។

៨- ញាណដឹងរូបនាមរលត់ទៅៗ រត់មិនផុតសម្ងឹងមើលព្រងើយៗ ។

កាលញាណសេចក្ដីដឹងចាស់ក្លាឡើង លុះឃើញទុក្ខច្បាស់ មិនមានសេចក្ដីចង់ សេចក្ដីអាល័យ សូម្បីតែបន្ដិចបន្ដួច បង្ហានទៅដើម្បីសេចក្ដីអស់ទុក្ខដោយចំណែកមួយ ពោរពេញបរិបូរហើយ ចិត្ដនឹងប្រព្រឹត្ដទៅតាមមគ្គជវនវិថីដូច្នេះ ៖

ខណៈទី១ ឃើញរូបនាមរលត់ទៅៗ មិនទៀងពិតៗ ។

ខណៈទី២ ឃើញរូបនាមរលត់ទៅៗ មិនទៀងពិតលើសដើម ។

ខណៈទី៣ ឃើញរូបនាមរលត់ទៅៗ មិនទៀងពិតទីបំផុត ។

ខណៈទី៤ ឃើញរូបនាមបង្ហាន់ទៅកាន់សេចក្តីរលត់ ចិត្តបរិសុទ្ធ ទីបំផុត ។

ខណៈទី៥ ឃើញរូបនាមរលត់ចុះទៀត មិនមែនលោកនេះ មិនមែនលោកដទៃ តែទៀង ។

ខណៈទី**៦** ឃើញសេចក្តីរលត់ដូច្នោះនៅទៀត ។

ខណៈទី៧ នឹងខណៈតទៅ ក៏ដឹងខ្លួនថ្មីជារូបនាមដូចមុនទៀត ឈ្មោះថា ឈានឡើងកាន់ភាពជាអ្នកឃើញសេចក្តីរលត់ចាកលោកនេះ ជាជាន់ទីពីរ ។

ជាន់ទី៣ ក៏គប្បីចម្រើនវិបស្សនាភាវនាទៅតាមលំដាប់របស់ញាណ និងជវនវិថី ដូចសម្តែងមកហើយនោះឯង តែរូបនាមប្រណីតល្អិតឡើងប៉ុណ្ណោះ។

ជាន់ទី៤ ក៏គប្បីចម្រើនវិបស្សនាភាវនាទៅតាមលំដាប់របស់សេចក្តីដឹងគឺញាណ លុះចូលកាន់មគ្គជវនវិថី ដូចសម្តែងមកហើយនោះឯង អ្នកបានលុះដឹងច្បាស់ចំពោះខ្លួនថា ភពនេះអស់ហើយ ជាតិនេះជាជាតិទីបំផុត លោភៈ ទោសៈ មោហៈ និងអកុសលធម៌រលត់អស់មិនមានសល់

ទៀត តទៅមិនមានល្អ មិនល្អ ព្រោះអស់ល្អហើយ ។

"បៃបបដិបត្តិទី១៧"

អ្នកជួបឃើញសេចក្តីរលត់ហើយ គ្រាទី១ ក្តី ទី២ ទី៣ ទី៤ ក្តី មានសេចក្តីត្រេកអរដែលនឹងចូលនៅក្នុងសេចក្តីរលត់នោះបាន ២វិធី ៖

វិធីទី១ : មានរូបនាមជាអារម្មណ៍ ជាបច្ច័យបញ្ជូន ដោយការពិចារណារូបនាមកើតរលត់ ឃើញនឹងបានលក្ខណៈ ៣ របស់រូបនាមដែលកើតរលត់ថា មិនទៀងជាដើម ជាអារម្មណ៍ ធ្វើវិបស្សនាញាណលុះដល់ឡើងកាន់ផលជវនវិថីគឺ ៖

ខណៈទី១ ឃើញរូបនាមរលត់ទៅ មិនទៀង ។

ខណៈទី២ ឃើញរូបនាមរលត់ទៅ មិនទៀងខ្លាំងឡើង ។

ខណៈទី៣ ឃើញរូបនាមរលត់ទៅ មិនទៀងខ្លាំងទីបំផុត ។

ខណៈទី៤ ឃើញរូបនាមរលត់ទៅ ចូលដល់សេចក្តីបរិសុទ្ធរបស់ចិត្ត ។

ខណៈទី៥ សេចក្តីរលត់ដែលធ្លាប់ឃើញមកប្រាកដទៀត ។

ខណៈទី៦ សេចក្តីរលត់ប្រាកដនៅដូច្នោះ ។

ខណៈទី៧ សេចក្តីរលត់ប្រាកដនៅដូច្នោះ ។

ខណៈចិត្តតទៅ ក៏សម្លឹងយកអារម្មណ៍រលត់នោះជាអារម្មណ៍ដរាបទៅ រលត់ចាកអារម្មណ៍ដទៃទាំងអស់ តាមកំណត់របស់វេលាដែល

អធិដ្ឋានទុកដោយមានលក្ខន្តិកៈដូច្នេះ ៖

១- មានសេចក្ដីប្រាថ្នានឹងនៅក្នុងសេចក្ដីរលត់ ជាបរមសុខនោះ ។

២- អ្នកជួបសេចក្ដីរលត់ គ្រាទី១-២-៣-៤ ចូលបានទាំងអស់ ។

៣- អធិដ្ឋានកំណត់វេលាចូលនៅក្នុងសេចក្ដីរលត់ ចាក ១ នាទី ២-៣-៤-៥-៦ នាទី រហូតដល់ ១ ម៉ោង ២-៣-៤-៥ ម៉ោង រហូតថ្ងៃ, យប់ ។ ល ។ ក៏បាន តាមសេចក្ដីជំនាញ និងកម្លាំងរបស់សមាធិ ។

៤- កំណត់រូបនាមតាមលំដាប់ញាណ លុះសេចក្ដីរលត់ប្រាកដ ចោលនិមិត្ត និងរូបនាមទាំងពួងរលត់អស់ ។

៥- កាន់យកសេចក្ដីរលត់ជាអារម្មណ៍ លុះដល់អប្បនាសមាធិ មានសេចក្ដីមាំមួននៅក្នុងសេចក្ដីរលត់ជាអារម្មណ៍មួយ តាមកំណត់វេលាដែលអធិដ្ឋានទុក (មានអង្គឈានរបស់បឋមជ្ឈានចូលប្រកប) ។

៦- កាលអស់អំណាចរបស់សមាធិ អស់វេលាក៏ចោលអារម្មណ៍រលត់ទទួលអារម្មណ៍ក្នុងបញ្ចទ្វារតាមដើម ។

វិធីទី២ : ចានឈានជាអារម្មណ៍ ជាបច្ច័យបញ្ជូន គឺការចូលនៅក្នុងសេចក្ដីរលត់ សេចក្ដីដឹងទាំងអស់ដោយអស់ដើង គឺរលត់ចិត្ត និងចេតសិករហូត ៧ ថ្ងៃ ដោយការសម្ដឹងឈានជាអារម្មណ៍ នាំកម្មដ្ឋានណាមួយ ដែលអាចឲ្យដល់បញ្ចមជ្ឈានបាន បរិកម្មលុះកើតឧគ្គហនិមិត្ត

ជាប់ក្នែក បរិកម្មទៅលុះកើតបដិភាគនិមិត្ត ពង្រីកនិមិត្តជាចំណែកៗ បាន លុះជាឧបចារសមាធិ ជិតដល់ភាពជាឈាន សម្ធីងទៅលុះជា អប្បនាសមាធិ មានអង្គ្គឈានគឺ **វិតក្ក: វិចារ: ** **ប**ីតិ **សុ**ខ **ឯ**ក**គ្គ**តា ចូលប្រកប សង្ក្ត**ន**ីវ**ណ**: **ក**ាម**ច្ឆ**ន្ទ: ចូលចិ**ត**្ត**ក**ុ**ង**ក**ាមារ**ម**្ម**ណ**៍ **ព្យ**ាបាទ: សេចក្ដីស្អប់ **ថ**ីន**ម**ិ**ទ**្ធ: សេចក្ដីងោ**ក**ង**ក**់ង**ង**ុយដេ**ក** **ឧ**ទ្ធ**ច**្ច**ក**ុ**ក**ុ**ច**្ច: សេចក្ដីរាយមាយរំ**ខ**ានចិ**ត**្ត **វ**ិ**ចិ**ិ**ក**ិ**ច**្ឆ សេចក្ដីសង្ស័យ**ស**្ម**ា**ក់ស្ទើ**រ**ចេ**ញ**ា**ន លុះ**ក**ន្ទ**ង**ឈានគឺ

១- **ក**ន្ទ**ង**ប**ឋ**ម**ឌ**្ឈ**ា**ន ហើ**យ**ចោ**ល**ប**ឋ**ម**ឌ**្ឈ**ា**ន ឡើ**ង**ទ**ុ**ត**ិ**យ**ឌ**្ឈ**ា**ន ។

២- **ក**ន្ទ**ង**ទ**ុ**ត**ិ**យ**ឌ**្ឈ**ា**ន ហើ**យ**ចោ**ល**ទ**ុ**ត**ិ**យ**ឌ**្ឈ**ា**ន ឡើ**ង**ត**ត**ិ**យ**ឌ**្ឈ**ា**ន ។

៣- **ក**ន្ទ**ង**ត**ត**ិ**យ**ឌ**្ឈ**ា**ន ហើ**យ**ចោ**ល**ត**ត**ិ**យ**ឌ**្ឈ**ា**ន ឡើ**ង**ច**ត**ុ**ត**្ថ**ឌ**្ឈ**ា**ន ។

៤- **ក**ន្ទ**ង**ច**ត**ុ**ត**្ថ**ឌ**្ឈ**ា**ន ហើ**យ**ចោ**ល**ច**ត**ុ**ត**្ថ**ឌ**្ឈ**ា**ន ឡើ**ង**ប**ញ**្ច**ម**ឌ**្ឈ**ា**ន ។

៥- **ក**ន្ទ**ង**ប**ញ**្ច**ម**ឌ**្ឈ**ា**ន ហើ**យ**ចោ**ល**ប**ញ**្ច**ម**ឌ**្ឈ**ា**ន ឡើ**ង**អ**រ**ូ**ប**ឌ**្ឈ**ា**ន ។

៦- **ក**ន្ទ**ង**អ**រ**ូ**ប**ឌ**្ឈ**ា**ន **អ**ា**ក**ា**ស**ា**ន**ញ**្ចា**យ**ត**ន: ឡើ**ង**វ**ិ**ញ**្ញ**ា**ណ**ញ**្ចា**យ**ត**ន: ។

៧- **ក**ន្ទ**ង**វ**ិ**ញ**្ញ**ា**ណ**ញ**្ចា**យ**ត**ន: ឡើ**ង**អ**ា**ក**ិ**ញ**ចៈ**ញ**្ចា**យ**ត**ន: ។

៨- **ក**ន្ទ**ង**អ**ា**ក**ិ**ញ**ចៈ**ញ**្ចា**យ**ត**ន: ឡើ**ង**ន**ៅ**ស**ញ**្ញ**ា**ន**ា**ស**ញ**្ញ**ា**យ**ត**ន: ។

កាលឡើ**ង**ដ**ល**់ន**ៅ**ស**ញ**្ញ**ា**ន**ា**ស**ញ**្ញ**ា**យ**ត**ន:ហើ**យ** **ក**ម្ចាំ**ង**ស**ម**ា**ធ**ិ អ**រ**ូ**ប**ឌ**្ឈ**ា**ន**ខ្ចាំ**ង**ប្រ**ើ**ន**ដ**ល**់ឲ**្យ**ចិ**ត**្ត**ដ**ែ**ល**ស្ថ**ិ**ត**ទ**ន**ៃ**ដ**ៃ**ស**ូ**ប**ៃ**ប**្រ**ណ**ីត **ចាំ**ប**ាន**ខ្ចុ**ះ ចាំ**ម**ិ**ន**ប**ាន**ខ្ចុ**ះ **ល**ត**ស**ិ**ទ**ុ**ចុ**ះ**ភ**ូ**ម **ជ**ា **ឯ**ក**ត**្ត**ប**រ**ម**ស**ុ**ខ **ចិ**ត**្ត **និ**ង**ចេ**ត**ស**ិ**ក

រលត់អស់នៅបាន ៧ ថ្ងៃ ក្នុងឥរិយាបថណាមួយ បើឈរក៏ឈរនៅ
រហូត ៧ ថ្ងៃ បើអង្គុយក៏អង្គុយនៅបានរហូត ៧ ថ្ងៃ មិនស្ងាប់ រៀលានោះ
នឹងយកភ្ជើងមកដុត ក៏មិនធេះ ការដែលអ្នកចូលនៅក្នុងសេចក្តីរលត់ តាម
វិធីទី២ ដែលហៅថា និរោធសមាបត្តិ នោះ ដោយមានលក្ខន្តិក:ដូច្នេះ

១- មានសេចក្តីប្រាថ្នានឹងចូលនិរោធ ដើម្បីចៀសទុក្ខរូប ទុក្ខនាម
ដែលបានទទួល ។

២- ត្រូវបានអរូបជ្ឈាន ដល់នេវសញ្ញានាសញ្ញាយតន: ។

៣- អ្នកចូលត្រូវជាព្រះអនាគាមី ឬព្រះអរហន្ត ដែលបានឈាន
សមាបត្តិ ៨ ។

៤- ធ្វើវសី ជំនាញក្នុងសម្បទា ៤ គឺ

ក- មានសមាធិ និងវិបស្សនាជាកម្ងាំងជំនាញ ។

ខ- ជំនាញក្នុងការរម្ងាប់កាយសង្ខារ វចីសង្ខារ និងមនោសង្ខារ ។

គ- ជំនាញក្នុងសោឡសញ្ញាណ ។

ឃ- ជំនាញក្នុងឈានសមាបត្តិ ៨ មកមុន ។

៥- ចិត្ត និងចេតសិករលត់អស់ ។

៦- តាំងនៅក្នុងសេចក្តីរលត់ អស់សេចក្តីដឹងណាៗ ទាំងអស់
៧ ថ្ងៃ ។

ខណ:ចូលនិរោធ នឹងយកទៅកប់ក្នុងដី ក៏មិនជាអន្តរាយដល់

មរណៈតែកាលគ្រប់កំណត់ ៧ ថ្ងៃ ជីកឡើងមកហើយ ក៏នឹងមានសេចក្តីដឹងដូចដើម និងមានកម្ចាំងតាំងនៅក្នុងសភាពប្រក្រតី ការដែលមិនស្ងាប់ មិនស្អុយ មិនរលួយ មិនជាអន្តរាយ យ៉ាងណានោះ ព្រោះអំណាចរបស់និរោធ និងឱជានៃអាហារឃុំគ្រងទុក កាលចេញចាកនិរោធសមាបត្តិ ថ្មីៗ នឹងដឹងឃ្ងាន ទាយក ទាយិកាណា បានថ្វាយទាន ដែលរកបានមកដោយសុចរិត មានចេតនាល្អក្នុងកាលទាំង ៣ គឺមុនថ្វាយ កំពុងថ្វាយ និងថ្វាយហើយក្នុងស្រែបុណ្យ គឺព្រះអរហន្ត ដែលចេញចាកនិរោធសមាបត្តិ ទាយកទាយិកានោះ នឹងបានទទួលផលក្នុងបច្ចុប្បន្នពិតប្រាកដ ព្រះអរិយៈអ្នកចូលសមាបត្តិនេះ គឺអ្នកចូលដល់សន្តិធម៌ដ៏មាំមួនជាមហាសន្តិសុខដ៏កំពូល មិនមានសុខដទៃនឹងលាយឡំ ដរាបអស់ខន្ធបរិនិញ្ចាននោះឯង ។

ភាគ២ចប់

ឆាគ៣

ភាគនេះជាភាគផល ចាត់ជាខត្តមភាគ ជាភាគដែលខ្ពស់បំផុតដោយ រាប់ជាប់ចាកសេចក្តីសម្រេចកិច្ចការងារ ក្នុងព្រះពុទ្ធសាសនាជាជាន់ៗ ទៅគឺ

ភាគ១- ភាគបរិយត្តិ ចាត់ជា **ភាគបឋម** ។

ភាគ២- ភាគបដិបត្តិ ចាត់ជា **ភាគមធ្យម** ។

ភាគ៣- ភាគបដិវេធ ចាត់ជា **ភាគខត្តម** ។

សុទ្ធសឹងតែជាភាគដែលចោលចេញអំពីគ្នាមិនបាន ត្រូវអាស្រ័យ នូវគ្នានិងគ្នា ភាគផលរបស់ការងារ គឺបដិវេធសាសនានេះ ត្រូវអាស្រ័យ ភាគពិសោធន៍ គឺបដិបត្តិសាសនា ភាគបដិបត្តិត្រូវអាស្រ័យភាគទ្រឹស្តី គឺ បរិយត្តិសាសនា អ្នកសម្រេចកិច្ចដល់ជាន់បឋម មិនជាប់នៅត្រឹមបរិយត្តិ-សាសនា មិនជាប់នៅត្រឹមបដិបត្តិសាសនា តែព្យាយាមលុះដល់បដិវេធ-សាសនា ក៏បាន ឈ្មោះថាជា **បណ្ឌិត** ជា **អ្នកប្រាជ្ញ** ជា **កល្យាណជន** ជា **វិញ្ញជន** ដែលបានទទួលបរិញ្ញាបត្រហើយ ព្រោះមិនស្ទុះទៅកាន់ សេចក្តីអាក្រក់ទៀតឡើយ កាត់បានដាច់ខាតចេញហើយ រួចផុតភ័យ អន្តរាយផ្សេងៗ ខបមាដូចបុរសចែវទូកកាត់រលកខ្យល់ក្នុងទន្ទេ លុះដល់ ច្រាំង ឡើងអំពីច្រាំងបាន រមែងស្រាលកាយ ស្រាលចិត្ត និងសប្បាយ ចិត្តដូច្នោះ ។

អ្នកបានលុះដល់បដិវេធធម៌ហើយ មានសេចក្តីស្ងប់សុខដោយចំណែក

មួយ ដូចអ្នកឈប់អំពីការកិច្ចផ្សេងៗ ដែលត្រូវលីសែងវេលាថ្ងៃ មកអង្គុយហាលខ្យល់ត្រជាក់ក្នុងពេលរាត្រី ដែលមានពន្លឺព្រះចន្ទ បញ្ចេញរស្មីភ្លឺស្រឡះដូច្នោះ មានចិត្តរីករាយនៅដោយសេចក្តីស្ងប់ កាលគិតដល់រឿងអតីតជំជិតដែលពេញទៅដោយសេចក្តីលំបាកគោកយ៉ាក ពេញទៅដោយការតទល់ចំពោះភ័យ រាងកាយ និងចិត្ត (ធ្លាក់) ផ្ដុំកម្លាំងចុះក្នុងការងាររបស់ខ្លួន សុខចិត្តលីការៈផ្សេងៗអម្បាលនោះ ដោយសេចក្តីអត់ធន់ និងសេចក្តីព្យាយាមក្លាពិតៗ ទើបសម្រេចមកបាន ដោយសេចក្តីនឿយលំបាកស្ទើរនឹងយកជីវិតមិនរួច ក៏មកឥឡូវនេះ យើងបានផុតការៈនោះហើយ ការកិច្ចយ៉ាងនោះដែលយើងនឹងត្រូវធ្វើទៀត ជាកិរិយាមិនមាន យើងអស់ហើយ (ចាកទុក្ខទាំងពួង) យើងស្ងប់ហើយ (ចាកបាប-ធម៌ទាំងពួង) យើងសប្បាយ យើងជាសុខ យើងស្រាលចិត្តហើយ ឧបមានេះដូចម្តេច សូម្បីព្រះយោគាវចរត្រូវតទល់ភ័យ និងកិលេសយ៉ាងធ្ងន់ ដែលពេញទៅដោយមាយា និងសេចក្តីបោកបញ្ឆោតរបស់កិលេសច្រើនយ៉ាង ច្រើនប្រការ ការឈ្នះហើយ ក៏ស្រាលចិត្ត ជាសុខ រំពឹងថាយើងផុតហើយចាកអន្ទាក់របស់មារ ទុក្ខដែលជាភ័យធំរបស់សត្វទាំង-ឡាយ យើងបានផុតហើយ ទុក្ខទាំងឡាយដែលកើតចាកហេតុរបស់កិលេសក្នុងអនាគតមិនមានហើយ ស្ងប់សុខពិតហ្ន៎ ដូច្នោះដូចគ្នា ជាអ្នកមានសេចក្តីស្ងប់ស្ងៀមនៅក្នុងធម៌វិន័យជាប្រក្រតី ។

ភ័យធំដែលរាំងរាមិនឲ្យបានលុះបដិវេធធម៌

ព្រះយោគាវចរទាំងឡាយ កាលមកដំណើរផ្ទូវវិបស្សនា ដើម្បីជាបច្ចុ័យឲ្យបានលុះលោកុត្តរធម៌ហើយនោះ នឹងត្រូវជួបប្រទះការតស៊ូ ជួបប្រទះការកាត់ចិត្ត លះបលិពោធ ជួបប្រទះសេចក្តីស្ងាប់ ជួបប្រទះការពិចារណា ជួបប្រទះញាណ សេចក្តីដឹងច្បាស់ឃើញពិត ទម្ងាយអន្តរាយផ្សេងៗ ដែលបង្កើតឡើងនឹងចិត្ត នឹងត្រូវតស៊ូជាមួយកិលេសមារ នឹងត្រូវតស៊ូជាមួយនីវរណធម៌ ដែលជាបណ្តាញសំខាន់របស់មោហៈគឺ **អវិជ្ជា** ធ្វើឲ្យកើតការងងឹតងងល់អន្ធការ កាត់ផ្តាច់សតិជានិច្ច មិនព្រមឲ្យកំណត់ដឹងភ្ជាមនូវរូបនាមជាបច្ចុប្បន្នបានងាយៗឡើយ ទាំងតណ្ហាសេចក្តីចំណង់មានប្រការផ្សេងៗ លុះក្ងាយជាឧបាទានប្រកាន់មាំថារូបនាមជារបស់យើង ទៀង ជាសុខ ជាតួខ្ជួន ជាសត្ត ជាបុគ្គល ជាយើង ជាគេ លុះសាងកម្ម សាងភព មិនមានទីបំផុត កាលលើកវិបស្សនាប្រើសតិកំណត់ដឹងបច្ចុប្បន្នជានិច្ច មិនបណ្តោយវាដូចអំពីមុន កិលេសមារគឺនីវរណៈ កើតក្តៅក្រហាយបម្រះននៀលភ្ជាម គ្រាខ្ជះមោហៈជាមេទ័ពអកុសលក៏ឈ្នះចូលកាន់ទីពួន សង្កត់សង្កិនរូបនាមដែលជាសមរភូមិ (ស្នាមចម្បាំង) ខ្ទេចខ្ទីទៅកាលណា កាលនោះ សតិដែលជាមេទ័ពចំណែកកុសល យឹតយករូបនាម ដែលជាសមរភូមិបាន ក៏រាបទាបស្ងប់អវិជ្ជាដ៏ងងឹតអន្ធការក៏បាត់ទៅ សតិរាំងរាមោហៈតួវង្វេងជាសីល សតិ

កំណត់រូបនាមបច្ចុប្បន្ន លុះជំនាញមាំទាំជាសមាធិ កាលសមាធិកើត ឡើងហើយ ពន្ធឺភ្ធឺស្ងាងគឺបញ្ញាក៏កើតឡើង កាលបញ្ញាកើតឡើង សេចក្តីសម្គាល់ខុសថា រូបនាមជារបស់ទៀងក៏បាត់ទៅ សេចក្តីសម្គាល់ថា រូបនាមនេះជាសុខ ជារបស់ល្អ របស់ប្រសើរក៏បាត់ទៅ សេចក្តីសម្គាល់ ថា រូបនាមនេះជាខ្លួន ជាប្រាណក៏រមែងបាត់ទៅ សេចក្តីពិតដែលស្ថិត នៅឲ្យវិបស្សនាឃើញស្ថិតនៅឲ្យវិបស្សនាពិសោធនោះ គឺរូបនាមនេះ កើតរលត់ៗជា **អនិច្ចំ** តាំងនៅមិនបានពិតប្រាកដជា **ទុក្ខំ** ធន់ទ្រាំ នៅមិនបានពិតប្រាកដ រូបនាមនេះកើតហើយរលត់ឥតខ្ជឹមសារ ជា **អនត្តា** មិនមានអំណាចនឹងបង្គាប់បញ្ជាឲ្យគង់សភាពពិតប្រាកដនៅបាន ។

ភ័យដ៏ធំកន្ធង គឺនីវរណៈ បានបិទរាំងដោយច្រើន មិនឲ្យវិបស្សនា កើតឡើង ពោលគឺ ធ្វើឲ្យកើត **កាមច្ឆន្ទៈ** សេចក្តីស្រឡាញ់ប្រាថ្នា ចូលចិត្តក្នុងអារម្មណ៍ដែលគួរស្រឡាញ់ គួរប្រាថ្នា មានរាគៈតម្រេកក្ងា ដុតបំផ្ងាញរូបនាមឲ្យធេះវិនាសទៅ កាលហេតុបច្ច័យ ត្រូវកាត់ផ្តាច់ដោយ សតិ រាក៏រមែងបម្រះនន្ទៀលដូចសុនខឆ្ពួត ដែលពេញទៅដោយ សេចក្តីកាចសាហាវដូច្នោះ ។ ភ័យធំគឺសេចក្តី **ព្យាបាទ** មិនចូលចិត្ត មិនល្មម ចិត្តក្នុងរបស់ណាៗ ទាំងអស់ធ្វើចិត្តឲ្យគ្នាន់ខ្នាញ់ ក្រោធងាយ ដុត បំផ្ងាញរូបនាមឲ្យធេះជានិច្ច ដូចអាវុធដែលសៀត ឬដោតជាប់ដួងចិត្ត ឲ្យ ឈឺផ្សាសែនសហ័សដូច្នោះ ។ ភ័យធំគឺ **ថីនមិទ្ធៈ** សេចក្តីងោកងក់

ឧឡុយដេក ដែលមានមោហ:ជាសមុដ្ឋានកើតឡើង រមែងទម្លាយបំផ្លាញ សតិ មិនឲ្យរពុកដឹងទាន់រូបនាម ងឿងងេងងោងរឿយៗ ដូចលម្អងធូលី ហុយឡើងទៅ បិទបាំងមិនឲ្យមនុស្សសញ្ចារក្នុងផ្លូវដើរផ្លូវតទៅបាន ព្រោះ មិនឃើញផ្លូវដូច្នោះ ។ ភ័យធំគឺ **ឧទ្ធច្ច: កុក្កុច្ច:** សេចក្តីរាយមាយរំខាន ចិត្ត គិតពិចារណាទៅផ្សេងៗ ទាំងរឿងក្នុងអតីត ទាំងរឿងក្នុងអនាគត ប្រការផ្សេងៗ រីវក់គ្របសង្កត់ចិត្ត ឲ្យឃ្លាតឆ្ងាយចំពោះការកំណត់ដឹង បច្ចុប្បន្នធម៌ ដូចក្នុងវស្សន្តរដូវដុំពពកអំពីទិសានុទិស បិទបាំងពន្លឺព្រះអាទិត្យ ឲ្យងងឹតជ្រប់ ទាំងភ្ជ្រៀងផ្គរក៏លាន់រំពង ជាឧបសគ្គរបស់បុរសអ្នកត្រូវការ ដើរផ្លូវដូច្នោះ ។ ភ័យធំគឺ **វិចិកិច្ឆា** សេចក្តីសង្ស័យស្ទាក់ស្ទើរអល់អែក បិទរាំងមិនឲ្យវិបស្សនាញាណកើតឡើង ចម្រើនឡើងបាន មានសេចក្តី កង្ខានៅក្នុងចិត្តជានិច្ចថា រូបនាមជាយ៉ាងណាហ្នឹ? រូបពណ៌សណ្ឋាន យ៉ាងណា? សេចក្តីរលត់របស់រូប និងនាមនោះ ជាដូចម្តេច? ដូចបុរស ដើរផ្លូវទៅដល់ផ្លូវបែកជាពីរ ទាំងមិនដឹងថានឹងទៅផ្លូវណា ទើបនឹងត្រូវត្រង់ បានតែអង្គុយរំពឹងនៅថា "ផ្លូវណាហ្នឹៗ" អស់កាលជាយូរ ។

ភ័យនៃវិបស្សនានោះ មិនមែនតែត្រឹមដែលពោលនេះប៉ុណ្ណោះ ហេតុដែលមានសេចក្តីសង្ស័យនោះឯង ដោយប្រើសតិសម្ចឹងជ្រៅចុះទៅ លើសការសមគួរ មិនជាមជ្ឈិមាបដិបទាហើយសមាធិក៏កើតឡើង កាល សមាធិកើតឡើងហើយ ចិត្តក៏នឹងសាងនិមិត្តនានាឲ្យកើតឡើង សរុប

ហើយចែកបានជា ៥ ភាពគឺ **ភាពបញ្ជោត** ១ **ភាពល្ហ** ១ **ភាពលង** ១ **ភាពជិន្ត** ១ **ភាពបំផ្លាញ** ១ ។

១- និមិត្តដែលហៅថា **ភាពបញ្ជោត** នេះ លោកខ្ញុះ ហៅថា **កាយទិព្យ** គឺប្រាកដភាពមួយទៀត ដូចខ្លួនរបស់យើងនេះឯង គឺអ្នកបដិបត្តិនឹងធ្វើអ្វី វាក៏ធ្វើខ្ញុះ នឹងឈរ វាក៏ឈរខ្ញុះ កាលដើរ វាក៏ដើរខ្ញុះ កាលឈ្វាក សណ្ហក កង្ហុញ ក្រមើក-បម្រះ វាក៏ធ្វើដូច្នោះខ្ញុះ ដូចភាពនោះធ្វើត្រាប់យើង ទីខ្ញុះអ្នកបដិបត្តិនឹងប្រើឲ្យវាទៅធ្វើអ្វីទីណាក៏បានតាមសេចក្តីនឹកគិតក្នុងខណៈនោះ និមិត្តនេះនឹងបាត់ទៅបាន ដោយការកំណត់ដឹងរូបនាម ឲ្យដឹងទាន់បច្ចុប្បន្នធម៌ ដោយមិនយកចិត្តទុកដាក់ហើយ ក្នុងទីបំផុតក៏បាត់ទៅឯង ។

២- និមិត្តដែលហៅថា ***ភាពល្ហ*** នេះបានដល់និមិត្តដែលប្រាកដការណ៍ ដោយសេចក្តីប្រណីតរបស់ចិត្ត ទើបសាងនិមិត្តដែលល្អស្រស់ឲ្យវង្វេងជាប់ក្រឡេកមើលដោយសេចក្តីចូលចិត្តក្នុងនិមិត្តនោះ ដូចផ្កាឈើដែលមានពណ៌ល្អធើត ច្រើនឃើញព្រះចេតិយស្រោបដោយមាសខ្ញុះ រមណីយស្ថានជាទីរីករាយធ្វើចិត្តឲ្យសប្បាយខ្ញុះ ឃើញទេវតា និងគ្រឿងរបស់ទេវតាខ្ញុះ ឃើញវិមានរបស់ទេវតាខ្ញុះ សុទ្ធតែធ្វើសេចក្តីសុខឲ្យកើតឡើងយ៉ាងប្លែកអស្ចារ្យ ក្នុងខណៈនោះ ព្រះយោគាវចរអ្នកបដិបត្តិអង្គណា មកជាប់នៅនឹងនិមិត្តដូច្នេះហើយ វិបស្សនានឹងចម្រើនឡើងមិនបាន

ឡើយ កាលវិបស្សនាមិនបង្កើតឡើងហើយ ខ្លួនក៏នឹងត្រូវវង្វេងជាប់នៅនឹងនិមិត្តនោះ ឲ្យវិលវល់នៅក្នុងវដ្ដៈមិនមានទីបំផុត និមិត្តនេះនឹងបាត់ទៅដោយការកំណត់រូបនាម ឲ្យដឹងទាន់បច្ចុប្បន្នធម៌ ដោយមិនយកចិត្តទុកដាក់ហើយ ក្នុងទីបំផុតក៏នឹងបាត់ទៅឯង ។

៣- និមិត្តដែលហៅថា **ភាពលង** នោះ បានដល់និមិត្តដែលធ្វើឲ្យភ្ញាក់ខ្លាច ដូចនិមិត្តសត្វកាចផ្សេងៗ មាននិមិត្តជាពស់ទាំ (ចឹក) ជាសុនខមកទាំ ជាដំរីមកព្រេច ជាខ្លាឃ្មុំ ជាសាកសពជាដើម ដែលធ្វើឲ្យសុតរន្ធត់ខ្លាច ប្រាសចាកសតិ ធ្វើឲ្យវិបស្សនាឈប់គាំង និមិត្តនេះនឹងបាត់ទៅបានដោយការប្រើសតិបញ្ញាកំណត់រូបនាម ឲ្យដឹងទាន់ចំពោះបច្ចុប្បន្នធម៌ ដោយមិនយកចិត្តទុកដាក់ហើយ ក្នុងទីបំផុតភាពលងនេះក៏នឹងអន្តរធានសូន្យបាត់ទៅឯង ។

៤- និមិត្តដែលហៅថា **ភាពជ្ជ** នោះ នឹងហៅថា **បដិភាគ-និមិត្ត** ក៏បាន គឺនឹកដល់ដួងព្រះចន្ទ ក៏នឹងប្រាកដដួងព្រះចន្ទ នឹកឲ្យធំក៏បានតាមចិត្តនឹក នឹកឲ្យតូចក៏តូចតាមចិត្តនឹកជាដើម ឬនឹកដល់នរក ក៏ឃើញពួកនរក នឹកដល់សួគ៌វិមាន ក៏ឃើញសួគ៌វិមានតាមចិត្តនឹក នឹកដល់ពួកព្រហ្ម ក៏ឃើញពួកព្រហ្មតាមចិត្តនឹក នឹកដល់ព្រះអរហន្ត ក៏ឃើញព្រះអរហន្តតាមចិត្តនឹក នឹកដល់ព្រះពុទ្ធជាម្ចាស់ ក៏ឃើញព្រះពុទ្ធតាមចិត្តនឹក ឬនឹកដល់សែនកោដិចក្រវាឡ ក៏ឃើញទៅទាំងអស់ ដូច្នេះហៅថា

ភាពជន្ត ព្រោះកើតត្រឹមនិមិត្ត មិនមែនសភាវធម៌ និមិត្តនឹងបាត់ទៅ ដោយការកំណត់រូបនាម ឲ្យដឹងទាន់បច្ចុប្បន្នធម៌ ដោយមិននឹកដល់ភាព អម្បាលនោះ វាក៏នឹងសាបសូន្យបាត់ទៅឯង ។

៥- និមិត្តដែលហៅថា **ភាពបំផ្លាញ** នោះ កើតដោយហេតុ ខាងក្រៅដែលមកទម្លាយបំផ្លាញ ឲ្យវិបស្សនាញាណកើតឡើង ឬចម្រើន ឡើងមិនបាន ដូចពួកប្រេតមកសម្តែងខ្លួនដើម្បីសុំចំណែកបុណ្យ ឬពួក ទេវតាមិច្ចាទិដ្ឋិ មកសម្តែងជន្លេងដោយប្រការផ្សេងៗ មានធ្វើរាង កាយមុខមាត់ភ្នែក គួរស្អប់ខ្ពើមណាស់ គប្បីខ្លាចខ្លះ ធ្វើសំឡេងជាទី រន្ធត់ខ្លាចខ្លះ ។ ល ។ អម្បាលនេះជាដើម និមិត្តនេះនឹងបាត់ទៅដោយ ហេតុ ២ ប្រការ គឺផ្សាយមេត្តាឧទ្ទិសចំណែកកុសលឲ្យប្រការ ១ ដោយ ការចម្រើនវិបស្សនា សតិបញ្ញាកំណត់រូបនាមឲ្យឃើញច្បាស់ក្នុងបច្ចុប្បន្នធម៌ លុះកើតសមាធិមិនវង្វេងភ្ជាប់ភ្ជាំងប្រការ ១ ។ បើអ្នកបដិបត្តិមាន សេចក្តីខ្លាច ចិត្តមិនរឹងប៉ឹង ក៏មិនអាចបដិបត្តិវិបស្សនាតទៅបាន ។ បើ អ្នកបដិបត្តិមិនមានសេចក្តីខ្លាច មិនមានសេចក្តីស្ទុតរន្ធត់ មានសតិ មាន សមាធិមាំមួន មានបញ្ញាដឹងច្បាស់គ្រប់កាល ក៏នឹងអាចចម្រើនវិបស្សនា តទៅបានដោយស្រួល ព្រោះកាលចិត្តមិនទៅទទួលដឹងហើយ និមិត្ត អម្បាលនោះ ក៏នឹងវិនាសទៅឯង ។

កិលេសក្នុងវិបស្សនានៅមានច្រើនទៀត កាលណាព្រះយោគាវចរ

ចម្រើនវិបស្សនា ទាល់តែមានសីលបរិសុទ្ធ មានចិត្តបរិសុទ្ធ និងជិត ដល់ទិដ្ឋិដ៏បរិសុទ្ធ ផុតចាកសេចក្តីសង្ស័យ ចូលដល់សេចក្តីម៉ត់ចត់នៃ ញាណ សេចក្តីដឹងថាផ្ទូវ ឬមិនមែនផ្ទូវ នឹងបង្កើត **ឧភាសៈ** គឺពន្ធឺ ភ្ធឺស្វាងឡើងខ្ទះ បើមាន **ឩកន្ធិ** សេចក្តីពេញចិត្ត ចូលចិត្តក្នុងពន្ធឺនោះ វិបស្សនាក៏ចម្រើនឡើងមិនបាន ឬកើត **ញាណ** សេចក្តីដឹងចាស់ក្ខាឡើង បើមាន **ឩកន្ធិ** ពេញចិត្ត ឬចូលចិត្តក្នុងញាណនោះ វិបស្សនាក៏ចម្រើនឡើង មិនបាន ឬកើត **បីតិ** សេចក្តីធ្មែតចិត្តឡើង បើមាន **ឩកន្ធិ** សេចក្តី ពេញចិត្ត ឬចូលចិត្តក្នុងសេចក្តីធ្មែតចិត្តនោះ វិបស្សនាក៏ចម្រើនឡើងមិន បាន ឬកើត **បស្សទ្ធិ** សេចក្តីស្ងប់ឡើង បើមាន **ឩកន្ធិ** គឺពេញចិត្ត ឬ ចូលចិត្តក្នុងសេចក្តីស្ងប់នោះ វិបស្សនាក៏ចម្រើនឡើងមិនបាន ឬកើត **សុខ** គឺសេចក្តីសប្បាយចិត្តឡើង មាន **ឩកន្ធិ** ពេញចិត្ត ឬចូលចិត្តក្នុងសេចក្តី សប្បាយនោះ វិបស្សនាក៏ចម្រើនឡើងមិនបាន ឬកើត **អធិមោក្ខ** គឺសេចក្តីបង្អោនចិត្តជឿ បើមាន **ឩកន្ធិ** ពេញចិត្ត ឬចូលចិត្តក្នុងអធិមោក្ខ នោះ វិបស្សនាក៏ចម្រើនឡើងមិនបាន ឬកើត **បគ្គហៈ** សេចក្តីព្យាយាម មាន **ឩកន្ធិ** សេចក្តីពេញចិត្ត ឬចូលចិត្តក្នុងសេចក្តីព្យាយាមនោះ វិបស្សនា ក៏កើតឡើងមិនបាន ឬកើត **ឧបដ្ឋានៈ** គឺសតិតាំងឡើង មាន **ឩកន្ធិ** សេចក្តីពេញចិត្ត ឬចូលចិត្តក្នុងសតិដែលចាស់ក្ខានោះ វិបស្សនាក៏ចម្រើន ឡើងមិនបាន ឬកើត **ឧបេក្ខា** សេចក្តីដាក់ចិត្តជាកណ្តាលឡើង មាន

ឧិកឧ្ឌិ ពេញចិត្ត ឬចូលចិត្តក្នុងឧបេក្ខានោះ វិបស្សនាក៏ចម្រើនឡើងមិនបាន កាលនិកន្តិមិនកើត សហជាតិទាំង ៩ របស់វិបស្សនា ក៏មិនចាត់ជាកិលេស ព្រោះដូច្នោះ កាលសតិបញ្ញារពុកដឹងទាន់ហើយ វិបស្សនូ-បក្កិលេសអម្បាលនេះ ក៏នឹងបាត់ទៅ ព្រោះតណ្ហាសេចក្តីចូលទៅស្រឡាញ់មិនមានហើយ ។

បច្ច័យរបស់បដិវេធធម៌ គឺញាណលោកិយ

បដិវេធធម៌ ជាធម៌ចំណែកលោកុត្តរ: ផុតចាកលោក លោកិយ ដែលត្រូវញាំញីដោយកងទុក្ខមានប្រការផ្សេងៗនោះ ចាត់ជាផលរបស់ការបដិបត្តិធម៌ និងប្រាសចាកហេតុបច្ច័យចេញមិនបាន ហេតុបច្ច័យរបស់លោកុត្តរធម៌គឺ មគ្ត ផល និញ្ជាន នោះមិនមែនដទៃ បានដល់សេចក្តីដឹងដ៏ខ្ពស់បំផុតចំណែកលោកិយនោះឯង ដែលព្រះបរមសាស្តាទ្រង់ហៅថា "**វិបស្សនាញាណ**" វិបស្សនាញាណនេះ មានខែត្រដែនជាប់តនឹងលោកុត្តរ: ឃើញផ្ទូវទៅកាន់លោកុត្តរ: មាននៅនឹងបុគ្គលអ្នកប្រើសតិបញ្ញា ពិចារណារពុកដឹងទាន់បច្ចុប្បន្នរបស់រូបធម៌ នាមធម៌ លុះមានញាណកើតឡើងឃើញជាក់ច្បាស់ ដរាបដល់ទីបំផុតរបស់ញាណលោកិយ ក៏នឹងបញ្ជូនឲ្យញាណលោកុត្តរ:ភូាម រួមទាំងញាណលោកិយ និងញាណលោកុត្តរ: បាន ១៦ ញាណ ញែកគ្នាដូច្នេះ ៖

ក- ញាណលោកិយមាន ១៤ ញាណគឺ

១- នាមរូបបរិច្ឆេទញាណ

២- នាមរូបបច្ចយបរិគ្គហញាណ

៣- សម្មសនញាណ

៤- ឧទយព្វយញាណ

៥- ភង្គញាណ

៦- ភយតូបដ្ឋានញាណ

៧- អាទីនវញាណ

៨- និព្វិទាញាណ

៩- មុញ្ចិតុកម្យតាញាណ

១០- បដិសង្ខាញាណ

១១- សង្ខារុបេក្ខាញាណ

១២- អនុលោមញាណ

១៣- គោត្រភូញាណ

១៤- បច្ចវេក្ខណាញាណ

ខ- ញាណលោកុត្តរៈមាន ២ ញាណ គឺ

១- មគ្គញាណ

២- ផលញាណ

អ្នកបានលុះផលពិសេសពិសាលក្នុងចំណែកលោកុត្តរៈគឺ មគ្ត ផលនិញ្ចាននោះ បានដល់អ្នកបានលុះបដិវេធធម៌ ព្រះពុទ្ធអង្គទ្រង់ឲ្យនាមថា ព្រះអរិយបុគ្គល បុគ្គលអ្នកប្រសើរ ឆ្ងាយចាកសត្រូវ គឺកិលេសភាពជាបុថុជ្ជនបានអស់សូន្យទៅ ព្រមជាមួយនឹងមគ្គញាណកើតឡើងហេតុនោះ នឹងបានពោលដល់ចំណែកលោកិយបញ្ញាតទៅតាមលំដាប់នៃញាណដូច្នេះ ៖

១- **នាមរូបបរិច្ឆេទញាណ** ញាណដឹងនឹងរូបធម៌ នាមធម៌ ច្បាស់ក្នុងចិត្តថា ក្នុងលោកនេះ របស់ដែលមានពិត កើតពិតមាននៅស្ថិតនៅឲ្យពិសោធ មាននៅ ២ យ៉ាងគឺ រូបធម៌របស់ដែលស្ថិតនៅឲ្យដឹងនាមធម៌របស់ដែលចូលទៅដឹងប៉ុណ្ណោះ ដោយនៅត្រង់ទ្វារ គឺទ្វារទាំង ៦ ខណៈអារម្មណ៍ខាងក្រៅមកប៉ះ ។

ផ្លូវបក្ខុទ្វារ ទ្វារភ្នែក មានរូបារម្មណ៍ គឺពណ៌ ដែលអាស្រ័យពន្ធឺនិង **បក្ខុបសាទរូប** ប្រសាទភ្នែក ឬកែវភ្នែកក៏ហៅ ពីរនេះមកប៉ះគ្នា ហៅថា **រូបធម៌មួយ** កើតសេចក្តីដឹងឡើងប្រភេទមួយដែលចូលទៅឃើញពណ៌ គឺ **បក្ខុវិញ្ញាណ** សេចក្តីដឹងផ្លូវភ្នែកជា **នាមធម៌** ។

ផ្លូវសោតទ្វារ ទ្វារត្រចៀក មានសទ្ទារម្មណ៍ គឺសំឡេង ជារលករបស់បរមាណូក្នុងអាកាស និង **សោតបសាទរូប** ប្រសាទត្រចៀក ឬកែវត្រចៀកក៏ហៅ ពីរនេះមកប៉ះគ្នាជាគូ ហៅថា **រូបធម៌មួយ** កើតសេចក្តីដឹង

ឡើងប្រភេទមួយ ដែលចូលទៅបានញ្ញសំឡេងគឺ **សោតវិញ្ញាណ** សេចក្តីដឹងផ្លូវត្រចៀក ជា **នាមធម៌មួយ** ។

ផ្លូវឃានទ្វារ ទ្វារច្រមុះ មានគន្ធារម្មណ៍ គឺក្លិន ជាទឹកប្រេងរហើយដែលមាននៅទូទៅនិង **ឃានបសាទរូប** ប្រសាទច្រមុះជាគូគួរដល់គ្នាមកប៉ះគ្នា ហៅថា **រូបធម៌មួយ** កើតសេចក្តីដឹងឡើងប្រភេទមួយដែលចូលទៅដឹងក្លិន គឺ **ឃានវិញ្ញាណ** សេចក្តីដឹងផ្លូវច្រមុះជា **នាមធម៌មួយ** ។

ផ្លូវជិវ្ហាទ្វារ ទ្វារអណ្តាត មានរសារម្មណ៍ គឺរស ជាជ័រដែលមាននៅទូទៅនិង **ជិវ្ហាបសាទរូប** ប្រសាទអណ្តាត ជារបស់គូគ្នាមកប៉ះគ្នា ហៅថា **រូបធម៌មួយ** កើតសេចក្តីដឹងឡើងប្រភេទមួយ ដែលចូលទៅដឹងរសគឺ **ជិវ្ហាវិញ្ញាណ** សេចក្តីដឹងផ្លូវអណ្តាតជា **នាមធម៌មួយ** ។

ផ្លូវកាយទ្វារ ទ្វារកាយ មានផោដ្ឋព្វារម្មណ៍ គឺត្រជាក់ ក្តៅ ទន់ រឹង ជាដើមនិង **កាយបសាទរូប** ប្រសាទកាយ ជារបស់គូគ្នាមកប៉ះគ្នា ហៅថា **រូបធម៌មួយ** កើតសេចក្តីដឹងឡើងប្រភេទមួយ ដែលចូលទៅដឹង ត្រជាក់ ក្តៅ ទន់ រឹង គឺ **កាយវិញ្ញាណ** សេចក្តីដឹងផ្លូវកាយ ជា **នាមធម៌មួយ** ។

ផ្លូវមនោទ្វារ ទ្វារចិត្ត មានធម្មារម្មណ៍គឺ ឈរ ដើរ អង្គុយ ដេក បត់ លាត កម្រើក ជាដើមគឺ **ហទយវត្ថុ** គឺបេះដូង ហៅថា **រូបធម៌មួយ** សេចក្តីដឹងនឹកគិតដែលបង្ហាប់ឲ្យកាយឈរ ដើរ អង្គុយ ដេក បត់ លាត

ករម្រើកគឺ **មនោវិញ្ញាណ** *សេចក្ដីដឹងផ្លូវចិត្ដជា* **នាមធម៌មួយ** *។*

២- **នាមរូបបច្ចយបរិគ្គហញ្ញាណ** *ញ្ញាណសេចក្ដីដឹងបច្ច័យរបស់នាមរូប គឺដឹងថានាមនិងរូបនេះ ក៏ជាបច្ច័យដល់គ្នានិងគ្នាគឺ៖*

ផ្លូវភ្នែក រូបារម្មណ៍ គឺពណ៌ មកប៉ះនឹងបក្ខុបសាទរូប គឺកែវភ្នែក ជា **រូបធម៌** *ជាបច្ច័យឲ្យ* **បក្ខុវិញ្ញាណ** *គឺឃើញជា* **នាមធម៌** *ឡើង ។*

*ផ្លូវត្រចៀក សទ្ទារម្មណ៍ គឺសំឡេង មកប៉ះនឹង*សោតបសាទរូប *គឺកែវត្រចៀក ជា* **រូបធម៌** *ជាបច្ច័យឲ្យកើត* **សោតវិញ្ញាណ** *គឺបានឮជា* **នាមធម៌** *ឡើង ។*

*ផ្លូវច្រមុះ គន្ធារម្មណ៍ គឺក្លិន មកប៉ះនឹង*ឃានបសាទរូប *គឺប្រសាទច្រមុះ ជា* **រូបធម៌** *ជាបច្ច័យឲ្យកើត* **ឃានវិញ្ញាណ** *គឺដឹងក្លិន ជា* **នាមធម៌** *ឡើង ។*

*ផ្លូវអណ្ដាត រសារម្មណ៍ គឺរស មកប៉ះនឹង*ជិវ្ហាបសាទរូប *គឺបសាទអណ្ដាតជា* **រូបធម៌** *ជាបច្ច័យឲ្យកើត* **ជិវ្ហាវិញ្ញាណ** *គឺដឹងរស ជា* **នាមធម៌** *ឡើង ។*

ផ្លូវកាយ ផោដ្ឋព្វារម្មណ៍ គឺ ត្រជាក់ ក្ដៅ ទន់ រឹង មកប៉ះនឹង **កាយបសាទរូប** *គឺបសាទកាយជា* **រូបធម៌** *ជាបច្ច័យឲ្យកើត* **កាយវិញ្ញាណ** *គឺសេចក្ដីដឹងផ្លូវកាយជា* **នាមធម៌** *ឡើង ។*

ផ្លូវចិត្ដ **មនោវិញ្ញាណ** *គឺសេចក្ដីដឹងនឹកគិត (ប្រាជ្ញា) ជា* **នាមធម៌**

ជាបច្ច័យឲ្យកើត **កាយវិញ្ញត្តិរូប** **វចីវិញ្ញត្តិរូប** គឺឈរ ដើរ អង្គុយ ដេក បត់ លាត ក្រមើកជាដើម ជា **រូបធម៌** ឡើង ។

ទ្ធ១ដ១ដ១ត១ទៅ១ទ្ធ១ត១ថា រូបធម៌របស់ដែលស្ថិតនៅឲ្យដ១ដ១ កើតអំពីកម្ម ការធ្វើ ១ កើតអំពីចិត្តបង្ហាប់ ១ កើតអំពីរដូវ ដ១ មេឃ អាកាស ១ អាហារ គឺ១ជា ១ ចែកជាខាងក្ន១ និ១ខាងក្រៅដូច្នេះ ៖

ហេតុបច្ច័យរបស់រូបខាងក្ន១និ១រូបខាងក្រៅ ដូចតទៅនេះ ៖

រូបខាងក្ន១ ៦ គឺ ៖

១- **ចក្ខុបសាទរូប** ប្រសាទភ្នែក គឺកែវភ្នែក កើតអំពីកម្ម អាហារ ។

២- **សោតបសាទរូប** ប្រសាទត្រចៀក គឺកែវត្រចៀក កើតអំពីកម្ម អាហារ ។

៣- **ឃានបសាទរូប** ប្រសាទច្រមុះ កើតអំពីកម្ម អាហារ ។

៤- **ជិវ្ហាបសាទរូប** ប្រសាទអណ្តាត កើតអំពីកម្ម អាហារ ។

៥- **កាយបសាទរូប** ប្រសាទកាយ កើតអំពីកម្ម អាហារ ។

៦- **ហទយវត្ថុរូប** រូបបេះដូ១ កើតអំពីកម្ម អាហារ ។

រូបខាងក្រៅ ៦ គឺ

១- **រូបារម្មណ៍** គឺពណ៌ កើតអំពីចិត្ត រដូវ កម្ម អាហារ ។

២- **សទ្ទារម្មណ៍** គឺសំឡេ១ កើតអំពីចិត្ត រដូវ កម្ម អាហារ ។

៣- **គន្ធារម្មណ៍** គឺក្លិ១ កើតអំពីចិត្ត រដូវ កម្ម អាហារ ។

៤- **រសារម្មណ៍** *គឺរស កើតអំពីចិត្ត រដូវ កម្ម អាហារ ។*

៥- **ផោដ្ឋព្វារម្មណ៍** *គឺគ្រឿងខ្ទប់ កើតអំពីចិត្ត រដូវ កម្ម អាហារ ។*

៦- **ធម្មារម្មណ៍** *(ចំពោះសុខុមរូប) កើតអំពីកម្ម ចិត្ត រដូវ អាហារ ។*

ហើយដឹងតទៅទៀតថា នាមធម៌ កើតអំពីសម្ផស្ស ការប៉ះរបស់រូបធម៌ នាមធម៌គឺ ៖

១- **នាមផ្ទ្ធ្ធ្ធ្ធ្ធ** *គឺសេចក្ដីដឹងផ្ទ្ធ្ធ្ធ្ធ្ធ នឹងកើតឡើងបាន ត្រូវអាស្រ័យឧបត្ថម្ភហេតុ ហេតុឲ្យកើត ៤ យ៉ាង បានដល់ពណ៌ ១ ប្រសាទភ្នែក ១ ពន្ធ ១ ការយកចិត្តទុកដាក់ ១ មកប្រជុំផ្ទ្ធ្ធ:ប៉ះគ្នា ទើបកើតនាមផ្ទ្ធ្ធ្ធ្ធ្ធ្ធ្ធ ។*

២- **នាមផ្ទ្ធ្ធ្ធ** *គឺសេចក្ដីដឹងផ្ទ្ធ្ធ្ធ នឹងកើតឡើងបាន ត្រូវអាស្រ័យហេតុឲ្យកើត ៤ យ៉ាង បានដល់សំឡេង ១ ប្រសាទត្រចៀក ១ ប្រហោងត្រចៀក ១ ការយកចិត្តទុកដាក់ ១ មកប្រជុំផ្ទ្ធ្ធ: ប៉ះគ្នា ទើបកើតនាមផ្ទ្ធ្ធ្ធ្ធ្ធ ។*

៣- **នាមផ្ទ្ធ្ធ** *គឺសេចក្ដីដឹងផ្ទ្ធ្ធ នឹងកើតឡើងបាន ត្រូវអាស្រ័យហេតុឲ្យកើត ៤ យ៉ាង បានដល់ក្លិន ១ ប្រសាទច្រមុះ ១ ខ្យល់ ១ ការយកចិត្តទុកដាក់ ១ មកប្រជុំផ្ទ្ធ្ធ:ប៉ះគ្នាហើយ ទើបកើតនាមផ្ទ្ធ្ធ្ធ ។*

៤- **នាមផ្ទ្ធ្ធ** *គឺសេចក្ដីដឹងផ្ទ្ធ្ធ នឹងកើតឡើងបាន*

ត្រូវអាស្រ័យហេតុឲ្យកើត ៤ យ៉ាង បានដល់ប្រសាទអណ្តាត ១ រស ១ ទឹក ១ ការយកចិត្តទុកដាក់ ១ មកប្រជុំផស្សៈប៉ះគ្នាហើយទើបកើតនាមផ្លូវអណ្តាតឡើង ។

៥- **នាមផ្លូវកាយ** គឺសេចក្តីដឹងផ្លូវកាយ ទឹងកើតឡើងបាន ត្រូវអាស្រ័យហេតុឲ្យកើត ៤ យ៉ាង បានដល់ប្រសាទកាយ ១ គ្រឿងប៉ះ ១ ដី ១ ការយកចិត្តទុកដាក់ ១ មកប្រជុំផស្សៈប៉ះគ្នាហើយ ទើបកើតនាមផ្លូវកាយឡើង ។

៦- **នាមផ្លូវចិត្ត** គឺសេចក្តីដឹងផ្លូវចិត្ត ទឹងកើតឡើងបាន ត្រូវអាស្រ័យហេតុឲ្យកើត ៤ យ៉ាង បានដល់បេះដូង ១ ធម្មារម្មណ៍ ១ ភវង្គចិត្ត ១ ការយកចិត្តទុកដាក់ ១ មកប្រជុំផស្សៈប៉ះគ្នាហើយ ទើបកើតនាមផ្លូវចិត្តឡើង ។

ហើយដឹងតទៅទៀតថា នាមរូប កើតអំពីអាហារ ៤ គឺ កើតអំពី **កវលិង្ការាហារ** អាហារគឺដុំបាយ ១ កើតអំពី **ផស្សាហារ** អាហារគឺផស្សៈការប៉ះ ១ កើតអំពី **មនោសញ្ចេតនាហារ** អាហារគឺសេចក្តីតាំងចិត្ត ១ កើតអំពី **វិញ្ញាណាហារ** អាហារគឺវិញ្ញាណសេចក្តីដឹង ១ ។

អាហារ កើតអំពី **កម្ម** គឺធ្វើ ។

កម្ម កើតអំពី **ឧបាទាន** គឺសេចក្តីប្រកាន់មាំ ប្រកាន់ខ្ជាប់ ។

ឧបាទាន កើតអំពី **តណ្ហា** គឺសេចក្តីចង់បាន ។

តណ្ហា កើតអំពី **អវិជ្ជា** គឺសេចក្ដីមិនដឹង ។

ឬ **អវិជ្ជា** ជាបច្ច័យឲ្យកើត **តណ្ហា** ។

តណ្ហា ជាបច្ច័យឲ្យកើត **ឧបាទាន** ។

ឧបាទាន ជាបច្ច័យឲ្យកើត **កម្ម** ។

កម្ម ជាបច្ច័យឲ្យកើត **អាហារ** ។

អាហារ ជាបច្ច័យឲ្យកើត **នាមរូប** ។

នាមរូប ជាបច្ច័យឲ្យកើត **អវិជ្ជា** ។

ជាវដ្ដៈវិលវល់នៅយ៉ាងនេះ មិនមានទីបំផុត ជាហេតុ ជាបច្ច័យ ទូវគ្នានិងគ្នាជានិច្ច ។

៣- **សម្មសនញាណ** ញាណសេចក្ដីដឹងឃើញរូបនាមជា **អនិច្ចំ** មិនទៀង ឬជា **ទុក្ខំ** ធន់នៅមិនបាន ឬជា **អនត្តា** បង្គាប់បញ្ជាមិនបាន ព្រោះរូបនាមប្រជុំគ្នាកើតឡើងហើយរលត់ទៅជានិច្ច កាលយោគាវចរ អ្នកប្រកបសេចក្ដីព្យាយាមចម្រើនព្រះវិបស្សនាកម្មដ្ឋាន មានសតិផ្ដោតជាប់នៅនឹងរូប និងនាមទាន់ក្នុងបច្ចុប្បន្នហើយ **មោហៈ** ក៏កើតឡើងមិនបាន កាលមោហៈកើតឡើងមិនបាន **រាគៈ** **ទោសៈ** និង **អកុសលធម៌** ដទៃ ក៏កើតឡើងមិនបាន ព្រោះបានត្រូវប្រហារចេញហើយដោយសតិរហូតយប់និងថ្ងៃ ក្ងើងគឺ **រាគៈ** ក្ងើងគឺ **ទោសៈ** ក្ងើងគឺ **មោហៈ** ដែលនឹងដុតបំផ្លាញនៅជានិច្ច ហូរទៅរហូតកាល មិនមែនត្រឹមតែប៉ុណ្ណោះ នៅ

សន្សំ **រាគ:** គឺសេចក្ដីស្រឡាញ់ **ទោស:** គឺសេចក្ដីស្អប់ **មោហ:** គឺសេចក្ដីវង្វេងនេះ ចុះកាន់ភវង្គ ដេកត្រាំនៅក្នុងសន្ធាន ធ្លើចិត្តឲ្យសៅហ្មងកកវ ល្អក់នៅជានិច្ច កាលមានសតិហើយ ក៏ហូរចូលមកក្នុងភវង្គសន្ធានមិនបាន កាលសតិចម្រើនចាស់ក្លាច្រើនឡើង សេចក្ដីឃើញច្បាស់គឺ **ផ្ទ្រាំ**ង**ភ្នែក** ក៏កើតឡើង កាលនោះ **បញ្ញា**ក៏កើតឡើង **ញាណ** ក៏កើតឡើង **វិជ្ជា** ក៏កើតឡើង **ពន្លឺភ្លឺស្វាង** ក៏កើតឡើង កាលពន្ធឺភ្លឺស្វាងកើតឡើងហើយ ក៏ទ**ង**ឃើញការកើតរលត់របស់រូបនាមកើតក្នុងគតិមានលក្ខណៈ ៣ គឺ ជា **អនិច្ចំ** តាំងនៅមិនបានពិត ជា **ទុក្ខំ** ទ្រាំនៅមិនបានពិត ជា **អនត្តា** បង្ខាំបង្ខាមិនបានពិត សេចក្ដីពិតនេះនឹងប្រាកដដូច្នេះគឺ ៖

រូបនាមផ្ទ្រាវ**ចក្ខុ** គឺភ្នែក កាលរូបារម្មណ៍គឺពណ៌មកប៉ះនឹងចក្ខុបសាទ-រូបគឺប្រសាទភ្នែក រូបកើតឡើង ចក្ខុវិញ្ញាណ គឺឃើញពណ៌ នាមក៏កើតឡើង កាលសតិដ**ង**ទាន់ មោហ: គឺអវិជ្ជា សេចក្ដីមិនដ**ង**កើតឡើងមិនបាន រូបរលត់ទៅ កាលរូបរលត់ទៅហើយ នាមក៏រលត់ទៅផ**ង** ។

រូបនាមផ្ទ្រាវ**សោត:** គឺត្រចៀក កាលសទ្ទារម្មណ៍ គឺសំឡេ**ង**មកប៉ះនឹ**ង**សោតបសាទរូប គឺប្រសាទត្រចៀក រូបកើតឡើ**ង** សោតវិញ្ញាណ គឺ**ជ**ានឮ នាមក៏កើតឡើ**ង** កាលសតិដ**ង**ទាន់ មោហ:កើតឡើ**ង**មិនបាន រូបរលត់ទៅ កាលរូបរលត់ទៅហើយ នាមក៏រលត់ទៅផ**ង** ។

រូបនាមផ្ទ្ររាវ**ឃាន:** គឺច្រមុះ កាលគន្ធារម្មណ៍ គឺក្លិនមកប៉ះនឹ**ង**ឃាន-

បសាទរូប គឺប្រសាទច្រមុះ រូបកើតឡើង ឃានវិញ្ញាណ ដឹងក្លិន នាមក៏កើតឡើង កាលសតិដឹងទាន់ មោហៈកើតឡើងមិនបាន រូបរលត់ទៅ កាលរូបរលត់ទៅហើយ នាមក៏រលត់ទៅផង ។

រូបនាមផ្លូវជិវ្ហា *គឺអណ្ណាត កាលរសារម្មណ៍មកប៉ះនឹងជិវ្ហាបសាទរូប គឺប្រសាទអណ្ណាត រូបកើតឡើង ជិវ្ហាវិញ្ញាណ ដឹងរស នាមក៏កើតឡើង កាលសតិដឹងទាន់ មោហៈកើតឡើងមិនបាន រូបរលត់ទៅ កាលរូបរលត់ទៅហើយ នាមក៏រលត់ទៅផង ។*

រូបនាមផ្លូវកាយ *គឺកាយ កាលផោដ្ឋព្វារម្មណ៍គ្រឿងប៉ះត្រជាក់ ក្តៅ ទន់ រឹង ប៉ះកាយបសាទរូប គឺប្រសាទកាយ រូបកើតឡើង កាយ-វិញ្ញាណដឹងសម្ផស្ស នាមក៏កើតឡើង កាលសតិដឹងទាន់ មោហៈកើតឡើងមិនបាន រូបរលត់ទៅ កាលរូបរលត់ទៅហើយ នាមក៏រលត់ទៅផង ។*

រូបនាមផ្លូវមនោ *គឺចិត្ត កាលធម្មារម្មណ៍ប៉ះហទយវត្ថុ រូបកើតឡើង មនោវិញ្ញាណ ដឹងផ្លូវចិត្ត នាមក៏កើតឡើង កាលសតិដឹងទាន់ មោហៈកើតឡើងមិនបាន រូបរលត់ទៅ កាលរូបរលត់ទៅហើយ នាមក៏រលត់ទៅផង ។*

រូបនាមមានសេចក្តីកើតឡើងហើយរលត់ទៅព្រមគ្នាយ៉ាងនេះ វិបស្សនាញ្ញាណក៏ដឹងឃើញច្បាស់ក្នុងរូបនាមថា មានសភាពតាំងនៅមិន

បានពិតៗ ធន់ទ្រាំនៅមិនបានពិតៗ បង្ក្រាប់បញ្ជាមិនបានពិតៗ កើតនៅយ៉ាងនេះ មានលក្ខណៈជា **អនិច្ចំ ទុក្ខំ អនត្តា** ៣ យ៉ាងនេះប៉ុណ្ណោះ មានគតិយ៉ាងនេះ តាំងនៅយ៉ាងនេះ ។

កាលវិបស្សនាញាណបានបង្កើតឡើងហើយ ក៏រមែងដឹងតទៅទៀតថាសូម្បីក្នុងអតីតដ៏សែនឆ្ងាយ គឺក្នុងជាតិមុនខ្លះ ដែលត្រាច់នៅក្នុងវដ្ដៈ (វិលវល់) នៃការកើតរលត់យ៉ាងនេះ អស់អនេកជាតិ អនន្ដជាតិ ក៏ព្រោះមិនដឹងសេចក្ដីពិតថា រូបនាមនេះ មានសភាព **អនិច្ចំ** តាំងនៅមិនបាន មានសភាព **ទុក្ខំ** ទ្រាំនៅមិនបាន មានសភាព **អនត្តា** បង្ក្រាប់បញ្ជាមិនបាន សូម្បីក្នុងអតីតដ៏ជិត តាំងអំពីបដិសន្ធិក្នុងគភ៌មាតា ក៏ជាយ៉ាងនេះ ប្រសូតចេញមកចាកគភ៌មាតាហើយ ក៏យ៉ាងនេះ ធំឡើងមកជាក្មេងតូចៗ លុះរូបក្មេងតូចៗនោះបាត់ទៅ ក្លាយជាក្មេងធំ ក៏ជាយ៉ាងនេះ ចម្រើនធំឡើងជាកំលោះ ក្រមុំក៏មានរូបនាមកើតរលត់នៅយ៉ាងនេះ មានគតិជា **អនិច្ចំ ទុក្ខំ អនត្តា** ឆ្នាំដែលកន្ទងមកហើយ ក៏រស់នៅយ៉ាងនេះ ខែដែលកន្ទងមកហើយ ក៏រស់នៅយ៉ាងនេះ ថ្ងៃដែលកន្ទងមកហើយ ក៏រស់នៅយ៉ាងនេះ ម៉ោងដែលកន្ទងមកហើយក៏រស់នៅយ៉ាងនេះ នាទីដែលកន្ទងមកហើយ ក៏រស់នៅយ៉ាងនេះ វិនាទីដែលកន្ទងមកហើយ ក៏រស់នៅយ៉ាងនេះ ។

សូម្បីក្នុងអនាគតដ៏ជិត វិនាទីតទៅ ក៏មានរូបនាមកើតរលត់ៗ

នៅយ៉ាងនេះ មានលក្ខណៈយ៉ាងនេះ ក្នុងនាទីតទៅ ក៏រស់នៅយ៉ាងនេះ ក្នុងថ្ងៃតទៅ ក៏រស់នៅយ៉ាងនេះ ក្នុងខែតទៅ ក៏រស់នៅយ៉ាងនេះ ក្នុងឆ្នាំតទៅ ក៏រស់នៅយ៉ាងនេះ ក្នុងវ័យនៃសេចក្ដីជរា ដែលមានរាងកាយទ្រុឌទ្រោម ក៏រស់នៅយ៉ាងនេះ មានរូបនាមកើតរលត់ៗ ជាលក្ខណៈមិនទៀង ជាទុក្ខ ជាអនត្តា គ្រាន់តែជារូបធម៌ នាមធម៌ កើតឡើងហើយរលត់ទៅ តាមហេតុ តាមបច្ច័យយ៉ាងនេះ មិនមែនសត្ត្ব មិនមែនបុគ្គល មិនមែនខ្លួន-ប្រាណ មិនមែនយើងមិនមែនគេ, សូម្បីក្នុងអនាគតដែលសែនឆ្ងាយជាតិមុខនោះ នឹងត្រាច់រង្គាត់ទៅក្នុងសង្សារវដ្ដទៀតអស់កាលយូរ ក៏នឹងរស់នៅយ៉ាងនេះ ផុតចាកភាពជាយ៉ាងនេះទៅមិនបាន ព្រោះនៅមិនអស់កិលេសហេតុឲ្យកើត កាលអស់កិលេសគឺសេចក្ដីវង្វេង បានដល់មោហៈ សេចក្ដីចង់បាន បានដល់លោភៈ សេចក្ដីក្រោធ បានដល់ទោសៈ ជាសមុច្ឆេទកាលណា ទើបមិនបាច់កើតជាតិមុខទៀតតទៅកាលនោះ ។

ដ៏ងតទៅទៀតថា បុរសគ្រប់គ្នា ក៏មានរូបនាមកើតរលត់នៅយ៉ាងនេះ ស្ត្រីគ្រប់គ្នា ក៏មានរូបនាមកើតរលត់នៅយ៉ាងនេះ សត្ត្ববកប្រេត អសុរកាយក៏មានរូបនាមកើតរលត់នៅយ៉ាងនេះ សូម្បីសត្ត្ববិរច្ឆាន ក៏មានរូបនាមកើតរលត់នៅយ៉ាងនេះ ជាលក្ខណៈ ៣ មិនទៀងធន់មិនបាន មិនមានអំណាចនឹងបង្ការ៉ាប់ការ៉ាងបានដូច្នេះ សូម្បីក្នុងទេវលោក

ពួកទេព្តាទាំងឡាយ អ្នកសោយទិព្វសម្បត្តិនៅអស់កាលយូរ ក៏ព្រោះមិនដឹង មិនឃើញ រូបនាមដែលកើតរលត់យ៉ាងនេះ សូម្បីក្នុងព្រហ្មលោកសោយឧបេក្ខាវេទនា នៅក្នុងដែនដីរបស់រូបលោក និងអរូបលោកអស់កាលជាយូរអង្វែង ព្រោះមិនដឹង មិនឃើញរូបនាមយ៉ាងនេះ ។

កាលបានមកពិចារណាដោយវិបស្សនាញាណ ឃើញរូបនាមតាមសេចក្តីពិតយ៉ាងនេះ គឺកើតរលត់ សភាពដែលពិតនោះគឺ **អនិច្ចំ** តាំងនៅមិនបាន កាលវិបស្សនាឃើញថា ជា **អនិច្ចំ** តាំងនៅមិនបាន មិនទៀងដូច្នេះ សេចក្តីសម្គាល់ថា ជា **និច្ចំ** ទៀងក៏វិនាសទៅ ត្រឡប់មានសេចក្តីឃើញត្រង់តាមសេចក្តីពិតថា រូបនាមនេះមានសភាពជា **ទុក្ខំ** ទ្រាំនៅមិនបាន កាលឃើញថារូបនាមនេះជាទុក្ខពិតហើយ ក៏រមែងឃើញថា រូបនាមនេះ មានសភាពជា **អនត្តា** មិនអាចនឹងបង្គាប់បញ្ជាបានពិត ព្រោះមិនមែន **អត្តា** ខ្លួនប្រាណរបស់អ្នកណា កាលឃើញថាមិនមែនតួខ្លួន **ទិដ្ឋិ** ដែលមានសេចក្តីឃើញខុសថាជាខ្លួនប្រាណ ក៏វិនាសទៅ កាលទិដ្ឋិវិបល្លាសអស់ទៅ **ឧបាទាន** សេចក្តីប្រកាន់មាំដោយកាន់ថាជាយើង ជាគេ ក៏វិនាសទៅ កាលឧបាទានវិនាសទៅហើយ **តណ្ហា** សេចក្តីចំណង់ដោយប្រការផ្សេងៗ ដើម្បីនឹងបានមកនូវរូបនិងនាមនោះ ក៏វិនាសអស់ទៅ កាលតណ្ហាអស់ទៅ ជាត់ទៅ ស្រាលស្តើងទៅហើយ **អវិជ្ជា** គឺសេចក្តីងងឹតអន្ធការនឹងមានមកអំពីណា កាលអវិជ្ជាអស់ហើយ

ក៏សល់តែ **វិជ្ជា** ដែលជាតួវិបស្សនា ឃើញរូបនិងនាមជាក់ច្បាស់ ឧបមាដូចបុរសគោងក្ដុំឡើងទៅកាន់កំពូលបពិត ហើយក្រឡេកមើលឃើញ សព្វរបស់ (វត្ថុ) ទាំងឡាយ ទាំងជិត និងឆ្ងាយបានដូច្នោះ ។

៤- **ឧទយព្វយញាណ** ញាណឃើញរូបនាមទាំងកើត ទាំងរលត់ព្រមៗគ្នាទៅនឹងវិបស្សនា អ្នកដឹងក៏រលត់ទៅផង ជាបច្ចុប្បន្នសុទ្ធ មិនលាយអតីត អនាគត រូបនាមច្បាស់ប្រាកដលើសឡើង ច្បាស់ក្នុងត្រៃ-លក្ខណៈបរិសុទ្ធម៉ត់ចត់ ចាកឧបក្លិសេសផ្សេងៗ ដឹងតែសភាវៈបរមត្ថ ច្បាស់ មិនមានសន្ដតិជាប់តជ្រុលទៅដល់បញ្ញត្ដិ ទម្ងាយសេចក្ដីឃើញ ថាជា **សុខ** ទម្ងាយសេចក្ដីឃើញថាជា **សុភៈ** របស់ល្អស្រស់ ទម្ងាយ សេចក្ដីឃើញថាជា **ធុំ** ដែលសម្គាល់ចាំមក ដែលហៅថាឃនសញ្ញាចេញ ដោយការពិចារណារូប និងនាម កើតៗ រលត់ៗ ជា **អនិច្ចំ** មិនទៀង ជា **ទុក្ខំ** ទ្រាំនៅមិនបាន ជា **អនត្ដា** បង្ខាប់បញ្ជាមិនបានដូច្នេះ ជាក់ច្បាស់លើសឡើង លុះកើតសមាធិមាំមិនវង្វេង នឹងកើតញាណបញ្ញាដ៏លើស ឃើញអ្នកដឹងគឺតួវិបស្សនានេះរលត់ទៅៗ ព្រមនឹងរូបនាម ដែលជាអារម្មណ៍ ដូចនឹងសម្ដែងតទៅនេះគឺ ៖

កាល **បក្ខុវិញ្ញាណ** ឃើញប្រាកដឡើង គឺរូបនាមផ្ទូរភ្នែកកើតឡើង វិបស្សនាអ្នកដឹងក៏កើតឡើង កាលឃើញបាត់ទៅ គឺរូបនាមរលត់ទៅ វិបស្សនាអ្នកដឹងក៏រលត់ទៅព្រមគ្នា ។

កាល **សោតវិញ្ញាណ** *បានឮប្រាកដឡើង គឺរូបនាមផ្លូវត្រចៀកកើតឡើង វិបស្សនាអ្នកដឹងក៏កើតឡើង កាលបានឮបាត់ទៅ គឺរូបនាមរលត់ទៅ វិបស្សនាអ្នកដឹងក៏រលត់ទៅព្រមគ្នា ។*

កាល **ឃានវិញ្ញាណ** *ដឹងក្លិនប្រាកដឡើង គឺរូបនាមផ្លូវច្រមុះកើតឡើង វិបស្សនាអ្នកដឹងក៏កើតឡើង កាលដឹងក្លិនបាត់ទៅ គឺរូបនាមរលត់ទៅ វិបស្សនាអ្នកដឹងក៏រលត់ទៅព្រមគ្នា ។*

កាល **ជិវ្ហាវិញ្ញាណ** *ដឹងរសប្រាកដឡើង គឺរូបនាមផ្លូវអណ្តាតកើតឡើង វិបស្សនាអ្នកដឹងក៏កើតឡើង កាលដឹងរសបាត់ទៅ គឺរូបនាមរលត់ទៅ វិបស្សនាអ្នកដឹងក៏រលត់ទៅព្រមគ្នា ។*

កាល **កាយវិញ្ញាណ** *ដឹងសម្ផស្ស ត្រជាក់ ក្តៅ ទន់ រឹង គឺរូបនាមផ្លូវកាយកើតឡើង វិបស្សនាអ្នកដឹងក៏កើតឡើង កាលដឹងសម្ផស្សបាត់ទៅ គឺរូបនាមរលត់ទៅ វិបស្សនាអ្នកដឹងក៏រលត់ទៅព្រមគ្នា ។*

កាល **មនោវិញ្ញាណ** *ដឹងនឹកគិតប្រាកដឡើង គឺរូបនាមផ្លូវចិត្តកើតឡើង វិបស្សនាអ្នកដឹងក៏កើតឡើង កាលដឹងនឹកគិតបាត់ទៅ វិបស្សនាអ្នកដឹងក៏រលត់ទៅព្រម ឬកាលចិត្តបង្ហាប់ឲ្យឈរ ដើរ អង្គុយ ដេក បត់លាត កម្រើកញ័រឡើង រូបនាមកើតឡើង វិបស្សនាអ្នកដឹងក៏កើតឡើង កាលចិត្តឈប់បង្ហាប់ឲ្យឈរ ដើរ អង្គុយ ដេក បត់ លាត កម្រើកញ័រ បាត់ទៅ រូបនាមរលត់ទៅ វិបស្សនាអ្នកដឹងរលត់ទៅព្រមគ្នា ។*

កាលបានឃើញប្រាកដច្បាស់ដូចសម្តែង ទាំងរូបនាមរបស់ដែលតាំងនៅឲ្យដឹង ទាំងវិបស្សនាអ្នកដឹងកើតឡើងហើយ រលត់ទៅក៏ព្រមគ្នា ដែលហៅថា **ឧទយពូយញាណ** *ជាញាណដែលឈានឡើងកាន់* **ពលវវិបស្សនា** *ពិត បើនៅមិនដល់ផ្នែកនេះ ចាត់ជា* **តរុណវិបស្សនា** *គឺសតិនៅឱនថយ (ទន់ខ្ចី) មិនជាកម្ចាំងដែលនឹងឲ្យចម្រើនលើសឡើងបាន ឧបមាដូចឃើញមនុស្សដើរកំបាំងបាត់ទៅម្តងម្នាក់ៗ តមកឃើញមនុស្ស ២ នាក់ ក្រៀកកគ្នាដើរកំបាំងបាត់ទៅៗ ដូច្នោះ* **វិបស្សនាញាណ** *ទើបប្រហារ* **និច្ចសញ្ញា** *សម្គាល់ថាទៀង* **សុខសញ្ញា** *សម្គាល់ថាសុខ* **អត្តសញ្ញា** *សម្គាល់ថាខ្លួន ថាប្រាណចេញបាន ព្រោះបានច្បាស់នៅក្នុង* **អនិច្ចំ ទុក្ខំ អនត្តា** *សូម្បីនឹងមានជីវិតនៅត្រឹមមួយថ្ងៃ ក៏រមែងប្រសើរជាងអ្នកមិនដឹងច្បាស់ដែលមានអាយុយឺនយូររាប់រយឆ្នាំពិត ។*

៥- **ភង្គញាណ** *ណាណឃើញរូបនាមមានតែរលត់ទៅៗ ល្អិតឡើងញាប់ឡើង ជាងអំពីកាលមុន តអំពីដែលបានមានវិបស្សនា ឃើញសេចក្តីកើតឡើងនិងរលត់ទៅព្រមនឹងរូបនាមដូច្នោះ ឧបមាដូចមនុស្ស ២ នាក់ដើរក្រៀកកគ្នា កំបាំងបាត់ទៅដូច្នោះ* **ពលំ** *គឺសទ្ធាជឿមាំក្នុងធម្មរតន: មិនប្រែប្រួល រូបនាមកើតរលត់នៅយ៉ាងនេះពិតប្រាកដ* **ពលំ** *គឺវីរិយ: សេចក្តីព្យាយាមក្ងៀវក្ងា* **ពលំ** *គឺសតិ រពុកដឹងទាន់រូបនាម មិនវង្វេង* **ពលំ** *គឺសមាធិ មានសេចក្តីតាំងមាំក្នុងរូបនាម* **ពលំ** *គឺបញ្ញា ដឹងរូបនាម*

ឃើញកើតរលត់ច្បាស់លាស់ មានលក្ខណៈជា **អនិច្ចំ** តាំងនៅមិនបាន មានលក្ខណៈជា **ទុក្ខំ** ទ្រាំនៅមិនបាន មានលក្ខណៈជា **អនត្តា** បង្ខាំប់ បញ្ជាមិនបាន ពិតដូច្នេះហើយ ក៏កើតវិបស្សនាញាណ កើតជាកម្លាំង ឃើញរូបនាមរលត់ទៅៗ ជានិច្ចគឺ ៖

រូបនាមផ្លូវភ្នែក ក៏ឃើញរលត់ទៅៗជា **អនិច្ចំ ទុក្ខំ អនត្តា** ។

រូបនាមផ្លូវត្រចៀក ក៏ឃើញរលត់ទៅៗជា **អនិច្ចំ ទុក្ខំ អនត្តា** ។

រូបនាមផ្លូវច្រមុះ ក៏ឃើញរលត់ទៅៗជា **អនិច្ចំ ទុក្ខំ អនត្តា** ។

រូបនាមផ្លូវអណ្តាត ក៏ឃើញរលត់ទៅៗជា **អនិច្ចំ ទុក្ខំ អនត្តា** ។

រូបនាមផ្លូវកាយ ក៏ឃើញរលត់ទៅៗជា **អនិច្ចំ ទុក្ខំ អនត្តា** ។

រូបនាមផ្លូវចិត្ត ក៏ឃើញរលត់ទៅៗជា **អនិច្ចំ ទុក្ខំ អនត្តា** ។

ឧបមាដូចបុរសអ្នកឈរនៅក្នុងច្រក ក្រឡេកទៅកាន់ថ្នល់ធំគ្រាដំបូង ឃើញយានជំនិះរត់កាត់មាត់ច្រកធ្លោ ហើយបាត់ទៅ យូរទៅៗ ក៏ឃើញ តែបាត់ទៅៗដូច្នោះ អ្នកបដិបត្តិវិបស្សនា លុះឃើញរូបនាមរលត់ទៅៗ តែម្យ៉ាងដូច្នេះ ឈ្មោះថាចូលដល់ **ភង្គានុបស្សនា** ។

សតិរបស់អ្នកប្រកបសេចក្តីព្យាយាមក្នុងភង្គញាណនេះ រមែងស្ងប់ចុះនៅនឹង **១យ:** *សេចក្តីសាបសូន្យរបស់រូបនាម គឺរលត់ទៅៗ* **២យ:** *សេចក្តីបាត់ទៅរបស់រូបនាម គឺរលត់ទៅៗ* **ភេទ:** *សេចក្តីបែកធ្លាយ របស់រូបនាម គឺរលត់ទៅៗ* **និរោធ:** *សេចក្តីរលត់របស់រូបនាមរឿយៗ*

អារម្មណ៍ គឺរូបនាមក៏រលត់ផង និងវិបស្សនាអ្នកចាប់យករូបនាមជាអារម្មណ៍ ក៏រលត់ទៅព្រម ជាធម្មជាតិដែលរលត់នៅរឿយៗ អ្នកឃើញតែសេចក្តីរលត់នៅដូច្នេះ ដូចការរលត់របស់កករទឹក ឬពន្ធឺភ្ជឹបភ្ជែតដូច្នោះ មានកិលេសាសវៈទាំងឡាយ ក្នុងភវង្គសន្តានតិចឬស្តើងទៅ ព្រោះមកដឹងច្បាស់ក្នុងបច្ចុប្បន្នធម៌ ដែលរលត់ទៅៗ ឆ្ងាយចាកអតីត និងអនាគត មានសេចក្តីវិនាសទៅជាលក្ខណៈ ឧបមាដូចទឹកសន្សើមដែលវិនាសទៅ ព្រោះត្រូវកម្តៅព្រះអាទិត្យ ។

កាលពិចារណាឃើញរូបនាមរលត់ៗ ជា **អនិច្ចំ** តាំងនៅមិនបានពិត ជា **ទុក្ខំ** ទ្រាំនៅមិនបានពិត ជា **អនត្តា** បង្គាប់បញ្ជាមិនបានពិត ក៏នឹងដក **ទិដ្ឋិវិបល្លាស** សេចក្តីឃើញខុស ជារបស់ទៀង ជាសុខ ជាអត្តាខ្ជូនប្រាណ ដក **បិត្តវិបល្លាស** សេចក្តីដឹងខុសថាទៀង ថាជាសុខ ថាជាខ្ជូនប្រាណ ដក **សញ្ញាវិបល្លាស** សេចក្តីសម្គាល់ចាំខុសថា ជារបស់ទៀង ជាសុខ ជាខ្ជូនប្រាណចេញបាន លះមោហៈ តួវង្វេងនៅគ្រប់ខណៈ កាលលះតួវង្វេងហើយឈ្មោះថា លះតួចង់បាន លះតួក្រោធ និងអកុសលធម៌ពួកដទៃផង ចិត្តបង្អោនទៅដើម្បីសេចក្តីអស់ទុក្ខដោយចំណែកមួយ ឃើញរលត់ទាំងខណៈដើម ខណៈកណ្តាល និងខណៈចុង តាំងនៅក្នុង **អនិច្ចានុបស្សនា** ឃើញរូបនាមរលត់ទៅៗ មិនទៀងជានិច្ច ឬ **ទុក្ខានុបស្សនា** ឃើញរូបនាមរលត់ទៅៗ ជាទុក្ខជានិច្ច ឬ **អនត្តានុបស្សនា**

ឃើញរូបនាមរលត់ទៅៗ ជាអនត្តាជានិច្ច ឬ **ឥ**ត្ថិ**ទ**ាតុបស្សនា ឃើញ
រូបនាមរលត់ទៅៗ គួរនឿយណាយជានិច្ច ឬ **វ**ិរាគានុបស្សនា ឃើញ
រូបនាមរលត់ទៅៗ ប្រាសចាកសេចក្តីចូលចិត្តជានិច្ច ឬ **និ**រោធានុបស្សនា
ឃើញរូបនាមរលត់ទៅៗ បង្អោនទៅដើម្បីសេចក្តីរលត់មិនកើតជានិច្ច ឬ
បដិ**និ**ស្សគ្គានុបស្សនា ឃើញរូបនាមរលត់ទៅៗ ឃើញទោសនិងបង្អោន
ចិត្តទៅកាន់សេចក្តីរលត់មិនកើតទៀត បញ្ជូនចិត្តទៅកាន់សេចក្តីរលត់ទុក្ខ
ជានិច្ច ឃើញរូបធម៌ នាមធម៌ ជារបស់សាបសូន្យជារបស់បាត់ទៅ ជារបស់
ទម្លាយទៅ ជារបស់ដែលរលត់នៅជានិច្ចដូច្នេះ ប្រៀបដូចបុរសឈរ
នៅមាត់ច្រាំងស្ទឹងក្នុងខណៈភ្លៀងធ្លាក់ កាលគ្រាប់ភ្លៀងធ្លាក់ចុះមកត្រូវ
ផ្ទៃទឹកក្នុងស្ទឹង ពពុះទឹកក៏បង្កើតឡើងជាប៉ោងៗ ជាគ្រាប់ធំៗ ចេញទៅៗ
ក៏នឹងបែកធ្លាយមួយរំពេច អន្តរធានសូន្យអស់ទៅដូចម្តេច អ្នក
បដិបត្តិវិបស្សនា ដល់ភូមិនៃកង្គ្ចញ្ញាណ ឃើញអាការរលត់ទៅៗ នៃ
រូបនាមមានឧបមេយ្យដូច្នោះ នឹងរមែងបានទទួលកម្លាំងអានិសង្ស ៨ ប្រការ
ដូចតទៅនេះ ៖

១- នឹងប្រហារសស្សតទិដ្ឋិ សេចក្តីឃើញថាទៀងបាន ។

២- នឹងលះសេចក្តីស្រឡាញ់ជីវិតចេញបាន ។

៣- នឹងអាចប្រកបសេចក្តីព្យាយាមបដិបត្តិវិបស្សនាលើសឡើងទៅ ។

៤- នឹងចិញ្ចឹមជីវិតដោយបរិសុទ្ធិប្រាសចាកទោស ។

៥- នឹងលះបង់បាននូវសេចក្ដីហួងហែង ក្នុងការស្វែងរកគ្រឿងឧបភោគបរិភោគមកប្រើប្រាស់ លះការស្វែងរកបរិក្ខារផ្សេងៗ មានសេចក្ដីប្រាថ្នាតិចសន្ដោសនៅប្រចាំ ។

៦- អស់សេចក្ដីស្ងុតខ្ចាចចំពោះកយន្ដរាយផ្សេងៗ ។

៧- មានខន្ដីសេចក្ដីអត់ធន់ និងទន់ភ្ងន់ ។

៨- នឹងអត់ធន់បាននូវសេចក្ដីអផ្សុក និងបង្ក្រាបសេចក្ដីត្រេកអរ ក្នុងកាម-គុណ ជ្រះថ្លាក្នុងកុសលធម៌ បើជាឃរាវាសក៏នឹងត្រេកអរក្នុងទីស្ងាត់ ដើម្បីនឹងបានបដិបត្ដិវិបស្សនា បើជាបព្វជិត ក៏នឹងត្រេកអរតែក្នុងអរញ្ញវាសី វត្ដព្រៃ ដែលស្ងប់ចាកកាមគុណ ។

៦- **ភយតូបដ្ឋានញាណ** ញាណឃើញរូបនាមរលត់ទៅជាភ័យ គួរខ្ចាចកាលបានចម្រើនវិបស្សនា ឃើញរូបនាមរលត់ទៅៗ ជាក់ច្បាស់ ដោយមិនវង្វង ។ មានសេចក្ដីព្យាយាម មានបញ្ញាឃើញ **អនិច្ចំ ទុក្ខំ អនត្ដា** ប្រាកដជាប់នៅនឹងរូប មានរូបនិងនាមជាអ្នកវ៉ាប់រង **អនិច្ចំ ទុក្ខំ អនត្ដា** ទុកដូច្នេះ កាលណា កាលនោះ រមែងឃើញរូបនាមរលត់ទៅៗ នោះជាភ័យដ៏ធំ គួរខ្ចាច ជា **អនិច្ចំ** របស់ដែលមិនទៀង មានលក្ខណៈតាំងនៅមិនបាន ព្រោះកើតឡើងហើយសូន្យអស់ទៅ ប្រែប្រួលនៅជានិច្ច ប្រព្រឹត្ដទៅមួយដង មួយយាម ហើយក៏រលត់ជាត់ទៅ ប្រដែងនឹង **ទុក្ខំ** សេចក្ដីទៀង មានសេចក្ដីមិនទៀងជាទីបំផុត មានសេចក្ដីបែកធ្លាយ មិន

យឺនយូរ មិនមានខ្វឹមសារ វិនាសជានិច្ច ត្រូវប្រុងតែងជានិច្ច និងមានសេចក្តីស្ងាប់ សេចក្តីរលត់ជាធម្មតា ។

ជា **ទុក្ខំ** *ធន់បានក្រ ធន់នៅមិនបានព្រោះមានទុក្ខ រូបនាមរលត់ទៅ ធន់មិនបាន* **សភាវទុក្ខ** *គឺទុក្ខប្រចាំសង្ខារគឺ* **ជាតិ ជរា មរណៈ** *ទើបមានឡើង ព្រោះមានទុក្ខ រូបនាមរលត់ទៅៗ ធន់នៅមិនបាន* **បកិណ្ណកទុក្ខ** *ត្រាច់មកគឺ* **សោកៈ បរិទេវៈ ទោមនស្សៈ ឧបាយាសៈ** *ទើបមានឡើង ព្រោះមានទុក្ខគឺរូបនាមរលត់ទៅៗ ធន់នៅមិនបាន* **និពទ្ធទុក្ខ** *គឺទុក្ខជាប់ជានិច្ច ឬទុក្ខជាម្ចាស់ផ្ទះ បានដល់ត្រជាក់ ក្តៅ ស្រេកឃ្ងាន ឈឺឧច្ចារៈ ឈឺបស្សាវៈទើបមានឡើង ព្រោះមានទុក្ខ គឺរូប-នាមរលត់ទៅៗ ធន់នៅមិនបាន* **ញាធិទុក្ខ** *គឺទុក្ខវេទនា បានដល់អវយវៈមិនធ្វើនាទីតាមប្រក្រតី ព្រោះមានទុក្ខ គឺរូបនាមរលត់ទៅៗ ធន់នៅមិនបាន* **សន្តាបទុក្ខ** *គឺសេចក្តីក្តៅក្រហាយទើបកើតមានឡើង ព្រោះមានទុក្ខ គឺរូបនាមកើតៗ រលត់ៗ ធន់នៅមិនបាន* **វិបាកទុក្ខ** *គឺទុក្ខដែលជាផល ទើបមានឡើង ព្រោះមានទុក្ខគឺរូបនាម ធន់នៅមិនបាន* **សហគត-ទុក្ខ** *គឺទុក្ខកើតរួមគ្នា កាន់កាប់គ្នា ប្រព្រឹត្តទៅដោយទុក្ខ ទើបមានឡើង ព្រោះមានទុក្ខ គឺរូបនាមរលត់ទៅៗ ធន់នៅមិនបាន* **អាហារបរិយេដ្ឋិទុក្ខ** *ទុក្ខជាប់ដោយការរកចិញ្ចឹមជីវិត ទើបមានឡើង ព្រោះមានទុក្ខ គឺរូបនាមកើតរលត់ ធន់នៅមិនបាន* **វិវាទមូលកទុក្ខ** *ទុក្ខមានការឈ្លោះវិវាទជា*

មូល ទើបមានឡើងព្រោះមានទុក្ខ គឺរូបនាមកើតៗ រលត់ៗ ធន់នៅមិនបាន **ទុក្ខទ្ទៈ** គឺទុក្ខរូបរូម បានដល់ទុក្ខឧបាទានក្ខន្ធ ទើបមានឡើង សរុបហើយ ព្រោះមានទុក្ខរូបទុក្ខនាមនេះឯង សេចក្តីក្តៅក្រហាយ សេចក្តីធន់បានក្រ សេចក្តីប្រឆាំងនឹងសុខទើបមានឡើងតាមលំដាប់ ។

ព្រោះរូបនាមរលត់ទៅៗជា **អនត្តា** បង្ក្រាប់បញ្ជាមិនបាន មិននៅក្នុងអំណាច មិនមែន **អត្តា** ជារបស់ចន្ទោះទទេ មិនមានម្ចាស់របស់ ជាដទៃទំនេរចាកម្ចាស់របស់ ប្រព្រឹត្តទៅតាមហេតុ តាមបច្ចុយ មិនមានអ្នកជាធំ ។

ទុក្ខផ្សេងៗ ដែលកើតមានអាស្រ័យសេចក្តីអស់ទៅនៃញាតិ ហើយជាទុក្ខក្តី អាស្រ័យសេចក្តីអស់ទៅនៃទ្រព្យ ហើយជាទុក្ខក្តី អាស្រ័យសេចក្តីអស់ទៅ ព្រោះរោគបៀតបៀនជាទុក្ខក្តី អាស្រ័យសេចក្តីអស់ទៅនៃសីលជាទុក្ខក្តី សេចក្តីអស់ទៅនៃទិដ្ឋិជាទុក្ខក្តី ក៏ព្រោះមានទុក្ខ គឺរូបនាមដែលរលត់ទៅៗនេះឯង កាលទុក្ខបច្ចុប្បន្ន គឺរូបធម៌ នាមធម៌មិនអស់ហើយ ទុក្ខដទៃៗ ក៏សូន្យអស់ទៅមិនបាន ។

កាលអ្នកបដិបត្តិវិបស្សនាញាណ ឃើញរូបនាមនេះជាភ័យដ៏ធំកន្ទង គួរខ្ទាច ដូចឃើញភ័យដែលកើតពីរាជសីហ៍ ខ្ទាធំ ខ្ទាដំបង ដំរីចុះប្រេងឬអសិរពិស ឃើញជារបស់គួរខ្ទាច ដូចរណ្តៅរងឹកភ្ទើងដែលកំពុងឆេះរុងរឿងដូច្នោះ ។

៧- **អាទីនវញ្ញាណ** ញ្ញាណឃើញរូបនាមរលត់ទៅៗ ជាទុក្ខ ជាទោស មិនមានសេចក្ដីប្រាថ្នា ប្រកាន់រូបនាមណាមួយឡើយ សូម្បីតែបន្ដិចបន្ដួច ដូចគំនរក្ងីង ១១ គំនរ ដែលកំពុងឆេះរាលដាល រូបនាមទាំងពួងយកជាទីពឹងមិនបានឡើយ មានតែទោស កាលដ៏ងច្បាស់យ៉ាងនេះ ចិត្តរមែងមិនញ្ជាប់ញ្ជ័រក្នុងទិដ្ឋិណាៗ ឡើយ មានតែសេចក្ដីព្យាយាមឲ្យអស់ទៅនៃរូបនាម បង្អ្នានទៅកាន់សេចក្ដីអស់ទុក្ខដោយចំណែកមួយ ព្រោះមានវិបស្សនាឃើញរូបនាមរលត់ៗ ជាក់ច្បាស់ដោយមិនច្រឡំ មានសេចក្ដីព្យាយាម មានបញ្ញាឃើញ **អនិច្ចំ ទុក្ខំ អនត្តា** ប្រាកដជាប់នៅនឹងរូបនិងនាម មានរូបនិងនាមជាអ្នកទទួលទុកជាក់ដូច្នេះ កាលនោះរមែងឃើញរូបនាមដែលរលត់ទៅៗ ជាទោស មិនមានសេចក្ដីត្រេកអរក្នុងរូបនាមឡើយ ប្រៀបដូចបុរសដែលមានសត្រូវកាន់ដាវចោមរោមជុំវិញ ទ្រិតចូលទៅកាប់បុរសនោះ ដោយឃើញតែទោសម្យ៉ាងដូចម្ដេច **អាទីនវញ្ញាណ** ក៏ឃើញរូបធម៌ នាមធម៌ មានតែទោសចំណែកមួយដូច្នោះ ។

៨- **និព្វិទាញ្ញាណ** ឃើញរូបនាមរលត់ទៅៗ គួរនឿយណាយ ឃើញរូបនាមជាក់ច្បាស់ដោយមិនវង្វេង មានសេចក្ដីព្យាយាមនៅ មានបញ្ញាឃើញ **អនិច្ចំ ទុក្ខំ អនត្តា** ប្រាកដនៅនឹងរូបនិងនាម មានរូបនាមជាអ្នកវ៉ាប់រង់ទុកដូច្នោះ កាលនោះរមែងឃើញរូបនាមដែលរលត់ទៅៗនោះ គួរនឿយណាយ ពិចារណាឃើញហើយប្រាសចាកសេចក្ដីត្រេកអរក្នុង

រូបនាម សំដៅចង់បានព្រះនិញ្ចានជាទីតាំង មានសេចក្តីដឹងច្បាស់ក្នុងចិត្ត បង្អោនទៅកាន់សេចក្តីសុខដែលមិនចាំបាច់កើតទៀត បង្អោនទៅកាន់សេចក្តីសុខដែលមិនបាច់គ្រប់គ្រងរូបនាមទៀត បង្អោនទៅកាន់សេចក្តីអស់ជាតិជរាទៀត បង្អោនទៅកាន់សេចក្តីមិនបាច់ខ្ចល់ខ្ចាយ បង្អោនទៅកាន់សេចក្តីមិនបាច់កើតរូបនាមទៀតតទៅ កាលណាអ្នកបដិបត្តិវិបស្សនាឃើញដោយបញ្ញាថា រូបនាមរលត់ទៅៗ មិនទៀង រូបនាមរលត់ទៅៗ ជាទុក្ខធន់នៅមិនបាន ឃើញរូបនាមរលត់ទៅៗ ជាអនត្តាបង្គាប់បញ្ជាមិនបាន មិនមែនអត្តា ខ្ជូនប្រាណ មិនប្រព្រឹត្តទៅតាមចិត្តប្រាថ្នា កាលនោះរមែងនឿយណាយក្នុងសង្ខាររូបនាម ផ្ទូវនេះប្រព្រឹត្តទៅដើម្បីសេចក្តីបរិសុទ្ធម៉ត់ចត់ចាកកិលេស គ្រឿងសៅហ្មងទាំងឡាយ ឧបមាបីដូចស្តេចគជសារដ៏ប្រសើរ ពូជពង្សធទ្ធន្ត មានពណិសផូរផង់ មានកន្ទុយនិងប្រមោយ និងនិមិត្តប្រផិតដល់ផ្ទៃដី មានឥទ្ធិប្ចទ្ធិ ដំណើរបានក្នុងវេហាស៍ មិនត្រេកអរនៅក្នុងកណ្តាលព្រះនគរឡើយ រមែងត្រេកអរតែស្រះធទ្ធន្ត ក្នុងហិមវន្តប្រទេសដូចម្តេច ឧបមេយ្យដូចអ្នកបំពេញព្យាយាមវិបស្សនា-ញាណ កាលដល់ **និព្ចិទាញាណ** ឃើញរូបនាមកើតរលត់ គួរនឿយណាយស្អប់ខ្ពើម ប្រាសចាកសេចក្តីត្រេកអរពេញចិត្ត ដូចបុរសអ្នកតែងកាយស្អាតម៉ត់ចត់ រមែងនឿយណាយ និងខ្ពើមរអើមក្នុងរបស់ស្មោកគ្រោកត្រេកអរតែសេចក្តីស្អាតបរិសុទ្ធដូច្នោះ ។

៩- **មុញ្ចិតុកម្យតាញ្ញាណ** ឃើញតែរូបនាមរលត់ទៅៗ ប្រាជ្ញានឹងរត់ចៀសឲ្យផុតចេញទៅ កាលវិបស្សនាឃើញរូបនាមរលត់ទៅៗជាក់ច្បាស់ដោយមិនវង្វេង មានសេចក្ដីព្យាយាម មានបញ្ញាឃើញ **អនិច្ចំ ទុក្ខំ អនត្តា** ប្រាកដជាប់នៅត្រង់រូបនាម មានរូបនិងនាមរ៉ាប់រងទុកដូច្នេះ កាលនោះរមែងឃើញរូបនាមរលត់ទៅៗ នោះថា ជារបស់ដែលមិនគួរជាប់ជំពាក់ទាក់ទងឡើយ ប្រាជ្ញាចង់ផុត ប្រាជ្ញាដោះរូបនាមអម្បាលនោះចេញ ប្រាជ្ញានឹងឲ្យរបូតផុតចាកសង្ខារវដ្ដរបស់រូបនាមដែលវិលវល់កើតរលត់ទៅ ប្រៀបដូចត្រីដែលនៅក្នុងសំណាញ់ ប្រាជ្ញានឹងផុតចាកសំណាញ់ ឬដូចបុរសអ្នកនៅក្នុងគំនរភ្លើងមានភ្លើងឆេះរាលដាលខ្លួន មានសេចក្ដីប្រាជ្ញាយ៉ាងខ្លាំងក្លា ប្រាជ្ញានឹងផុតចាកគំនរភ្លើងដូច្នោះ ឬប្រៀបដូចកង្កែបដែលនៅក្នុងមាត់ពស់ មានសេចក្ដីប្រាជ្ញាចង់ឲ្យរួចចាកមាត់ពស់ ឬប្រៀបដូចមាន់ព្រៃ ដែលបុគ្គលឃាំងទុកក្នុងទ្រុង មានសេចក្ដីប្រាជ្ញានឹងទៅឲ្យផុតចាកទ្រុង ឬប្រៀបដូចម្រ៉ឹគដែលជាប់អន្ទាក់ដ៏មាំមួនបម្រះនទៀលប្រាជ្ញានឹងទៅឲ្យផុតអន្ទាក់ ឬប្រៀបដូចពស់ដែលនៅក្នុងកណ្ដាប់ដៃរបស់អាលម្ពាយ (ហ្នពស់) មានសេចក្ដីប្រាជ្ញានឹងទៅឲ្យផុតចាកកណ្ដាប់ដៃរបស់អាលម្ពាយ (ហ្នពស់) ឬប្រៀបដូចដំរីសារដែលលិចកប់នៅក្នុងល្បប់ ប្រាជ្ញានឹងរើខ្លួនឲ្យផុតចាកល្បប់ ឬប្រៀបដូចស្ដេចនាគដែលនៅក្នុងក្រញ៉ាំក្រចកនៃស្ដេចគ្រុទ

ប្រាថ្នាតែនឹងទៅឲ្យផុតចាកគ្រុឧដូចម្តេច ឧបមេយ្យដូចព្រះយោគាវចរ អ្នកចម្រើនវិបស្សនា លុះដល់មុញ្ចិតុកម្យតាញាណ ប្រាថ្នានឹងផុតចាករូបនាម ដែលរលត់ទៅៗ ក៏ដូច្នោះ កាលនោះ ។

១០- **បដិសង្ខាញាណ** ញាណឃើញរូបនាមកើតរលត់ រកផ្ទូវ រត់(ចោល) រូបនាម កាលណាវិបស្សនាឃើញរូបនាមរលត់ទៅៗ ជាក់ ច្បាស់ដោយមិនវង្វេង មានសេចក្តីព្យាយាម មានបញ្ញាឃើញ **អនិច្ចំ ទុក្ខំ អនត្តា** ប្រាកដជាប់នៅនឹងរូបនាម មានរូបនាមជាអ្នកវ៉ាប់រងទុក ដូច្នេះ កាលនោះរមែងឃើញភ័យ ឃើញទោស នឿយណាយ ប្រាថ្នា នឹងផុតស្រឡះទៅដោយអនុលោមហើយ ពិចារណារកផ្ទូវដែលជាឧបាយ ដោះចាករូបនាមនេះចេញ សម្ងឹងចំពោះ **អនិច្ចំ** តាំងនៅមិនបាន **ទុក្ខំ** ធន់នៅមិនបាន **អនត្តា** បង្គាប់បញ្ជាមិនបាន ដែលជាប់នៅនឹងរូបនាម ដែលរលត់ទៅៗ ជានិច្ច ឧបមាដូចបុរសគិតចាប់ត្រី កាន់អង្រុតទៅរុត ចុះក្នុងទឹក លូកដៃចុះទៅតាមមាត់អង្រុត ចាប់អាសិរពិសត្រង់ក ហើយ មានសេចក្តីត្រេកអរដែលចាប់ត្រីបាន លើកឡើងឃើញក្បាលក៏ដឹងថា ពស់ មានសេចក្តីស្ទុតខ្ចាច នឿយណាយក្នុងសេចក្តីកាន់ខ្ជាប់នោះប្រាថ្នា នឹងលែងអាសិរពិសទៅដូចម្តេច ឧបមេយ្យដូចអ្នកបដិបត្តិវិបស្សនា បាន រូបនាមមកក៏ត្រេកអរប្រកាន់ថា ជាខ្ជូន ជាប្រាណ ដូចបុរសចាប់កពស់ ខាងក្នុងទឹក សម្គាល់ថាជាត្រី ហើយក៏ត្រេកអរ ក៏សម្ងឹងរូបនាមទៅ លុះ

ឃើញថាកើតរលត់ជា **អនិច្ចំ ទុក្ខំ អនត្តា** មានសេចក្តីសុតខ្ចាច ដូចបុរសលើកដៃឡើងចាកប្រហោងអង្រុត ឃើញផ្នត់កទាំង ៣ របស់ពស់ហើយសុតខ្ចាច កាលឃើញរូបនាមកើតរលត់ជាទោស គួរនឿយណាយនោះ ដូចជាបុរសឃើញផ្នត់កទាំង ៣ ដឹងថាពស់ មានចិត្តសុតខ្ចាចសម្ចឹងឃើញទោស ហើយក៏ណាយ ប្រាថ្នាដើម្បីនឹងរលាស់ឲ្យផុតទៅចាកខ្ជួន កាលព្រះយោគាវចរលើករូបនាមឡើងកាន់ព្រះត្រៃលក្ខណៈ ទៀតសោត ដើម្បីនឹងតាក់តែងស្វែងរកឧបាយឲ្យផុតចាករូបនាមដែលរលត់ទៅៗ ដូច្នោះ ។

១១- **សង្ខារុបេក្ខាញាណ** ញាណឃើញរូបនាមរលត់ទៅៗ រកផ្ទូវរត់មិនផុត នៅមើលព្រងើយ កាលណាវិបស្សនាឃើញរូបនាមរលត់ទៅៗជាក់ច្បាស់ដោយមិនវង្វេង មានសេចក្តីព្យាយាម មានបញ្ញាឃើញ **អនិច្ចំ ទុក្ខំ អនត្តា** ប្រាកដជាប់នៅនឹងរូបនាម មានរូបនាមជាអ្នករ៉ាប់រងទុកដូច្នេះ កាលនោះរមែងមានសេចក្តីឃើញថា ខ្ជួនប្រាណ មិនមានមិនមានអ្វីៗជារបស់ខ្ជួន ទំនេរទទេ របស់ទាំងឡាយទាំងពួងក្នុងលោកដែលដឹងបានដោយសម្មតិ ដឹងបានដោយបញ្ញត្តិ រមែងរលត់ទៅអស់សល់តែសភាវៈរបស់រូបនាមសុទ្ធៗ ដែលមិនមានខ្ចឹមសារអ្វីឡើយ មានកិរិយាកើតឡើងតាំងនៅហើយរលត់ទៅ មិនទៀង ធន់នៅមិនបាន បង្គាប់បញ្ជាមិនបានយ៉ាងនេះ ក៏ជាការចាំបាច់មើលព្រងើយៗ ឧបមាដូចស្វាមី

សម្ពែងអាការព្រងើយចំពោះភរិយា ដែលលែងលះគ្នាដាច់ស្រឡះហើយ ដូច្នោះ អ្នកចម្រើនវិបស្សនាឃើញរូបនាមរលត់ទៅៗ មានសេចក្តីនឿយ ណាយ ប្រាថ្នារកផ្ទូវទៅមិនបានហើយ រមែងសម្ពែងអាការព្រងើយក្នុង រូបនាមយ៉ាងនេះ ឈ្មោះថាចូលដល់ភូមិនៃសង្ខារុបេក្ខាញាណ ប្រកប ដោយយោនិសោមនសិការ: មានចិត្តផ្តោតនៅចំពោះរូបនាម ដែលជា កំណើតដើមពិតៗ សតិជាក់លាក់ឡើង មិនមានលោភ ក្រោធ វង្វេង ចូលមកបានឡើយ ចិត្តមិនមានការយិតតោងជាប់ចំពាក់ក្នុងវត្ថុអ្វីៗ មិន ទទួលនិមិត្តផ្សេងៗ មកជាអារម្មណ៍ ប្រាសចាកទុក្ខភ័យដទៃ ឃើញតែ ទុក្ខរូប ទុក្ខនាមប៉ុណ្ណោះ ជិតចំពោះព្រះនិញ្ចាន ដោយសេចក្តីព្យាយាមរក្សា កម្មដ្ឋានដែលអាចារ្យឲ្យទុក ជឿស្តាប់ពាក្យប្រៀបប្រដៅរបស់អាចារ្យ កាន់អាចារ្យជាទីពឹងនៅក្នុងស្ថានដែលសមគួរជាទីសប្បាយ និងជាអ្នកមាន **បុញ្ញាធិការ** មកអំពីមុន ជាបច្ច័យឲ្យមានសតិបញ្ញានឹងន ដឹងនៅជាមួយ រូបនាម តាមសេចក្តីពិតដោយត្រែលក្ខណ:ហើយ រមែងប្រាកដសភាព សេចក្តីព្រងើយនៅមាំនៅក្នុងអនុបស្សនា ៣ ប្រការគឺ **អនិច្ចានុបស្សនា ទុក្ខានុបស្សនា អនត្តានុបស្សនា** ពិចារណាលក្ខណ: ៣ ណាមួយ នៅរឿយៗ ឧបមាដូចបុរសមួយនាក់ មានភរិយាជាទីស្រឡាញ់ពេញ អធ្យាស្រ័យ ជាទីចម្រើនចិត្តក្រៃពេក បុរសនោះ បើមិនបានឃើញត្រឹម មួយដងក៏នៅមិនបាន បើឃើញភរិយានោះទៅឈរនៅជាមួយបុរសដទៃ

ក្តី ទៅអង្គុយលេងចរចាជាមួយបុរសដទៃក្តី ញញឹមញញែមជាមួយបុរសដទៃក្តី បុរសនោះក៏មានសេចក្តីទោមនស្សទាស់ចិត្តណាស់ តមកមិនយូរប៉ុន្មាន បុរសនោះពិចារណាឃើញទោសថា ភរិយាមិនស្មោះត្រង់ចំពោះខ្លួនហើយ ក៏បោះបង់ចោលលះលែងភរិយានោះចេញ មិនបានសម្គាល់ថា ជាភរិយារបស់ខ្លួនទៀតតទៅ តាំងអំពីលែងលះចាកគ្នាជាច់ស្រឡះហើយ សូម្បីឃើញស្ត្រីនោះទៅអង្គុយលេងចរចាសមាគមគប់រកនឹងនរណាៗក្តី បុរសនោះនឹងបានក្រេវក្រោធទោមនស្សទាស់ចិត្ត តែបន្ទិចបន្ទួចក៏ពុំមានឡើយ ព្រោះចិត្តរបស់បុរសនោះតាំងឧបេក្ខា ដូចនេះឯង មានឧបមាដូចម្តេច កាលព្រះយោគាវចរអ្នកចម្រើនវិបស្សនាកម្មដ្ឋាន ឃើញរូបនាមរលត់ៗ ផ្ទួនគ្នា ជារបស់ទទេៗ ឃើញតែលក្ខណៈ ៣ គឺ **អនិច្ចំ ទុក្ខំ អនត្តា** ជានិច្ច ចិត្តនៃព្រះយោគាវចរនោះក៏នឹងអស់ខ្ជាច អស់ស្ងុត អស់ស្រឡាញ់ ក្នុងរូបនាម តាំងនៅក្នុងទីឧបេក្ខា ព្រងើយចំពោះរូបនាមដែលរលត់ទៅៗ ឧបមេយ្យដូច្នោះ ។

កាលចិត្តតាំងនៅក្នុងសង្ខារុបេក្ខាញ្ញាណដូច្នេះ សន្តានៈនោះក៏នឹងមានតែស្ងួតស្ងប់ មិនរីករាយ ហេតុដែលនឹងនាំទៅឲ្យជាប់ជំពាក់ក្នុងភពទាំង ៣ កំណើត ៤ គតិ ៥ វិញ្ញាណឋិតិ ៧ សត្តាវាស ៩ ភូមិ ៣១ នោះមិនមានទៀតហើយ មានតែនឹងខ្ពើម នឹងនឿយណាយ នឹងមើលព្រងើយប៉ុណ្ណោះ ចិត្តមិនជាប់ជំពាក់ទាក់ទងក្នុងរូបលោក នាមលោក

ដែលជាលោកសន្និវាសនោះឡើយ ប្រៀបដូចស្ទឹកឈូក ដែលមានទង៨ទន់ល្ងន់ សូម្បីមានតំណក់ទឹកធ្លាក់ចុះមក ក៏មិនអាចជិតជាប់នៅឡើយដូច្នោះ ។

សង្ខារុបេក្ខាញាណ នេះ បើថាសូប់ នឹង៨ច្បាស់ព្រះនិញ្ជានហើយ មានអាការដូចលះសង្ខារស្រឡះបង្ហានទៅរកព្រះនិញ្ជាន តែបើនៅមិនច្បាស់ មិនដល់ព្រះនិញ្ជាន រមែង៨ចម្រើននៅក្នុង៨អារម្មណ៍រូបនាមដែលរលត់ទៅៗ ព្រងើយតទៅ ។

សង្ខារុបេក្ខាញាណ បានជាបច្ច័យឲ្យដល់មគ្គចិត្តផ្ទុតចាកកិលេសជាប់ខាតបាន សង្ខារុបេក្ខាញាណនោះ មាននាមថា **រុដ្ឋិ១ឥតាមិនី-វិបស្សនា** ។

១២- **អនុលោមញាណ** ញាណឃើញរូបនាមរលត់ទៅៗ មានកម្លាំ៨លើសឡើ៨ តាមអំណាចរបស់អរិយសច្ច អាចកម្ចាត់ទម្លាយសេចក្ដី៨ងងឹតដែលបិទបាំ៨អរិយសច្ចចេញបាន កាលវិបស្សនាញាណចម្រើនឡើ៨ដោយលំដាប់ជាអនុលោម បដិលោម ត្រឡប់ទៅ ត្រឡប់មក តាំ៨អំពីឧទយព្វយញាណលុះដល់សង្ខារុបេក្ខាញាណដឹ៨រូបនាមនិ៨ទុក្ខអរិយសច្ចជាក់ច្បាស់ ជាសេចក្ដីពិតដែលនឹ៨ឆ្លាយចាកសត្រូវគឺកិលេសឃើញរូបនាមរលត់ទៅៗ ថែមឡើ៨ មានអាការដូចនឹ៨ជាប់ខ្សាស់ ឬដូចត្រូវសង្ក្ដត់ឲ្យលិចទឹក លះលោកតណ្ហាសេចក្ដីចង់ដែលជាសមុទ័យបាន

ដោយវិបស្សនាញាណដែលចាស់ក្លាប្រហារនៅជានិច្ច ឃើញសេចក្តីរលត់របស់រូបនាមយ៉ាងច្បាស់លាស់ មគ្ត ៨ គឺវិបស្សនា ធ្វើការងារយ៉ាងពេញទី អាចកម្ចាត់ទម្លាយកិលេសបាន លុះមិនអាចធ្វើឲ្យរូបនាមសៅហ្មងបាន ។

អនុលោមញាណមានកិច្ច ២ គឺ

ក- **លក្ខណតយសម្មសនកិច្ច** គឺកិច្ចពិចារណាឃើញរូបនាមរលត់ទៅៗ ជា **អនិច្ចំ ទុក្ខំ អនត្តា** ប្រមូល **អនិច្ចំ ទុក្ខំ អនត្តា** ចុះកវង្ក: ទម្លាយអនុស័យដែលដេកត្រាំរឿយៗ នៅក្នុងសន្តានឲ្យស្រាលស្តើងចុះទៅឲ្យអស់រលីងទៅ ។

ខ- **សម្មោសាទិទមនកិច្ច** គឺកិច្ចរបស់សហជាតធម៌របស់វិបស្សនានិងជាតួវិបស្សនា ដែលជាធម៌ចំណែកនៃសេចក្តីត្រាស់ដឹង ដែលហៅថា **ពោធិបក្ខិយធម៌** បានដល់ **សតិបដ្ឋាន ៤** មានសតិជាទីតាំងរបស់វិបស្សនា **សម្មប្បធាន ៤** មានសេចក្តីព្យាយាមក្លៀវក្លាក្នុងវិបស្សនា **ឥន្ទ្រិយ ៥** មានភាពជាធំ គ្រប់គ្រងក្នុងវិបស្សនាភូមិ **ពល: ៥** មានកម្លាំងធំក្នុងវិបស្សនា **ពោជ្ឈង្ត ៧** អង្គត្រាស់ដឹងក្នុងវិបស្សនា **មគ្ត ៨** ផ្លូវរំលត់ទុក្ខរបស់វិបស្សនា មកប្រជុំព្រមជានិច្ច ដូចការប្រជុំពួកទាហានដើម្បីធ្វើការច្បាំងផ្តាច់សឹកសត្រូវត្រាតែដល់ទីបំផុតដូច្នោះ ។

១៣- ***គោត្រភូញាណ*** ញាណដែលដឹងព្រះនិញ្វាន អាចទម្លាយ

គោត្របុថុជ្ជនដោយអស់ជើង សេចក្តីដឹងបង្ហោនទៅកាន់ព្រះនិញ្ជាន សេចក្តីរលត់រូបនាមមិនកើតពិតប្រាកដ ដែលមាន **អនុលោមញ្ញាណ** *ជាញ្ញាណដែលអាចទម្លាយពួកកិលេស ដែលបិទបាំងសេចក្តីពិតទុកបានអស់ជើង តែមិនអាចនឹងឃើញព្រះនិញ្ជានបាន ជាបច្ច័យបញ្ជូនឲ្យ* **គោត្រភូញ្ញាណ** *ជាញ្ញាណដែលអាចដឹងបង្ហោនទៅរកព្រះនិញ្ជាន មិនអាចទម្លាយកិលេសទាំងឡាយ តែធ្វើនាទីធ្ងន់ចាកគោត្របុថុជ្ជនទៅកាន់អរិយគោត្របាន មានវិបស្សនាជាបច្ច័យ ទើបចាត់គោត្រភូញ្ញាណជា* **វិបស្សនាញ្ញាណ** *ផង កាលគោត្រភូញ្ញាណកើតឡើងហើយ មិនមានចន្ទោះខណ្ឌ ញ្ញាណក្នុងលោកុត្តរៈគឺ* **មគ្គញ្ញាណ ផលញ្ញាណ** *កើតឡើងដោយមិនមានចន្ទោះខណ្ឌដូចគ្នា ប្រកបនឹង* **មគ្គបិត្ត ផលបិត្ត** *បានព្រះនិញ្ជានជាអារម្មណ៍ តាមលំដាប់នៃមគ្គជវនចិត្តវិថីដូច្នេះ ។*

១- **មនោទ្វារ** *ដឹងរូបនាមជាអារម្មណ៍*

២- **អនុលោមវណៈទី១** *ដឹងរូបនាមដោយព្រះត្រៃលក្ខណៈជាអារម្មណ៍ ទម្លាយកិលេស ។*

៣- **អនុលោមវណៈទី២** *ដឹងរូបនាមដោយព្រះត្រៃលក្ខណៈជាអារម្មណ៍ ទម្លាយកិលេស ។*

៤- **អនុលោមវណៈទី៣** *ដឹងរូបនាមដោយព្រះត្រៃលក្ខណៈជាអារម្មណ៍ ទម្លាយកិលេស ។*

៥- **គោត្រភូ** *ខណៈបង្អោនទៅដឹងព្រះនិញ្ជានជាអារម្មណ៍ មិនបានទម្ងាយកិលេស ចោលរូបនាមហើយ ។*

៦- **មគ្គ** *ខណៈឃើញព្រះនិញ្ជាន រលត់រូបនាមដាច់ខាត ។*

៧- **ផល** *ខណៈឃើញព្រះនិញ្ជានជាអារម្មណ៍ ។*

៨- **ផល** *ខណៈឃើញព្រះនិញ្ជានជាអារម្មណ៍ ។*

៩- **បច្ចវេក្ខណៈ** *ខណៈពិចារណាមគ្គ ផល និញ្ជាន និង កិលេសដែលសល់ ឬដែលលះហើយតទៅ ដែលជាខណៈ ញាណសេចក្តីដឹងដែលចេញចាកលោកុត្តរៈ មកកាន់លោកិយ ចោលអារម្មណ៍ និញ្ជាន មកទទួលអារម្មណ៍លោកតាមដើម ។*

ឧបមាដូចបុរសដែលនឹងធ្ងងប្រឡាយទឹក ស្ទុះដោយកម្ងាំងខ្ងាំងចាប់វល្ងីដែលចងសំយុង លោតធ្ងងទៅដល់ច្រាំងមួយទៀត ហើយលែងវល្ងី តាំងខ្ជួនឡើងក៏កើតសេចក្តីសប្បាយ ដឹងថាខ្ជួនបានធ្ងងទៅសម្រេចហើយដូចម្តេច ឧបមេយ្យដូចព្រះយោគាវចរអ្នកបដិបត្តិវិបស្សនា បានប្រើសតិកំណត់ក្នុងញាណដែលខ្ជួនបានមកគ្រប់ៗញាណ តាមលំដាប់អំពីលះញាណ ក៏រឹតតែទ្ងេកម្ងាំងលើសឡើងជាលំដាប់ អាចដឹងច្បាស់ក្នុងរូបធម៌ នាមធម៌ ដើម្បីនឹងឲ្យបានមកនូវព្រះនិញ្ជាន ដោយដឹងច្បាស់តាមសេចក្តីពិតរបស់រូបនាមតាមលំដាប់របស់ញាណ តាំងអំពីនាមរូបបរិច្ឆេទ-ញាណ ឧទយព្ងយញាណជាដើមមក លុះដល់សង្ខារុបេក្ខាញាណនោះ

រាប់ថាញាណមានកម្លាំងយ៉ាងខ្លាំងក្លាបាន អាចសម្តែងកិរិយាព្រងើយនិងតាំងមាំក្នុងអត្តភាព គឺតាំងមាំនៅក្នុងញាណនិងសង្ខារុបេក្ខាញាណដែលទ្រកម្លាំងលើសឡើង លុះកម្លាំងរបស់សង្ខារុបេក្ខាញាណបានខ្លាំងក្លាដល់កម្រិតដែលនឹងមិនបង្អែបង្ហង់បានហើយ ក៏ប្រើកម្លាំងដែលខ្លាំងក្លានោះដូចបុរសដែលរត់ទៅដោយកម្លាំងខ្លាំង ចាប់ខ្សែដោយអាការនឹងយោលកាលចាប់ខ្សែបានមាំមួនខ្លាំងក្លា ពិចារណាញាណដែលពេញបរិបូរទាល់តែឆ្អែតកាយ និងប្រាកដក្នុងចិត្ត ការប្រាកដក្នុងចិត្តនេះ ក៏ប្រហែលគ្នានឹងបានដល់អាវជ្ជនចិត្ត គឺចិត្តដែលកើតមុនអនុលោមញាណ ក៏ប្រាកដក្នុងចិត្តហើយ ក៏យោលខ្ជូនដោយអាការយោលខ្សែ ខណៈយោលខ្ជូននោះ ក៏ប្រហែលគ្នានឹងបឋមអនុលោមជវនចិត្តកើត (បរិកម្ម) ហើយក៏មានអាការស្រេបទៅដោយកម្លាំងខ្លាំងបញ្ជូន ខណៈដែលស្រេបទៅនោះ ក៏ប្រហែលគ្នានឹងបានអនុលោមជវនចិត្តកើត (ឧបចារ) ហើយក៏ដល់នូវប្រាំងមួយទៀត ខណៈដែលស្រេបទៅនោះ ក៏ប្រហែលគ្នានឹងបានតតិយអនុលោមជវនចិត្តកើត (អនុលោម) ហើយក៏លែងខ្សែ ក៏ប្រហែលគ្នានឹងលែងរូបនាម នឹងរត់អស់ទៅនៃលោកិយ ការលែងខ្សែ ឬខណៈលែងនោះ ក៏ប្រហែលគ្នានឹងបានមគ្គជវនចិត្តកើត ការលែងខ្សែក៏ដូចជាការកាត់ពូជពង្សគោត្របុជ្ជន កាលលែងខ្សែហើយក៏ធ្លាក់ទៅដល់ដី ឬខណៈដល់ដីនោះ ក៏ប្រហែលគ្នានឹងបានមគ្គជវនចិត្តកើត កាល

ដល់ដីហើយក៏តាំងជំហរទ្រខ្ជូនឲ្យរៀបរយ ឬខណៈដែលទ្រខ្ជូនឡើងរៀបរយហើយ ក៏ប្រហែលគ្នានឹងបានបឋមផលជវនចិត្តកើតដូច្នោះ ។

ឬឧបមាមួយទៀត ដូចបុរសរែករបស់ធ្ងន់នាំទៅឆ្ងាយ រឹតតែធ្ងន់ឡើងៗ ស្ទើរធន់មិនបាន ទ្រាំឈានទៅទៀតមួយជំហាន ពីរជំហាន បីជំហាន ធន់មិនបានពិតៗ ទើបដាក់របស់នោះចុះអំពីស្មា កាលយករបស់ចុះអំពីស្មាហើយ ក៏កើតសេចក្ដីសប្បាយឡើង ដូចម្ដេច ដូចព្រះយោគាវចរអ្នកបដិបត្តិវិបស្សនាឃើញ **អនិច្ចំ** ច្បាស់លាស់ **ទុក្ខំ** ជាក់ **អនត្តា** ច្រាកដណាស់ទៅ ដោយអនុលោម បដិលោម ក្នុងញាណទាំង ៨ ដែលពោលហើយ ទើបឈានឡើងកាន់អនុលោមខណៈ ៣ ខណៈ ដូចឈាន ៣ ជំហាននោះ ធន់មិនបានទាល់តែដាក់របស់ធ្ងន់ សម្គាល់ដល់គោត្រភូចោលរូបនាម គឺរលត់ទុកមិនមានសល់ លោកុត្តរមគ្គចិត្តក៏កើតឡើង មានព្រះនិព្វានជាអារម្មណ៍ កើតសេចក្ដីសប្បាយនោះ សម្គាល់សេចក្ដីថា ផលចិត្តកើតឡើង ២ ខណៈ ដូច្នោះ ។

កាល **អនុលោមញាណ** ដែលជាញាណកម្ចាត់សេចក្ដីងងឹតរបស់កិលេសដែលបិទបាំងគ្របអរិយសច្ចកើតឡើងហើយ **គោត្រភូញាណ** ញាណដែលអាចទម្លាយគោត្របុថុជ្ជននោះ ក៏កើតឡើង អាស្រ័យព្រះនិព្វានជាអារម្មណ៍ ញ៉ាំងឲ្យ **វិរាគញាណ** កើតឡើង កាលវិរាគញាណកើតឡើងហើយ **វិមុត្តិញាណ** ក៏កើតឡើងតាមលំដាប់ ១ បានដល់

មគ្គញ្ញាណ **ផលញ្ញាណ** *នោះឯង* *តអំពីនោះ* **វិមុត្តិញ្ញាណទស្សនៈ** *គឺផលញ្ញាណរលត់ទៅហើយ* **បច្ចវេក្ខណញ្ញាណ** *ក៏កើតឡើង* *ដឹងថា* *រួចផុតហើយ* ។

១៤- **បច្ចវេក្ខណញ្ញាណ** *ញ្ញាណសេចក្ដីដឹងដែលកើតឡើង* *ពិចារណាឃើញមគ្គ* *ផល* *និព្វាន* *កិលេសដែលសល់នៅនិងកិលេសដែល* *លះហើយ* *បច្ចវេក្ខណៈទាំង* *៥* *ប្រការនេះ* *រមែងមានដល់ព្រះអរិយ-* *សាវ័ក* *គឺព្រះសោតាបន្ន* *ព្រះសកទាគামី* *ព្រះអនាគামី* *និងព្រះអរហន្ត* *តែព្រះអរហន្ត* *មិនមានបច្ចវេក្ខណញ្ញាណ* *គឺការពិចារណាកិលេសដែល* *សល់នៅ* *ព្រោះលោកលះកិលេសបានអស់ដើងហើយ* *បច្ចវេក្ខណ-* *ញ្ញាណនេះ* *សូម្បីនឹងពិចារណាមគ្គ* *ផល* *និព្វាន* *ដែលជាបដិវេធធម៌* *បានក៏ពិត* *ធម៌ក្នុងលោកុត្តរៈពិចារណាប្រព្រឹត្តទៅក្នុងអតីតប៉ុណ្ណោះ* *ព្រោះ* *បច្ចវេក្ខណញ្ញាណ* *ជាញ្ញាណក្នុងលោកិយ* *ចេញចាកលោកុត្តរៈមកហើយ* *ដូចគ្នានឹងវិបស្សនាញ្ញាណនោះឯង* ។

ញ្ញាណរបស់ព្រះអរិយបុគ្គល *ដែលបានពិចារណាមគ្គញ្ញាណ* *ដែល* *ខ្ជួនបានមកដោយលំដាប់នៃវិបស្សនាញ្ញាណនោះ* *ហៅថា* **មគ្គបច្ចវេក្ខណ-** **ញ្ញាណ** *ពិចារណាមគ្គជាអារម្មណ៍* ។

ញ្ញាណរបស់ព្រះអរិយបុគ្គល *ដែលបានពិចារណាក្នុងផលញ្ញាណ* *ដែលតចាកមគ្គញ្ញាណនោះ* *ហៅថា* **ផលបច្ចវេក្ខណញ្ញាណ** *ពិចារណា*

ផលជាអារម្មណ៍ ។

ញាណរបស់ព្រះអរិយបុគ្គល ដែលបានពិចារណាកិលេសដែលបានប្រហារហើយដោយដាច់ខាតនោះ ហៅថា **បហីនកិលេសបច្ចវេក្ខណញាណ** ពិចារណាកិលេសដែលលះហើយជាអារម្មណ៍ ។

ញាណរបស់ព្រះអរិយបុគ្គល ដែលបានពិចារណាកិលេស ដែលខ្ជួនលះមិនទាន់បាននោះ ហៅថា **អវសិដ្ឋកិលេសបច្ចវេក្ខណញាណ** ពិចារណាកិលេសដែលសល់ជាអារម្មណ៍ ។

ញាណរបស់ព្រះអរិយបុគ្គល ដែលបានពិចារណាអារម្មណ៍ព្រះនិញ្ជានដែលមគ្គញាណ ផលញាណ បានដឹង បានឃើញមកនោះ ហៅថា **និញ្ជានបច្ចវេក្ខណញាណ** ពិចារណាព្រះនិញ្ជានដែលស្ងប់រម្ងាប់ចាកទុក្ខទាំងពួងជាអារម្មណ៍ ។

បច្ចវេក្ខណៈនៃព្រះសោតាបន្ន ព្រះសកទាគামី ព្រះអនាគামី ៣ ជំពូក ពិចារណាពួកលះ ៥ រួមជាបច្ចវេក្ខណវារៈ ១៥ វារៈ ឯព្រះអរហន្ត ទីណាស្រេព មានបច្ចវេក្ខណវារៈ ៤ វារៈ រួមចូលជាមួយគ្នា ជាបច្ចវេក្ខ-ណវារៈ ១៩ ទើបពេញបរិបូរ ដូច្នេះ ដោយឧក្រិដ្ឋសង្គ្រោះយកបច្ចវេក្ខ-ណវារៈ ដែលពេញបរិបូរ ១៩ នេះ ព្រះសេខបុគ្គលអង្គខ្លះ មិនបានពិចារណាកិលេសដែលលះហើយ និងមិនបានពិចារណាកិលេស ដែលនៅសល់ក្នុងសន្ដានខ្លះក៏មាន អាស្រ័យហេតុដែលមិនបានពិចារណាដូច្នេះ

ស្តេចមហានាមសាក្យរាជ ទើបក្រាបទូលសួរសម្តេចព្រះមានព្រះភាគថា "កិលេសដូចម្តេចដែលមាននៅក្នុងសន្តាន ដែលខ្ញុំព្រះអង្គលះមិនបាន លោភ: ទោស: មោហ: ទើបធ្វើឲ្យចិត្តខ្ញុំព្រះអង្គរាយមាយក្នុងវេលាខ្ះ គ្រាខ្ះ ព្រោះធម៌ដូចម្តេចព្រះអង្គ ដូច្នេះ" ។

ហេតុនោះឯង ព្រះអរិយ:ម្ចាស់ទាំងឡាយ រមែងឧស្សាហ៍ពិចារណា មគ្គ ផល និញ្ចាន និងកិលេសដែលលះ ឬដែលសល់នៅជានិច្ច ចិត្ត រមែងស្ងប់ជាសន្តិសុខ សេពវិមុត្តិ ដែលកាមសុខ ឈានសុខមិនត្រឹមស្មើ មានចិត្តបង្អោនទៅហើយកាន់មហាសន្តិសុខនេះជានិច្ចកាល រហូតបរិនិញ្ចាន នោះឯង ។

ញាណលោកុត្តរ:

សេចក្តីត្រាស់ដឹងរហូតក្នុងលោកុត្តរ:ផុតចាកលោក ដែលជាចំណែក បដិវេធធម៌ បានដល់បញ្ញាចេតសិក កើតឡើងនឹងលោកុត្តរចិត្ត រលត់ ព្រមគ្នានឹងលោកុត្តរចិត្ត មានអារម្មណ៍ជាមួយគ្នានឹងលោកុត្តរចិត្ត មាន វត្ថុអាស្រ័យជាមួយគ្នានឹងលោកុត្តរចិត្ត ញាណលោកុត្តរ:នេះ ប្រជុំព្រម ដោយពោធិបក្ខិយធម៌ ប្រកបនឹងមគ្គចិត្ត ហៅថា **មគ្គញាណ** ប្រកបនឹង ផលចិត្ត ហៅថា **ផលញាណ** ចំណែកមគ្គញាណ ៤ ផលញាណ ៤ សុទ្ធ តែបានលោកុត្តរ:អារម្មណ៍ គឺព្រះនិញ្ចានជាអារម្មណ៍ មានព្រះនិញ្ចានជាទី ដឹង ជាទីឃើញ ជាទីបាន ជាទីដល់ ជាទីបានលុះ ជាញាណសេចក្តីដឹង

ដែលផ្សេងចាកលោកិយ មិនមានអ្វីក្នុងលោកិយនេះ នឹងទៅប្រៀបស្មើ នឹងសេចក្តីដឹងក្នុងលោកុត្តរ: ឲ្យត្រង់នឹងសេចក្តីពិតនោះបាន ព្រះអរិយ: ទាំងឡាយដោយច្រើន ទើបមិនសម្តែងសេចក្តីចូលទៅដឹង ទៅឃើញ ដល់បុថុជ្ជនឡើយ ព្រោះមិនអាចនឹងឲ្យបុថុជ្ជនដឹងបានឡើយ បើមិន បដិបត្តិឲ្យដល់ ឲ្យបានលុះ ការដឹងដោយអនុមាន ដោយការស្តាប់ ការគិត និងចម្រើនភាវនា តែមគ្គញាណ ផលញាណនៅមិនបង្កើត ក៏មិនអាចនឹង ដឹងយ៉ាងពិតបាន កាលណាបានចម្រើនវិបស្សនាកម្មដ្ឋាន លុះធ្ងងចាក គោត្របុថុជ្ជនទៅកាន់អរិយគោត្រ កាលនោះបានមានញាណលោកុត្តរ: កើតឡើងហើយ ក៏នឹងដឹងច្បាស់ចាក់ធ្ងុះក្នុងអារម្មណ៍ក្រៅលោក អស់ សង្ស័យដោយមិនបាច់អាស្រ័យចាំមក ឬគិតយក គ្នេរគ្នាន់យក កាលណា បានដឹងដោយបញ្ញាក្នុងលោកុត្តរ:ពិតៗ កាលនោះក៏អស់បញ្ហាដែលនឹង សាកសួរ ក្នុងសំណាក់នរណាៗ ព្រោះមកដឹងច្បាស់ចាក់ធ្ងុះចំពោះខ្លួនឯង ហើយ ដឹងជួសគ្នាមិនបាន អ្នកណាបដិបត្តិត្រូវផ្ទូវទាល់តែបានលុះដល់ អ្នកនោះដឹងចំពោះខ្លួនឯង ។

ញាណសេចក្តីដឹង សេចក្តីឃើញដ៏បរិសុទ្ធម៉ត់ចត់ចាកកិលេស ដែល ប្រកបនឹងលោកុត្តរចិត្ត ៨ បានព្រះនិញ្វានជាអារម្មណ៍នោះ នឹងបានសម្តែង ទៅដោយលំដាប់ដូច្នេះ ៖

១- ព្រះសោតាបត្តិមគ្គញាណ បញ្ញាសេចក្តីដឹងដែលប្រកប

ដោយសោតាបត្តិមគ្គចិត្តកើតឡើង ព្រោះញាណលោកិយជាបច្ចយគ្នាមក ដល់គោត្រភូញាណ ដោយមិនមានចន្ទោះខណ្ឌ សោតាបត្តិមគ្គញាណ ក៏កើតភ្ជាម បានព្រះនិញ្ជានជាអារម្មណ៍ជាគ្រាដំបូង តាំងអំពីវិលវល់ ស្ទាប់កើតមកក្នុងវដ្តសង្សារគ្រានោះជាគ្រាដំបូង ដែលបានឃើញបានដឹង សេចក្តីអស់វិលវល់មិនកើតទៀតឈ្មោះថា ជាអ្នកចូលដល់ក្រសែព្រះ និញ្ជាន ១ ខណៈចិត្តហើយ មិនមានចន្ទោះខណ្ឌ សោតាបត្តិផលញាណ ក៏កើតភ្ជាម ។

២- **សោតាបត្តិផលញាណ** បញ្ញាសេចក្តីដឹងដែលប្រកបដោយ សោតាបត្តិផលចិត្តកើតឡើង ព្រោះញាណសោតាបត្តិមគ្ត បញ្ជូនឲ្យបាន ព្រះនិញ្ជានជាអារម្មណ៍ដូចគ្នា កើត ២-៣ ខណៈចិត្តហើយរលត់ចុះ ព្រះ ពុទ្ធអង្គទ្រង់ប្រទាននាមអ្នកនោះថា ព្រះសោតាបន្នអរិយបុគ្គល អ្នកជា ពន្ធកជាក្រសែដែលនឹងអស់ទុក្ខ ប្រហារលោភៈ ដែលនឹងនាំទៅអបាយភូមិ បានអស់ ធ្វើឲ្យសង្សារវដ្តរីងស្ងួត ទម្ងាយសេចក្តីឃើញខុសបានអស់ជើង រលត់អស់ចាកវេរាភ័យទាំងឡាយ ហាក់បីដូចជាបុត្តរបស់ព្រះសម្មាសម្ពុទ្ធ ជាម្ចាស់យ៉ាងពិត នឹងកើតទៅខាងមុខយ៉ាងច្រើនត្រឹម ៧ ជាតិប៉ុណ្ណោះ ជាអ្នកមានសីល ៥ មិនសៅហ្មង មិនពពាលពព្រុស មិនធ្ទុះធ្ទាយ មិនដាច់ មិនប្រាថ្នាលោកិយ គួរដល់ការសរសើរទាំងអស់ ដូចនឹងបាន សមាធិនៅ ។

អកុសលដែលព្រះសោតាបន្នកាត់បានដាច់ខាត មិនកើតក្នុងសន្តានទៀតនោះ គឺចិត្តលោភដែលប្រកបដោយមិច្ឆាទិដ្ឋិ ៤ ដួង និងចិត្តវង្វេងដែលប្រកបដោយ **វិបិកិច្ឆា** សេចក្តីសង្ស័យទៀត ១ ដួង និងលះចេតសិកបាន ៥ ដួងគឺ **ទិដ្ឋិ វិបិកិច្ឆា ឥស្សា មច្ឆរិយៈ កុក្កុច្ចៈ** និងលះសំយោជនៈ គ្រឿងចងបាន ៣ គឺ **ទិដ្ឋិ** សេចក្តីយើញខុស **វិបិកិច្ឆា** សេចក្តីសង្ស័យ និង **សីលព្វត្តបរាមាសៈ** គឺសីលវត្តក្រៅពុទ្ធសាសនា និងលះនីវរណៈ គ្រឿងរាំងរាបាន ២ គឺ **វិបិកិច្ឆា** សេចក្តីសង្ស័យ និង **កុក្កុច្ចៈ** សេចក្តីរំខានចិត្ត និងលះអនុសយកិលេសដែលដេកត្រាំនៅរឿយៗក្នុងសន្តានបាន ២ គឺ **ទិដ្ឋិ** សេចក្តីយើញខុស និង **វិបិកិច្ឆា** សេចក្តីសង្ស័យ និងលះឧបាទានសេចក្តីប្រកាន់មាំបាន ៣ គឺ **ទិដ្ឋុបាទាន** ប្រកាន់មាំក្នុងសេចក្តីយើញ **សីលព្វត្តុបាទាន** ប្រកាន់មាំក្នុងសីលវត្ត និង **អត្តវាទុបាទាន** ប្រកាន់មាំតាមពាក្យនិយាយរបស់ខ្ជូន និងលះគន្ថៈគ្រឿងចងរឹតបាន ២ គឺ **សីលព្វត្តបរាមាសកាយគន្ថៈ** ការប្រជុំនៃសីលវត្តជាគ្រឿងចងរឹត និង **ឥទំសច្ចាភិនិវេសកាយគន្ថៈ** ការប្រជុំនៃសេចក្តីប្រកាន់ថា មតិរបស់ខ្ជូនត្រូវ របស់អ្នកដទៃខុសទាំងអស់ និងលះយោគៈគ្រឿងប្រកបបាន ១ គឺ **ទិដ្ឋិយោគៈ** គ្រឿងប្រកបគឺសេចក្តីយើញ និងលះឱឃៈគឺអន្ទង់បាន ១ បានដល់ **ទិដ្ឋោឃៈ** អន្ទង់គឺទិដ្ឋិសេចក្តីយើញខុស និងលះអាសវៈ គ្រឿងត្រាំបាន ១ គឺ **ទិដ្ឋាសវៈ** គ្រឿងតម្រាំគឺទិដ្ឋិសេចក្តីយើញខុស ។

ព្រះសោតាបន្នបានមានសេចក្ដីបែកផ្សេងគ្នា ដោយសេចក្ដីលើសខ្វះរបស់ឥទ្ធិបាទ ទើបចែកជា ៣ ជំពូកគឺ ៖

១- **ឯកពីជិសោតាបន្ន** គឺបុគ្គលដែលបានសោតាបន្នហើយ នឹងបដិសន្ធិទៀត ត្រឹមមួយជាតិហើយរលត់ខន្ធ ។

២- **កោលំកោលសោតាបន្ន** គឺបុគ្គលដែលបានព្រះសោតាបន្ន ហើយនឹងបដិសន្ធិទៀត យ៉ាងយូរត្រឹម ៥ ជាតិឬ ៦ ជាតិ (ចាកត្រកូលកាន់ត្រកូល)ហើយរលត់ខន្ធ ។

៣- **សត្តក្ខត្តុបរមសោតាបន្ន** គឺបុគ្គលដែលបានព្រះសោតាបន្ន ហើយត្រូវបដិសន្ធិទៀត ក្នុងកាមសុគតិភូមិ យ៉ាងយូរត្រឹម ៧ ជាតិ ហើយរលត់ខន្ធ ។

អ្នកចម្រើនវិបស្សនា ឃើញរូបនាមកើតរលត់ជា **អនិច្ចំ** តាំងនៅមិនបាន ឬជា **ទុក្ខំ** ធន់នៅមិនបាន ឬឃើញជា **អនត្តា** បង្ខាំបញ្ជាមិនបាន អ្នកនោះឈ្មោះថា **បុណ្ណសោតាបន្ន** អ្នកនឹងបានជាព្រះសោតាបន្ន ជាន់បឋមមគ្គក្នុងអនាគត ឧបមាដូចជារាជឱរស អ្នកជាមហាឧបរាជ នឹងបានជាព្រះរាជាគ្រងរាជសម្បត្តិក្នុងថ្ងៃមុខដូច្នោះ ដែលបាននាមថា អ្នកដល់ក្រសៃព្រះនិព្វាន បានឃើញព្រះនិព្វាន មានព្រះនិព្វានជាអារម្មណ៍ ក្នុងគ្រាដំបូង ហួងហែងព្រះនិព្វានណាស់ ដូចស្ត្រីជាមាតា ស្រឡាញ់កូនដំបូងយ៉ាងក្រៃលែង ប្រមូលកម្លាំងទាំងអស់ថ្នាក់ថ្នម ឬដូចព្រះរាជាមិន

ធ្លាប់មានព្រះរាជឱរស ជ្រាបថានឹងមានព្រះរាជឱរស ក៏ឲ្យថ្នមព្រះរាជ-ឱរស តាំងអំពីនៅក្នុងគភ៌របស់ព្រះមហេសីរហូតប្រសូត គាល់បម្រុងចិញ្ចឹមរក្សា ដោយការយកចិត្តទុកដាក់ ដូចម្តេច ព្រះសោតាបន្ន ក៏ហួងហែងព្រះនិញ្ជានដូច្នោះ ។

៣- **ព្រះសកទាគামិមគ្គញ្ញាណ** សេចក្តីដឹងគឺ បញ្ញាចេតសិកដែលកើតឡើងប្រកបនឹងសកទាគামិមគ្គចិត្ត ដោយការលើកលះចាកបច្ចវេក្ខណញ្ញាណ ដែលពិចារណាសោតាបត្តិមគ្គ សោតាបត្តិផលកិលេសដែលព្រះសោតាបន្នលះបានហើយ និងកិលេសដែលសល់ រហូតការពិចារណាព្រះនិញ្ជាន ដែលព្រះសោតាបន្នចូលទៅឃើញទាំង ៥ ណាមួយ ដោយការវៀរចេញ មិនពិចារណាទៀតតទៅ ត្រឡប់មកចម្រើនវិបស្សនាកម្មដ្ឋានថ្មី ក្នុងខណៈដែលកំពុងអង្គុយនៅក្តី ក្នុងវេលាកន្ទងទៅហើយមួយថ្ងៃក្តី ក្នុងវេលាកន្ទងហើយមួយខែក្តី ក្នុងវេលាកន្ទងហើយមួយឆ្នាំក្តី តាំងដើមកំណត់ដឹងពិចារណារូបធម៌ នាមធម៌ ឲ្យឃើញកើតរលត់ជា **អនិច្ចំ ទុក្ខំ អនត្តា** ប្រាកដជាប់នៅត្រង់រូបត្រង់នាម រូបនាមស្រាលល្អិតជាងអំពីមុន តែឃើញបានច្បាស់ដូចគ្នា កន្ទងញ្ញាណតាំងអំពីឧទយព្វយញ្ញាណ លុះដល់សង្ខារុបេក្ខាញ្ញាណ ហើយជាកម្លាំងឲ្យកើតអាវជ្ជនចិត្ត មនោទ្វារ ឡើងកាន់អនុលោមញ្ញាណ ៣ ខណៈ និងកើតវោទានៈ ដោយមិនមានចន្ទោះខណ្ឌ សកទាគামិមគ្គ រមែងកើតភ្លាម បាន

ព្រះនិញ្ជានជាអារម្មណ៍ កាត់ **កាមរាគ ព្យាបាទ** ឲ្យស្រាលស្តើង ។

៤- **សកទាគាមិផលញ្ញាណ** គឺសេចក្តីដឹង បានដល់បញ្ញា-ចេតសិកដែលប្រកបនឹងសកទាគាមិផលចិត្ត ខណៈដែលសកទាគាមិមគ្គ រលត់ចុះហើយកាលណា មិនប្រកបដោយកាល ជា **អកាលិកធម៌** មិនមានចន្ទោះខណ្ឌ សកទាគាមិផលញ្ញាណ ក៏កើតភ្លាម បានព្រះនិញ្ជានជាអារម្មណ៍ ២ ខណៈ ឬ ៣ ខណៈហើយ ឈ្មោះថា ជាព្រះសកទាគាមិអរិយ-បុគ្គល ដែលលះកិលេសជាសមុច្ឆេទបាន តាមដែលព្រះសោតាបន្នលះទៅហើយ និងធ្វើ រាគៈ ទោសៈ មោហៈ ឲ្យស្រាលស្តើង ដែលមាន ៥ ប្រភេទគឺ ៖

១- **ឥធ** **ឯកា** **ឥធ** **ឯកិញ្ចាយ** នឹងបានសម្រេចព្រះនិញ្ជានក្នុងបច្ចុប្បន្នជាតិ ។

២- **ឥធ** **ឯកា** **ឥត្ត** **ឯកិញ្ចាយ** នឹងបានសម្រេចព្រះនិញ្ជានកាលបដិសន្ធិក្នុងទេវលោកហើយ ។

៣- **ឥត្ត** **ឯកា** **ឥត្ត** **ឯកិញ្ចាយ** នឹងបានសម្រេចព្រះនិញ្ជានក្នុងទេវលោកជាតិនោះឯង ។

៤- **ឥត្ត** **ឯកា** **ឥធ** **ឯកិញ្ចាយ** នឹងបានសម្រេចព្រះនិញ្ជានកាលចាកទេវលោកមកបដិសន្ធិក្នុងមនុស្សហើយ ។

៥- **ឥធ** **ឯកា** **ឥត្ត** **ឥកូត្តិកា** **ឥធ** **ឯកិញ្ចាយ** គឺព្រះអរិយសាវ័ក

ដែលសម្រេចព្រះសកទាគামិបុគ្គលក្នុងមនុស្សហើយ បានបដិសន្ធិក្នុងទេវលោក ចុតិចាកទេវលោក មកបដិសន្ធិក្នុងមនុស្សលោក ហើយសម្រេចជាព្រះអនាគាមី និងព្រះអរហន្ត ហើយរំលត់ខន្ធចូលកាន់បរិនិព្វាន ។

ការបានមកនូវសកទាគামិមគ្គញ្ញាណ សកទាគামិផលញ្ញាណនោះ ឧបមាដូចបុរសអ្នកប្រាថ្នានឹងជម្រះ ឬកាប់ឆ្ការទីកន្លែងឲ្យវាលស្រឡះ ទើបប្រើកាំបិត និងចប ធ្វើការជម្រះកាប់ឆ្ការ និងជីកដើមឈើ ដើមស្មៅឲ្យវាលស្អាតម្តងហើយ តែឫសស្មៅនៅមិនទាន់អស់ កាលភ្លៀងធ្លាក់បំព្រំចុះមកមិនយូរប៉ុន្មានឫសស្មៅនោះ ក៏ជាបច្ច័យឲ្យចម្រើនឡើងជាដើម បែកមែកជាងសាខាស្ងឹកឡើងទៀត បុរសនោះ នាំចបកាប់ ចបជីក មកជីកឫសគល់តទៅទៀត ដើម្បីនឹងឲ្យអស់ឫសគល់នោះជាគ្រាទីពីរ ការស្អាតស្រឡះក៏ប្រាកដជាគ្រាទីពីរទៀត ឧបមាដូចព្រះយោគាវចរ អ្នកចម្រើនវិបស្សនា-កម្មដ្ឋាន ញ្ញាណបង្កើតឡើងលុះដល់សោតាបត្តិមគ្គញ្ញាណ និងសោតា-បត្តិផលញ្ញាណ បានព្រះនិព្វានជាអារម្មណ៍ អស់អាសវកិលេស ជាសមុច្ឆេទ ទៅខ្លះហើយ តែនៅមិនទាន់អស់ តមកទើបចម្រើនវិបស្សនា លុះបានលុះសកទាគামិមគ្គញ្ញាណ និងសកទាគামិផលញ្ញាណ បានព្រះនិព្វានជាអារម្មណ៍ម្តងទៀត នឹងធ្វើ **រាគៈ ទោសៈ មោហៈ** ឲ្យស្រាលស្តើង ។

៥- **អនាគামិមគ្គញ្ញាណ** ញ្ញាណសេចក្តីដឹងគឺ អង្គបញ្ញាប្រកប

នឹងអនាគាមិមគ្គចិត្ត បានព្រះនិព្វានជាអារម្មណ៍ កាលបច្ចវេក្ខណញាណ ពិចារណាសកទាគាមិមគ្គ សកទាគាមិផល ព្រះនិព្វាន កិលេសដែលលះ ដែលសល់នៅ មានសេចក្តីប្រាថ្នា នឹងបដិបត្តិឲ្យបានលុះធម៌ជាន់ខ្ពស់ឡើង ទៅទើបលះចាកបច្ចវេក្ខណ: ពិចារណាមគ្គ ផល និព្វាន និងកិលេស នោះ មកចម្រើនវិបស្សនាញាណថ្មី តាំងអំពីខទយព្វយញាណឡើងទៅ ឃើញរូបនាមកើតរលត់ជា **អនិច្ចំ ទុក្ខំ អនត្តា** សូម្បីរូបនាមជាន់នេះ នឹងល្អិតច្រើន តែមានញាណចូលទៅដឹងជាក់ច្បាស់ដូចគ្នា លុះឡើង អនុលោមញាណកន្ធងរៅទាន: ធ្ងងចាកសកទាគាមិផល ទៅកាន់អនា-គាមិមគ្គញាណ បានព្រះនិព្វានជាអារម្មណ៍ ព្រមទាំងការអស់ទៅនៃ **កាមរាគ ព្យាបាទ** បានអស់ផុតចុះដាច់ខាត មិនកើតឡើងទៀត ។

៦- **អនាគាមិផលញាណ** គឺសេចក្តីដឹង គឺអង្គបញ្ញាដែលប្រកប នឹងអនាគាមិផលចិត្ត បានព្រះនិព្វានជាអារម្មណ៍ ដែលតជាប់មកចាក អនាគាមិមគ្គញាណ កាលអនាគាមិមគ្គញាណកើតឡើងរលត់ចុះ មិនមាន ចន្ទោះខណ្ឌ អនាគាមិផលញាណ ក៏កើតភ្ជាម បានព្រះនិព្វានជាអារម្មណ៍ ២-៣ ខណ: សម្រេចជាព្រះអនាគាមី ព្រះអរិយបុគ្គលលះអកុសលធម៌ ទាំងឡាយបានដាច់ខាត ថែមឡើងចាកព្រះសោតាបន្ន និងព្រះសកទាគាមី ដូច្នេះ ៖

លះទោសមូលចិត្តបាន ២ ដួងដាច់ខាត មិនកើតទៀត ។

លះទោសចេតសិក បានដាច់ខាត មិនកើតទៀត ។

លះអកុសលកម្មបថ ១០ បាន ៣ ដាច់ខាតគឺ **បិសុណាវាចា** និយាយញុះញង់ **ផរុសវាចា** និយាយសម្តីអាក្រក់ និង**ព្យាបាទ** ប្រទូសร៉ាយ ។

លះទោសកិលេសបានដាច់ខាត ។

លះ **កាមរាគសំយោជនៈ** ចងសេចក្តីស្រឡាញ់ក្នុងកាមារម្មណ៍ និង**បដិឃសំយោជនៈ** ចងក្រោធទុកបានដាច់ខាត មិនកើតទៀត ។

លះអនុស័យបាន ២ គឺ **កាមរាគានុស័យ** សេចក្តីស្រឡាញ់ដែលដេកត្រាំនៅរឿយៗ ក្នុងសន្តាន និង **បដិឃានុស័យ** សេចក្តីក្រោធដែលដេកត្រាំនៅរឿយៗក្នុងសន្តាន រលត់អស់ចាកសន្តានមិនកើតឡើងទៀតឡើយ ។

លះនីវរណៈបាន ២ គឺ **កាមច្ឆន្ទនីវរណៈ** គ្រឿងរាំងរាគឺសេចក្តីស្រឡាញ់ពេញចិត្តក្នុងកាមគុណ និង **ព្យាបាទនីវរណៈ** គ្រឿងរាំងរាគឺសេចក្តីស្អប់ចេញអស់ មិនមកជាគ្រឿងរាំងទៀតឡើយ ។

លះ **ព្យាបាទកាយគន្ថៈ** គ្រឿងចងរឹតរបស់សេចក្តីក្រោធបានដាច់ខាត ។

លះ **កាមយោគៈ** ការប្រកបទុកក្នុងកាមបានដាច់ខាត ។

លះ **ភវោឃៈ** អន្ទង់គឺសេចក្តីស្រឡាញ់បានយ៉ាងដាច់ខាត ។

លះ **ភវាសវៈ** គ្រឿងតម្រាំគឺកាមបានយ៉ាងដាច់ខាត ។

ព្រះអនាគামី មិនត្រឡប់មកកាន់ផ្ទះសម្បែង គឺកាមភូមិទៀត មានសុទ្ធាវាសជាន់ព្រហ្មលោកជាទីទៅ ចែកជា ៥ ប្រភេទដូច្នេះ ៖

១- **អន្តរាបរិនិព្វាយី** សម្រេចព្រះអរហន្ត បរិនិព្វានក្នុងសុទ្ធាវាសកាលពាក់កណ្តាលអាយុដំបូង ។

២- **ឧបហច្ចបរិនិព្វាយី** សម្រេចព្រះអរហន្ត បរិនិព្វានក្នុងសុទ្ធាវាសកាលពាក់កណ្តាលអាយុក្រោយ ។

៣- **សសង្ខារបរិនិព្វាយី** សម្រេចព្រះអរហន្ត បរិនិព្វានដោយសេចក្តីព្យាយាមដុតកិលេសច្រើន ។

៤- **អសង្ខារបរិនិព្វាយី** សម្រេចព្រះអរហន្ត បរិនិព្វានដោយសេចក្តីព្យាយាមដុតកិលេសមិនច្រើនណាស់ ។

៥- **ឧទ្ធំសោតោអកនិដ្ឋគামី** សម្រេចព្រះអរហន្ត កាលចុតិបដិសន្ធិទៅលុះដល់អកនិដ្ឋភូមិ ។

ការបដិបត្តិឲ្យបានមកនូវព្រះអនាគামី ឧបមាដូចបុរសដែលបានពិចារណាឃើញសេចក្តីទុក្ខលំបាកជាទាស:របស់តណ្ហានិងទោស: ទើបសម្រេចផ្តាច់ចិត្តលះចាកគេហដ្ឋានស្រុក ភូមិ ទៅកាន់សំណាក់បព្វជិត ហើយបំពេញសមណធម៌ បានទទួលសេចក្តីស្ងប់ ហើយមិនត្រឡប់មកទៀតឡើយ ឧបមេយ្យដូចការចម្រើនវិបស្សនា លុះបានព្រះសោតាបន្ន និងសកទាគামីហើយ តែនៅមានសេចក្តីស្រឡាញ់ចូលចិត្តក្នុងកាម តមក

ឃើញភ័យក្នុងសេចក្តីស្រឡាញ់ សេចក្តីអាល័យ ទើបចម្រើនវិបស្សនា តទៅ លុះបានលុះអនាគាមិបុគ្គល បានព្រះនិញ្ចានជាអារម្មណ៍ដូច្នោះ ។

៧- **អរហត្តមគ្គញាណ** ញាណសេចក្តីដឹងដែលជាអង្គបញ្ញា-ចេតសិក ដែលប្រកបនឹងអរហត្តមគ្គចិត្ត បានព្រះនិញ្ចានជាអារម្មណ៍ កាលបច្ចវេក្ខណញាណរបស់ព្រះអនាគាមីពិចារណាមគ្គ ផល និញ្ចាន និងកិលេសដែលលះ ដែលសល់នៅ ប្រាថ្នានឹងធ្វើមគ្គ ផល ឲ្យដល់ទីបំផុត ទើបបានឈប់ចាកការពិចារណាមគ្គ ផល និញ្ចាន និងកិលេស ក្នុងវេលាដែលកំពុងអង្គុយនៅខ្ងះ ក្នុងវេលាដែលកន្ងទៅ ១ ថ្ងៃខ្ងះ ១ ខែខ្ងះ ១ ឆ្នាំខ្ងះ ក្នុងសុទ្ធាវាសជាន់ណាមួយខ្ងះ មកពិចារណារូបនាមដោយវិបស្សនា-ញាណ លុះកើតញាណដឹងរូបនាម សូម្បីរូបនាមនឹងល្អិតទន់ត្រឹមណាក្តី វិបស្សនាញាណនោះ នឹងមុតក្ងាអាចដែលនឹងឃើញបានជាក់ច្បាស់គ្រប់កាល គ្រប់ខណ: ដែលរូបនាមកើតរលត់ មាន **អនិច្ចលក្ខណ: ទុក្ខ-លក្ខណ:** និង **អនត្តលក្ខណ:** ជាប់នៅប្រាកដនៅ កន្ងឧទយព្ងយ-ញាណ ទៅលុះដល់សង្ខារុបេក្ខាញាណ ចាកសង្ខារុបេក្ខាញាណ ឡើងអនុលោមញាណ ធ្វើនាទីប្រហារកិលេស ដល់រៅទាន: បរិសុទ្ធសស្អាត បង្អោនទៅកាន់ព្រះនិញ្ចាន មិនមានអ្វីឃាំង អរហត្តមគ្គញាណក៏កើតភ្ងាម ឃើញព្រះនិញ្ចាន អស់អាសវកិលេសជាសមុច្ចេទប្រហារ ដូចជារន្ទះបាញ់ មកត្រូវវត្ថុធាតុ មានដើមឈើ និងផ្ទះសម្បែងជាដើម ដាច់បាត់ និង

ល្ងិតវិនាសទៅដូច្នោះ សូម្បីតែកំណើតពេជ្រ កំណើតដែក ដែលសែនរឹងមិនមានអ្វីប្រៀបប្រដូចបាន ក៏វិនាសខ្ទេចខ្ទីទៅ ដោយអំណាចគ្រាប់រន្ទះនោះ ក្នុងខណៈនោះកើតអរហត្តផលយ៉ាងរហ័ស ។

៨- **អរហត្តផលញាណ** ញាណសេចក្តីដឹង គឺតួបញ្ញាចេតសិកដែលប្រកបនឹងអរហត្តផលចិត្ត បានព្រះនិព្វានជាអារម្មណ៍ កាលអរហត្ត-មគ្គញាណកើតឡើងហើយ មិនមានចន្ទោះខណ្ឌ អរហត្តផលញាណក៏កើតឡើងភ្លាម មិនតម្រូវដល់កាលវេលា តែយ៉ាងណា អរហត្តផលញាណកើតឡើង ២ ឬ ៣ ខណៈ តាមកម្លាំងរបស់ **ទន្ធាភិញ្ញា** គឺដឹងយូរ និង **ទិប្បាភិញ្ញា** ដឹងរហ័ស បានព្រះនិព្វានជាអារម្មណ៍ ជាអរហន្តអរិយ-បុគ្គលទីណាស្រេច មានកិលេសតណ្ហាអស់ហើយ ជាតិនោះជាជាតិទីបំផុតរំលត់ខន្ធ ហើយនឹងចូលកាន់បរិនិព្វានជាបរមសុខ មិនចាប់កើត ចាស់ ឈឺ ស្លាប់ ទៀតតទៅ ។ កាលព្រះអរហន្តបុគ្គលបង្កើតឡើងហើយ បានព្រះនិព្វានជាអារម្មណ៍ ប្រហារកិលេសដែលសល់ចាកព្រះអរិយៈ ៣ ជំពូកខាងដើមប្រហារមិនបាន ក៏ប្រហារបានដាច់ខាត មិនមានសល់ទៀតតទៅ ខន្ធរបស់ព្រះអរហន្តដែលនៅមិនរលត់ ហៅថា **"វិសុទ្ធិខន្ធ"** មានខន្ធដ៏បរិសុទ្ធ ដូចប្រេងដែលត្រងហើយបានមួយរយដងដូច្នោះ អកុសលធម៌ទាំងឡាយដែលត្រូវប្រហារ កាលអរហត្តមគ្គញាណកើតឡើងនោះមានដូច្នេះ ៖

១- លះចិត្ត **លោភ** ដែលមិនប្រកបទៅដោយសេចក្តីយើញខុស ៤ ដួង និងចិត្តវង្វេងដែលប្រកបដោយសេចក្តីរាយមាយទៀត ១ ដួង បានដាច់ខាត ។

២- លះ **មោហបេតសិក** គឺសេចក្តីមិនដឹង លះ **អហិរិកបេតសិក** គឺសេចក្តីមិនខ្មាសចំពោះបាប លះ **អនោត្តប្បបេតសិក** សេចក្តីក្រែងខ្ជាចចំពោះបាប លះ **ឧទ្ធច្ចបេតសិក** ចេតសិកដែលរាយមាយ លះ **លោភបេតសិក** ចេតសិកដែលចង់បាន លះ **មានបេតសិក** ចេតសិកដែលកាន់ខ្ជួន និង **ថីនមិទ្ធ:** សេចក្តីងោកងក់ងងុយដេក ចេញបានដាច់ខាត មិនមានសល់ទៀត ។

៣- លះអកុសលកម្មបថដែលសល់ ២ គឺ **សម្ផប្បលាបាវាចា** និយាយចែប្រប្រែជ្រោកជ្រាក និង **អភិជ្ឈា** សេចក្តីសម្ងឹងរំពៃ (ចង់បាន) ចេញបានដាច់ខាត ។

៤- លះ **លោភកិលេស** **មោហកិលេស** **មានកិលេស** **ថីន-កិលេស** ដែលជាគ្រឿងសៅហ្មងចេញបានដាច់ខាត ។

៥- លះសំយោជន:បាន ៣ គឺ **ភវសំយោជន:** ចង់ទុកក្នុងភព **មានសំយោជន:** ចង់ទុកក្នុងមាន: **អវិជ្ជាសំយោជន:** ចង់ទុកក្នុងអវិជ្ជា បានអស់ដោយមិនសល់តាមអភិធម្ម ។ បើតាមន័យព្រះសូត្រ លះសំយោជន:បាន ៥ គឺ **រូបរាគ:** សេចក្តីចូលចិត្តក្នុងរូបជ្ឈាន **អរូបរាគ:**

សេចក្តីចូលចិត្តក្នុងអរូបជ្ឈាន **មានៈ** *សេចក្តីកាន់ខ្លួន* **ឧទ្ធច្ចៈ** *សេចក្តីរាយមាយ និង* **អវិជ្ជា** *សេចក្តីមិនដឹង ចេញបានអស់ មិនកើតក្នុងសន្តានរបស់ព្រះអរហន្តទៀត ។*

៦- លះអនុស័យបាន ៣ គឺ **មានានុស័យ** *មានៈដែលដេកនៅក្នុងកវង្គសន្តាន* **ភវានុស័យ** *សេចក្តីចូលចិត្តក្នុងភពដែលដេកនៅក្នុងសន្តាន* **អវិជ្ជានុស័យ** *សេចក្តីមិនដឹងដែលដេករឿយៗនៅក្នុងសន្តាន ។*

៧- លះនីវរណៈបាន ៣ គឺ **ឋីនមិទ្ធនីវរណៈ** *គ្រឿងរាំងគឺសេចក្តីងោកងក់ងុយដេក* **ឧទ្ធច្ចនីវរណៈ** *គ្រឿងរាំងគឺសេចក្តីរាយមាយ* **អវិជ្ជា-នីវរណៈ** *គ្រឿងរាំងគឺសេចក្តីមិនដឹង លះបានយ៉ាងដាច់ខាត មិនកើតក្នុងសន្តានព្រះអរហន្តទៀត ។*

៨- លះឧបាទានដែលសល់ ១ គឺ **កាមុបាទាន** *សេចក្តីប្រកាន់មាំកាន់ខ្ជាប់ក្នុងកាមគុណ ។*

៩- លះគន្ថៈដែលសល់ ១ គឺ **អភិជ្ឌាកាយគន្ថៈ** *គ្រឿងចងរឹតគឺសេចក្តីសម្ងឹងរំពៃចង់បាន ។*

១០- លះយោគៈដែលសល់ ២ គឺ **ភវយោគៈ** *ការប្រកបទុកក្នុងភព និង* **អវិជ្ជាយោគៈ** *ការប្រកបទុកក្នុងសេចក្តីមិនដឹង ។*

១១- លះឱឃៈដែលសល់ ២ គឺ **ភវោឃៈ** *អន្ទង់គឺភព* **អវិជ្ជោឃៈ** *អន្ទង់គឺអវិជ្ជា ។*

១២- លះអាសវៈដែលសល់ ២ គឺ **ភវាសវៈ** គ្រឿងត្រាំគឺកពនិង **អវិជ្ជាសវៈ** គ្រឿងត្រាំគឺអវិជ្ជាសេចក្តីមិនដឹង ។

សរុបហើយ ព្រះអរហន្តលះអកុសលធម៌បានទាំងអស់ លើកវៀរព្រះអរហន្តសាវ័ក លះវាសនាដែលធ្លាប់ប្រព្រឹត្តជាប់មកអំពីអតីតជាតិមិនបាន ចំណែកព្រះអរហន្តសម្មាសម្ពុទ្ធជាម្ចាស់ លះបានទាំងកិលេស និងវាសនាអស់ដើងរលីង កិលេសមិនមានហើយ សែនសុខសប្បាយមិនមានអ្វីនឹងប្រៀបបាន ព្រះអរហន្តទាំងឡាយក្នុងអតីតជាតិ បានសាងបារមីមកមិនដូចគ្នា ហេតុនោះទើបមានគុណពិសេសមិនដូចគ្នា ដែលចែកជា ៤ ប្រភេទគឺ ៖

១- **បដិសម្ភិទាបត្ត:** ព្រះអរហន្តសម្រេចព្រមដោយបដិសម្ភិទា ៤

២- **ឆឡាភិញ្ញា** ព្រះអរហន្តសម្រេចព្រមដោយអភិញ្ញា ៦

៣- **តេវិជ្ជា** ព្រះអរហន្តសម្រេចព្រមដោយវិជ្ជា ៣

៤- **សុក្ខវិបស្សក:** ព្រះអរហន្តសម្រេចព្រមដោយវិបស្សនាញាណសុទ្ធសុទ្ធ ។

ញាណក្នុងលោកុត្តរៈទាំង ៨ ញាណនេះ កើតឡើងតជាប់ចាកញាណលោកិយទាំងអស់ កាលរួមចូលគ្នាហើយបាន ២ គឺ **មគ្គញាណ** និង **ផលញាណ** រួមទាំងញាណលោកិយទៀត ១៤ ជាញាណ ១៦ ញាណទាំង ១៦ នេះ រមែងជាបច្ច័យបញ្ជូនតៗគ្នាទៅ គឺញាណទី១

បញ្ជូនឲ្យញ្ញាណទី២, ញ្ញាណទី២ បញ្ជូនឲ្យញ្ញាណទី៣, ញ្ញាណទី៣ បញ្ជូនឲ្យញ្ញាណទី៤, ញ្ញាណទី៤ បញ្ជូនឲ្យញ្ញាណទី៥, ញ្ញាណទី៥ បញ្ជូនឲ្យញ្ញាណទី៦, ញ្ញាណទី៦ បញ្ជូនឲ្យញ្ញាណទី៧, ញ្ញាណទី៧ បញ្ជូនឲ្យញ្ញាណទី៨, ញ្ញាណទី៨ បញ្ជូនឲ្យញ្ញាណទី៩, ញ្ញាណទី៩ បញ្ជូនឲ្យញ្ញាណទី១០, ញ្ញាណទី១០ បញ្ជូនឲ្យញ្ញាណទី១១, ញ្ញាណទី១១ បញ្ជូនឲ្យញ្ញាណទី១២, ញ្ញាណទី១២ បញ្ជូនឲ្យញ្ញាណទី១៣, ញ្ញាណទី ១៣ បញ្ជូនឲ្យញ្ញាណទី១៤, ញ្ញាណទី១៤ បញ្ជូនឲ្យញ្ញាណទី១៥, ញ្ញាណទី១៥ បញ្ជូនឲ្យញ្ញាណទី១៦, ដែលអាស្រ័យវិបស្សនាញ្ញាណ ជាមូលដ្ឋាន ដូចនឹងលើកឧសេចក្តីឧបមាជាបុគ្គលាធិដ្ឋានដូចតទៅនេះ ៖

នៅមានបុរសម្នាស់ផ្ទះម្នាក់ ទទួលទានអាហារក្នុងវេលាល្ងាច ហើយ ក៏ឡើងកាន់ដំណេក ដេកលក់ទៅ ក្នុងយប់នោះកើតភ្លើងឆេះឡើងក្នុងផ្ទះ ជាច្រើន បង្ហើលបុរសនោះភ្ញាក់ឡើង ឃើញភ្លើងឆេះផ្ទះកំពុងឆេះរុង រោចន៍ជោតនា ក៏សុតរន្ធត់ចិត្តរំពឹងថា "អនិច្ចាអើយ! ខ្ញុំនេះនៅកណ្តាល ភ្លើងតែម្តង ហើយក៏នឹងស្លាប់ក្នុងភ្លើងទៀតទេ ធ្វើម្តេច ខ្ញុំទើបនឹង ចេញផុតអំពីភ្លើងទៅបាន ផ្លូវណាហ្ន៏?" តម្រិះដូច្នេះហើយ បុរសនោះ ក៏ក្រោកចេញអំពីកន្ទែង ហើយក៏ប្រញាប់ស្ទុះចេញមកដោយរហ័ស លុះ ផុតភ្លើងឆេះហើយ បុរសនោះ ក៏ឈរនៅក្នុងទីដែលភ្លើងឆេះមិនដល់ ដូច្នេះឯង នេះមានឧបមាដូចម្តេច ឧបមេយ្យដូចព្រះយោគាវចរអ្នកចម្រើន

វិបស្សនាទៅតាមលំដាប់ញាណ ១៦ គឺ ៖

ខណៈម្ចាស់ផ្ទះដេកនៅក្នុងផ្ទះ ប្រៀបបាននឹងអ្នកគ្រប់គ្រងរូបនាម ។

ខណៈកាលម្ចាស់ផ្ទះ បរិភោគអាហារហើយដេកក្នុងកណ្តាលយប់ ប្រៀបដូចអ្នកបដិបត្តិវិបស្សនាទន់ (ខ្វៃ) គឺនៅមាន ៖

ញាណទី១- ឃើញរូបនាម ដូចកំពុងដេក លុះកន្ទងទៅដល់ ញាណទី ២ ។

ញាណទី២- ឃើញបច្ច័យរបស់រូបនាម ដូចជិតនឹងភ្ញាក់ លុះកន្ទង ទៅដល់ញាណ ទី៣ ។

ញាណទី៣- ឃើញលក្ខណៈរបស់រូបនាម ដូចបុរសដែលភ្ញាក់ឡើង ឃើញពន្ធឺភ្លើង ។

ញាណទី៤- ឃើញរូបនាមកើតរលត់ ដូចឃើញភ្លើងកំពុងឆេះ ។

ញាណទី៥- ឃើញរូបនាមរលត់ទៅៗ ដូចឃើញភ្លើងឆេះរាល ជិតមក ។

ញាណទី៦- ឃើញរូបនាមជាភ័យ ដូចឃើញភ្លើងនោះនឹងឆេះ ខ្លួនគួរខ្ជាប ។

ញាណទី៧- ឃើញរូបនាមជាទោស ដូចឃើញភ្លើងនោះជាទោស យ៉ាងកាចសាហាវ ។

ញាណទី៨- ឃើញរូបនាមគួរនឿយណាយ ដូចនឿយណាយ

ចំពោះក្លឹងនោះ ។

ញាណទី៩- ឃើញរូបនាមប្រាជ្ញានឹងរត់ ដូចប្រាជ្ញារកផ្លូវរត់អំពីក្លឹងនោះ ។

ញាណទី១០- ឃើញរូបនាមរកផ្លូវរត់ ដូចរកផ្លូវរត់អំពីក្លឹង ។

ញាណទី១១- ឃើញរូបនាមរត់មិនផុត មើលព្រងើយនៅដូចមើលក្លឹងរំពឹងនៅ ។

ញាណទី១២- ឃើញរូបនាមមានកម្លាំងច្បាស់ឡើង ដូចឃើញក្លឹងជិតចូលមក ។

ញាណទី១៣- ឃើញផ្លូវទៅព្រះនិញ្ជាន ដូចឃើញផ្លូវចេញចាកក្លឹង ។

ញាណទី ១៤- ឃើញព្រះនិញ្ជាន ដូចកំពុងរត់ចេញចាកក្លឹង ។

ញាណទី១៥- ឃើញព្រះនិញ្ជាន ដូចផុតក្លឹងហើយ ។

ញាណទី១៦- ពិចារណាមគ្គ ផល និញ្ជាន និងកិលេសដែលលះហើយ ឬដែលនៅសល់ ដូចបុរសនោះ មកឈរមើលក្លឹង ដឹងថាខ្លួនផុតហើយដូច្នោះ ។

ញាណទាំង ១៦ នេះ រមែងជាបច្ច័យដល់គ្នានិងគ្នា ញាណខ្លះក៏កើតក្នុងវិថីចិត្តជាមួយគ្នាក៏មាន ជាបច្ច័យដល់បដិវេធធម៌គឺ មគ្គ ផល និញ្ជាននោះឯង ។

លោកុត្តរអារម្មណ៍

អារម្មណ៍ក្នុងលោកុត្តរ: មាននៅមួយយ៉ាងគឺ ព្រះនិញ្ចានជាអារម្មណ៍ របស់មគ្គចិត្ត ៤ និងផលចិត្ត ៤ ដែលលោកុត្តរចិត្ត ជាអ្នកចាប់យកព្រះនិញ្ចានជាអារម្មណ៍ និញ្ចាននោះស្ថិតនៅទុកឲ្យមគ្គចិត្ត ផលចិត្តដឹង ស្ថិតនៅទុកឲ្យមគ្គចិត្ត ផលចិត្តនោះឃើញ ស្ថិតនៅទុកឲ្យមគ្គចិត្ត ផលចិត្តនោះបានលុះ កាលចិត្ត ៨ ដួងនេះ ចាប់យកព្រះនិញ្ចានជាអារម្មណ៍ហើយកាលណា កាលនោះឈ្មោះថាបានអារម្មណ៍ជាអធិបតី ចោលអារម្មណ៍របស់លោកនេះភ្ជាម ប្រមូលធន្ទ:សេចក្តីពេញចិត្តក្នុងព្រះនិញ្ចានក្រៃពេក និញ្ចាននោះអស់កិលេស កិលេសមិនមានហើយ នឹងកាត់តម្លៃថាសឃ្យាយ មិនមានអ្វីប្រៀប បើនឹងកាត់តម្លៃថាទំនេរ ថាទទេ ក៏មិនមានអ្វីទំនេរ មិនមានអ្វីទទេ ដូចព្រះនិញ្ចាន បើនឹងតាំងនាមព្រះនិញ្ចាននេះទៅក្នុងជ្រុងជ្រោយផ្សេងៗហើយ ល្អគ្រប់ជ្រុងជ្រោយឥតមានកន្ទែងប្រៀបបាន និញ្ចាននោះជា **អសង្ខូត:** មិនកើត មិនចាស់ មិនឈឺ មិនស្ជាប់ រិលវល់ទៀតតទៅ **និញ្ចានំ បរមំ សុខំ** ព្រះនិញ្ចានជាសន្តិសុខយ៉ាងក្រៃពេក មិនមានសុខដទៃលាយឡំ **អជាតំ** ព្រះនិញ្ចានមិនកើតទៀត **អជរំ** ព្រះនិញ្ចានមិនចូលដល់សេចក្តីចាស់គ្រាំគ្រាជរា **អមរណំ** ព្រះនិញ្ចានមិនស្ជាប់ទៀតតទៅ ជាបរមសុខដ៏ក្រៃលែង ជាទីបាន ជាទីដល់ ទីបានលុះ របស់ព្រះអរិយ:ម្ចាស់ទាំងឡាយ ព្រះអរិយ:ទាំងឡាយ បណ្តាដែលបានលុះ

ព្រះនិញ្ជានហើយ នៅមានច្រើនជាងគ្រាប់ខ្សាច់ក្នុងផ្ទៃមហាសមុទ្រទាំង ៤ ព្រះនិញ្ជាននោះ មិនចេះចង្អៀតណែន ទើសទាស់ ប្រជ្រៀតគ្នា តែយ៉ាងណា ព្រះអរិយៈច្រើនដល់ប៉ុណ្ណោះក៏ពិត ព្រះនិញ្ជាននេះជា **មហាសន្តិសុខោ** មានសេចក្តីសុខធំហៀរហូរ ជា **ឯកន្តបរមសុខ** ពិតប្រាកដលើសជាងសុខដទៃទាំងអស់ ។

ព្រះនិញ្ជាននោះ រលត់ទាំងកិលេស និងបញ្ចក្ខន្ធ ជា **សន្តិលក្ខណៈ** មួយយ៉ាង លោកលោកិយនេះរលត់អស់ អ្នកមិនទាន់បាន មិនដល់ មិនបានលុះ មិនអាចនឹងដឹងបានឡើយ គិតយក ដោយក អនុមានយក មិនបានទាំងអស់ អ្នកបានលុះហើយ អ្នកដល់ហើយ ទើបមិនប្រាប់ដល់អ្នកណាទាំងអស់ ក្រៅអំពីសម្តែងទៅតាមធម៌ពាក្យប្រៀនប្រដៅរបស់ព្រះបរមសាស្តាប៉ុណ្ណោះ ។

ព្រះនិញ្ជានមិនមែនរូប មិនមែនសំឡេង មិនមែនក្លិន មិនមែនរស មិនមែនត្រជាក់ មិនមែនក្តៅ មិនមែនទន់ មិនមែនរឹង ដែលមាននៅក្នុងលោកទាំង ៣ ។

ព្រះនិញ្ជានមិនមែនភ្នែក មិនមែនត្រចៀក មិនមែនច្រមុះ មិនមែនអណ្តាត មិនមែនកាយ មិនមែនចិត្ត ។

ព្រះនិញ្ជានមិនមែនសុខកាយសប្បាយចិត្ត មិនមែនទុក្ខ មិនមែនព្រងើយៗ ។

ព្រះនិញ្ជានមិនមែនសេចក្ដីចាំ មិនមែនសេចក្ដីស្រឡាញ់ មិនមែនសេចក្ដីស្អប់ ។

ព្រះនិញ្ជានមិនមែនចិត្ត មិនមែនចេតសិក មិនមែនរូប ។

ព្រះនិញ្ជានមិនមែនវិញ្ញាណ មិនមែនមនោ មិនមែនមនោធាតុ មិនមែនមនោវិញ្ញាណធាតុ ។

ព្រះនិញ្ជានមិនមែនអាកាស មិនមែនប្រហោងចន្ទោះ ។

ព្រះនិញ្ជានមិនមែនដី មិនមែនទឹក ភ្លើង ខ្យល់ ។

ព្រះនិញ្ជានមិនមែនលោកនេះ មិនមែនលោកដទៃ ។

ព្រះនិញ្ជានមិនមែនដួងអាទិត្យ មិនមែនដួងចន្ទ មិនមែនផ្កាយផ្សេងៗ ។

ព្រះនិញ្ជានមិនមានអារម្មណ៍ មិនទៅដល់ មិនមកដល់ មិនតាំងនៅ មិនចុះ មិនកើត ។

ព្រះនិញ្ជានជា **ធម្មារម្មណ៍** ជា **ធម្មាយតន:** ។

សេចក្ដីរលត់បញ្ចក្ខន្ធហើយ មិនកើតទៀត ដូចភ្លើងរលត់អស់ទាំងដួងភ្លើង និងពន្ធឹ មិនកើតដូច្នោះ នោះឯងជា **និញ្ជានធាតុ** ។

និញ្ជានធាតុគោះមាន ២ យ៉ាងគឺ

១- **សឧបាទិសេសនិញ្ជាន** និញ្ជាននៅមាន **ឧបាទិ** គឺ ខន្ធ ៥ សល់នៅ សម្គាល់ដល់ព្រះអរហន្ត មានអាសវ:អស់ហើយ មានករណីយកិច្ច

ដែលធ្វើស្រេចហើយ មានការៈដាក់ចុះហើយ មានប្រយោជន៍យ៉ាងល្អ ជាអ្នកតាមបានលុះហើយ មានគ្រឿងប្រកបទុកក្នុងកពអស់រលីងហើយ ដ៏ងប្រពៃហើយទើបរួចផុត ឥន្ទ្រីយ៍ ៥ នៅ តាំងនៅ ព្រោះឥន្ទ្រីយ៍មាន នៅ រមែងសោយអារម្មណ៍ដែលគួរពេញចិត្តខ្លះ មិនគួរពេញចិត្តខ្លះ សោយសុខខ្លះ ទុក្ខខ្លះ សេចក្តីអស់រាគៈ សេចក្តីអស់ទោសៈ សេចក្តីអស់មោហៈនៃព្រះអរហន្ត មិនកើតក្នុងសន្ធានទៀតនោះ ឈ្មោះថា **សឧបាទិសេសនិព្វានធាតុ** ។

២- **អនុបាទិសេសនិព្វានធាតុ** និព្វានធាតុដែលមិនមាន **ឧបាទិ** គឺខន្ធ ៥ សល់នៅ សម្គាល់ដល់សេចក្តីរលត់ខន្ធរបស់ព្រះអរហន្ត អ្នកអស់អាសវៈហើយ ចប់កិច្ចក្នុងសាសនាហើយ ដាក់ការៈចេញហើយ កពអស់ហើយ ដ៏ងប្រពៃហើយ រួចផុតហើយ ការសោយអារម្មណ៍របស់លោកមិនភ្ជីតភ្ជីនហើយក្នុងលោកនេះ មិនកើតទៀត ជាធាតុនិព្វាន ឈ្មោះថា **អនុបាទិសេសនិព្វានធាតុ** ។

ព្រះនិព្វាននេះ មានសភាវៈតែមួយ គឺសេចក្តីរលត់ទុក្ខក៏ពិត តែផ្សេងប្រភេទដោយការចូលទៅដ៏ង ចូលទៅឃើញ ចូលទៅបានលុះ ដោយអាការដូចតទៅនេះគឺ ៖

១- **អនិមិត្តនិព្វាន** និព្វានរលត់រូបនាម មិនមាននិមិត្ត គ្រឿងសម្គាល់អាស្រ័យចម្រើនវិបស្សនា លើករូបនាមឡើងកាន់ **អនិច្ចលក្ខណៈ**

លុះឃើញរូបនាមកើតរលត់ជា **អនិច្ចានុបស្សនា** ឃើញមិនទៀងជានិច្ច កន្ទងញាណ ១៦ ដល់ព្រះនិញ្ជាន ផុតដោយអនិមិត្តវិមោក្ខ ហៅថា **អនិមិត្តនិញ្ជាន** បើចូលផលសមាបត្តិ ក៏សម្ធឹងអនិច្ចានុបស្សនា និងចូលដោយអនិមិត្តនិញ្ជាន គឺសេចក្តីរលត់រូបនាម មិនមាននិមិត្តគ្រឿងសម្គាល់ ហៅថាតាំងនៅក្នុង ***អនិមិត្តានុបស្សនា*** ឃើញសេចក្តីរលត់មិនមាននិមិត្ត ជាទីតាំងលុះដំនាញ ។

២- **អប្បណិហិតនិញ្ជាន** និញ្ជានរលត់រូបនាម ឥតរាគៈ ទោសៈ មោហៈឡើយ ព្រោះបានបដិបត្តិវិបស្សនា លើករូបនាមឡើងកាន់ **ទុក្ខលក្ខណៈ** លុះឃើញរូបនាមកើតរលត់ ធន់នៅមិនបាន ជា **ទុក្ខ-នុបស្សនា** ឃើញជាទុក្ខធន់បានក្រជានិច្ច កន្ទងញាណ ១៦ បានព្រះនិញ្ជាន ជាអារម្មណ៍ ផុតដោយអប្បណិហិតវិមោក្ខ ហៅថា **អប្បណិហិតនិញ្ជាន** បើនឹងចូលផលសមាបត្តិ ក៏សម្ធឹងទុក្ខានុបស្សនា នឹងចូលដោយអប្បណិ-ហិតនិញ្ជាន សេចក្តីរលត់រូបនាម ឥតរាគៈ ទោសៈ មោហៈ ជាឧបាទិ ឡើយ ហៅថា **អប្បណិហិតានុបស្សនា** ឃើញសេចក្តីរលត់រាគៈ ទោសៈ មោហៈ មិនបានជាទីតាំងជានិច្ច លុះដំនាញ ។

៣- **សុញ្ញតនិញ្ជាន** និញ្ជានរលត់រូបនាម ទំនេរចាករាគៈ ទោសៈ មោហៈ ព្រោះបានបដិបត្តិវិបស្សនា លើករូបនាមឡើងកាន់ **អនត្ត-លក្ខណៈ** លុះឃើញរូបនាមកើតរលត់ បង្ក្រាប់បញ្ជាមិនបាន ជា **អនត្ត-**

នុបស្សនា ឃើញអនត្តាជានិច្ច កន្ទង់ញាណ ១៦ បានព្រះនិព្វានជាអារម្មណ៍ ផុតដោយសុញ្ញតវិមោក្ខ ហៅថា **សុញ្ញតនិព្វាន** បើនឹងចូលផលសមាបត្តិ ក៏សម្ល័ងអនត្តានុបស្សនា នឹងចូលដោយសុញ្ញតនិព្វាន សេចក្តីរលត់រូបនាម ទំនេរចាករាគៈ ទោសៈ មោហៈ ហៅថា **សុញ្ញតានុបស្សនា** ឃើញសេចក្តីរលត់ ទំនេរចាករាគៈ ទោសៈ មោហៈ បង្វឹកទៅជានិច្ច ទាល់តែស្ទាត់ជំនាញ ។

លក្ខណៈ របស់និព្វាន គឺ ស្ងប់

រស របស់និព្វាន គឺ មិនច្យុត

គ្រឿងប្រាកដ របស់និព្វាន គឺ មិនមាននិមិត្ត

ព្រះនិព្វានជាសុខយ៉ាងក្រៃលែង

សេចក្តីសុខក្រៅចាកព្រះនិព្វាន មិនមាន ។

សមាបត្តិ

ការចូលនៅក្នុងឈាន ឬការចូលនៅក្នុងផល ឬការចូលនៅក្នុងនិរោធ ហៅថា **សមាបត្តិ** ឧបមាដូចអ្នកគេចវេះកម្តៅក្នុងរដូវក្តៅ ចូលទៅនៅក្នុងផ្ទះដែលខ្លួនបានសាងទុកហើយ ប្រោះព្រំដោយសេចក្តីត្រជាក់ដូច្នោះ បានចែកសមាបត្តិចេញជា ៣ ប្រភេទ ដូចនឹងបានអធិប្បាយតាមលំដាប់គឺ ៖

១- **ឈានសមាបត្តិ** ចូលនៅក្នុងឈាន អ្នកចូលសមាបត្តិត្រូវជា

អ្នកដែលបានធ្វើសមថកម្មដ្ឋាន មានបញ្ញត្តិជាអារម្មណ៍ និងបានឈាន តាំងអំពីបឋមជ្ឈានឡើងទៅ លុះដល់បញ្ចមជ្ឈាន ក្នុងកម្មដ្ឋាន ៤០ ដែលអាចជាឈានបានគឺ ៖

កសិណ ១០	ធ្វើដល់បញ្ចមជ្ឈានបាន
អានាបាណសតិ	ធ្វើដល់បញ្ចមជ្ឈានបាន
ឧបេក្ខាអប្បមញ្ញា	ធ្វើបានចំពោះបញ្ចមជ្ឈាន
អរូប ៤	ធ្វើដល់អរូបជ្ឈាន (បញ្ចមជ្ឈាន)
មេត្តា ករុណា មុទុតា អប្បមញ្ញា ៣	ធ្វើបានត្រឹមចតុត្ថជ្ឈាន
អសុភ ១០	ធ្វើបានត្រឹមបឋមជ្ឈាន
កាយគតាសតិ	ធ្វើបានត្រឹមបឋមជ្ឈាន

ក្នុងកម្មដ្ឋាន ៤០ ធ្វើឈានបាន ៣០ ក្រៅនោះទៀត ១០ កម្មដ្ឋានមិនអាចនឹងឲ្យដល់ឈានបាន ធ្វើបានត្រឹមឧបចារសមាធិ បានឧគ្គហនិមិត្ត ធ្វើឲ្យចិត្តស្ងប់បានមួយឧណ: មួយគ្រាប៉ុណ្ណោះ កាលវេលានឹងចូលឈាន-សមាបត្តិ ដោយមកគិតឃើញសេចក្តីទុក្ខលំបាក ដែលនឹងត្រូវទទួលដឹងបរិត្តារម្មណ៍ អារម្មណ៍តិចតួច ស្ងឹមហគ្គតារម្មណ៍ អារម្មណ៍យូរក្នុងឈានមិនបាន ទើបនាំយកកម្មដ្ឋានណាមួយ លុះកើតឧគ្គហនិមិត្តជាប់ភ្នែក ធ្វើទាល់តែជាបដិភាគនិមិត្ត ធ្វើឲ្យ ធំ-តូចជាចំណែកៗបាន ដល់ ឧបចារ-សមាធិ ជិតភាពជាឈាន សម្ងឹងទៅដល់អប្បនាសមាធិ នឹងនក្នុង

អារម្មណ៍កម្មដ្ឋាន មានអង្គ្គឈានចូលប្រកប ហាមឃាត់នីវរណៈចេញ បាន ប្រព្រឹត្តទៅតាមឈានជវនវិថី គឺបរិកម្មហើយឡើងអនុលោម ចាក អនុលោមក៏ដល់គោត្រភូ ធ្ងន់គោត្រកាមដល់ឈាន កាលដល់ឈាន នឹងនៅក្នុងអារម្មណ៍កម្មដ្ឋាន គួយ៉ាងដូចការកំណត់ ខ្យល់ដង្ហើមចូល ចេញ ដោយមិនបានលើកឡើងកាន់ព្រះត្រៃលក្ខណៈ សម្ងឹងស្ងៀម នៅដូច្នោះ ទាំងខ្យល់ដង្ហើមចូល និងចេញ រលត់ចាកអារម្មណ៍ទាំងពួង សំឡេងក៏មិនបានឮ ត្រចៀកក៏មិនបានឃើញ ច្រមុះក៏មិនបានក្លិន កាយ ក៏មិនដឹងសម្ផស្ស មិនមានងងុយ ភ្ញេចចាកអារម្មណ៍ទាំងពួងចេញអស់ មានតែផ្ទៃតចិត្ត សុខចិត្ត នឹងនស្ងៀមនៅក្នុងអានាបាណសតិប៉ុណ្ណោះ ការសម្ងឹងនៅដូច្នេះ ដោយមិនព្រមលែងអារម្មណ៍ឡើយ ឈ្មោះថា **ឈានសមាបត្តិ** ចូលនៅក្នុងឈានសុខ ជាសន្តិសុខក្នុងលោកនេះ ។

២- **ផលសមាបត្តិ** ក៏អាការចូលនៅក្នុងអារម្មណ៍ព្រះនិព្វាន ដែលបានមកចាកអរិយផលញ្ញាណបង្កើតឡើងហើយ បុគ្គលដែលចូល ផលសមាបត្តិបាននោះគឺ ព្រះអរិយបុគ្គល បានដល់ព្រះសោតាបន្ន ព្រះ សកទាគামី ព្រះអនាគামី និងព្រះអរហន្ត លើកវៀរបុថុជ្ជនទាំងពួង និងការចូលផលសមាបត្តិ ព្រះអរិយៈចូលបានចំពោះអរិយផលដែលខ្លួន បានដល់ប៉ុណ្ណោះ កាលផុតមកហើយ ក៏មិនអាចនឹងចូលបាន គឺព្រះ អរហន្តនឹងទៅចូលផលសមាបត្តិរបស់ព្រះអនាគামីមិនបាន ព្រះអនាគামី

នឹងចូលផលសមាបត្តិរបស់ព្រះសកទាគামីមិនបាន ព្រះសកទាគামីនឹងចូលផលសមាបត្តិរបស់ព្រះសោតាបន្នក៏មិនបាន ព្រះអនាគামីនឹងចូលផលសមាបត្តិរបស់ព្រះអរហន្តក៏មិនបាន ផលសមាបត្តិរបស់ព្រះអរិយ-បុគ្គលណា ក៏ចូលបានចំពោះផលសមាបត្តិរបស់ព្រះអរិយបុគ្គលនោះ ។

ព្រះអរិយបុគ្គលដែលចូលផលសមាបត្តិ ក៏ព្រោះឃើញប្រយោជន៍ក្នុងសេចក្តីស្ងប់សុខរបស់ផលសមាបត្តិ ដែលឃើញប្រាកដក្នុងបច្ចុប្បន្ន ឧបមាដូចព្រះមហាក្សត្រ សោយសេចក្តីសុខនៅក្នុងរាជ្យសម្បត្តិ ឬទេវតាដែលសោយសេចក្តីសុខក្សេមក្សាន្តក្នុងទិព្វសម្បត្តិដូចម្តេចក្តី ឧបមេយ្យដូចព្រះអរិយបុគ្គលទាំងឡាយ កំណត់វេលាដោយមនសិការៈថា នឹងសោយនូវលោកុត្តរសុខ ហើយចូលកាន់ផលសមាបត្តិដូច្នោះ ។

ក្នុងវេលាចូលកាន់ផលសមាបត្តិ មានមនសិការៈក្នុងអារម្មណ៍ព្រះនិព្វានមួយយ៉ាង មិនទទួលដឹងអារម្មណ៍ដទៃទាំងអស់ បានបដិបត្តិទៅតាមលំដាប់ដូច្នេះ ៖

កាលព្រះអរិយបុគ្គលអ្នកប្រាថ្នាប្រយោជន៍ដោយការចូលផលសមា-បត្តិគប្បីចូលកាន់ទីរហោស្ថាន ជាទីគួរដល់កាយវិវេក មានចិត្តចេញចាកអារម្មណ៍ផ្សេងៗ ពួននៅក្នុងព្រះកម្មដ្ឋាន ពិចារណារូបនាមដោយលើកឡើងកាន់ព្រះត្រៃលក្ខណៈ លុះកើតវិបស្សនាញាណ តាំងអំពីឧទយព្វយញាណ ឃើញរូបនាមកើតរលត់ជាដើម លុះដល់អនុលោម-

ញាណ ហើយឡើងវៅទាន: រលត់ចាកអារម្មណ៍លោកិយដល់ផលញាណ បានព្រះនិញ្ចានជាអារម្មណ៍ ហើយចូលកាន់ក្នុងអារម្មណ៍ព្រះនិញ្ចានដែល ប្រាកដដល់ផលញាណនោះជាប់តទៅ តាមកំណត់វេលាដែលតាំងទុក ។ កាលព្រះសេខបុគ្គល មានព្រះសោតាបន្នជាដើម ពិចារណារូបនាម លុះកើតខទយព្វយញាណជាដើម ដូចសម្តែងមកហើយ លុះដល់ផលចិត្ត កើតនោះ ជាអប្បនាសមាធិ នឹងបង្កើតមគ្គចិត្តមិនបាន ព្រោះហេតុថា អធ្យាស្រ័យបង្អោនទៅផលសមាបត្តិ ជា **ទិដ្ឋធម្មសុខវិហារ** នៅក្នុងធម៌ ដែលស្ងប់សុខ ដែលនៅនឹងបច្ចុប្បន្នជាតិនេះដោយពិត ព្រះនិញ្ចានដែល ជាអារម្មណ៍របស់ផលចិត្តជាប់តមក ។

ប្រការមួយ ព្រះអរិយ:ទាំងពួង កាលដំបូងបានព្រះអរិយមគ្ត មាន ព្រះសោតាបត្តិមគ្គជាដើម តាំងនៅក្នុងបឋមជ្ឈាន ប្រកបដោយវិតក្ក: វិចារ: បីតិ សុខ ឯកគ្គតា អរិយផលដែលតជាប់មកក្នុងមគ្គវិបី ក៏ជាបឋមជ្ឈាន ផង និងការចូលផលសមាបត្តិ ក៏បានតាំងនៅក្នុងផលញាណ មានព្រះ និញ្ចានជាអារម្មណ៍ ជាបឋមជ្ឈានជាមួយគ្នា បើថាអរិយមគ្គដែលបាន នោះ ប្រកបដោយទុតិយជ្ឈាន តតិយជ្ឈាន ចតុត្ថជ្ឈាន ឬបញ្ចមជ្ឈាន ណាមួយ កាលចូលកាន់ផលសមាបត្តិ ក៏ចូលដោយឈាននោះ ។

សភាវ:ដែលតាំងនៅក្នុងផលសមាបត្តិ គឺយកចិត្តទុកជាក់ក្នុងនិមិត្ត

ទាំងពួង បានតែព្រះនិញ្ជានជាអារម្មណ៍នោះ តាំងនៅដោយគោល ៣ ប្រការគឺ

១- មិនយករូបនាម ១ន្ធ ៥ ជាអារម្មណ៍ ។

២- កំណត់វេលាចូល និងកំណត់វេលាចេញ ។

៣- កាលនៅមិនអស់វេលាដែលកំណត់ទុក ក៏តាំងនៅក្នុងផលសមាបត្តិលុះត្រាតែអស់វេលា ។

កាលវេលានឹងចេញចាកផលសមាបត្តិ ក៏បានអារម្មណ៍និមិត្តរូបនាមណាមួយ មានកម្មនិមិត្តជាដើម ដែលជាអារម្មណ៍នៃភវង្គចិត្ត ដែលជាប់ព័ន្ធមកអំពីបដិសន្ធិជាដំបូង ក្នុងបច្ចុប្បន្នភពនោះ ដោយលះចាកអារម្មណ៍ព្រះនិញ្ជានដូច្នេះ ។

ផលចិត្តនេះ កើតក្នុងលំដាប់នៃផលក៏មាន ជួនកាលភវង្គចិត្តកើតក្នុងលំដាប់នៃផលក៏មាន ជួនកាលផលនោះកើតក្នុងលំដាប់នៃមគ្គក៏មាន ជួនកាលផលបង្កើតក្នុងលំដាប់នៃគោត្រភូក៏មាន ជួនកាលផលបង្កើតក្នុងលំដាប់នៃនេវសញ្ញានាសញ្ញាយតនៈក៏មាន ផលដ៏លើសដែលបង្កើតតចាកមគ្គនោះ បានចំពោះក្នុងមគ្គវិថី ២-៣ ១ណៈ ផលដួងដំបូងកើតក្នុងលំដាប់នៃមគ្គ ផលក្នុងដួងក្រោយៗ កើតក្នុងលំដាប់នៃផលដួងមុនក្នុងផលសមាបត្តិវិថីនោះ ផលដួងដំបូងនោះ ក៏កើតក្នុងលំដាប់នៃគោត្រភូដែលជាអន្តរបច្ច័យមកចាកអនុលោមចិត្ត អនុលោមចិត្តនៃព្រះអរហន្ត ជា

អនន្តរបច្ច័យដល់ផលសមាបត្តិរបស់ព្រះអរហន្ត អនុលោមចិត្តនៃព្រះសេខបុគ្គល ក៏ជាអនន្តរបច្ច័យ ដល់ផលសមាបត្តិរបស់ព្រះសេខបុគ្គលអ្នកនៅក្នុងផលសមាបត្តិ មានសេចក្តីសុខស្ងប់ដោយចំណែកមួយ ជាឯកន្តបរមសុខពិតប្រាកដ ។

៣- **និរោធសមាបត្តិ** គឺការចូលនៅក្នុងសេចក្តីរលត់ចិត្ត និងរលត់ចេតសិក សម្គាល់ដល់ការចូលឈានតាមលំដាប់ តាំងអំពីបឋមជ្ឈានឡើងទៅ លុះដល់នេវសញ្ញានាសញ្ញាយតនៈ ហើយក៏ចូលនិរោធ-សមាបត្តិតទៅបណ្តោយ រំលត់សេចក្តីដឹងទាំងអស់ នៅបានរហូត ៧ ថ្ងៃ មិនជាអន្តរាយ តែយ៉ាងណា នៅបានដោយអំណាចរបស់និរោធសមាបត្តិ មានឱជានៃអាហារឃុំគ្រងទុក កាលគ្រប់ ៧ ថ្ងៃ ក៏នឹងកើតចិត្តចេតសិកឡើងមក មានសេចក្តីដឹង មានកម្លាំងឡើង ។

បុគ្គលដែលនឹងចូលនិរោធសមាបត្តិបាន ចំពោះព្រះអនាគামី និងព្រះអរហន្ត ដែលបានសមាបត្តិ ៨ ប៉ុណ្ណោះ ក្រៅនោះចូលមិនបាន បានដល់បុគ្គលដែលជាបុថុជ្ជនទាំងពួង ព្រះសោតាបន្នបុគ្គលទាំងពួង ព្រះសកទាគামិបុគ្គលទាំងពួង សូម្បីថានឹងបានសមាបត្តិ ៨ ក៏មិនអាចចូលនិរោធសមាបត្តិបាន ព្រោះនៅមិនជា **បរិបូរណការី** បរិបូរដោយសមាធិ លះបង់នូវកាមច្ឆន្ទៈជាដើម ជាសមុច្ឆេទប្រហារដាច់ខាត ។

មួយព្រះអនាគামិបុគ្គល ដែលជាសុក្ខវិបស្សកៈក្តី ព្រះអរហន្តបុគ្គល

ដែលជាសុក្ខវិបស្សកៈក្តី ក៏មិនអាចដែលនឹងចូលនិរោធបាន ព្រោះតែកម្លាំងវិបស្សនាមួយយ៉ាង មិនបានសមាធិក្នុងសមាបត្តិ ៨ ។

សភាវៈដែលនឹងធ្វើឲ្យចូលនិរោធសមាបត្តិបាននោះ ត្រូវបរិបូរដោយកម្លាំងវិបស្សនា និងកម្លាំងសមាធិ ព្រះអនាគាមិបុគ្គល និងព្រះអរហន្តបុគ្គលដែលបានសមាបត្តិ ៨ ទ្រង់ទុកនូវកម្លាំងទាំង ២ ដោយបរិបូរ អាចដែលនឹងចូលនិរោធសមាបត្តិបាន ប្រកបដោយបញ្ញាដោយវសី អាចជំនាញក្នុងសម្បទា ៤ គឺ៖

១- មានកម្លាំងក្នុងវិបស្សនា និងមានកម្លាំងក្នុងសមថៈ ។

២- រម្លាប់ចាកត្រៃពិធសង្ខារគឺកាយសង្ខារ វចីសង្ខារ ចិត្តសង្ខារ ។

៣- ប្រព្រឹត្តទៅក្នុងសោឡសញ្ញាណ គឺញាណ ១៦ ។

៤- ប្រព្រឹត្តទៅក្នុងនវានុបុព្វវិហារសមាបត្តិ គឺជំនាញក្នុងការចូលនៅក្នុងសមាបត្តិទាំង ៩ មកមុន សមថពលៈកម្លាំងសេចក្តីស្ងប់ គឺសមាធិដែលកើតចាកការមិនរាយមាយ គឺចិត្តជាឯកគ្គតារម្មណ៍ ដោយអំណាចនៃ **នេក្ខម្មវិតក្កៈ** តម្រិះចេញចាកកាម ដែលកម្ចាត់បង់នូវកាមច្ឆន្ទៈ សេចក្តីស្រឡាញ់ក្នុងវត្ថុកាម ដោយអំណាចនៃកុសលចិត្តដែលកើតឡើង ប្រកបដោយអលោភៈ មិនលោភជាប្រធាន ប្រព្រឹត្តទៅដោយការកម្ចាត់បង់នូវកាមច្ឆន្ទៈ មិនរាយមាយចិត្ត ជាឯកគ្គតានឹងនក្នុងអារម្មណ៍កម្មដ្ឋាន ឈ្មោះថា **សមថពលៈ** ដោយអត្ថថា រម្លាប់បង់នូវបច្ចនិកធម៌ មានកាមច្ឆន្ទៈ

ជាដើម និងមិនកម្រើកញាប់ញ័រដោយបដិបក្ខធម៌ ធម៌ដែលជាសត្រូវ ដល់គ្នា (បដិបក្ខដល់គ្នា) ។

មួយ រីឯសភាវ:មិនបានរាយមាយឯណា គឺឯកគ្គតាចិត្តដែលតាំងនៅដោយ **អព្យាបាទវិតក្ក:** គិតមិនព្យាបាទ សង្កត់នូវសេចក្តីព្យាបាទ ដោយអំណាចកុសលចិត្តដែលកើតឡើង ដែលមានអទោស:ជាប្រធានប្រព្រឹត្តទៅដោយអំណាចសង្កត់ទុកនូវព្យាបាទយ៉ាងនេះ ក៏បានឈ្មោះថា **សមថពល:** ដូចគ្នា ។

មួយ សភាវ:ដែលមិនបានរាយមាយឯណា ពោលគឺឯកគ្គតាចិត្តតាំងមាំដោយអំណាចនៃចិត្តសមាទានព្រះរតនត្រ័យមាំ សង្កត់បាននូវឧទ្ធច្ច:ក្តីសភាវ:មិនបានរាយមាយឯណា គឺឯកគ្គតាចិត្តតាំងមាំដោយសេចក្តីអាចរបស់អ្នកបដិបត្តិពិចារណាអានាបាណសតិ កំណត់ឲ្យល់ដង្ហើមចូលចេញ សភាវ:ដែលសង្កត់នូវ **មិច្ឆាវិតក្ក:** ទាំងពួងក្តី ក៏ឈ្មោះថា **សមថពល:** ទាំងអស់ ។

សមាធិដែលប្រកបដោយឈាន គឺសមាបត្តិ ៨ ប្រការ គឺបឋមជ្ឈាន-ចិត្តតាំងមាំ មិនបានញាប់ញ័រដោយនីវរណ: ៥ ឃាំងឃាត់ទុកបានទុតិយជ្ឈានសមាធិ ចិត្តតាំងមាំ លះ **វិតក្ក: វិចារ:** ចេញបាន មិនបាច់អាស្រ័យទៀត តតិយជ្ឈានសមាធិ ចិត្តតាំងមាំ លះ **បីតិ** ចេញបាន មិនបាច់អាស្រ័យទៀត ចតុត្ថជ្ឈានសមាធិ ចិត្តតាំងមាំ លះ **សុ-**

សោមនស្ស មិនបានញាប់ញ័រ ឯកគ្គតាចិត្តក្នុងអាកាសានញ្ចាយតន-សមាធិ មិនបានញាប់ញ័រដោយរូបសញ្ញា បដិឃសញ្ញា អត្តសញ្ញា វិញ្ញាណញ្ចាយតន: មិនបានញាប់ញ័រដោយអាកាសានញ្ចាយតន: អាកិញ្ចញ្ញាយតន: មិនបានញាប់ញ័រដោយវិញ្ញាណញ្ចាយតន: នេវស-ញ្ញានាសញ្ញាយតនសមាធិ ចិត្តមិនបានញាប់ញ័រដោយអាកិញ្ចញ្ញាយតន: ចិត្តតាំងមាំមិនញាប់ញ័រដោយឧទ្ធច្ច: និងសព្វកិលេស ដែលកើតព្រម ដោយឧន្ធ ៥ ចិត្តមានអារម្មណ៍តែមួយក្នុងសេចក្តីស្ងប់ សេចក្តីប្រណីត ដូច្នេះ បាននាមបញ្ញត្តិថា **សមថពល:** ដោយប្រការដូច្នេះ ដែលនឹងជា បច្ចុ័យដល់និរោធសមាបត្តិជាប់តទៅ ។

វិបស្សនាពល: កម្ចាំងគឺវិបស្សនាដែលជាតួបញ្ញាចេតសិក ដែល ប្រកបដោយមហាកុសលចិត្តរបស់ព្រះយោគាវចរ ដែលពិចារណាឃើញ **អនិច្ចលក្ខណ:** ប្រាកដជាប់នៅនឹងរូបនាម **ឧយវយ:** រលត់ទៅ អស់ទៅ មិនទៀង ទាំងផ្ទូវភ្នែក ត្រចៀក ច្រមុះ អណ្តាត កាយ និងចិត្តជាបច្ចុ័យ ជានិច្ច សូម្បីអតីតក៏រលត់ទៅហើយ សូម្បីអនាគតក៏នឹងរលត់ទៅទៀត កើតទីណាក៏នឹងរលត់ទីនោះ បញ្ញាពិចារណារូបនាម ឃើញ **អនិច្ចំ** មិន ទៀង តាំងនៅមិនបាន នេះឈ្មោះថា **អនិច្ចានុបស្សនា** ។

វិបស្សនាបញ្ញា ពិចារណាឃើញរូបធម៌ នាមធម៌ កំពុងកើតរលត់ ជា ទុក្ខធន់នៅមិនបាន គួរខ្ជាច ផ្ទូវភ្នែក ផ្ទូវត្រចៀក ផ្ទូវច្រមុះ ផ្ទូវអណ្តាត

ផ្ទូវកាយ ផ្ទូវចិត្ត សុទ្ធតែកើតរលត់ជាទុក្ខទាំងអស់ បញ្ញាពិចារណាឃើញ **ទុក្ខលក្ខណៈ** ដូច្នេះ ឈ្មោះថា **ទុក្ខានុបស្សនា** ។

វិបស្សនាបញ្ញា ពិចារណាឃើញរូបធម៌ នាមធម៌ រលត់ៗ ជា **អនត្តលក្ខណៈ** មិនមានអំណាចនឹងបង្គាប់បញ្ជាបាន ទាំងផ្ទូវក្នែក ត្រចៀក ច្រមុះ អណ្តាត កាយ ចិត្ត សុទ្ធហើយតែកើតរលត់ មិនមែនខ្ទួន មិនមែនប្រាណ ឈ្មោះថា **អនត្តានុបស្សនា** ។

កាលវិបស្សនាបញ្ញា ពិចារណាព្រះត្រៃលក្ខណៈរបស់រូបធម៌ នាម-ធម៌ លុះកើតនិព្វិទាញាណ ឃើញជាភ័យ ជាទោស គួរនឿយណាយ ព្រោះមានសេចក្តីកើតរលត់ៗ មិនមានទីបំផុតរឿយៗ ឈ្មោះថា **និព្វិទានុបស្សនា** ។

ពិចារណាតទៅលុះអស់រាគៈ អស់សេចក្តីអាល័យក្នុងរូបនាម ដល់ភាវៈដកចាកគោត្របុថុជ្ជនទៅកាន់អរិយគោត្រ មគ្គចិត្តកើតឡើងប្រហារកិលេសជាច់ខាត ជាសមុច្ឆេទជាជាន់ៗ ដល់ **វិរាគញាណ** *ហើយពិចារណាសេចក្តីអស់អាសវកិលេស មានរាគៈជាដើម ក្នុងខណៈដំបូងដែលមគ្គចិត្តកើតនោះ ឬពិចារណាមគ្គនោះ ឈ្មោះថា* **វិរាគានុបស្សនា** ។

បញ្ញាដែលពិចារណាព្រះនិព្វាន ដែលជាទីរលត់នៃសង្ខាររូបនាមដែលជាអារម្មណ៍របស់មគ្គចិត្ត ផលចិត្តជាប់មកនោះឈ្មោះថា **និរោធានុបស្សនា** ។

បញ្ញាដែលពិចារណាកិលេសតណ្ហា ដែលអាល័យក្នុងសង្ខាររូបនាម

ដែលខ្លួនបានលះហើយដោយដាច់ខាតឈ្មោះថា **បដិនិស្សគ្គានុបស្សនា** ។

បញ្ញាដែលបានពិចារណារូបធម៌ នាមធម៌ ដោយន័យដែលសម្តែងមកនេះ លុះស្គាត់ជំនាញ ឈ្មោះថា **វិបស្សនាពលៈ** *ដែលនឹងជាបច្ច័យឲ្យចូលនិរោធសមាបត្តិបានស្រួល ។*

វិបស្សនាពលៈនោះ គឺចិត្តតាំងមាំ សត្រូវគឺកិលេសមិនអាចគ្របសង្កត់ឲ្យញាប់ញ័របាន បានដល់លះ **និច្ចសញ្ញា** *សេចក្តីសម្គាល់ថាទៀង ដោយ* **អនិច្ចានុបស្សនា** *ឃើញរូបនាមរលត់ទៅៗ ជានិច្ច ថាមិនទៀង លះ* **សុខសញ្ញា** *ដោយ* **ទុក្ខានុបស្សនា** *និងលះសេចក្តីសម្គាល់ថាជាខ្លួនជាប្រាណចេញបាន ដោយ* **អនត្តានុបស្សនា** *លះ* **តណ្ហា** *សេចក្តីស្រឡាញ់ក្នុងរូបនាម ដោយ* **និព្វិទានុបស្សនា** *លះ* **រាគៈ** *ដោយ* **វិរាគានុបស្សនា** *លះ* **តណ្ហាសមុទយ** *ដោយ* **និរោធានុបស្សនា** *លះ* **ឆន្ទរាគ** *និង* **ទិដ្ឋិ** *ដោយ* **បដិនិស្សគ្គានុបស្សនា** *សភាវៈដែលចម្រើនដ៏ធំនិងធ្វើឲ្យច្បាស់ដោយវិបស្សនាបញ្ញាដូច្នេះឯង គួរដល់និរោធសមាបត្តិ ។*

ក្នុងសម្បទាទីពីរសម្តែងដល់ការរម្ងាប់ត្រៃពិធសង្ខារនោះ សម្គាល់សេចក្តីដល់ការរម្ងាប់កាយសង្ខារ វចីសង្ខារ និងចិត្តសង្ខារ មានអធិប្បាយថា ៖

១- **កាយសង្ខារ** *បានដល់* **បិត្តជវាយោធាតុ** *ខ្យល់ដែលកើតអំពីចិត្ត គឺអស្សាសបស្សាសៈ ខ្យល់ដង្ហើមចេញខ្យល់ដង្ហើមចូល ដែល*

បានបញ្ញត្តិថា កាយសង្ខារនោះ ព្រោះខ្យល់ដង្ហើមចេញ ដែលនាមកាយ គឺចិត្ត និងរូបកាយ គឺសហជាតរូប អាចជាជនកបច្ច័យ និងសហជាត-បច្ច័យ ទើបចាត់ខ្យល់ដង្ហើមចូល-ចេញ ជាកាយសង្ខារ ។

មួយ ខ្យល់ដង្ហើមចូល ខ្យល់ដង្ហើមចេញ កាលបង្កើតក្នុងកាយប្រព្រឹត្ត ជាប់ដោយកាយ ដែលធ្វើឲ្យកាយញ័រ(ក្រមើក) បានឈ្មោះថាកាយសង្ខារ ទាំងអស់ កាយសង្ខារ គឺខ្យល់ដង្ហើមចូល ខ្យល់ដង្ហើមចេញ រម្ងាប់ក្នុង ខណៈកាលចូលកាន់ចតុត្ថជ្ឈានសមាធិ ព្រោះដូច្នោះ ការរម្ងាប់កាយសង្ខារ បាន ក៏កាលចម្រើនឈានដល់ចតុត្ថជ្ឈានហើយ (ដោយចតុកន័យ) ។

*២- **វចីសង្ខារ** បានដល់ **វិតក្ក: វិចារ:** ជាភ្នាក់ងារតាក់តែងវចីភេទ កាលបុគ្គលពោលពាក្យណាមួយ អាស្រ័យវិតក្ក: វិចារ: លើកឡើង កាន់អារម្មណ៍ ពិចារណាមុនហើយ ទើបនិយាយជាខាងក្រោយ វចីសង្ខារ គឺវិតក្ក: វិចារ:នេះ រម្ងាប់ទៅក្នុងខណៈមួយ កាលព្រះអរិយសាវ័ក ចូលកាន់ទុតិយជ្ឈានសមាធិ (ដោយចតុកន័យ) ។*

*៣- **ចិត្តសង្ខារ** នោះបានដល់ **សញ្ញា វេទនា** ដែលតាក់តែង ចិត្តឲ្យចាំ ឲ្យសោយ **សញ្ញា** មាននាទីចាំអារម្មណ៍ **វេទនា** មាននាទី សោយអារម្មណ៍ កាលកើតឡើងក៏អាស្រ័យចិត្តជាធំជាប្រធាន ចិត្តសង្ខារ គឺសញ្ញា វេទនានេះ រម្ងាប់ទៅក្នុងខណៈកាលចូលនិរោធសមាបត្តិ បញ្ញា ដែលជាវសី ជំនាញក្នុងការរម្ងាប់សង្ខារនេះ ជាឧបករណ៍គុណសម្បទា*

ដល់និរោធសមាបត្តិតទៅ កាលព្រះអនាគាមី និងព្រះអរហន្ត អ្នកព្រមព្រៀងទៅដោយគុណសម្បទាទាំង ៤ ពិចារណាឃើញការនៅដោយរូបនាមកើតរលត់ផ្ទួនៗគ្នា ត្រូវឃើញ ត្រូវបានព្ទ ត្រូវដឹងក្ងិន ត្រូវដឹងរស ត្រូវដឹងសម្ផស្ស ត្រូវដឹងនឹកគិត ត្រូវស៊ី ត្រូវដេក ត្រូវលំបាកគ្រាំគ្រាក្នុងការបរិហាររាងកាយចិញ្ចឹមជីព ហើយតម្រិះថា អាត្មានឹងចូលនិរោធ-សមាបត្តិ ដែលជាបរមសុខល្អជាង កាលតម្រិះដូច្នេះហើយ ទៅកាន់ទីរហោស្ថាន ដែលស្ងៀមស្ងាត់ប្រាសចាកអារម្មណ៍រុកកួន អង្គុយខាត់សមាធិ តាំងកាយឲ្យត្រង់ តម្រង់ស្មារតីឲ្យមាំ កំណត់សម្ងឹងសមថកម្មដ្ឋានលុះឡើងកាន់បឋមជ្ឈាន កន្ងងបឋមជ្ឈានតាមលំដាប់ដល់បញ្ចមជ្ឈានហើយឡើងអរូបជ្ឈាន លុះដល់នេវសញ្ញានាសញ្ញាយតន: ពិចារណាសេចក្តីស្ងប់ប្រណីតនៃសញ្ញារលត់ទៅទាំងចិត្ត និងចេតសិករហូត ៧ ថ្ងៃជាមហាសន្តិសុខហួសវិស័យនឹងពណិនាបាន ។

កាលអ្នកណាបានថ្វាយបច្ច័យទេយ្យទានប្រកបដោយសម្បទា៤យ៉ាងគឺ៖

១- **បដិគ្គាហក** គឺព្រះអរហន្ត ។

២- **បដិគ្គាហក** ចេញចាកនិរោធសមាបត្តិ ។

៣- វត្ថុទាននោះ បានមកដោយបរិសុទ្ធ ផុតចាកមិច្ឆាជីព ។

៤- ទាយកមានចេតនាទាំង ៣ សម្បូណិគឺ **បុព្វបេតនា** តាំងចិត្តល្អកាលមុនវេលាថ្វាយ ១ **មុញ្ចនបេតនា** តាំងចិត្តល្អកាលកំពុង

ថ្វាយ ១ **អបរាបរបេតតា** តាំងចិត្តល្អជានិច្ច កាលថ្វាយហើយ ១ ។

អ្នកនោះនឹងបានទទួលផលក្នុងបច្ចុប្បន្នភ្លាមៗ ។

អានិសង្សរបស់វិបស្សនា

បណ្តាផលប្រយោជន៍ទាំងឡាយ មិនមានអ្វីនឹងត្រឹមស្មើប្រហែលវិបស្សនា ជាប្រទីបដ៏ភ្លឺស្វាងច្បាស់យ៉ាងធើតឆាយ នៅក្នុងចិត្តរបស់អ្នកកាន់ព្រះពុទ្ធសាសនា អ្នកធ្វើព្រះវិបស្សនាកម្មដ្ឋាន សម្ចឹងឃើញវត្ថុគ្រប់យ៉ាង បានធ្ចុះធ្លាយរហូតរូបនាមរបស់ខ្លួនឯង និងអ្នកដទៃ ជ្រាបច្បាស់ក្នុងចិត្តផ្ចូវភ្នែក ចិត្តផ្ចូវត្រចៀក ចិត្តផ្ចូវច្រមុះ ចិត្តផ្ចូវអណ្តាត ចិត្តផ្ចូវកាយ ចិត្តផ្ចូវមនោ ដឹងច្បាស់ចាក់ធ្ចុះរហូតក្នុងចិត្តរបស់សត្វក្នុងអបាយភូមិ ចិត្តប្រេត ចិត្តអសុរកាយ ចិត្តសត្វនរក និងចិត្តសត្វតិរច្ឆាន ជ្រាបដល់ចិត្តរបស់មនុស្ស និងចិត្តរបស់ទេវតា រហូតលុះដល់ចិត្តរបស់ព្រហ្ម ជ្រាបច្បាស់ដល់ចិត្តដែលជាកុសលជាបុណ្យ និងចិត្តដែលជាអកុសលជាបាប រហូតដល់ចិត្តដែលជាអព្យាក្រឹតមិនជាបុណ្យមិនជាបាប ខណៈណាចិត្តចង់បានកើតឡើងក៏ដឹងទាន់ ចិត្តក្រោធកើតឡើងក៏ដឹងទាន់ ចិត្តវង្វេងកើតឡើងក៏ដឹងទាន់ ចិត្តដែលជាផលរបស់បុណ្យកើតឡើងក៏ដឹង ចិត្តដែលជាផលរបស់បាបកើតឡើងក៏ដឹង ចិត្តដែលជាកុសលកើតឡើងក៏ជ្រាប ចិត្តដែលជាផលរបស់កុសលកើតឡើងក៏ជ្រាបច្បាស់ កាលជ្រាបក្នុងចិត្តលុះជា **ចិត្តានុបស្សនា** ឃើញសេចក្តីកើតឡើង និងរលត់ទៅរបស់ចិត្ត លុះ

អស់ហេតុ អស់បច្ច័យរបស់អកុសលចិត្ត មិនកើតទៀត មិនក្តៅក្រហាយ ព្រោះចិត្តបាបទៀត ទើបជាបរមសុខក្នុងលោកនេះ និងលោកមុខ ដរាប លុះផុតចាកលោក ។

កាលវិបស្សនាបញ្ញាច្បាស់ចែសហើយ ញ្ចុំងប្រយោជន៍ឲ្យឃើញ ចេតសិករបស់ដែលប្រកបនឹងចិត្តបាប គឺចេតសិកដែលប៉ះ ចេតសិកដែល សោយ ចេតសិកដែលចាំ ចេតសិកដែលតាំងចិត្ត ចេតសិកដែល ទទួលអារម្មណ៍មួយ ចេតសិកដែលផ្គងជីវិតទុក ចេតសិកដែលយកចិត្តទុក ជាក់ ចេតសិកទាំងនេះ រមែងប្រកបសាធារណៈដល់ចិត្តគ្រប់ដួង និង ដ៏ងក្នុងចេតសិកតទៅទៀត បានដល់ចេតសិកដែលត្រិះរិះ ចេតសិក ដែលពិចារណា ចេតសិកដែលសម្រេចចិត្ត ចេតសិកដែលព្យាយាម ចេតសិកដែលផ្ចែតចិត្ត ចេតសិកដែលគាប់ចិត្ត ដែលប្រកបនឹងចិត្តព្រម គ្នាខ្លះ មិនព្រមគ្នាខ្លះ និងឃើញច្បាស់តទៅ ក្នុងអកុសលចេតសិកទៀត បានដល់ចេតសិកដែលវង្វេង ចេតសិកដែលមិនខ្មាស ចេតសិកដែល មិនខ្ជាចក្រែង ចេតសិកដែលរាយមាយ ចេតសិកដែលចង់បាន ចេតសិក ដែលឃើញខុស ចេតសិកដែលកាន់ខ្ជួន ចេតសិកដែលក្រោធ ចេត-សិកដែលឥច្ឆា ចេតសិកដែលកំណាញ់ ចេតសិកដែលរំខាន ចេត-សិកដែលងងុយងោកងក់ និងចេតសិកដែលសង្ស័យ និងឃើញច្បាស់ ក្នុងសោភណចេតសិកដែលល្អទៀត គឺចេតសិកដែលជឿ ចេតសិកដែល

រពុកបាន ឬដឹងទាន់ ចេតសិកដែលខ្មាស ចេតសិកដែលក្រែងខ្ជាច ចេតសិកដែលមិនលោភ ចេតសិកដែលមិនក្រោធ ចេតសិកដែលដឹងកណ្តាលៗ ចេតសិកដែលស្ងប់ ចេតសិកដែលស្រាល ចេតសិកដែលទន់ ចេតសិកដែលគួរដល់ការងារ ចេតសិកដែលក្ងៀវក្ងា ចេតសិកដែលត្រង់ ចេតសិកដែលវៀរអាក្រក់ឲ្យនិយាយត្រូវ ចេតសិកដែលវៀរអាក្រក់ឲ្យធ្វើត្រូវ ចេតសិកដែលវៀរអាក្រក់ឲ្យមានសេចក្តីរស់នៅប្រពៃ ចេតសិកដែលអាណិតអាសូរអ្នកដទៃ ចេតសិកដែលត្រេកអរក្នុងកាលអ្នកដទៃបានល្អ និងចេតសិកដែលជាធំក្នុងសេចក្តីដឹង កាលបានជ្រាបច្បាស់ដោយវិបស្សនា ក្នុងចេតសិកលុះឃើញកើតឡើងរលត់ទៅព្រមនឹងចិត្ត លុះអាចលះអកុសលចិត្តជាច់ខាត មិនកើតទៀត តាមកម្ងាំងរបស់បញ្ញាក្នុងលោកុត្តរៈមិនធ្វើឲ្យក្តៅក្រហាយណា មានឡើងបានទៀតដោយអំណាចពិចារណាក្នុងចេតសិកដែលជាសុខ ឬទុក្ខ ខបេក្ខារឿយៗទៅ ឈ្មោះថា **វេទនានុបស្សនា** ក្រៅនោះចាត់ជាចេតសិកធម៌ វិបស្សនាបញ្ញាពិចារណាឃើញជាក់ច្បាស់ជានិច្ច ឈ្មោះថា **ធម្មានុបស្សនា** ។

វិបស្សនាញាណសេចក្តីដឹងច្បាស់ឃើញពិត ជា **បក្ខុដ្ឋងភ្នែក** បញ្ញាដែលប្រសើរ ជា **វិជ្ជា** សេចក្តីដឹងដែលព្រោកប្រាជ្ញ ជា **អាលោកៈ** ភ្ងឺស្វាងដែលមានរស្មីរុងរឿង ឬរុងរោចន៍មិនមានប្រមាណ អាចដឹងធម្មជាតិ ដែលកំពុងបែករលត់ទម្ងាយគ្រប់កាលនោះ គឺ **រូប** បានដល់រូបដី រូបទឹក

រូបខ្យល់ រូបកើតរូបពណ៌ រូបសំឡេង រូបក្លិន រូបរស រូបត្រជាក់ រូបក្តៅ រូបរឹង រូបឈរ រូបដើរ រូបអង្គុយ រូបដេក រូបបម្រះនទៀល រូបញ័រ រូបប្រសាទភ្នែក រូបហទយវត្ថុ រូបស្រី រូបប្រុស រូបជីវិត រូបអាហារ រូបអាកាស រូបកម្រើកវាចា រូបកម្រើកកាយ រូបស្រាល រូបទន់ រូបគួរដល់ការងារ រូបកើត រូបចម្រើន រូបសូន្យ រូបរលត់ វិបស្សនាបញ្ញា ពិចារណាឃើញរូបទាំងនេះ កើតឡើងហើយរលត់ទៅជានិច្ចមិនជាប់ក្រសៃដូច្នេះ ក៏ជាបច្ច័យឲ្យចោលបិយរូប សាតរូបបានជាប់ខាត បានចូលដល់សន្តិភាពជាស្ថាពរ ក៏ព្រោះចម្រើនកំណត់រូបកាយឈ្មោះថា ***កាយានុបស្សនា*** *នេះជានិច្ច លើសជាងនេះក៏បានច្បាស់លាស់ក្នុងវិបស្សនាភូមិ ផ្នែកនៃ្ងដែលឲ្យកើតវិបស្សនា មានគំនរទាំង ៥ ដែលផ្សេងដោយគ្រោតគ្រាត ល្អិត ថោកទាប ប្រណីត ជិត ឆ្ងាយ ខាងក្នុង ខាងក្រៅ អតីត អនាគត បច្ចុប្បន្ន ដែលជាលក្ខណៈរបស់គំនររូប គំនរសោយរូប គំនរចាំរូប គំនរប្រុងតែងរូប គំនរដឹងរូប និងឃើញច្បាស់ទីតអណ្តូងកើតនៃបុណ្យ និងបាប ដែលមាននៅក្នុងខ្លួនយើង និងក្រៅខ្លួនយើង ក្នុងខ្លួនគឺភ្នែក ត្រចៀក ច្រមុះ អណ្តាត កាយ ចិត្ត ក្រៅខ្លួនគឺពណ៌ សំឡេង ក្លិន រស គ្រឿងប៉ះអារម្មណ៍ផ្លូវចិត្ត ដែលប៉ះទង្គិចគ្នាជានិច្ចមិនបានជាប់ ជាទីហូរមកនៃបុណ្យ និងបាប និងឃើញជាក់ច្បាស់ក្នុងធាតុពិតរបស់ជីវិតនោះ គឺធាតុប៉ះ ធាតុទទួល ធាតុដឹង ពណ៌ជាធាតុប៉ះ កែវភ្នែកជាធាតុទទួល*

ឃើញជាធាតុដឹង សំឡេងជាធាតុប៉ះ កែវត្រចៀកជាធាតុទទួល បានញ្ច សំឡេងជាធាតុដឹង ក្លិនជាធាតុប៉ះ ប្រសាទច្រមុះជាធាតុទទួល ដឹងក្លិន ជាធាតុដឹង រសជាធាតុប៉ះ ប្រាសាទអណ្ណាតជាធាតុទទួល ដឹងរសជាធាតុ ដឹង ត្រជាក់ ក្តៅ ទន់ រឹង ជាធាតុប៉ះ ប្រសាទកាយជាធាតុទទួល ដឹង (សម្ផស្ស) ជាធាតុដឹង ធម្មារម្មណ៍ជាធាតុប៉ះ ហទយវត្ថុជាធាតុទទួល ចិត្ត ជាធាតុដឹង ឃើញច្បាស់តទៅក្នុងឥន្ទ្រីយ៍ជាធំគ្រប់គ្រងក្នុងនាទីរបស់ខ្លួន គឺភាពជាធំរបស់ ភ្នែក មាននាទីឃើញ ភាពជាធំរបស់ ត្រចៀក មាននាទី បានញ្ច ភាពជាធំរបស់ ច្រមុះ មាននាទីដឹងក្លិន ភាពជាធំរបស់ អណ្ណាត មាននាទីដឹងរស ភាពជាធំរបស់ កាយ មាននាទីដឹងសម្ផស្ស ត្រជាក់ ក្តៅ ទន់ រឹង ភាពជាធំរបស់ ស្ត្រី មាននាទីស្រី ភាពជាធំរបស់ បុរស មាន នាទីប្រុស ភាពជាធំរបស់ជីវិត មាននាទីរក្សា ភាពជាធំរបស់ បិត្ត មាន នាទីដឹងធម្មារម្មណ៍ ភាពជាធំរបស់ សុខ មាននាទីសប្បាយកាយ ភាពជាធំរបស់ ទុក្ខ មាននាទីទុក្ខកាយ ភាពជាធំរបស់ សោមនស្ស មាននាទីត្រេកអរ ភាពជាធំរបស់ ទោមនស្ស មាននាទីតូចចិត្ត ភាពជា ធំរបស់ ឧបេក្ខា មាននាទីដាក់ចិត្តព្រងើយៗ ភាពជាធំរបស់ សទ្ធា មាននាទីជឿជ្រះថ្លា ភាពជាធំរបស់ សតិ មាននាទីរព្ចកដឹងទាន់ ភាព ជាធំរបស់ វីរិយៈ មាននាទីព្យាយាម ភាពជាធំរបស់ សមាធិ មាននាទី ទទួលអារម្មណ៍នឹងន ភាពជាធំរបស់ បញ្ញា មាននាទីដឹងរូបនាម

ភាពជាធំរបស់ **អញ្ញតញ្ញស្សាមីតិន្ទ្រិយ** មានវាទីយើញព្រះនិញ្ជាន ភាពជាធំរបស់ **អញ្ញិន្ទ្រិយ** មានវាទីយើញព្រះនិញ្ជាន ភាពជាធំរបស់ **អញ្ញាតាវិន្ទ្រិយ** មានវាទីយើញព្រះនិញ្ជាន ឥន្ទ្រិយដែលមានវាទីយើញព្រះនិញ្ជាននេះ នៅមានវាទីពិសេស គឺកាត់កិលេសដាច់ជាដុំៗ លុះត្រាតែអស់រលីងមិនមានសល់ ។

នៅមានសេចក្តីដឹងច្បាស់ចាក់ធ្ទុះរហូតតាមទស្សនៈ ដែលពិតតទៅទៀតគឺ របស់ទាំងឡាយទាំងពួងក្នុងលោកនេះ ក្នុងខ្ជួន និងក្រៅខ្ជួន មានតែទុក្ខទាំងអស់ របស់ដែលស្ថិតនៅឲ្យដឹង គឺរូប ក៏ជាទុក្ខធន់នៅមិនបានត្រូវរលត់ទៅរបស់ដែលចូលទៅដឹងគឺនាម ក៏ជាទុក្ខធន់នៅមិនបានរលត់ទៅ ខន្ធ ៥ ជាមនុស្សលីសែងទុក្ខមក កំពុងលីសែងទុក្ខ នឹងលីសែងទុក្ខតទៅ ជាភារៈដែលធ្ងន់លើសប្រមាណ ព្រោះមានទុក្ខគឺរូបនាមនេះឯងទុក្ខក៏កើតតាមក្រោយមក ទុក្ខការយាងចុះកាន់គភ៌តាមក្រោយមក ទុក្ខកើតចាកការវិបត្តិនៃគភ៌តាមក្រោយមក ទុក្ខប្រសូតិចាកគភ៌តាមក្រោយមក ទុក្ខចេញក្រៅគភ៌ក៏តាមក្រោយមក ទុក្ខដោយសេចក្តីព្យាយាមរបស់ខ្ជួនក៏តាមក្រោយមក ទុក្ខដោយសេចក្តីព្យាយាមរបស់អ្នកដទៃក៏តាមក្រោយមក ទុក្ខគឺសេចក្តីជរាក៏តាមក្រោយមក ព្រោះមានទុក្ខរូប ទុក្ខនាម ធន់នៅមិនបាន ទុក្ខមានពណ៌សម្បុរស្បែកជ្រីវជ្រួញហួតហែងក៏តាមក្រោយមក ទុក្ខមានកម្ចាំងថយក៏តាមក្រោយមក ទុក្ខមានរាងកាយទ្រុឌ

ទ្រោមក៏តាមក្រោយមក ទុក្ខព្រោះមានរាងកាយទ្រេតទ្រោតក៏តាមក្រោយមក ទុក្ខព្រោះមានធ្មេញបាក់ ទុក្ខព្រោះមានភ្នែកងងឹតស្រវាំង ទុក្ខព្រោះត្រចៀកហ៊ឹងថ្ងង់ក៏តាមក្រោយមក ទុក្ខព្រោះក្តៅក្រហាយ ទុក្ខព្រោះធន់បានក្រ ទុក្ខព្រោះជាទីតាំងនៃសេចក្តីធន់បានក្រក៏តាមក្រោយមក ។

ព្រោះមានទុក្ខរូប ទុក្ខនាមរលត់ទៅៗ ធន់នៅមិនបាន ទុក្ខដោយមានកិរិយាបៀតបៀនរឿយៗ ទុក្ខព្រោះជារបស់អាក្រក់ក៏តាមក្រោយមក ទុក្ខដោយរោគ ទុក្ខដោយកើតបូស ទុក្ខដូចជាកូនសរ ទុក្ខដោយរបស់ចង្អៀតចង្អល់ ទុក្ខដោយអាពាធក៏តាមក្រោយមក ទុក្ខដោយជារបស់ចង្រៃ ទុក្ខដោយជារបស់ឧបទ្រាវៈ ទុក្ខដោយជារបស់គួរខ្ជាប ទុក្ខដោយជារបស់ទំនាស់ក៏តាមក្រោយមក ទុក្ខដោយមិនមានគ្រឿងទប់ទល់ ទុក្ខមិនមានទីចៀសពួន ទុក្ខមិនមានទីពឹងក៏តាមក្រោយមក ទុក្ខដោយជាទោស ទុក្ខដោយជាឫសគល់នៃសេចក្តីចង្អៀតចង្អល់ក៏តាមក្រោយមក ទុក្ខដោយជាអ្នកសម្ងាប់ ទុក្ខដោយមានអាសវៈគ្រឿងត្រាំ ទុក្ខដោយជាចំណីរបស់មារក៏តាមក្រោយមក ទុក្ខដោយមានសេចក្តីឈឺចាប់ជាធម្មតា ទុក្ខដោយមានសេចក្តីស្លាប់ជាធម្មតាក៏តាមក្រោយមក ទុក្ខដោយមានសេចក្តីយំរៀបរាប់ ទុក្ខដោយមានសេចក្តីសោយសោកជាធម្មតា ទុក្ខដោយសេចក្តីចង្អៀតចង្អល់ចិត្តជាធម្មតា ទុក្ខដោយមានសេចក្តីសៅហ្មងចិត្តជាធម្មតាក៏តាមក្រោយមក ។

កាលវិបស្សនា ដឹងក្នុងទុក្ខច្បាស់លាស់ហើយ ថែមទាំងអាចលះ **សមុទយ** *គឺតណ្ហា ១០៨ ដែលចង់បានអាយតនៈ ១២ និងចង់បានក្នុងកាល ៣ នោះទៀត តាមលំដាប់លុះអស់រលីង ។*

វិបស្សនាបញ្ញាដែលជាកំពូលរបស់លោកិយ អាចជាបច្ច័យតលោកុត្តរៈឲ្យឃើញច្បាស់ក្នុងសេចក្ដីទុក្ខ មិនមានចំណែកសល់បានទៀត គឺព្រះនិព្វាន ដែលអរិយមគ្គ អរិយផល ដែលសម្បយុត្តដោយអង្គទាំង ៨ ឲ្យបរិបូរបានដល់ **សីល** *គឺនិយាយត្រូវ ធ្វើត្រូវ និងរស់នៅត្រូវ រៀរសេចក្ដីអាក្រក់ជានិច្ច បានដល់* **សមាធិ** *គឺព្យាយាមត្រូវ រឭកត្រូវ តាំងចិត្តមាំត្រូវជានិច្ច មិនវង្វេង បានដល់* **បញ្ញា** *គឺឃើញត្រូវ តម្រិះត្រូវ ឃើញកើតរលត់ និងឃើញព្រះត្រៃលក្ខណៈ ចម្រើនជានិច្ចដូច្នេះ លុះបរិបូរដឹងទុក្ខច្បាស់ លះសមុទយបាន ដល់និរោធសេចក្ដីសន្តិសុខ ដែលជា* **អមតៈ** *ដែលមិនធ្លាប់មាន មិនធ្លាប់ឃើញ ក៏នឹងឃើញឡើងមកឲ្យប្រាកដ ។*

កាលវិបស្សនាឃើញជាក់ច្បាស់ ដឹងហេតុ ដឹងផល មកប្រជុំព្រមជាបទបាទឲ្យជាបច្ច័យនូវគ្នានិងគ្នា គឺសេចក្ដីមិនដឹងជាបច្ច័យឲ្យកើតសេចក្ដីប្រុងតែង សេចក្ដីប្រុងតែងជាបច្ច័យឲ្យកើតសេចក្ដីដឹង សេចក្ដីដឹងជាបច្ច័យឲ្យដល់របស់ដែលស្ថិតនៅឲ្យដឹង និងរបស់ដែលចូលទៅដឹងបានដល់នាមរូប ៖

នាមរូប ជាបច្ច័យឲ្យកើត អាយតនៈ គ្រឿងភ្ជាប់ គ្រឿងត

អាយតនៈ ជាបច្ច័យឲ្យកើត ផស្សៈ ប៉ះខ្ទប់

ផស្សៈ ជាបច្ច័យឲ្យកើត វេទនា ការសោយ

វេទនា ជាបច្ច័យឲ្យកើត តណ្ហា សេចក្តីចង់

តណ្ហា ជាបច្ច័យឲ្យកើត ឧបាទាន សេចក្តីប្រកាន់មាំខ្ជាប់

ឧបាទាន ជាបច្ច័យឲ្យកើត កម្មភព ធ្វើឲ្យមាន ធ្វើឲ្យកើត

ភព ជាបច្ច័យឲ្យកើត ជាតិ សេចក្តីកើត

ជាតិ ជាបច្ច័យឲ្យកើត ជរាមរណៈ សេចក្តីចាស់-ស្លាប់ ។

កាលវិបស្សនាបញ្ញា បានពិចារណាលុះអស់ហេតុ អស់បច្ច័យ កាលនោះការប្រជុំឲ្យជាបទជាបាទដល់សេចក្តីទុក្ខ សេចក្តីសោក នឹងមិនមានទៀត ព្រោះការរលត់ដោយអស់រលីងដាច់ខាតចេញហើយ គឺកាលអវិជ្ជារលត់ សង្ខារក็รลต់ កាលសង្ខាររលត់ វិញ្ញាណก็รลต់ កាលវិញ្ញាណរលត់ នាមរូបก็รลต់ កាលនាមរូបរលត់ អាយតនៈก็รลต់ កាលអាយតនៈรลต่ ផស្សៈก็รลต่ កាលផស្សៈรลต่ វេទនาก็รลต่ កាលវេទនารลต่ តណ្ហาก็รลต่ កาลตณฺหารลต่ ឧปาทานก็รลต่ กาลอุปาทานรลต่ ภพก็รลต่ กาลภพรลต่ ชาติก็รลต่ กาลชาติรลต่ ชรามรณะก็รลต่ กาลชรามรณะรลต่ ทุกฺขทั้งปวงมีสโศกะ ปริเทวะ โทมนสฺส อุปายาส ตรัชาก่กาล ฆ่าน ศรีก ฉีอุจาระ ปสฺสาวะ

ទុក្ខអវយវៈ មិនធ្វើនាទីតាមប្រក្រតី ទុក្ខរោលក្តៅ ទុក្ខការចញ្ចឹមជីវិត ទុក្ខវិវាទជាមូល ទុក្ខឧបាទានក្ខន្ធ ទាំងនេះក៏រលត់ទៅអស់រលីង ជាសេចក្តីស្ងប់សុខស្ងាត់ជានិរន្តរ៍ គឺ **អមតមហានិព្វាន** រលត់ទុក្ខទាំងពួងមិនស្ងាប់ទៀតតទៅ ។

កាលសាធុជនមកធ្វើបញ្ញាឲ្យឃើញជាក់ច្បាស់ក្នុងលក្ខណៈ ៣ របស់រូបនាមមានឡើងក្នុងចិត្តកាលណា កាលនោះឈ្មោះថា **វិបស្សនា-ភាវនា**បានបង្កើតឡើងហើយ *មានសេចក្តីដឹងតាមសភាវៈពិតជា* **លក្ខណៈ** *មានកិរិយាកម្ចាត់ចេញនូវសេចក្តីងងឹត គឺ* **មោហៈ**ជា **កិច្ច** *មានសេចក្តីមិនរង្គើជា* **ផល** *មានសមាធិសេចក្តីនឹងនរ មិនរង្គើចំពោះ*ធម្មជាតិ**ហេតុជិត** *ទាំងរូបនិងនាម ២ យ៉ាងនេះ ដែលស្ថិតនៅទុកឲ្យ*វិបស្សនា*ពិសោធន៍ ។ វិបស្សនាចូលទៅពិសោធបានក្នុងបច្ចុប្បន្នកាលប៉ុណ្ណោះ ព្រោះក្នុងអតីតកាលកន្លងមកហើយ រូបនាមរលត់ទៅហើយពិសោធមិនបាន សូម្បីក្នុងអនាគត រូបនាមក៏នៅមិនកើតឡើង វិបស្សនាពិសោធឲ្យមិនបាន នឹងដឹងបាន នឹងឃើញបាន នឹងចូលទៅពិសោធបាន ក៏តែក្នុងបច្ចុប្បន្ន ខណៈដែលកំពុងកើតឡើងប៉ុណ្ណោះ* **វិបស្សនា**ត្រូវ*ធ្វើ*សតិ*អ្នកវព្រ*ួកដឹ*ងបច្ចុ*ប្ប*ន្ន*ជ*ាប្ប*ម*ុ*ខ *គឺ*ត*ួ*ម*េ*ទ*ព*ធ*ដ*ែ*ល*ន*ាំ*ទ*ព*ចេ*ញ*ទ*ៅ*ត*ស*ូ*ន*ឹ*ង*ម*ោ*ហ*ៈ*ត*ួ*ម*ិ*ន*ដ*ឹ*ង*រ*ូ*ប*ន*ាម *ត*ែ*ទ*ៅ*ដ*ឹ*ង*ប*ញ*ញ*ត*ិ *ន*ាំ*យ*ក*ប*ញ*ញ*ត*ិ*ព*្ម*ម*ដ*ោ*យ *ត*ណ*ា *ម*ា*ន*ៈ *ទ*ិ*ដ*ិ *ម*ក*គ*្ម*ប*ប*ិ*ទ*រ*ូ*ប*ន*ាម*ទ*ុ*ក *ម*ិ*ន*ឲ*្យ*វ*ិ*ប*ស*្ស*ន*ា*ឃ*ើ*ញ *ម*ិ*ន*

ឲ្យវិបស្សនាដឹង ដូច្នោះ សតិទើបត្រូវចេញកាន់ស្នាមចម្បាំង តស៊ូទី
បច្ចុប្បន្នធម៌នេះ៦ង និងធ្វើសង្ត្រាមរឿយទៅ ទម្រាំនឹងឈ្នះសត្រូវ គឺ
មោហៈដែលជាសត្រូវកំណាចកាចអាក្រក់របស់វិបស្សនា ដែលធ្វើឲ្យ
វង្វេង ធ្វើឲ្យភ្ងេច មានច្រើនហួសវិស័យនឹងប្រមាណបាន ក៏នឹងសន្សឹម
ថយស្រាលស្តើងចុះ ព្រមនឹងវិបស្សនា សតិបញ្ញាក៏ចម្រើនច្រើនឡើងតាម
លំដាប់ លុះពេញបរិបូរកាលណា ក៏នឹងឃើញព្រះត្រៃលក្ខណៈ កាល
បានព្រះត្រៃលក្ខណៈ គឺ **អនិច្ចំ ទុក្ខំ អនត្តា** ដែលដិតតោងជាប់នៅនឹង
រូបនាម មករួមចុះកាន់ភវង្គៈ ប្រហារអនុស័យដែលដេកត្រាំនៅរឿយៗក្នុង
សន្តាន ឲ្យដាច់ចុះអស់ក្នុងខណៈណា កាលនោះក៏នឹងឃើញព្រះនិញ្ចាន
សេចក្តីរលត់ទុក្ខ **សមថយានិកៈ** ធ្វើសមថៈលុះបានឈានហើយ លើក
ឈានឡើងកាន់វិបស្សនាក៏បាន ឬចម្រើនវិបស្សនាសុទ្ធៗ ដោយការលះ
បលិពោធ គ្រឿងកង្វល់ហួងហែងទុកខាងដើម និងបានចាត់រក
កល្យាណមិត្ត រកសប្បាយ មានស្ថានទីបដិបត្តិអាហារ និងបុគ្គល រហូត
ដល់ធម្មសប្បាយជាដើម រៀរខដែលគួរវៀរ បដិបត្តិខដែលគួរបដិបត្តិ
តាមបែបបដិបត្តិដែលអាចារ្យបានឲ្យទៅគ្រប់ៗ បែបបដិបត្តិ តាំងអំពីទី១
ដល់ទី១៧ កន្ងងញាណ ១៦ គឺ ៖

១- **នាមរូបបរិច្ឆេទញាណ** ឃើញរូបនាម ។

២- **នាមរូបបច្ចយបរិគ្គហញាណ** ឃើញបច្ច័យរបស់រូបនាម ។

៣- សម្មសនញាណ ឃើញរូបនាមមានលក្ខណៈ ៣ ។

៤- ឧទយព្វយញាណ ឃើញរូបនាមកើតរលត់ ។

៥- ភង្គញាណ ឃើញរូបនាមរលត់ទៅៗ ។

៦- ភយតូបដ្ឋានញាណ ឃើញរូបនាមជាភ័យ ។

៧- អាទីនវញាណ ឃើញរូបនាមជាទោស ។

៨- និព្វិទាញាណ ឃើញរូបនាមគួរនឿយណាយ ។

៩- មុញ្ចិតុកម្យតាញាណ ឃើញរូបនាមប្រាថ្នានឹងរត់ ។

១០- បដិសង្ខាញាណ ឃើញរូបនាមហើយរកផ្លូវរត់ ។

១១- សង្ខារុបេក្ខាញាណ ឃើញរូបនាមហើយមើលព្រងើយរត់
មិនរួច ។

១២- អនុលោមញាណ ឃើញរូបនាមជាក់ច្បាស់តាមកម្លាំង
អរិយសច្ច ។

១៣- គោត្រភូញាណ ឃើញព្រះនិព្វានធ្វើគោត្របុថុជ្ជនទៅ
កាន់អរិយៈ ។

១៤- មគ្គញាណ ឃើញព្រះនិព្វាន ។

១៥- ផលញាណ ឃើញព្រះនិព្វានផ្ទួន ។

១៦- បច្ចវេក្ខណាញាណ ពិចារណាឃើញមគ្គ ផល និព្វាន និង
កិលេសដែលលះហើយ ឬដែលនៅសល់ ។

បង្វឹកហាត់ឲ្យជំនាញក្នុងការចូល **ផលសមាបត្តិ** **និរោធសមាបត្តិ** *តាមគួរដល់ភាវនារបស់ខ្ជួនៗ ដែលនឹងធ្វើបាន ។*

អ្នកបដិបត្តិវិបស្សនាដឹងច្បាស់ចាក់ធ្ទុះរហូតក្នុងចិត្ត ចេតសិក រូប និង និញ្ចានហើយ ពោធិបក្ខិយធម៌រមែងចូលប្រជុំព្រមគ្នាជានិច្ច មានសតិបញ្ញានឹងន រមែងពិចារណា **កាយ** **វេទនា** **បិត្ត** **ធម៌** *រឿយៗ លុះយើញកើតរលត់មិនទៀង ជាទុក្ខ ជាអនត្តា គ្រាន់តែថា* **កាយ** *មិនមែនសត្ត បុគ្គល ខ្ជួនប្រាណ យើងគេ គ្រាន់តែថា* **វេទនា** *មិនមែនសត្ត បុគ្គល ខ្ជួនប្រាណ យើងគេ គ្រាន់តែថា* **បិត្ត** *មិនមែនសត្ត បុគ្គល ខ្ជួនប្រាណ យើងគេ គ្រាន់តែថា* **ធម៌** *មិនមែនសត្ត បុគ្គល ខ្ជួនប្រាណ យើងគេ មាន* **សម្មប្ឆធាន** *ព្យាយាមមិនឲ្យអកុសលកើតឡើង ព្យាយាមលះអកុសលដែលកើតឡើងហើយ ព្យាយាមចម្រើនកុសលឲ្យកើតឡើង មានឡើង ព្យាយាមរក្សាកុសលដែលកើតឡើងហើយមិនឲ្យសាបសូន្យ ព្រមដោយឥទ្ធិបាទ ៤ មាន* **ធន្ទៈ** *សេចក្តីពេញចិត្តបដិបត្តិក្នុងវិបស្សនាឲ្យសម្រេច* **វីរិយៈ** *សេចក្តីព្យាយាមបដិបត្តិឲ្យសម្រេច* **បិត្តៈ** *យកចិត្តទុកដាក់ឲ្យសម្រេច* **វិមំសា** *ពិនិត្យពិចារណាឲ្យសម្រេច ព្រមទាំងមានកម្ចាំងភាពជាធំដោយ* **សទ្ធា** *សេចក្តីជឿ មានកម្ចាំងភាពជាធំដោយ* **សេបក្តីព្យាយាម** *មានកម្ចាំងភាពជាធំដោយ* **សតិ** *មានកម្ចាំងភាពជាធំដោយ* **សមាធិ** *មានកម្ចាំងភាពជាធំដោយ* **បញ្ញា** *និងប្រជុំព្រមដោយ*

គ្រឿងត្រាស់ដឹង គឺសតិរពុកទាន់ ធម្មវិបយ: មានបញ្ញាជ្រើសរើស ឃើញធម៌ វីរិយ: សេចក្តីព្យាយាម បីតិ សេចក្តីផ្អែតចិត្ត បស្សទ្ធិ សេចក្តីស្ងប់ សមាធិ សេចក្តីតាំងចិត្តនឹងនមិនវង្វេង ឧបេក្ខា សេចក្តីព្រងើយចំពោះសហជាតធម៌ ប្រជុំព្រមដោយ សីល រៀរមោហ: ដោយ សមាធិ មិនវង្វេង ដោយ បញ្ញា ឃើញព្រះត្រៃលក្ខណ: របស់រូបនាម ប្រជុំព្រមដោយអដ្ឋង្គិកមគ្គទាំង ៨ គឺ ៖

សម្មាទិដ្ឋិ មានសេចក្តីឃើញត្រូវ ឃើញរូបនាមរលត់ទៅៗ ។

សម្មាសង្កប្បោ តម្រិះត្រូវ ឃើញមិនទៀង ធន់នៅមិនបាន បង្គាប់មិនបាន ។

សម្មាវាចា និយាយត្រូវ រៀរមោហ:ជានិច្ច ។

សម្មាកម្មន្តោ ធ្វើការងារត្រូវ រៀរមោហ:ជានិច្ច ។

សម្មាអាជីរោ រស់នៅត្រូវ រៀរមោហ: ។

សម្មាវាយាមោ ព្យាយាមត្រូវ ព្យាយាមដឹងរូបនាមជានិច្ច ។

សម្មាសតិ រពុកត្រូវ ដឹងទាន់រូបនាមជានិច្ច ។

សម្មាសមាធិ តាំងចិត្តត្រូវ គឺមិនវង្វេង នឹងនជានិច្ច ។

កាលពោធិបក្ខិយធម៌ប្រជុំព្រមដូច្នេះ ក៏អស់អាសវ:ដល់សន្តិលក្ខណ: គឺព្រះនិញ្ចានជាបរមសុខ ចូលដល់សន្តិភាពជាស្ថាពរ បើវិបស្សនានេះ ផ្សព្វផ្សាយចូលកាន់ចិត្តរបស់ប្រជាជនពលលោក កម្ចាត់សេចក្តីលោភ

សេចក្តីក្រោធសេចក្តីវង្វេង និងបាបកម្មទាំងឡាយ មានកាយ និងចិត្ត ដ៏ស្ងប់អស់ សេចក្តីទុច្ចរិតផ្លូវកាយ វាចា ចិត្តអស់ហើយ លោកនេះក៏នឹង ពេញទៅដោយសេចក្តីសុខស្ងប់ត្រជាក់ ប្រាសចាកសេចក្តីបៀតបៀន គ្រប់មនុស្សមានតែ មេត្តា សេចក្តីស្រឡាញ់រាប់អាន **ករុណា** សេចក្តីអាណិតអាសូរ **មុទិតា** សេចក្តីរីករាយត្រេកអរកាលអ្នកដទៃបានល្អ **ឧបេក្ខា** មិនមានអគតិណាៗ ទាំងអស់ ។

អានិសង្សផលរបស់វិបស្សនាមានច្រើនប្រការ ពណិនាមិនចប់ មិន អស់ ធ្វើមនុស្សឆ្ពួតឲ្យជាមនុស្សជា ធ្វើមនុស្សល្អឲ្យរឹតតែល្អឡើងទៅ ធ្វើ មនុស្សល្ងង់ឲ្យជាមនុស្សឆ្លាត ធ្វើមនុស្សអាក្រក់ឲ្យជាមនុស្សល្អ ធ្វើមនុស្ស ឲ្យឈប់អបាយមុខ ឈប់ផឹកស្រា របស់ស្រវឹង ឈប់លេងការភ្នាល់ មិនខ្ជិលច្រអូសក្នុងកិច្ចការដែលជាបុណ្យជាកុសល លះបានតាមកម្លាំង សេចក្តីអាចរបស់វិបស្សនាញាណ ទាំងជានិស្ស័យជាប់តាមខ្លួន ជួនទៅ ទាំងជាតិនេះ ជាតិមុខ ជាតិយ៉ាងលើស ទម្រាំនឹងចូលកាន់ព្រះនិញ្វានគឺ ៖

១- មានសតិមាំមួនជានិច្ច កាលជិតនឹងមរណ: កាយបែករលត់ ចុតិចាកបច្ចុប្បន្នជាតិនេះ ក៏មិនវង្វេងធ្វើកាលកិរិយា គឺស្លាប់យ៉ាងមាន សតិ មិនវង្វេងភ្លេច បិទរាំងអបាយភូមិបានក្នុងជាតិនោះ ។

២- មានសុគតិភព គឺមនុស្ស និងសួគ៌ជាទីទៅក្នុងខាងមុខ ។

៣- កាលនៅមានឧបនិស្ស័យវាសនាបារមីមិនទាន់ចាស់ក្លា បាន

ឈ្មោះថាជាអ្នកមានឧបនិស្សយបច្ចយដល់មគ្ត ផល និញាន ដិតជាប់សន្តានតទៅក្នុងភពខាងមុខ ។

៤- បើមានឧបនិស្សយវាសនាបារមីចាស់ក្លា ក៏រមែងនឹងធ្វើឲ្យបានលុះមគ្ត ផល និញាន ក្នុងជាតិនោះ ។

អហោ ពុទ្ធោ ព្រះពុទ្ធជាម្ចាស់នេះជាអស្ចារ្យ ត្រាស់ដឹង **អនុត្តរ-សម្មាសម្ពោធិញាណ** មានខន្ធដ៏បរិសុទ្ធ ពេញដោយមហាករុណាទិគុណ លើសលប់ មានព្រះបញ្ញាត្រាស់ដឹងឯងដោយប្រពៃ ទ្រង់ដល់ព្រមដោយវិជ្ជា និងចរណ: ទ្រង់ស្តេចទៅល្អហើយ ដឹងច្បាស់លោក ទ្រង់ទូន្មានបុរសដោយមិនមានអ្នកណាប្រសើរជាង ជាព្រះសាស្តានៃទេវតា និងមនុស្សទាំងឡាយ ព្រះអង្គទ្រង់ជាទីពឹងដ៏ប្រសើររបស់សត្វលោក ជាស្តេចឪរបស់អ្នកកាន់ព្រះពុទ្ធសាសនាគ្រប់គ្នា ខ្ញុំក្រាបថ្វាយបង្គំព្រះគុណដ៏លើសលប់នេះ ដោយសិរសា ។

អហោ ធម្មោ ព្រះធម៌ទាំងឡាយជាអស្ចារ្យ ដែលព្រះមានព្រះភាគទ្រង់សម្តែងទុកល្អហើយ ចូលទៅដឹង ចូលទៅឃើញ ចូលទៅពិសោធបាន មិនប្រកបដល់កាលវេលា ស្រែកហៅឲ្យមនុស្សលោកទាំងឡាយមកមើលបាន ជាធម៌ដែលបង្អោនចូលមកកាន់ខ្លួនបាន ជាធម៌ដែលវិញ្ញូជនគប្បីដឹងច្បាស់ចំពោះខ្លួន ដឹងជួសគ្នាមិនបាន ជាធម្មរង្សី ដែលភ្ជឺស្វាង ចិញ្ចាចចិញ្ចែងនៅក្នុងចិត្ត ឲ្យបានទទួលសេចក្តីស្ងប់សុខរហូត

កាលនិរន្តរ៍ ខ្ញុំក្រាបថ្វាយបង្គំព្រះបរិយត្តិធម៌ បដិបត្តិធម៌ និងបដិវេធធម៌ ដោយសិរសា ។

អហោ សង្ឃោ *ពួកព្រះអរិយសង្ឆសាវ័ក អ្នកបដិបត្តិតាមព្រះមានព្រះភាគដោយល្អ បដិបត្តិតាមព្រះមានព្រះភាគដោយសេចក្តី (ស្មោះ) ត្រង់ បដិបត្តិតាមព្រះមានព្រះភាគដើម្បីចេញចាកទុក្ខ បដិបត្តិសមគួរដល់មគ្គ ផល និញ្ចាន របស់ព្រះមានព្រះភាគ ដែលបានដល់បុរស ៤ គូ បុគ្គល ៨ គឺ មគ្គបុគ្គល ៤ ផលបុគ្គល ៤ នេះឯង គឺអរិយសាវ័ករបស់សម្តេចព្រះមានព្រះភាគ អ្នកគួរដល់ការក្រោកទទួល គួរដល់ការក្រាបសំពះ គួរដល់ការថ្វាយទក្ខិណាទាន គួរដល់ការធ្វើអញ្ជលីកម្ម រាប់ជាស្រែបុណ្យរបស់លោក ទ្រង់បវរពុទ្ធសាសនា ឲ្យចម្រើនវឌ្ឍនាខ្ជាប់ខ្ជួន មកកាន់ពុទ្ធបរិស័ទ ឲ្យបានផឹកនូវអមតរសរឿយៗ ខ្ញុំក្រាបថ្វាយបង្គំព្រះអរិយសង្ឆសាវ័កទាំងនោះគ្រប់អង្គ ដោយសិរសា ។*

ភាគ ៣ ចប់ ។

រៀបចំវាយអក្សរឡើងវិញនិងពិនិត្យតាមច្បាប់ដើមដោយ

គណៈកម្មការពុទ្ធិកវប្បធម៌អង្គការមូលនិធិវត្តបញ្ញាធំ

ការវាយអក្សរ និងបោះពុម្ពសាឡើងវិញនូវសៀវភៅធម៌ដែលជាស្នាដៃចាស់ៗ របស់អ្នកនិពន្ធជំនាន់មុនគឺអាស្រ័យ ដោយការមើលឃើញ នូវកត្តាចាំបាច់មួយចំនួន ដូចខាងក្រោម ៖

- ឯកសារដើម ត្រូវបានថតចម្លងច្រើនសា ធ្វើឲ្យមានលក្ខណៈមិនច្បាស់ ពិបាកក្នុងការអាន
- រក្សាស្នាដៃវប្បធម៌ព្រះពុទ្ធសាសនាឲ្យគង់វង្សស្ថិតស្ថេរ
- តម្រូវការរបស់សិក្ខាកামអ្នកប្រាថ្នាចង់យល់ដឹងនូវខ្លឹមសារពុទ្ធសាសនា
- ផ្សាយនូវធម្មទាន ធ្វើឲ្យព្រះពុទ្ធសាសនាកាន់តែមានភាពរីកចម្រើនរុងរឿងក្នុងលោក

ក្នុងករណីដែលលោកអ្នកអានបានពើបប្រទះនូវកំហុសឆ្គងណាមួយ ចង់ឲ្យយើងកែតម្រូវ ឬចង់បានសៀវភៅធម៌យកទៅអាន សូមទាក់ទងមកយើងខ្ញុំតាមអាសយដ្ឋានដូចខាងក្រោម:

វត្តបញ្ញា សង្កាត់ក្រាំងធ្នង់ ខណ្ឌសែនសុខ រាជធានីភ្នំពេញ

លេខទូរស័ព្ទ: (៨៥៥) ១២ ៩៦១ ៤២៩, (៨៥៥) ៨៨៧ ៩៦១ ៤២៩

អ៊ីមែល: maha.panna@gmail.com

គេហទំព័រ: http://www.mahapanna.org